# សាសនអច្ឆរាមហាកាមមហានគខ្មែរ

## ភាគ២




ព្រះមហាគាសម្តេចឫទ្ធិ

ឯកសារសាវតាព្រះម៉ែមហានគរ ស្រាវជ្រាវនិងរៀបរៀងដោយ ខ្ញុំព្រះករុណា

ខ្ញុំបាទ គៀត ចាន់ថុន អតីតសិស្សសាលាវិចិត្រសិល្បៈ

# អារម្ភបទ

ពេលដែលខ្ញុំព្រះករុណាខ្ញុំបាទ សរសេរចងក្រងភាគទីមួយរួចហើយ ខ្ញុំបានប្រគេនជូនលោកម្ចាស់ ដែលបាននិមន្តមកបិណ្ឌបាតនៅមុខផ្ទះខ្ញុំព្រះករុណាខ្ញុំបាទ នូវឯកសារសាវតាបណ្ដាំមាតាមហានគរថតចម្លងមួយច្បាប់ ដើម្បីឲ្យព្រះអង្គយកទៅអាន ឈ្វេងយល់។ រំលងជាច្រើនថ្ងៃក្រោយមក លោកម្ចាស់អង្គនោះ លោកបាននិមន្តមកបិណ្ឌបាតម្ដងទៀត ព្រះអង្គបានសួរខ្ញុំថា ញោមស្រាវជ្រាវអស់រយៈពេលជាង១០ឆ្នាំសរសេរចងក្រងបានតែប៉ុណ្ណឹងទេឬ?

សំណួរដែលលោកម្ចាស់សួរខ្ញុំ ធ្វើឲ្យខ្ញុំភ្ញាក់រួចគិតពិចារណាក្នុងចិត្តតែម្នាក់ឯងថា ៖ លោកម្ចាស់អង្គនេះច្បាស់ជាមើលការស្រាវជ្រាវ **អាថ៌កំបាំងបណ្ដាំព្រះម៉ែ** នេះពុំយល់ឡើយ ដូច្នេះខ្ញុំត្រូវតែស្រាវជ្រាវ ភាគទីពីរជាបន្ត ដើម្បីយកមកពន្យល់បកស្រាយជាបន្ថែមទៀត បើពុំដូច្នោះទេអ្នកអានដែលមានបញ្ហាក្នុងការសិក្សាស្រាវជ្រាវបានតិចតួច ពិតជាពុំអាចមើលយល់បានឡើយនៅឯកសារសាវតាចងក្រងដោយសង្ខេបក្នុងភាគ១នេះ។ ហេតុនេះទើបខ្ញុំព្រះករុណាខ្ញុំបាទ ខិតខំស្រាវជ្រាវប្រមូលផ្ដុំនូវការសិក្សានិងការចងចាំទាំងឡាយជិតមួយជីវិតនេះ មកសរសេរពន្យល់បកស្រាយក្នុងភាគទីពីរ ដើម្បីទុកជាមរតកបណ្ដាំគំនិតព្រះម៉ែ សម្រាប់បំភ្លឺមើលការពិតពីអតីតកាល បច្ចុប្បន្ន និងតទៅអនាគត ទុកជាប្រយោជន៍ឲ្យកូននាគប្រុសស្រីដែលជាអ្នកកាន់និងគោរពព្រះពុទ្ធសាសនា ឲ្យបានយល់ច្បាស់ពី**សាសនបណ្ដាំព្រះម៉ែ** ដែលលោកបានផ្ដាំទុកនៅក្នុងប្រាសាទថ្ម ទំនៀមទម្លាប់ ប្រពៃណីសាសនា ឈ្មោះភូមិស្រុក ឈ្មោះប្រាសាទ ធម្មជាតិ ទំនាយផ្សេងៗ.... **សម្រាប់ឲ្យកូននាគទាំងឡាយជួយគាស់កកាយសើរើរឿងពិត** រួចនាំគ្នារួមសាមគ្គីជួយឧទ្ទិសបុណ្យស្រង់គាត់ពីទីទុក្ខដែលបានបន្សល់ទុកជាយូរយារណាស់មកហើយនោះ ឲ្យគាត់បានទៅកាន់សុគតិភព។

គេហទំព័រ: http://kietchanthon.blogspot.com
http://kietchanthon.info
អ៊ីម៉ែល: kietchanthon@gmail.com
info@kietchanthon.info

ឯកសារសាវតាព្រះម៉ែនេះ ស្រាវជ្រាវ និងចងក្រងដោយ

ខ្ញុំព្រះករុណា ខ្ញុំបាទ **គៀត ចាន់ថុន**
អតីតសិស្សសាលាវិចិត្រសិល្ប:

# <u>សាសនអច្ឆរាមាតាមហានគរខ្មែរ</u>

I. *នៅក្នុងស្នាដៃរបស់ខ្ញុំ ភាគទីមួយខ្ញុំបាននិយាយជាហូរហែ នូវរឿងរ៉ាវទុក្ខវេទនារបស់មាតាមហានគរ ដែលគាត់សុខចិត្តរងទុក្ខនៅក្នុងមហាសមុទ្រទឹកដោះ ក្នុងការតាំងខ្លួនជាប្រមុខគេ ជាម៉ែគេ (ស្គរតាំងម៉ែ) ទើបស្ត្រីជា* **មាតុ** *លោកភ្លេចធ្វើទីពឹងឲ្យខ្លួនឯង គួរឲ្យអាណិតនិងសង្វេគគាត់ណាស់។ បើគាត់មាននូវមហាគុណដ៏ធំធេងដូចនេះ តើកូនខ្មែរប្រុសស្រីគួរបំពេញកិច្ចតបស្នងយ៉ាងណា ដើម្បីឲ្យសមជាកូនដែលជាអ្នកទទួលនូវមរតកម៉ែ(ខ្មែរ) ជាអ្នកបានកើត ថែមទាំងបានកប់ទងសុក និងចុងក្រោយ គឺត្រូវកប់សាកសពនៅលើទឹកដីរបស់គាត់នេះ ។*

***ក/****.តើកូនម៉ែដឹងទេ? ដំណក់ទឹកដោះ ដែលអ្នកបៅ បឺត ជញ្ជក់ដំបូងឡើយ គឺមានរសជាតិផ្អែម ពណ៌សថ្លា ប្រៀបដូចជាទឹកចិត្តម៉ែបង្ហូរមកដើម្បីចិញ្ចឹមកុលបុត្រប្រុសស្រី ហើយបានហូរចេញពីក្នុងទ្រូងម្តាយ។ ទឹកដោះហូរចេញដំបូងមានរសផ្អែម ទុករំលងច្រើនម៉ោង ក្លាយទៅជាមានក្លិនឆ្អាបដូចឈាម ទុករំលងច្រើនថ្ងៃប្រែក្លាយទៅជាទឹកគំរង់ដែលមានក្លិនស្អុយ។ ពេលណាអ្នកពិចារណាតាមការបកស្រាយរបស់ខ្ញុំនេះ តើអ្នកនឹងមានសេចក្តីអាណិតដល់***មាតាមហានគរខ្មែរ** *ដែលលោកខិតខំកកើត* **មាតុភូមិ***នេះទេ?* **ព្រះម៉ែ***លោកសុខចិត្តស៊ូទ្រាំដេកត្រាំក្នុងមហាសមុទ្រទឹកដោះខ្លួនឯងរាប់ពាន់ឆ្នាំ ដែលទឹកដោះនេះសព្វថ្ងៃ បានក្លាយទៅជាមហាសមុទ្រគំរង់ស្អុយគួរឲ្យខ្ពើម ប៉ុន្តែដើម្បីកូនប្រុសស្រី ក្នុងនាមជាម៉ែគេ(តាំងម៉ែ) គាត់សុខចិត្តដេកត្រាំក្នុងមហាសមុទ្រគំរង់នេះ (សមុទ្រទឹកដោះ = អបាយភូមិ = ទីទុក្ខ)។ តើមានកូនប្រុសស្រីណាដឹងពីទុក្ខវេទនានេះទេ? ម៉ែបានដេកត្រាំក្នុងទុក្ខយ៉ាងនេះ ដើម្បីតែកូនខ្មែរប្រុសស្រី តើកូនខ្មែរប្រុសស្រី ដែលប្រមាថគាត់ជេរគាត់ តើកម្មនេះកូនម៉ែប្រុសស្រី ទទួលទោសដូចគាត់ ឬមួយក៏លើសពីគាត់?* ***សូមមិត្តអ្នកអានពិចារណាបាបកម្ម ដែលខ្លួនបានជេរប្រមាថនេះ ដោយខ្លួនឯងចុះ!*** *។*

***ខ/****.ក្នុងភាគមុន ខ្ញុំពុំបានបកស្រាយពីសមុទ្រទឹកដោះនេះឲ្យបានក្បោះក្បាយទេ ឥឡូវខ្ញុំសូមលើកយកមកពន្យល់បន្ថែម ដើម្បីឲ្យកូនខ្មែរយល់កាន់តែច្បាស់ថា ហេតុអ្វីបានជាគាត់ត្រូវយកសាសនា*

*ព្រហ្មញ្ញចូលមកក្នុងនគរខ្លួន? ព្រោះរឿងរ៉ាវក្នុងសាសនានេះវាមានចំណុចជាច្រើន ដែលដូចរឿងរបស់គាត់ (ឧទាហរណ៍: ដូចជារឿងកូរសមុទ្រទឹកដោះនេះជាដើម)។ តើអ្នកធ្លាប់បរិភោគផ្លែទឹកដោះឬទេ?*

*ផ្លែទឹកដោះមានពីរបែប មួយទុំពណ៌ស និងមួយទៀតទុំពណ៌ក្រហមក្រម៉ៅ ហេតុអ្វីបានជាគាត់ហៅផ្លែនេះថាផ្លែទឹកដោះ? ព្រោះផ្លែនេះមានសណ្ឋានរាងដូចដោះស្ត្រី ហើយជាពិសេសពេលដែលយើងចិតវាហូបនោះ វាបានហូរចេញនូវជ័រពណ៌សដូចជាទឹកដោះម៉ែដែរ ហើយជ័រនេះមានរសជាតិផ្អែមថែមទៀតគួរឲ្យចង់ទទួលទាន ដូចជាទារកដែលបានទទួលបំបៅ ជញ្ជក់បឺតបៅទឹកដោះម្តាយដែរ។ ហើយពណ៌ក្រហមក្រម៉ៅនិងសនេះ គឺតំណាងឲ្យម៉ែដែលមានស្បែកសំបុរថ្ងៃជ្រះ ឬម៉ែដែលមានស្បែកសំបុរថ្ងៃស្រអែមនិងខ្មៅ (នេះជារអាថ៌កំបាំងរបស់ឈ្មោះផ្លែទឹកដោះ ដែលទាក់ទងនឹងរឿងអាថ៌កំបាំងព្រះម៉ែយើង)។*

*ហេតុអ្វីបានជា យើងមានរឿងព្រះថោងនាងនាគ? តើរឿងព្រះថោងនាងនាគ បានលាក់ទុកនូវអាថ៌កំបាំងអ្វីខ្លះ? តើរឿងនេះហេតុអ្វីមានតែនៅក្នុងស្រុកខ្មែរ?*

***គ**/.យើងដឹងហើយថារឿងនេះ វាទាក់ទងទៅនឹងប្រវត្តិដំបូងរបស់នគរនេះ បឋមក្សត្ររបស់នគរនេះ គឺព្រះនាងនាគ ដែលខ្ញុំបានពន្យល់ពីខាងដើមរួចមកហើយ (គឺបុព្វពាក្យ **មេ** ក្នុងភាគ១) ដើម្បីចង់ដឹងពីរឿងពិតរបស់នគរនេះ យើងត្រូវយករឿងព្រេងនេះមកវែកញែក ដើម្បីស្វែងរកការពិតរបស់ជនជាតិខ្មែរ ព្រោះនេះជារឿងតែមួយគត់ដែលយើងជាកូនខ្មែរ បានចេះចាំតៗគ្នាមកដល់សព្វថ្ងៃនេះ។ ពាក្យថានាគ គឺខ្ញុំបានពន្យល់រួចហើយ នៅក្នុងភាគ១នៃឯកសារអាថ៌កំបាំងនេះ ឥឡូវខ្ញុំពន្យល់ពីកាតព្វកិច្ចរបស់កូននាគប្រុសស្រីដែលជាអ្នកស្នងមរតកព្រះម៉ែវិញ តើកូននាគប្រុសត្រូវធ្វើអ្វី? កូននាគស្រីត្រូវធ្វើអ្វី? កាលពីសម័យដើម មាតាបិតាខ្មែរតែងធ្វើការជាមង្គលឲ្យកូនចំនួនបីលើកគ្រប់កូនប្រុសនិងកូនស្រី រាល់ពិធីមង្គលនីមួយៗ គាត់តែងតែអញ្ជើញអាចារ្យពេលា ដើម្បីស្វែងរកពេលវេលាល្អធ្វើមង្គល ហើយបានអញ្ជើញញាតិមិត្តជិតឆ្ងាយ មកចូលរួមក្នុងពិធីនីមួយៗនេះ។ នៅក្នុងពិធីមង្គលទាំងបីនេះ តែងបញ្ចប់កិច្ចចុងក្រោយដោយការ បង្វិលពពិលព័ទ្ធសីមាឲ្យកូនប្រុសស្រីគ្រប់ៗពិធីមង្គល។*

## <u>ពន្យល់ពាក្យៈ</u>

*ពពិល* => ពពារ => បើកពពារ => គឺព្រះម៉ែមហានគរគង់នៅលើនាគបើកពពារ (រូបពពិលពីសម័យដើម) ហើយព្រះម៉ែតែងតែទៅព័ទ្ធសីមាកាពារឲ្យកូនខ្មែរគ្រប់ៗជំនាន់ ទោះបីជាខ្លួនត្រូវជាប់ទោសក្នុងសមុទ្រទឹកដោះទៅហើយ ក៏គាត់នៅតែតាំងខ្លួនជាម៉ែគេងដែល (**ស្គរតាំងម៉ែ**) ហើយពិធីមង្គលទាំងបីនេះ មានន័យស្រដៀងនឹងរឿងកបិលមហាព្រហ្មក្នុងសិរីបីប្រការ ដែលគេធ្វើពិធីមហាសង្ក្រាន្តផ្លាស់ប្តូរគ្រប់រាល់ៗឆ្នាំថ្មី។ ហើយរឿងកបិលមហាព្រហ្មនេះ ខ្ញុំនឹងព្យាយាមស្រាវជ្រាវរាវរកនូវអត្ថន័យពិត ដើម្បីយកមកបកស្រាយពន្យល់ក្នុងទំព័រខាងក្រោយ តើហេតុអ្វីរឿងសិរីបីប្រការនេះ មានតែនៅក្នុងស្រុកខ្មែរ?

## <u>ការបកស្រាយអាថ៌កំបាំងក្នុងមង្គលបី ៖</u>

### ១/.មង្គលទីមួយ

*ពន្យល់ពាក្យ មង្គល = សេចក្តីចម្រើន សេចក្តីសុខ សិរីសួស្តី*

មាតាបិតាពីសម័យដើម តែងធ្វើមង្គលទីមួយឲ្យកូនប្រុសស្រី ពេលកូនធំដឹងក្តី គឺពិធីកោរទុកជុក ឬទុកកំប៉ោយ) ពិធីកោរជុកទុកកំប៉ោយសក់សម្រាប់លាក់បិទបាំងនូវបង្គើយ ព្រោះបង្គើយនេះមានន័យថា **ចប់** ដូច្នេះបើអ្នកដទៃគេរកឃើញបង្គើយរស់របស់យើង បានន័យថាចប់ វាពុំមែនដូចរឿងអាជ័យប្តីនាងគ្រតនោះឡើយ ដែលលូងហើយទៅចាក់បង្គើយដែល ជាដង្ហើមរស់របស់កូន ហើយនិយាយថាមិនដឹង ដោយស្មានច្រឡំថាជាបូសនោះទេ។ តើអាថ៌កំបាំងក្នុងមង្គលទី១ គាត់ចង់និយាយពីអ្វី? គឺម៉ែនាគគាត់ចង់ប្រាប់កូននាគប្រុសស្រីថា ពាក្យថា កោរទុកជុក ត្រឡប់ ពាក្យមកវិញ គឺគុកទុកចោរ។ តើអ្នកណាជាចោរ? ចោរគឺមាតាបិតានោះឯង ព្រោះហេតុតែចិញ្ចឹមកូនប្រុសស្រី ម៉ែឪសុខចិត្តដាច់សីលគឺសិក្ខាបទប្រាំ មានឈ្មោះថាជាអ្នកធ្វើនូវបាបកម្មដើម្បីកូន ទីបំផុតត្រូវរងទុក្ខជាប់ឃុំឃាំង (ក្នុងសមុទ្រទឹកដោះ)។ អត្ថន័យនេះ ខ្ញុំបានពន្យល់រួចហើយពីក្នុងភាគទី១ (តាំងខ្លួនជាម៉ែ) ដូច្នេះហើយ ទើបគាត់

លួចចេញពីគុកឡើងមកប្រាប់កូនសម័យនោះឲ្យកសាងប្រាសាទថ្មរាប់រយពាន់ហើយមានប្រាសាទមួយដាក់ឈ្មោះថា **ប្រាសាទវត្តភូ** ដែលសព្វថ្ងៃប្រាសាទនេះ ស្ថិតនៅក្នុងប្រទេសឡាវ។


រូបនៅប្រាសាទ វត្តភូ

## <u>ពន្យល់ពាក្យ</u> **វត្តភូ**

វត្ត = បដិបត្តិ ប្រតិបត្តិ ធ្វើតាមរឺ អនុវត្តតាម ឧ៖ វត្តិប្រតិបត្តិ

ភូ = សំណុំសក់រោម សរសៃអ្វីៗសំរាប់ចងជាវំយោលកំប៉ោយ

ភូ = ផែនដី លោក ពិភពលោក ចិញ្ចើម (វចនានុក្រមសម្ដេចសង្ឃរាជ ជួនណាត១+២)

វត្តភូ = មានន័យថាការធ្វើតាម រឺអនុវត្តតាមពិធីទុកសំណុំសក់ (កោរទុកជុករឺ កំប៉ោយ) ដែលគាត់បានឆ្លាក់រឿងរ៉ាវរបស់គាត់ ទុកលើផ្ទៃប្រាសាទនោះ ដែលរៀបរាប់ពីកូននាគម្នាក់ដកផ្នូកកំប៉ោយចេញ រួចហែកចូលទៅមើលរឿងក្នុងបេះដូងម៉ែ (**អាថ៌កំបាំងក្នុងល្បែងចាក់ទឹកដូង**) (ភាគទី១)។

ដោយការតាមរកនូវបង្អើយ(ដង្ហើមរស់) របស់ព្រះម៉ែនេះ ពួកបរទេសគេតាមស្រាវជ្រាវអស់កាលជ័យូរ ទីបំផុតពួកគេបានរកឃើញបង្អើយរស់របស់គាត់នៅក្នុងភ្នំអដ្ឋរស ឬរាជទ្រព្យ ទើបពួកគេសាងរូបពុទ្ធបដិមាមួយអង្គ កំពស់១៨ហត្ថព្រះសុគតសន្ធប់មាត់រូង ដែលជាបង្អើយរបស់ព្រះមាតា


ព្រះម៉ែទ្រក្ដុំ

មហានាគ ដើម្បីកុំឲ្យគាត់ចេញមកក្រៅរូច។ ព្រោះគេដឹងថាចំណុចខ្សោយរបស់ព្រះម៉ែនាគ គឺព្រះរូប ព្រះធាតុ...... របស់ព្រះសម្មាសម្ពុទ្ធ ដែលជាព្រះបិតាវិវដ្ដ ហើយព្រះបិតានេះ គឺព្រះម៉ែនាគគាត់បាននាំមកប្រតិស្ថានទុកក្នុងនគរនេះតាំងពីអតីតកាលមកម្ល៉េះ គឺដើម្បីទុកជាកេររបស់ម៉ែ (ខ្មែរ)។ នៅពេលណាដែលមានព្រះចេតិយ ព្រះពុទ្ធ ព្រះធាតុ និងរបស់របរផ្សេងៗដែលជាតំណាងព្រះសម្មាសម្ពុទ្ធ នៅពីខាងលើក្បាលព្រះម៉ែ (បង្អើយ) គឺគាត់ពុំអាចចេញមកខាងលើរូចឡើយ ព្រោះពេលដែលគាត់ចេញមក នឹងធ្វើឲ្យព្រះចេតិយជាទីសក្ការ:ទាំងនោះ ប្រេះរលំវិនាសបាក់បែកជាពុំខាន ហេតុនេះគាត់មានតែ ស៊ូទ្រាំនៅទ្រភ្នំ ឬទ្រទុក្ខបន្តទៅទៀត

(រូបចម្លាក់ស្ត្រីទ្រទ្រង់ឆ្នាំសព្វថ្ងៃតាំងនៅក្នុងសារមន្ទីរជាតិភ្នំពេញ)។

ចំណុចខ្សោយទាំងអស់នេះហើយ ដែលធ្វើឲ្យពួកបរទេសជិតឆ្ងាយគេមើលយល់ គេបានមកស្រាវជ្រាវរាវរកដង្ហើមរស់ទាំងនេះ តាំងពីដើមសតវត្សមកម្ល៉េះ ដូច្នេះហើយទើបសម័យក្រោយៗពួកគេតែងតែសាងរូបព្រះពុទ្ធបដិមា ឬព្រះចេតិយដំកល់ព្រះធាតុ... មកបិទសន្ធប់តាមមាត់រូងភ្នំណាដែលគេសង្ស័យថា ព្រះម៉ែនាគនឹងចេញតាមបង្ហើយនោះ ខ្ញុំសូមលើកយកឧទាហរណ៍មួយមកពន្យល់។ សម័យពីដើម ដូនតាយើងគាត់ចង់ជីកអណ្ដូងយកទឹកមកប្រើប្រាស់ក្នុងរដូវប្រាំង ដែលខ្សត់ទឹក តើគាត់ត្រូវធ្វើដូចម្ដេច? គឺគាត់ត្រូវប្រើវិធីសាស្ត្រស្ទង់ រកមើលដង្ហើមរបស់ទឹកបីយ៉ាង។

## <u>វិធីទាំងបីសំរាប់ជីកអណ្ដូង ៖</u>

១.គាត់ត្រូវដើរមើលស្មៅដែលដុះតាមវាលស្រែ បើស្មៅត្រង់ទីណា នៅមានពណ៌បៃតងស្រស់ខ្ចី បានន័យថាទីកន្លែងនោះ ពិតជាមានប្រភពទឹកនៅខាងក្រោមជាពុំខានឡើយ។

២.គាត់ត្រូវយកក្អម ឆ្នាំង ឬភាជន៍ផ្សេងៗ យកទៅគ្របតាមទីកន្លែងដែលពួកគាត់ចង់ជីកអណ្ដូងនៅពេលព្រលប់ ប្រសិនបើព្រឹកឡើងមានចំហាយដំណក់ទឹកជាប់នៅខាងក្នុងភាជន៍ទាំងនោះ គឺទីត្រង់នោះ នឹងមានប្រភពទឹកនៅខាងក្រោមជាពុំខាន។

៣.ពួកគាត់អញ្ជើញលោកគ្រូអាចារ្យ ដែលសិក្សាផ្នែក**កម្មដ្ឋានសមាធិ** មកអង្គុយមើលដោយប្រើឫទ្ធិក្នុងអភិញ្ញាគឺ **ចក្ខុទិព្វ** ដើម្បីរកមើលនូវប្រភពទឹកខាងក្រោម។

ក្នុងវិធីទាំងបីយ៉ាងនេះ វិធីទីបីគឺមានភាពវិសេសជាងគេ វិធីនេះលុះត្រាតែអ្នកមាននូវឈានសមាបត្តិបួន ឬប្រាំបីទើបអាចយកមកប្រើបាន យ៉ាងណាមិញពួកបរទេសក៏ដូច្នេះដែរ ដើម្បីស្វែងរកបង្ហើយរស់របស់ព្រះម៉ែ (បិសាចពស់នៅក្នុងឯកសារ ចិនជីវតាក្វាន់) ពួកគេបានបញ្ជូនអ្នកមានឫទ្ធិអភិញ្ញា **(អ្នកមើលហុងស៊ុយ)** មកក្នុងស្រុកខ្មែរដើម្បីដើរស្រាវជ្រាវរាវរក រួចបិទសន្ធប់បង្ហើយរស់របស់ម៉ែនោះ ដើម្បីកុំឲ្យស្ត្រីជាព្រះម៉ែមហានគរចេញពីក្នុងគុករួច ព្រោះពួកគេមិនចង់ឲ្យនគរនេះរុងរឿងឡើងវិញឡើយ ហេតុនេះគេត្រូវប្រើប្រាស់មនោគមវិជ្ជាគ្រប់បែបយ៉ាង ដើម្បីសន្ធប់បិទបញ្ញាកូនខ្មែរកុំឲ្យដឹង

រឿងពិតរបស់ខ្លួនឡើយ (ខ្ញុំបានពន្យល់នៅក្នុងភាគ១រួចហើយ)។ ម្យ៉ាងទៀតគ្រប់រូបសំណាកអង្គជាតិ (លិង្គព្រះឥសូរ) ដែលនៅចុកបិទរន្ធយោនីរបស់មាតានោះ គេតែងតែឆ្លាក់រូបព្រះពុទ្ធនៅពីខាងលើក្បាលលិង្គ ពីមួយអង្គទៅដល់បួនអង្គ រួចបែរមុខទៅរកទិសទាំងបួន ដើម្បីកុំឲ្យព្រះម៉ែចេញពីក្នុងរន្ធយោនី (មាតុភូមិ) នេះរួច (រូបចម្លាក់នៅប្រាសាទនាគព័ន្ធគេឆ្លាក់រូបក្បាលម៉ែពាក់ម្កុដរាជកប់ត្រឹមកមាត់ហាស្រែកហៅកូនឲ្យជួយ ដែលនៅលើក្បាលទូលយោនីខ្លួនឯង)។ តើមិត្តអ្នកអានមានឆ្ងល់ឬទេ? បើតួលិង្គជារបស់ព្រះឥសូរហេតុអ្វីក៏ត្រូវឆ្លាក់រូបព្រះពុទ្ធ? នេះជាអាថ៌កំបាំងប្រស្នារូបដែលយើងត្រូវស្រាវជ្រាវរាវរកនូវអត្ថន័យពិត។

ធម្មតារឿងពិតរបស់ធម្មជាតិ ប្រសិនបើចង់បង្កើតកូនប្រុសស្រី ក្បាលលិង្គត្រូវបែរចុះទៅខាងក្រោម ចុះហេតុអ្វីបានជាក្បាលលិង្គបែរទៅខាងលើ ហើយមានរូបពុទ្ធបដិមាទៀត? នេះហើយគឺជាប្រស្នាដែលបរទេសដើរបិទសន្ធប់រន្ធបង្ហើយវាត្រូវនឹង ពាក្យ**កុងម៉ាឬកុងសង្កត់ម៉ា** ដែលផ្ទុយពីពាក្យខ្មែរថា **ដូនតា ឬមេបា**។ ដូច្នេះបើរន្ធយោនី ឬភេទដែលមានឆ្នុកចុក ហើយមានរូបព្រះពុទ្ធបដិមាទៀតនោះ ធ្វើដូចម្ដេចទើបឲ្យគាត់ចេញពីសមុទ្រទុក្ខរួច? នេះជាប្រស្នាទាក់ទងនឹងមង្គលទីមួយ ដែលគាត់បានលាក់ទុកអាថ៌កំបាំងក្នុងឈ្មោះប្រាសាទ និងរូបចម្លាក់។ ពេលដែលធ្វើពិធីកោរជុកចប់កូនស្រីនៅជួយកិច្ចការម៉ែឪ ចំណែកឯកូនប្រុសវិញ ម៉ែឪបានយកទៅផ្ញើរនឹងភិក្ខុសង្ឃនៅឯវត្ត ដើម្បីបានសិក្សារៀនសូត្រធម៌អាថ៌ និងជួយបម្រើព្រះសង្ឃ (កូនសិស្សលោក)។

## ២.មង្គលទីពីរ

ក/. ក្រោយពីចប់មង្គលទីមួយហើយ វ័យរបស់កូនប្រុសស្រីត្រូវចំរើនឡើង ដូច្នេះមាតាបិតាត្រូវរៀបចំមង្គលទីពីរឲ្យកូនទៀត គឺធ្វើទៅតាមកម្លាំងធនធានគ្រួសារនីមួយៗ គ្រួសារក្រីក្រធ្វើតិចតួច គ្រួសារដែលមានស្ដុកស្ដម្ភគេធ្វើអធិករអធម។ មង្គលទីពីរនេះ កូនប្រុសត្រូវធ្វើពិធី **បំបួសនាគខ្នាន់** ចំណែកឯកូនស្រីវិញ ត្រូវធ្វើពិធី **ចូលម្លប់** នេះជាកិច្ចរបស់កូននាគប្រុសស្រី។ ហេតុអ្វីកូនប្រុសចាំបាច់ធ្វើកូននាគ កូនស្រីចូលម្លប់? ខ្ញុំនឹងបកស្រាយពន្យល់ទៅតាមការស្រាវជ្រាវ ក្នុងបណ្ដាំគំនិតរបស់**ព្រះម៉ែ** ដែលបានបន្សល់ទុក នៅក្នុងពិធីមង្គលនេះ។ យើងដឹងហើយថា មង្គលទីមួយនៅខាងលើក្បាល

(ការដុកលាក់ទុកបង្កើយ) មង្គលទីពីរ គឺចុះមកដល់ដើមទ្រូងជាទីកន្លែងលាក់ទុកនូវបេះដូង ដែលបេះដូងនេះ គឺជាទីលាក់ទុករឿងល្អនិងអាក្រក់របស់ចិត្ត **(ទ្រូង = ទ + រូង)** ។

ទ ➜ ទីបង្ហូរនូវទឹក ➜ ទឹកចិត្ត

រូង ➜ ផ្លូវលាក់កំបាំង កម្រមានមនុស្សដឹង **ឧ.** (រូងភ្នំ រូងដី)

បេះដូង = ទីលាក់ទុករឿងរ៉ាវល្អអាក្រក់របស់ចិត្ត **ឧ.** (រឿងអាក្រក់ល្អលាក់ទុកក្នុងចិត្ត) ហេតុនេះហើយ ទើបពួកបរទេសគេតាមបិទសន្ធប់គ្រប់រូង ធម្មជាតិ និងរូងសិប្បនិម្មិតនោះ ព្រោះវា ទាក់ទិននឹងរឿងរ៉ាវខាងក្នុងទ្រូងម៉ែ អ្នកចង់ដឹងរឿងម៉ែទាល់តែចាក់ទឹកបេះដូងពីក្នុងទ្រូងម៉ែ (នៅក្នុងភាគ១) ទើបដឹងរឿងបណ្ដាំរបស់ម៉ែ ។

ក្នុងសម័យពុទ្ធកាល កុលបុត្រអ្នកបួសដំបូង ព្រះអង្គបំបួសដោយឫទ្ធិ គឺ**ឯហិភិក្ខុ** បន្តមកព្រះអង្គបំបួសដោយឲ្យឱវាទគឺ **ព្រះមហាកស្សប:** ហើយការបំបួសជាចុងក្រោយ គឺព្រះអង្គឲ្យសង្ឃបំបួសដោយ**សូត្រញត្តិចតុត្ថកម្មវាចាឧបសម្បទា**(សូត្រញត្តិនាគ) ចុះហេតុអ្វីនៅក្នុងនគរព្រះម៉ែនេះ មុននឹងបួសត្រូវបំបួសនាគសិន (ធ្វើកូននាគ)? ហេតុអ្វីក៏ខុសពីព្រះវិន័យព្រះសម្មាសម្ពុទ្ធពីអតីតកាល? នេះជាហេតុដែលព្រះម៉ែមហានាគម្ចាស់នគរដែលបានទទួលយកនូវព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសនាមកប្រតិស្ថានក្នុងនគរនេះទុកជាកេរមរតក វាត្រូវតែមានហេតុផល ព្រោះការបំបួសនាគ និងធ្វើជាកូននាគ គឺគាត់ឲ្យកូននាគស្វែងរកមេនាគ ដើម្បីឲ្យបានដឹងរឿងគាត់ នឹងព្យាយាមជួយគាត់នេះជា **បញ្ហា**។ បើមិនបន្សល់ទំនៀមទម្លាប់បំបួសនាគនេះទុកទេ កូននាគសម័យក្រោយៗច្បាស់ជាពុំមានចម្ងល់ឡើយ ហើយបើពុំឆ្ងល់ គឺពុំអាចរកបណ្ដាំពិតរបស់ម៉ែឃើញឡើយ។

**កូននាគ**ត្រូវកោរសក់ស្លៀកសំពត់ហូល...ដូចស្ត្រីដែរ ហើយមានពាក់ឆៀងស្មាម្ខាង **សំពត់ហូល** តំណាងឲ្យស្បែកសត្វនាគ ព្រោះ**ក្រឡាគោមសំពត់ ដូចក្រឡាសត្វនាគ**ដែរ។ សូមស្ត្រីទាំងឡាយដែលនាំគ្នាស្លៀកពាក់ហូល... ប្រយ័ត្នមិនដឹងពីអាថ៌កំបាំងក្រឡាគោមសំពត់នេះ យើងជាពូជនាគឈប់នាំគ្នាធ្វើពើមិនដឹងទៀតទៅ។ កូននាគនៅក្នុងចន្លោះកណ្ដាល គឺចន្លោះគ្រហស្ថ និងបព្វជិត តើកូននាគគ្រប់ជំនាន់ អ្នកដែលស្គាល់មេនាគរបស់អ្នកទេ? តើមេអ្នកនៅឯណា? ចុះហេតុអ្វីក៏កូននាគពុំស្គាល់មេ

នាគ? នេះជាប្រស្នាដែលព្រះម៉ែនាគ ទុកឲ្យកូននាគគ្រប់ជំនាន់ត្រិះរិះពិចារណា ដើម្បីស្វែងរកម៉ែនាគ រួចជួយគាត់ ព្រោះគាត់បានឆ្លាក់បណ្ដាំរឿងនៅលើប្រាសាទរាប់ពាន់ ទៅអនាគតគាត់ដឹងថានឹងមាន កូននាគណាម្នាក់ដែលជាកំពូលលើកូននាគទាំងឡាយ (ឈ្មោះ**ជីសូរ**) នឹងដឹងរឿងគាត់ហើយព្យាយាម ជួយគាត់ឲ្យរួចផុតពីបាបកម្ម ដែលគាត់បានទទួលកន្លងមក ហើយដែលរឿងរបស់គាត់ត្រូវគេ (បរទេស)តាមបិទសន្ធប់ជិតគ្រប់ទីកន្លែងដែលគេសង្ស័យ ។

កូននាគខុសពីមនុស្សធម្មតា (កូននាគពិត) ព្រោះកូននាគស្គាល់កាលបី **អតីត** + **បច្ចុប្បន្ន** + **អនាគត** និងស្គាល់ផ្លូវទៅកាន់ **អបាយភូមិ សុគតិ ព្រះនិព្វាន្ត**។

## តើមេនាគជាអ្នកណា?

– មេនាគទីមួយ គឺមាតាបិតាបង្កើតបច្ចុប្បន្ន

– មេនាគទីពីរ គឺមាតាបិតាមហានគរ ព្រោះគាត់ជាព្រះម៉ែនាគដែលបានបន្សល់ទុកនូវកេរ មរតកសព្វបែបយ៉ាង ពីមុនយើងហៅថា**ព្រះនាងនាគ**។

– មេនាគទីបី គឺព្រះអរហន្តសម្មាសម្ពុទ្ធបរមគ្រូនៃយើង (ព្រះពុទ្ធនាគ) ព្រះអង្គជាធំលើស សាវ័កទាំងឡាយគឺ ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា សាមណេរហើយនិងទេវតាគ្រប់ជាន់ថ្នាក់ ។ តើព្រះ ម៉ែនាគគាត់នៅឯណា? ខ្ញុំបានពន្យល់ហើយ នៅក្នុងអាចិកំបាំងភាគទីមួយ។

ចុះហេតុអ្វីបានជាកូននាគមិនស្គាល់មេនាគ ឬព្រះមាតានាគ? ព្រោះហេតុតែអកុសលកម្មបាន តាក់តែងនូវបាបរបស់ព្រះម៉ែដែលបានធ្វើហើយ ទើបធ្វើឲ្យកូននាគប្រុសស្រីគ្រប់ជំនាន់ខាងក្រោយ ភ្លេចឆ្ងល់ ម្យ៉ាងទៀតព្រោះតែកូននាគពុំព្រមចុះទៅក្នុងទ្វងរូងយកបេះដូងម៉ែឪមកបើកមើលរឿងក្នុង ចិត្តប្រកបដោយ ព្រហ្មវិហារធម៌របស់គាត់ចេះតែនាំគ្នានៅមាត់រូងខាងក្រៅ ព្រោះរវល់មើលតែនឹង ភ្នែកមិនបានមើលហើយគិតនឹងថ្វាស (ត្រិះរិះគិតឆ្ងល់) ហេតុនេះទើបមិនស្គាល់មេនាគ។ ទោះបីជា គាត់ខំសាងប្រាសាទទុករាប់ពាន់ ហើយប្រាសាទខ្លះគាត់ឆ្លាក់មុខព្រហ្មត្រឹម**ក** ទុកឲ្យកូនខ្មែរមើលយ៉ាង ណា ក៏យើងមិនបានអើពើឆ្ងល់ថា ហេតុអ្វីព្រហ្មខ្មែរមានតែក្បាល តើខ្លួនបាត់ទៅណាហ្ន៎? ឥណ្ឌាជា

ប្រភពនៃទីកើតរបស់ព្រហ្មញ្ញសាសនា ចុះហេតុអ្វីបានជាគ្មានប្រាសាទមុខព្រហ្មដ៏ច្រើន និងស្កឹមស្កៃដូចយើងជាខ្មែរ? ហេតុអ្វីដូនតាខ្មែរគ្រាន់តែជាអ្នកទទួលឥទ្ធិពល បែរជាមានប្រាសាទចម្លាក់មុខព្រហ្មដ៏ច្រើន និងស្កឹមស្កៃទៅវិញ? តើគំនិតបណ្ឌិតព្រះម៉ែមហានគរខ្ពស់ឬបរទេសខ្ពស់? ចម្លើយកូនម៉ែប្រុសស្រីពិចារណាត្រិះរិះរួចឆ្លើយដោយខ្លួនឯងចុះ ជាពិសេសគឺកូននាគ។ កូននាគទាំងឡាយតែងប្រែភេទ ពី **ហីនភេទ** (ភេទទាប) ទៅរក**ឧត្ដមភេទ** (ភេទប្រសើរ) ហើយគុណធម៌នេះចំរើនឡើងថែមទៀតតាមថ្នាក់ **សីល សមាធិ បញ្ញា** ដែលជាមាគ៌ាត្រៃសិក្ខារបស់ព្រះសម្មាសម្ពុទ្ធ រួចធ្វើដំណើរឆ្ពោះទៅរកទីបញ្ចប់នៃទុក្ខ **វិមុត្តិសុខគឺព្រះនិព្វាន្ត**។ កូននាគបានប្រែភេទទៅជាបព្វជិត គឺអ្នកបួសក្នុងព្រះពុទ្ធសាសនាទទួលនូវសំពត់កាសាវៈ ហើយបព្វជិតដែលក្លាយខ្លួនពីកូននាគនោះសូម្បីតែញាតិសន្តាន និងគ្រហស្ថរួមទាំងមាតាបិតាបង្កើតផង តែងតែលំឱនកាយថ្វាយបង្គំសមណៈនោះ ព្រោះលោកជារតនៈត្រៃទីបីគឺ **សង្ឃរតនៈ**។ពេលនោះកូននាគក្លាយទៅជាកូនរបស់មេនាគទីបីគឺ **ព្រះពុទ្ធនាគ** ដែលជាមេនាគធំលើសនាគទាំងឡាយក្នុងភពបីគឺ **កាមភព រូបភព អរូបភព**។

ពេលដែលកូននាគនោះអស់និស្ស័យក្នុងផ្នួសតែងតែសុំឧបជ្ឈាយ៍លាចាកសិក្ខាបទ (សឹក) មកវិញជាគ្រហស្ថ គេតែងឲ្យនាមថ្មីមួយទៀតថា **បណ្ឌិត** ឬ**ជី** (សម័យដើម) សព្វថ្ងៃនេះហៅថាអន្ទិត ឬអន្ទិតគោលោត ព្រោះអីសឹកមកមិនទាន់ទាំងដុះសក់ស្រួលផង កូននាគភាគច្រើនបានដាច់សិក្ខាបទប្រាំអស់ទៅហើយ (ដាច់សីលប្រាំ)។ ចំពោះកូននាគបែបនេះ ពុំមែនជាពូជនាគតំណពីអតីតកាលទេព្រោះពួកខ្លួនបានធ្វើឲ្យខូចពូជពង្សដ៏ប្រសើរឧត្ដម ហើយត្រូវអាប់ឱនអន់ថយនូវកេរ្តិ៍ឈ្មោះនេះដោយសារតែខ្លួន។ សម័យពីដើមបើកូនប្រុសមិនបានបួសរៀនទេ ហើយទៅស្ដីដណ្ដឹងកូនគេៗពុំឲ្យឡើយ តែបច្ចុប្បន្ននេះវាខុសស្រឡះ ព្រោះកូននាគភាគច្រើន បានធ្វើឲ្យអាប់ឱនពូជពង្សត្រកូលនាគអស់ហើយ មិនត្រឹមតែប៉ុណ្ណឹងទេ កូននាគមួយចំនួននាំគ្នាជេរប្រមាថមេនាគ ដែលជាព្រះម៉ែនាគទៀតផង។

នេះជាការបកស្រាយដោយសង្ខេប នៅក្នុងមង្គលទីពីរចំពោះកូនប្រុស ដែលបានធ្វើជាកូននាគ ហើយមាតាបិតាតែងធ្វើបន្តគ្នាពីមួយជំនាន់ទៅមួយជំនាន់ រហូតបានក្លាយជាទំនៀមទំលាប់ប្រពៃណីត្រូវបានបន្សល់ទុកជាកេរតំណែលរបស់ព្រះម៉ែម្ចាស់ប្រទេស ដូច្នេះទើបមានពាក្យទំនៀមមួយឃ្លាថា

**បួសនេនសងគុណម្ដាយ បំពេញភិក្ខុសងគុណឪពុក** (នេះជាពាក្យទំនៀមដែលបន្សល់ទុកពីដូនតាសម័យខាងដើម) ព្រោះហេតុអ្វី? ចម្លើយមិត្តអ្នកអានត្រិះរិះគិតរួចឆ្លើយ។

ខ/. ចុះចំណែកកូនស្រី តើមាតាបិតាគាត់ធ្វើមង្គលអ្វីឲ្យក្នុងមង្គលលើកទីពីរនេះ? គឺពួកគាត់ធ្វើពិធីចូលម្លប់ ដែលពិធីនេះទាក់ទងនឹងរឿងព្រេងពីបូរាណមួយ គឺរឿង**មេចោរចិញ្ចឹមកូនស្រី** (ប្រជុំរឿងព្រេងខ្មែរ) លាក់ទុកក្នុងរូងភ្នំ ដែលជាហេតុឲ្យកើតរឿងទំនៀមទំលាប់ប្រពៃណីរហូតមកដល់សម័យខាងក្រោយ គឺរឿងពិធីបញ្ចូលម្លប់កូនស្រី។

ពន្យល់ពាក្យ ( **ចូលម្លប់**)

ចូល = ទៅខាងក្នុង (សាច់រឿងគឺក្នុងរូងភ្នំ)

ម្លប់ = ទីដែលមានស្រមោលបាំង

ម្លប់ = ម + លុប (មឲ្យគេលប់កុំឲ្យដឹងរឿង) ព្រោះសាច់រឿង គឺពុំឲ្យអ្នកទីបី ដឹងរឿង។

ចំណែកឯកូនស្រីដែលត្រូវចូលម្លប់ក៏ដូច្នោះដែរ គឺពុំបានឲ្យអ្នកខាងក្រៅដឹងឡើយ ជាពិសេស **បុរស** រហូតពេលខ្លះគេពុំដឹងថា ក្នុងផ្ទះនោះមានកូនក្រមុំផង។ ក្នុងមង្គលទីពីរនេះ ទាក់ទិននឹងរឿងរបស់ស្ត្រីវាដូចជារឿងអាថ៌កំបាំងរបស់ **ព្រះម៉ែ** មហានគរយ៉ាងដូច្នោះដែរ គេបានបិទសន្ធប់លុបដានគាត់បាត់អស់ទៅហើយ ព្រោះក្នុងសាច់រឿងបុរសជាមេចោរដែលជាឪពុកចិញ្ចឹម បានសន្ធប់បិទមាត់រូងឲ្យជិតពុំឲ្យអ្នកទីបីដឹងរឿងឡើយ តែក្រោយមកដោយកូនចិញ្ចឹមនោះ មានជម្ងឺស្លេកស្លាំង ទើបឪពុកចិញ្ចឹមទៅរកពេទ្យឆ្មបស្រី ដើម្បីមកមើលជម្ងឺទើបកើតជារឿងដឹងបន្តគ្នា រហូតក្លាយទៅជាទំនៀមកូនស្រីត្រូវចូលម្លប់នេះ (បង្ខាំងទុក)។

គ/. សរុបសេចក្ដីមក ក្នុងមង្គលទីពីរដែលខ្ញុំបានបកស្រាយត្រួសៗនេះ មិនថាកូនម៉ែប្រុស ឬស្រីឡើយសុទ្ធតែត្រូវចូលទៅក្នុងទ្រូង (ទ + រូង) ទើបដឹងរឿងក្នុងបេះដូងម៉ែ (នៅក្នុងប្រស្នាចាក់ទឹកដូង) ពេលដឹងបណ្ដាំរឿងក្នុងបេះដូងព្រះម៉ែហើយ គេនឹងព្យាយាមជួយស្រង់គាត់ឲ្យរួចផុតពីទីទុក្ខនេះ

ទៅតាមកម្លាំងឧបនិស្ស័យកតញ្ញូកតវេទីរបស់កូននាគម្នាក់ៗ ដោយមានសទ្ធាជឿលើកម្មផល និងរួមទាំងមានសេចក្ដីព្យាយាមរបស់កូននាគប្រុសស្រី (សព្វថ្ងៃបណ្ដាំប្រស្នាចូលម្លប់នេះ មាននៅក្នុងរូងភ្នំឈ្មោកខេត្តកំពត) (គុហារ ក្នុងគុហារ) និងក្នុងរូងគុហារដទៃទៀត។

## ៣.មង្គលទីបី

នៅពេលដែលវ័យរបស់កូននាគប្រុសស្រី ចំរើនដល់វ័យគ្រប់អាយុ (គ្រប់ការ) ម្ដាយឪពុករាល់រូបតែងតែធ្វើ មង្គលទីបីជាចុងក្រោយឲ្យកូនប្រុសស្រី គឺមង្គលការ (អាពាហ៍ពិពាហ៍) មង្គលនេះ បានរំកិលធ្លាក់ទៅដល់ចុងជើងហើយ ព្រោះកូនប្រុសស្រីត្រូវចាកចេញពីម៉ែឪដើម្បីបង្កើតគ្រួសារថ្មី គឺចាប់ផ្ដើមកវែក កឆ្នាំង រៀបចំខ្លួនធ្វើជាម៉ែឪគេនៅពេលមង្គលទីបីនេះត្រូវបានបញ្ចប់។ តើក្នុងមង្គលទីបីនេះ កូននាគប្រុសត្រូវធ្វើអ្វី? កូននាគស្រីត្រូវធ្វើអ្វី?

ក/. ខាងកូនប្រុសត្រូវដើរតួជាព្រះថោង នាំយកនូវគ្រឿងបណ្ណាការចូលមកស្ដីដណ្ដឹងកូនស្រីតាមទំនៀមទំលាប់ ដែលបានធ្វើតៗគ្នាមកនៅក្នុងរឿងព្រេង **ព្រះថោងនាងនាគ**។ (សូមមិត្តអ្នកអានស្រាវជ្រាវក្នុងពិធីមង្គលការនេះ ដោយខ្លួនឯងចុះ)

ខ/. ចំណែកខាងកូនស្រីត្រូវដើរតួជាព្រះនាងនាគ ព្រោះខ្លួនបានចេញពីម្លប់ហើយ ដូច្នេះដល់ពេលដែលមាតាបិតារៀបចំទុកដាក់ឲ្យមានស្វាមី ទៅតាមគន្លងប្រពៃណី។ នៅក្នុងមង្គលទីបីនេះ ខ្ញុំចង់លើកយកនៅប្រស្នាអាថ៌កំបាំងខ្លះៗមកពន្យល់ថា ហេតុអ្វីបានជាព្រះនាងនាគបច្ចុប្បន្ននេះពុំបានដឹងរឿងរ៉ាវពិតរបស់ព្រះនាងនាគពីអតីតកាល? ហេតុអ្វីព្រះនាងនាគបច្ចុប្បន្ននេះ ពុំរុងរឿងថ្កុំថ្កើង ដូចព្រះនាងនាគពីអតីតកាល? ខ្ញុំនឹងឆ្លើយសំណួរនេះនៅទំព័រខាងក្រោយ។

គ/. នៅក្នុងមង្គលទីបីនេះ ខ្ញុំនឹងលើកយកគោលធំៗ ដែលមាននៅក្នុងពិធីនេះ គឺមាតាបិតាទាំងខាងកូនប្រុសកូនស្រី អ្នកផ្លូវចៅមហា មេបាប្រុសស្រី ដែលត្រូវបំពេញនូវកិច្ចការនេះ ។ខ្ញុំសូមដកស្រង់ទាំងស្រុងចេញពីសៀវភៅ **លំអានទំនៀមទម្លាប់ខ្មែរបុរាណ** (រៀបរៀងចងក្រងដោយលោក ញាណ ភឿន និងលោក ម៉ម ផៃ ក្នុងការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត ព.ស ២៥៤៦ គ.ស ២០០២)។

<u>គោលធំៗ មាន ៖</u>

១.ពិធីសែនក្រុងពលី

២.ពិធីស្ដីដណ្ដឹង

៣.ពិធីហែរកំណាត់

៤.ពិធីកាត់ផ្កាស្លា

៥.ពិធីកាត់សក់

៦.ពិធីសូត្រមន្ត

៧.ពិធីសែនគួចដៃ

៨.ពិធីធ្វើធ្មេញ ចែកជា ៖

ក.ក្រាលអង្កររាប

ខ.ធ្វើធ្មេញ

គ.ប្រតប់ធ្មេញ

ឃ.បរសេះ

ង.កាត់ខាន់ស្លា

ច.កប់ដី

៩.ពិធីយកពេលា (វេលា)

១០.ពិធីផ្ទឹមសំពះ

១១.ពិធីផ្សំដំណេក

ក្នុងពិធីទាំងដប់មួយធំៗនេះ ខ្ញុំសូមដកយកតែពិធីទី១០ មកបកស្រាយពន្យល់វែកញែក ដើម្បីកុំឲ្យអត្ថបទនេះកើនទំព័រច្រើនពេក ម្យ៉ាងទៀតខ្ញុំទុកឲ្យមិត្តអ្នកអានស្រាវជ្រាវពិធីនេះដោយខ្លួនឯង ដើម្បីជាកូនសោសំរាប់ពិចារណា បើកនូវអាថ៌កំបាំងក្នុងមង្គលទីបីនេះ ដែលទាក់ទងជាមួយនឹងរឿងព្រះម៉ែមហានគរ។

១.ក្នុងពិធីសំពះផ្ទឹម **អ្នកមហា** បានសុំឲ្យកូនស្រីមកលាងជើងកូនប្រុស ខាងកូនស្រីត្រូវមានផ្លែដូងឡៅទុកជាស្រេច រួចរកសំឡី ឬកូនកន្សែងថ្មីមកទុកជិតផ្លែដូងនោះ។ **មេខ្មែរ** អ្នកដឹកដៃកូនស្រីឲ្យនាងមកឈរមុខកូនប្រុស រួចឲ្យលុតជង្គង់សំពះកូនប្រុស ហើយកូនស្រីយកសំឡីឬកូនកន្សែងថ្មីមកជ្រលក់ទឹកដូងដែលឡៅទុកនោះ មកជូតជើងឲ្យកូនប្រុស ចំណែកឯកូនប្រុសយកវត្ថុដែលមានតម្លៃ មកបំពាក់ជូនឲ្យកូនស្រី ដែលជានិមិត្តរូបតំណាងឲ្យ**សុភមង្គល** ។ តើមិត្តអ្នកអានដឹងទេ ហេតុអ្វីបានជាត្រូវយកទឹកដូង មកលាងជើងឲ្យកូនប្រុស? អាថ៌កំបាំងទឹកដូងនេះ ខ្ញុំបានពន្យល់នៅភាគ១រួចហើយ កូននាគប្រុសស្រី ពុំអាចស្គាល់ទឹកក្នុងបេះដូងរបស់ព្រះ**ម៉ែនាគ**ឡើយគឺបានត្រឹមតែយកមកលាងជើងឲ្យគ្នា តែប៉ុណ្ណោះនេះជាអាថ៌កំបាំងក្នុងពិធីយកទឹកដូងមកលាងជើង។

២. ហើយកិច្ចមួយទៀត គឺពិធីហែកូនប្រុសស្រីចូលបន្ទប់ ពេលនោះកូនស្រីដើរតួជាព្រះ**នាងនាគ** រីឯកូនប្រុសដើរតួជាព្រះថោង (រឿងព្រះថោងតោងស្បៃនាងនាគ) តើក្នុងចំណោមទាំងពីរនាក់នេះអ្នកណាជា **មេ**? មេ គឺពិតជា**ព្រះនាងនាគ** ព្រោះគាត់បាន**ដើរមុខ នាំមុខ ដឹកមុខ** បុរសជាព្រះថោង។ តែគួឲ្យអាណិតព្រះនាងនាគណាស់ គ្រាន់តែដឹកគេចូលក្នុងបន្ទប់ផុតភ្លាម គេក៏បិទទ្វារបន្ទប់អាចារ្យនៅខាងក្រៅ បានឲ្យអ្នកភ្លេងច្រៀងបទលុបជើងពីរ(លុបដាន) ដោយឲ្យអ្នកច្រៀងអង្គុយចោងហោងច្រៀងបទលុបដាន ហើយធ្វើកាយវិការរំកិលថយក្រោយ ដូចជាលុបដានស្នាមជើងមនុស្សមែនៗ(**ស្នាលុបបំបាត់ដានព្រះម៉ែ**) ។ ចប់ពិធីលុបដានគេធ្វើពិធីសាកន្ទេល អ្នកភ្លេងលេងបទសាកន្ទេល អ្នកច្រៀងធ្វើកាយវិកាដូចជាអ្នកមូរសាកន្ទេល ចប់ពិធីសាកន្ទេលគេធ្វើពិធីលក់កន្ទេល ។ តើមិត្តអ្នកអានយល់ពីប្រស្នាក្នុងពិធីទាំងបីនេះទេ? **លុបដាន សាកន្ទេល លក់កន្ទេល** ។

នេះជាចម្លើយ ដែលព្រះនាងនាគបច្ចុប្បន្នពុំអាចដឹងនូវបណ្ដាំនៃភាពរុងរឿងថ្កុំថ្កើងរបស់ព្រះម៉ែនាគ គឺរឿងរ៉ាវពិតពីអតីតកាលរបស់គាត់ ព្រោះគ្រាន់តែគាត់ដឹកព្រះថោងចូលក្នុងបន្ទប់ភ្លាម គេបិទទ្វារជិត ដោយពុំបានដឹងរឿងអ្នកនៅខាងក្រៅគេធ្វើអ្វីឡើយ ។ គាត់មិនដឹងថាពួកគេនៅខាងក្រៅលុបដានស្នាមនៃភាពរុងរឿងរបស់ខ្លួនឡើយ ហើយស្នាមដែលនៅសេសសល់លុបមិនអស់ គេ**សាដានស្នាម**នោះឡើង (សាកន្ទេល) រួចប្រមូលយកទៅដើរលក់នៅខាងក្រៅ ហើយអ្នកដែលទិញដានស្នាមនៃភាពរុងរឿងរបស់គាត់គឺអ្នកខាងក្រៅ(បរទេស)នេះជាប្រស្នា **លុបដាន សាដាន លក់ដាន។**

៣/. ដូច្នេះកូននាគដែលកើតអំពីព្រះម៉ែនាគ ដែលគេបានលុបដាននៃភាពរុងរឿងរបស់គាត់អស់ហើយ ដែលគាត់នៅក្នុងបន្ទប់ពុំបានដឹងថាអ្នកខាងក្រៅលុបដានស្នាមដែលតំណាងឲ្យភាពរុងរឿងរបស់គាត់ឡើយ។ តើកូននាគដែលកើតចេញពីម៉ែនាគនៅក្នុងបន្ទប់ ដែលត្រូវគេលុបដានអស់នោះ ធ្វើដូចម្ដេចអាចដឹងពីបណ្ដាំរុងរឿងរបស់ព្រះម៉ែនាគពីអតីតបាន? បើពុំដឹងបណ្ដាំព្រះម៉ែនាគយ៉ាងហ្នឹង តើធ្វើដូចម្ដេចអាចក្លាយខ្លួនទៅជា **ព្រះនាងនាគ** ពិតប្រាកដបាន? (ស្គាល់ដានស្នាមប្រវត្តិសាវតាពិតរបស់ព្រះម៉ែពីអតីតកាល)។ ឧ: ដូចជារឿងមាតាទាំង **១២** សព្វថ្ងៃត្រូវគេខ្វេះកែវភ្នែកទាំងដប់មួយកន្លះចោលអស់ទៅហើយតើកូនដែលកើតចេញពីមាតាទាំង**១២**នោះភ្លឺ ឬមួយងងឹត?

ភ្នែកមាតាមួយគូ = **៣០**ឬ**៣១**ថ្ងៃ x **១២**ខែ = **៣៦៥**ថ្ងៃ តែសព្វថ្ងៃនៅសល់តែភ្នែកមួយចំហៀងស្មើ**១៥**ថ្ងៃ តើធ្វើដូចម្ដេចឲ្យកូនខ្មែរដឹងរឿងពីអតីតបាន ? បើ**៣៦៥**ថ្ងៃដក នឹង**១៥**ថ្ងៃ = **៣៥០**ថ្ងៃ នេះ គឺជា ថ្ងៃដែលកូន និងម៉ែសម័យក្រោយងងឹតព្រោះនគរនេះ គឺជាមាតុភូមិ = ទីកើតរបស់កូនប្រុសស្រី ហើយរឿងមាតាទាំង**១២**នេះទៀតសោត គឺជារឿងពិតប្រចាំនគរនេះទៀតផង។ ដោយពួកគាត់បានសាងប្រាសាទព្រះនាង**១២** ឬស៊ូព្រាត់ទុកជាកេរបណ្ដាំព្រះម៉ែឲ្យយើងមើលរហូតមកដល់សព្វថ្ងៃ ។

ឃ/. នេះជាចម្លើយដែលខ្ញុំបានបកស្រាយពន្យល់ដោយសង្ខេបនៅក្នុងអាថ៌កំបាំងដែល ទាក់ទងនឹងមង្គលទីបីនេះ។ សរុបសេចក្ដីមក កាតព្វកិច្ចរបស់មាតាបិតាពីអតីត តែងធ្វើការជាមង្គលឲ្យកូនបីលើក ដូច្នេះហើយទើបកូនខ្មែរពីសម័យដើម ពុំសូវមានកូនដែលទៅប្រព្រឹត្តអំពើខុសឆ្គងឡើយ ព្រោះម្ដាយឪពុកតាមគ្រប់គ្រងកូនគ្រប់កាលនិងគ្រប់វ័យ បើនិយាយពីបច្ចុប្បន្ននេះវិញ មានមាតាបិតាខ្លះ សូម្បីតែមង្គលមួយក៏ពុំបានធ្វើឲ្យកូនផង នេះហើយអ្នកស្នងមរតកព្រះម៉ែ(ខ្មែរ) បើមាតាបិតារាល់រូប

ប្រោះបង់នូវមង្គលគឺសេចក្ដីល្អចោលអស់យ៉ាងហ្នឹង តើអនាគតមាតុភូមិនេះនឹងទៅជាយ៉ាងណា? តើព្រះម៉ែមហានគរលោកអាចសង្ឃឹមទៅលើកូននាគប្រុសស្រីសម័យក្រោយបានដែរឬទេ? ដែលគាត់រង់ចាំឲ្យកូននាគជួយគាត់នោះជាពិសេសគឺកូននាគសព្វថ្ងៃដែលជាអ្នកទទួលនូវមរតកបណ្ដាំព្រះម៉ែ ។

សូមឲ្យកូននាគប្រុសស្រី(ម៉ែឪកូនចៅ) នាំគ្នាសាមគ្គីពួតដៃជាធ្លុងមួយ (សាមគ្គីនាគព័ន្ធ ឬព័ន្ធនាគ) ដើម្បីជួយស្រង់ព្រះមាតាបិតាឡើងវិញ មានតែកូនកតញ្ញូទេដែលអាចជួយស្រោចស្រង់ពួកគាត់បាន។ ព្រះម៉ែនាគមានគុណធំជាងភ្នំ**ព្រះសុមេរុ** ហេតុអ្វីបានជាយើង មើលពុំឃើញនូវគុណដ៏ធំរបស់លោក? ហេតុអ្វីបានជាយើងយកភាពអាក្រក់នៃភេទរបស់គាត់(យោនី) ដែលសំរាប់បង្ហូរនូវទឹកមូត្រ និងកាកសំណល់ ឈាមខ្មះ យកមកដាក់នៅក្នុងមាត់ទៅវិញ? (ពេលជេរម៉ែគ្នាម្ដងៗកូនតែងយកភេទម៉ែមកដាក់ក្នុងមាត់)។ សូមកូននាគប្រុសស្រីភ្ញាក់ឡើង ពេលវេលារបស់យើងដល់ហើយ សូមកូនខ្មែរនាំគ្នាក្រោកចាកចេញពីអន្លង់ក្រពើ(ក្រធ្វើដឹង)នេះទៅ។ ព្រោះយើងជាអ្នកកាន់ និងគោរពព្រះពុទ្ធសាសនា ដូច្នេះយើងត្រូវតែដឹងហេតុផលរបស់ **កុសល** និង**អកុសល** ដែលពួកគាត់បានសាងសន្សំទុកដើម្បីជាប្រយោជន៍សម្រាប់កូនខ្មែរគ្រប់ៗគ្នាហេតុនេះអ្នកទទួលមរតកព្រះម៉ែ ត្រូវតែតបនូវគុណគឺសេចក្ដីល្អទៅពួកគាត់វិញ(កតញ្ញូកតវេទី)។

**II.** ហើយជាបន្តខ្ញុំនឹងបកស្រាយ ពន្យល់អំពីអាថិកំបាំងមហាសង្ក្រាន្តខ្មែរក្នុងរឿង **កបិលមហាព្រហ្ម** ដែលទាក់ទងនឹងរឿងសិរីបីប្រការ ដែលកូនខ្មែរប្រុសស្រីប្រារព្ធធ្វើនៅខែចេត្រក្នុងរដូវចូលឆ្នាំថ្មី។ ដើម្បីប្រៀបធៀបថា តើរឿងមង្គលបី និងរឿងសិរីបី វាមានបង្កប់អត្ថន័យដូចគ្នា ឬមួយក៏ខុសគ្នា? (រឿងព្រេងនេះជារឿងទាក់ទងក្នុងនគរខ្មែរ)។

ពន្យល់ពាក្យសិរី = ស្រី ➔ សិរីបីប្រការ = រឿងរ៉ាវស្ត្រីបីយ៉ាង

រឿងសិរីបីប្រការ គឺជាបណ្ដាំរឿងរបស់ស្ត្រីបីយ៉ាង ដែលបានលាក់ទុកក្នុងទំនៀមទំលាប់នៃពិធីមហាសង្ក្រាន្តចូលឆ្នាំថ្មី ហើយជារឿងប្រចាំនគរនេះសំរាប់ផ្លាស់ប្ដូរឆ្នាំថ្មី សិរីទាំងបីប្រការនោះមាន ៖

១.ពេលព្រឹកសិរី (ស្រី) នៅលើមុខឬក្បាល (បុរសស្ត្រីត្រូវយកទឹកលាងមុខឬលុបមុខ)

២.ពេលថ្ងៃ សិរី (ស្រី) ធ្លាក់ចុះមកដល់ដើមទ្រូង (បុរសស្ត្រីត្រូវយកទឹកមកលុបលាងទ្រូង)

៣.ពេលល្ងាចសិរី (ស្រី) ធ្លាក់ចុះមកដល់ចុងជើង (បុរសស្ត្រីត្រូវយកទឹកមកលុបលាងជើង)

រឿងសិរីទាំងបីនេះ យើងបានតែត្រឹមធ្វើតគ្នាពីមួយជំនាន់ទៅមួយជំនាន់តែប៉ុណ្ណោះ គឺពុំបានដឹងរឿងពិតរបស់ស្ត្រី ដែលជាម្ចាស់រឿងនោះឡើយ។ ហើយសិរីបីនេះ កើតមានក្នុងរឿងព្រេងខ្មែរ គឺរឿងកបិលមហាព្រហ្ម ដែលបានយកប្រស្នាបីខទៅសាកសួរថៅមាណពឈ្មោះធម្មបាល ដែលល្បីថាគាត់ចេះដឹងធម៌អាថ៌ច្រើន ហើយបានដាក់ខសន្យាគ្នាថា ៖ ប្រសិនបើថៅមាណពឯងដោះប្រស្នាសិរីទាំងបីនេះមិនចេញទេត្រូវតែកាត់ក្បាល តែបើដោះប្រស្នាចេញយើងសុខចិត្តកាត់ក្បាលឲ្យ។ ទីបំផុតថៅធម្មបាលមាណព បានដោះប្រស្នានោះចេញ ដោយសារបានស្តាប់ពាក្យ កូនឥន្ទ្រីសាកសួរមេឥន្ទ្រីពីអាថ៌កំបាំងនៃប្រស្នាទាំងបី។ ពេលដែលមហាព្រហ្មបានចាញ់ក្តីនេះ ដោយធម្មបាលមាណពដោះប្រស្នាសិរីបីនេះរួច គាត់ក៏ព្រមកាត់ព្រះសិរសា (ក្បាល) ប៉ុន្តែមុននឹងកាត់ គាត់ក៏បានហៅកូនស្រីតំណាងឲ្យថ្ងៃទាំង**៧** មកប្រាប់រួចផ្តាំថា ក្បាលរបស់ឪពុកនេះ ប្រសិនបើយកទៅដាក់នៅក្នុងសមុទ្រ នឹងរីងទឹកសមុទ្រ ប្រសិនបើដាក់នៅអាកាសនឹងរាំងភ្លៀង ប្រសិនបើដាក់នៅលើផែនដី នឹងធ្វើឲ្យឆេះដីប្រេះបែកក្រហែង មានតែយកទៅដំកល់ទុកក្នុងរូងគុហារភ្នំព្រះសុមេរុ។ ពេលផ្តាំបុត្រីទាំង**៧** រួចហើយកបិលមហាព្រហ្មក៏ចាប់កាន់ព្រះខ័ន កាត់សិរិសាហុចទៅឲ្យកូនស្រី កូនស្រីក៏នាំគ្នាដង្ហែរ ព្រះសិរិសាព្រះបិតាទៅដំកល់ទុកនៅភ្នំព្រះសុមេរុ (សុម៉ែរុ)។ បុត្រីទាំង**៧**បានប្រជុំដាក់វេនគ្នាថា ប្រសិនបើចក្រវិល (ផែនដីវិល) ទៅដល់ខួបចំលើថ្ងៃអ្នកណាដែលជាថ្ងៃសង្ក្រាន្ត កូនស្រីនោះត្រូវមកហែព្រះសិរសាបិតាប្រទក្សិណាប្រាំពីរជុំជុំវិញភ្នំព្រះសុមេរុជារៀងរាល់ឆ្នាំ។

តាមពិត កូនស្រីរបស់គាត់មានដល់**១២**នាក់ឯណោះ ប៉ុន្តែអ្នកមកដង្ហែមានតែប្រាំពីរនាក់ទេ




នេះម្យ៉ាង ម្យ៉ាងទៀត កូនស្រីៗរបស់គាត់តែងប្រចាំគ្នា ព្រោះតែមានការប្រចាំគ្នាដល់វេនអ្នកណាអ្នកហ្នឹងដង្ហែទៅ ឯអ្នកមិនត្រូវវេនគឺមិនរវីរវល់ឡើយ។ ព្រោះហេតុអ្វី? ព្រោះហេតុតែកូនស្រីទាំង**១២**ត្រូវយក្សខ្វេះយកភ្នែក (បញ្ញា) អស់ទៅហើយ នៅសល់មួយចំហៀង ហើយកូនស្រីទាំង**១២**នេះទៀតសោតមានតែ**៧**

ទេដែលមកដង្ហែសិរសាមាតាបិតាខ្លួនជារៀងរាល់ៗឆ្នាំនោះ (រូបចម្លាក់នៅជុំវិញកព្រហ្មនៅប្រាសាទតាព្រហ្ម និងបន្ទាយក្ដី)។

ក. ***សិរីទីមួយ*** សូមមិត្តអ្នកអានពិចារណា និងប្រៀបធៀបទៅមើល សិរីទីមួយស្ថិតនៅលើមុខ **មុខ**មានន័យថា ប៉ែកខាងក្បាលឬខាងលើ ដូច្នេះវាដូចនឹងមង្គលទីមួយដែលនៅពីខាងលើដែរគឺ***ការដុកលាក់បង្កើយ*** បានន័យថាប្រស្នាយកទឹកមកលុបមុខឬក្បាលនេះ គឺគាត់ចង់ឲ្យយល់ពីប្រស្នាអាថ៌កំបាំងនៃមង្គលទីមួយ និងសិរីទីមួយ គឺវាទាក់ទងនឹងអវយវៈប៉ែកខាងលើ គឺសិរសានេះឯង។ តើទឹកដែលយកមកលុបគ្រប់កាលទាំងបីនោះតំណាងឲ្យអ្វី? ទឹកតំណាងឲ្យ ទឹកចិត្តកូននាគប្រុសស្រី តើកូននាគប្រុសស្រីណាដែលមានឧបនិស្ស័យសន្សំនូវទឹកចិត្តកតញ្ញូ ដែលអាចចាក់ទឹកទៅក្នុងបេះដូងរបស់ព្រះម៉ែ ហើយដឹងរឿងព្រះម៉ែ រួចជួយស្រោចស្រង់គាត់ចេញពីអបាយភូមិបាន? ព្រោះដូនតាយើងមានពាក្យទំនៀមមួយឃ្លាថា ***ម៉ែឪគិតកូនដូចជាច្រវាប្រដេញ ចំណែកកូនគិតម៉ែឪវិញដូចព្រះបែរក្រោយ*** តើព្រះឯណាងាយនឹងបែរព្រះភក្ត្រទៅខាងក្រោយនោះ? តើកូននាគណាមួយ ដែលបានយកទឹកចិត្តទៅលាងអកុសលកម្មឲ្យព្រះម៉ែបាន? តើកូននាគណាដែលបានយកទឹកចិត្តព្រះម៉ែទៅលុបមុខ ដើម្បីឲ្យស្វាងងងុយ ហើយមើលឃើញពីបណ្ដាំពិតរបស់ព្រះម៉ែ?

ខ. ***សិរីទីពីរ*** គឺស្ថិតនៅលើដើមទ្រូង មានន័យថាថ្ងៃត្រង់ត្រូវយកទឹកទៅលាងទ្រូង ពាក្យ ***ទ្រូង*** ខ្ញុំបានពន្យល់រួចហើយ ***ទ្រូង*** គឺជាទីលាក់ទុកនូវបេះដូង បេះដូងជាទីលាក់ទុកនូវចិត្ត ប្រសិនបើយើងប្រៀបធៀបសិរីទីពីរនេះទៅនឹងមង្គលទីពីរ គឺកូនប្រុសបំបួសនាគកូនស្រីចូលម្លប់ មានន័យថា៖ ចូលទៅក្នុងទ្រូង រុងយកបេះដូងម៉ែឪមកមើល។ តែអត្ថន័យនៅក្នុងសិរីទីពីរ គឺមានន័យស្រាលជាងមង្គលទីពីរ ព្រោះគ្រាន់តែយកទឹកមកលុបលាងទ្រូងខាងក្រៅ ធ្វើដូចម្ដេចអាចដឹងរឿងខាងក្នុងចិត្តបាន? ព្រោះរឿងខាងក្នុងចិត្តទាល់តែយកបញ្ញាទៅស្រាយ ព្រោះព្រះម៉ែជាប់ចំណងអកុសលចិត្ត ប្រសិនបើកូនប្រុសស្រីចង់ស្រាយចំណងចិត្តម៉ែឪ ទាល់តែកូនប្រុសស្រីបំពេញនូវ**កតញ្ញូ**និង**កតវេទី** គឺជាទឹកចិត្តដែលមាននូវគុណធម៌ ទើបអាចយកទៅលាងទឹកចិត្តនៅក្នុងបេះដូងម៉ែឪបាន ធ្វើឲ្យពួកគាត់អាចរួចផុតពីអបាយភូមិបាន ដូចព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ព្រះអង្គបានបំពេញកិច្ចជាកូនបានល្អហើយ ដោយព្រះអង្គបានសំដែងព្រះធម៌ប្រោសពុទ្ធបិតា អោយបានទទួលនូវអមតធម៌ គឺព្រះនិព្វាន្ត ហើយ

ចំណែកឯពុទ្ធមាតាវិញ គឺលោកបានសំរេចនូវអរិយផលថ្នាក់ **លោកានាមិស្សសោតា** ទៀងតែនឹងបានត្រាស់ដឹង និងត្រូវបរិនិព្វានត្តនៅឋានព្រហ្មលោក។ ចុះចំណែកកូននាគប្រុសស្រីវិញ ដែលបានទទួលមរតកពីព្រះម៉ែ គឺព្រះពុទ្ធសាសនានេះ តើអ្នកមានបំពេញសេចក្ដីល្អ គឺការតបគុណដល់មាតាបិតាបង្កើត ឬក៏ដល់ព្រះមាតាបិតាម្ចាស់នគរនេះទេ? តើអ្នកបានដើរតាមគន្លងព្រះយុគលបាទ ព្រះពុទ្ធជាបរមគ្រូអ្នកទេ? ចម្លើយនេះ គឺកូននាគប្រុសស្រីពិចារណារួចឆ្លើយដោយខ្លួនឯង !...

គ.**សិរីទីបី** គឺថ្ងៃល្ងាចយកទឹកទៅលាងជើង គឺប៉ែកខាងក្រោមបើប្រៀបធៀបនឹងមង្គលទីបី គឺកូនប្រុសធ្វើជាព្រះថោងចំណែកឯកូនស្រីធ្វើជាព្រះនាងនាគ គឺអ្នកទាំងពីរចាប់ផ្ដើមចាកចេញពីមាតាបិតាដើម្បីបង្កើតគ្រួសារថ្មី។ ចុះហេតុអ្វីក៏ក្នុងសិរីទីបីត្រូវយកទឹកទៅលុបលាងជើង? ព្រោះមង្គលទាំងបីជាកិច្ចរបស់មាតាបិតារាល់រូបដែលត្រូវបំពេញ(ពីសម័យដើម) ពេលដែលបំពេញរួចហើយចុងក្រោយគឺមាតាបិតាត្រូវតែលាងជើង បានន័យថា ដើម្បីលាងជម្រះនូវរឿងជំពាក់ទាំងឡាយ ហើយមកធ្វើទីពឹងឲ្យខ្លួនឯងសម្រាប់លោកខាងមុខ(ស្វែងរកសីលសមាធិបញ្ញា) ទប់ទល់នូវបាបអកុសលដែលពួកគាត់ក្នុងមួយជីវិត ដើរគ្រប់ច្រកល្ហកស្វែងរកនូវបច្ច័យបួន(ទ្រព្យ)ដើម្បីយកមកចិញ្ចឹមបុត្រ។ ដូច្នេះកិច្ចចុងក្រោយរបស់មាតាបិតាគឺរកស្វាមី ភរិយាឲ្យកូនរួចចែករំលែកនូវទ្រព្យទៅតាមខ្លួនមាន ពួកគាត់បានបំពេញកិច្ចទៅដល់ទីបញ្ចប់ហើយ រីឯកូនប្រុសស្រីត្រូវបំពេញនូវសេចក្ដីល្អរបស់ខ្លួនតបទៅពួកគាត់វិញ ដែលពួកគាត់បានខំពុះពារមួយជីវិត ដើម្បីបំពេញកិច្ចជា **ព្រះព្រហ្ម**។ ការបកស្រាយពន្យល់មួយបែបទៀតពីសិរីបីប្រការនេះ គឺតំណាងឲ្យពួកគាត់រួចចេញពីទីឃុំឃាំង ក្នុងទ្វារគុកទាំងបី (ខ្ញុំពុំបកស្រាយឡើយ)។

ហេតុនេះរឿង **សិរីបីប្រការ** និងរឿង**មង្គលទាំងបី** មានអត្ថន័យប្រហាក់ប្រហែលគ្នា ហើយរឿងទាំងនេះ សុទ្ធតែបានបង្កប់នូវអាថ៌កំបាំងបណ្ដាំព្រះមាតាបិតាមហានគរ វាខុសពីមង្គលសូត្រដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងក្នុងមង្គល **៣៨ប្រការ** នោះ។ មង្គលរបស់ខ្មែរទាក់ទិនទៅក្នុងរឿង អាថ៌កំបាំងប្រស្នារបស់ព្រះម៉ែម្ចាស់នគរ (មាតាមហានគរ) ចំណែកឯមង្គលសូត្រដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងទាក់ទងនឹងមង្គលរបស់មនុស្ស និង ទេវតា ដែលក្នុងកាលសម័យនោះ ទេវតាបានចុះមកសាកសួរមង្គលពីព្រះអង្គនៅវត្ត **ជេតពនមហាវិហារ**។

ចំណែកឯរឿងកបិលមហាព្រហ្ម ដែលទាក់ទងនឹងប្រស្នាសិរីបីប្រការ មកទល់សព្វថ្ងៃនេះ ពួកគាត់នៅតែមិនស្លាប់ នៅតែស្ថិតក្នុងសន្ដានកូនខ្មែរប្រុសស្រីគ្រប់ៗរដូវចូលឆ្នាំថ្មី ហើយសិរិសារបស់មហាព្រហ្មនេះទៀតសោត បានរីកសាយដុះដាលគ្រប់ប្រាសាទថ្ម ដែលជាស្នាព្រះហស្ថរបស់ស្ដេចជ័យវរ្ម័នទី៧ (ប្រាសាទមានមុខ **ព្រហ្ម**) ហើយបានបន្សល់ទុកជាកេរតំណែលរហូតមកដល់សព្វថ្ងៃជាមរតកបណ្ដាំរបស់ព្រះម៉ែ (រឿងរ៉ាវនេះខ្ញុំបានពន្យល់ក្នុងភាគមួយខ្លះហើយ)។

សរុបសេចក្ដីមករឿងមង្គលបីប្រការក្ដី រឿងសិរីបីប្រការក្ដីគឺមានតែក្នុងនគរខ្មែរនេះទេ ព្រោះពួកគាត់ បានតែងសាច់រឿងបញ្ចូលលាយឡំទៅក្នុងព្រះត្រៃបិដក(ពុទ្ធសាសនា) ក្នុងគម្ពីរវេទ (ព្រហ្មញ្ញសាសនា) ព្រោះវាជារឿងទាក់ទងនឹងមាតុភូមិនេះ មិនត្រឹមតែប៉ុណ្ណឹងទេ ដូនតាអ្នកនគរនេះ បានតាក់តែងលាយឡំទៅក្នុងជាតក បញ្ញាសជាតក និងជាតកនានា ដែលមាននៅក្នុងព្រះពុទ្ធសាសនា ដើម្បីបំភាន់លាក់រឿងពិតរបស់ព្រះម៉ែមហានគរ។ ដូចជារឿងឥសីមាត់ទិព្វ សព្វសិទ្ធ ព្រះសុធន ក្រុងសុភមិត្ត) ពុទ្ធសែន...។ល។ ឧ. ដូចរឿងពុទ្ធសែននាងកង្រី ឬនាងដប់ពីរ ក្នុងសាច់រឿងគាត់ចង់និយាយពីម្ដាយទាំងដប់ពីរ ដែលបានទទួលមរតកពីព្រះម៉ែមហានគរ ប៉ុន្តែទីបំផុតពួកគាត់ពុំអាចថែរក្សានូវពូជបញ្ញា និងភាពថ្កុំថ្កើងរបស់ព្រះម៉ែមហានគរបានឡើយ ព្រោះត្រូវគេខ្វេះកែវភ្នែក (យក្សខ្វេះ) គឺខ្វេះបញ្ញានៅសល់តែកែវភ្នែកមួយចំហៀងតែប៉ុណ្ណោះ តើធ្វើដូចម្ដេចឲ្យកូនខ្មែរបានដឹងរឿងរបស់បុព្វជនព្រះម៉ែនាគខាងដើមបាន? បើអ្នកទទួល**បណ្ដាំមរតក**ងងឹតទៅហើយនោះ (ចូរមើលការពន្យល់នូវទំព័រលើ)។ បើកូនកើតចេញពីម្ដាយដែលឥតបញ្ញាដូច្នេះ តើពួកគេអាចដឹងពីសាវតាពិតរបស់ខ្លួនបានដែរឬទេ? គឺពិតជាពុំអាចដឹងបានឡើយ។ ចុះយក្សដែលជាអ្នកខ្វេះកែវភ្នែកជានរណា? ខ្ញុំបានពន្យល់រួចមកហើយពីរអាថ៌កំបាំងកូរសមុទ្រទឹកដោះ គឺយក្សគេកាន់ក្បាលនាគ (និមិត្តរូបក្បាលព្រះម៉ែ) បើក្បាលគេជាអ្នកគ្រប់គ្រងទៅហើយ តើអ្នកនៅកាន់កន្ទុយមានប្រយោជន៍អ្វី? ដូចជាមាតាខ្វាក់ទាំងដប់ពីរក៏យ៉ាងដូច្នោះដែរ មានកែវភ្នែកឯណាដើម្បីមើលដឹងរឿងពិតរបស់ខ្លួន បើកែវភ្នែកពួកគាត់នៅសល់តែមួយចំហៀងយ៉ាងនេះ ហើយមួយចំហៀងនេះ ត្រូវកើតមានរោគភ្នែកខ្លះទៀត (មានរូបមានរោគ ព្រោះរូបជាសំបុកនៃរោគ) ដែលធ្វើឲ្យភាពភ្លឺ នៅសល់ដប់ប្រាំថ្ងៃនោះ រឹតតែនៅខើចខ្លីទៅទៀត។ នេះជាអាថ៌កំបាំងដែលដូនតាបានលាក់ទុកក្នុងរឿងព្រេង ឈ្មោះប្រាសាទ ឈ្មោះភ្នំ និងធម្មជាតិ រួមទាំង

ប្រពៃណីទំនៀមទំលាប់សាសនា និងទំនាយផ្សេងៗ...។ល។ បើចង់ដឹងរឿងពួកគាត់ត្រូវតែបូកបញ្ចូលកេរទាំងអស់ ទើបអាចដឹងរឿងរ៉ាវកេរតំណែលរបស់ពួកគាត់បាន ព្រោះរឿងពួកគាត់បានពូនគរដូចជាភ្នំ ហើយពួកគាត់ធ្វើប្រាសាទនៅលើភ្នំមួយក្នុងខេត្តសៀមរាបឈ្មោះថា **ប្រាសាទភ្នំបូក** បើយើងត្រឡប់ពាក្យនេះមកវិញ គឺបូកភ្នំមានន័យថា បើចង់ដឹងរឿងដ៏ធំដូចជា **ភ្នំ** របស់ពួកគាត់ ទាល់តែនាំគ្នាបូកភ្នំទូទាំងមាតុភូមិនេះ ទើបអាចរកអាថិកំបាំងរបស់ព្រះម៉ែឃើញ ព្រោះនៅលើភ្នំនោះ គាត់បានសាងរូបស្តេចលិង្គ និងយោនីដ៏ធំដែលសព្វថ្ងៃត្រូវបានបំផ្លាញ គាត់បានប្រាប់ឈ្មោះផ្លូវទៅកាន់ភ្នំបូក គឺភូមិប្រដាក់ ឬបណ្តាក់ប្រៀបបីដូចជា សត្វខ្យងបណ្តាក់គ្នាដើម្បីផ្ញាញ់ទន្សាយយ៉ាងដូច្នោះ។ ពាក្យថា **បណ្តាក់** គឺមានន័យថា **តៗគ្នា** នៅក្នុងភាគមួយខ្ញុំបានពន្យល់ពីភ្នំហាន់ជ័យ ឬប្រាសាទហាន់ជ័យ ចង់ផ្តុំផ្គុំនូវរឿងរ៉ាវដែលគេហាន់ជាចំណិតៗនោះ ទាល់តែផ្គុំតៗគ្នា ព្រោះហេតុអ្វី? ព្រោះទីដែលកើតនូវភាពរុងរឿងពីអតីតរបស់ព្រះម៉ែ ត្រូវបាត់ដាន(បាត់ទី)អស់ទៅហើយ ព្រោះពួកគេបានលុបដានស្នាមរបស់គាត់ (អាថិកំបាំងក្នុងមង្គលទីបី ព្រះថោងតោងស្បៃព្រះនាងនាគ)។ ដូចនេះ ទើបគាត់កសាងប្រាសាទមួយឡើងក្នុងខេត្តតាកែវ ក្នុងទីតាំងទន្លេបាត់ទី **ប្រាសាទតាព្រហ្ម** ចុះហេតុអ្វីបានជាបាត់ទី? ព្រោះទីដែលហូរនាំមកនូវប្រភពទឹកចូលទន្លេនោះ បានបាត់ប្រភពដើមវាអស់ហើយ។ សព្វថ្ងៃគេហៅប្រាសាទនោះថា ទន្លេបាទី ពាក្យថា **បាទី** និង **បាត់ទី** តើពាក្យទាំងពីរនេះ ពាក្យមួយណាត្រឹមត្រូវជាង? សូមមិត្តអ្នកអានពិចារណា ទៅតាមការបកស្រាយខាងក្រោមចុះ។ ឧ. ដូចទន្លេមេកុង (មេគង្គ) ប្រភពដើមហូរចេញមកពីភ្នំទីបេ ចុះទន្លេបាទីវិញ ប្រភពហូរមកពីណា? ហើយទន្លេមេកុងនេះ មិត្តអ្នកអានពិចារណាទៅមើល ហូរមកពីដំបូង **មេ** មុន **កុង** (មេនៅពីមុខកុង) ប៉ុន្តែពេលដែលហូរមកដល់ខេត្តកំពង់ចាមទន្លេត្រូវបិទ(ទន្លេបិទ) ប៉ុន្តែការបិទមេពុំជាប់ឡើយ មេត្រូវហូមកដល់ ទន្លេបួនមុខទើបត្រូវបាត់ពាក្យមេ (បាត់ដាន) អស់ទៅហើយ។ បែកទីមួយឈ្មោះ**ទន្លេសាប** បែកទីពីរឈ្មោះ**ទន្លេបាសាក់** បែកទីបីឈ្មោះ**ទន្លេធំឬអ្នកលឿង** ហេតុអ្វីបានជាបាត់ឈ្មោះមេកុង? ព្រោះស្នាមដានរបស់មេ ត្រូវគេលុបបាត់ដានទៅហើយ សព្វថ្ងៃបុរសដណ្តើមធ្វើមេតែតាមពិតគឺជា **បា** សោះ (វប្បធម៌សង្កត់មេ ឬលុបដានមេ គឺ **កុង សង្កត់ ម៉ា**)។

ចំណែកនៅប្រាសាទទន្លេបាត់ទី(ប្ញាទី)វិញ គាត់បានឆ្លាក់រៀបរាប់រឿងមាតា នៅក្នុងចម្លាក់ផ្ដែរមួយផ្ទាំង ដែលសព្វថ្ងៃបានបាក់ធ្លាក់ជ្រុះទៅលើដីខាងមុខផ្លូវចូលប្រាសាទនោះ។ គាត់បានឆ្លាក់


**ផ្ដែរប្រាសាទតាព្រហ្ម នៅទន្លេប្ញាទី**

រៀបរាប់ពីបុរសម្នាក់ ក្បាលពាក់មកុដ ដៃកាន់ព្រះខ័ន លែងខ្លួនទទេល្វែងខាងលើ កំពុងបរទេះសេះ ដែល មានដឹកស្ត្រីបីនាក់នៅលើរទេះនោះ ។ ស្ត្រីទាំងបីអ្នកនោះក្បាលពាក់មកុដ លែងខ្លួនទទេល្វែងខាងលើ ដូចអ្នកបរទេះដែរ ប៉ុន្តែគេ ឆ្លាក់ស្ត្រីទាំងបីនោះ ស្ត្រីទីមួយមានរូបរាងតូច ទីពីររាងធំបន្តិច ឯរូបស្ត្រីទីបីធំជិតស្មើនឹងបុរសបរទេះ ហើយនៅពីខាងមុខនិងខាងក្រោយរទេះ មានកងទ័ពកំពុងឈរជាជួរ ខ្លះកាន់ក្លស់ ខ្លះកាន់លំពែង ឬដាវខ្លះកាន់ផ្លិត និងខ្លះទៀតកាន់ទង់ជ័យនៅឈរហែហមរទេះ ដែលកំពុងដឹកស្ត្រីទាំងបីនោះចេញ។ តើស្ត្រីទាំងបីនាក់នៅលើរទេះនោះតំណាងឲ្យអ្វី? ហើយនាក់បរទេះតំណាងអ្វី? ពួកគាត់ទាំងបីនាក់នោះតំណាងឲ្យរឿងរ៉ាវ ក្នុងមង្គលទាំងបីនិងក្នុងរឿងសិរីបីប្រការ (ស្រីបី) ចំណែកឯបុរសជាអ្នកបរទេះវិញ គឺជាអ្នកដឹកបណ្ដាំរឿងរបស់ពួកគាត់ទាំងបីនាក់ចេញ (ស្រីបី) ដើម្បីយកមកបើកបង្ហាញឲ្យកូននាគប្រុសស្រីបានឃើញ និងដឹងពីអាថិកំបាំងពិតរបស់ស្ត្រីនោះ គឺ **ព្រះម៉ែមហានគរ**។

**III.** ដោយខ្លាចក្រែងមិត្តអ្នកអានពុំទាន់យល់ ខ្ញុំនឹងលើករឿងដែលទាក់ទងនឹងឈ្មោះភ្នំ ប្រាសាទ និងភូមិ ស្រុក.... ដែលមានអាថិកំបាំងបង្កប់នូវរឿងរ៉ាវរបស់មាតាមហានគរ មកពន្យល់បកស្រាយជាបន្ថែមដើម្បីឲ្យកាន់តែច្បាស់។

ភ្នំជាទីដីខ្ពស់ ដែលធម្មជាតិបានតាក់តែង ឬមនុស្សពូនចាក់គរឲ្យទៅជាភ្នំ ភ្នំមានជើងភ្នំ ចង្កេះភ្នំ ច្រមុះភ្នំ ខ្នងភ្នំ កំពូលភ្នំ មាត់រូងភ្នំ...។ ភ្នំពិតមែនតែជាដីធម្មជាតិ ប៉ុន្តែមានឈ្មោះស្រដៀងអវយវៈមនុស្សដែរ(ជើង ចង្កេះ ច្រមុះ មាត់ ខ្នង...) គឺខ្វះតែបន្តិចបន្តួចតែប៉ុណ្ណោះ។ ហេតុនេះហើយ បានជាព្រះម៉ែនាគយកគំនិតបណ្តាំរបស់គាត់មួយចំនួន បញ្ចូលទៅក្នុងឈ្មោះរបស់ភ្នំ ព្រោះរឿងរបស់គាត់គឺពូនទៅជាភ្នំ ហើយភ្នំខ្លះទៀតគាត់បានឲ្យកូននាគសម័យអង្គរ កសាងប្រាសាទបន្ថែមពីលើភ្នំនោះ ដើម្បីឲ្យកាន់តែច្បាស់នូវរឿងហេតុបណ្តាំរបស់គាត់។ ខ្ញុំនឹងរៀបរាប់ពន្យល់ពីឈ្មោះភ្នំ ប្រាសាទ រួមទាំងអ្វីៗដែលទាក់ទងអាថ៌កំបាំង**ព្រះម៉ែ**នេះ ដើម្បីជាប្រយោជន៍ដល់កូននាគទាំងឡាយគ្រាន់បាន ជាទុនសំរាប់ត្រិះរិះ និងពិចារណាឈ្វេងយល់ក្នុងបណ្តាំ **ព្រះម៉ែ**។

**១.ភ្នំប្រាសាទភ្នំបូក**(ខេត្តសៀមរាប)

ពាក្យនេះបើត្រឡប់មកវិញ គឺបូកភ្នំ ព្រះម៉ែគាត់ចង់ប្រាប់យើងថា បើកូនចង់ដឹងរឿងព្រះម៉ែ ហើយជួយ ស្រង់ព្រះម៉ែ កូនត្រូវយកភ្នំទាំងអស់ដែលមានក្នុងភូមិព្រះម៉ែ មកបូកបញ្ចូលគ្នា កូននឹងអាចរកឃើញចម្លើយមួយដោយសន្ទត់។ ព្រោះរយៈពេលនៃការកកើតទឹកដីព្រះម៉ែ (ប្រទេសព្រះម៉ែ) ជាងរាប់ពាន់ឆ្នាំនេះ រឿងរ៉ាវរបស់ព្រះម៉ែពូនគរដូចជាភ្នំ ដែលកូននាគប្រុសស្រីមិនអាច គណនានូវមហាគុណដ៏ធំធេងនេះបានឡើយ គឺមានតែព្រះអរហន្តសម្មាសម្ពុទ្ធទេ ទើបព្រះអង្គមាននូវព្រះបញ្ញាញាណអាចជ្រាបនូវគុណនេះបាន ដូច្នេះហើយទើបខ្មែរមានសុភាសិតមួយឃ្លាថា **គុណមាតាបិតាធំជាងភ្នំព្រះសុមេរុ** ហេតុអ្វីបានជាគាត់យកស្តេចភ្នំព្រះសុមេរុ មកប្រៀបធៀបយ៉ាងនេះ? ព្រោះគាត់ចង់ពន្យល់ប្រាប់កូននាគទាំងអស់ថា៖ ពាក្យ **សុមេរុ** ឬ**សុម៉ែ** គឺម៉ែល្អ ជាពាក្យសំរាប់កូនខ្មែររស់ក្នុងនគរនេះ ហៅស្ត្រីដែលជាអ្នកបង្កើតនូវបុត្រថា**ម៉ែ** ដែលខ្ញុំបានពន្យល់នៅក្នុងភាគ១រួចហើយ។ ហេតុអ្វីបានជាក្នុងទ្រឹស្តីអាចារ្យខ្លះថា គុណម៉ែមាន**១២**គុណឪពុកមាន**២១**?ក្នុងទ្រឹស្តីនេះបើយើងមិនបានយកគំនិតនេះមកត្រិះរិះពិចារណាទេ យើងច្បាស់ជារកប្រភពនៃគំនិតពុំឃើញឡើយ។ តាមការពិតលេខទាំងពីរនេះ គឺវាតែមួយទេ គ្រាន់តែបញ្ច្រាសគ្នាទៅវិញទៅមកតែប៉ុណ្ណោះ ពេលណាយើងដាក់លេខ**១**ពីខាងមុខ២ ទៅជា**១២** ពេលណា ដាក់លេខ **២** នៅខាងមុខ **១** ទៅជា **២១** លេខនេះគឺដូចគ្នា **១២**=**១**+**២**=**៣** → **២១**=**២**+**១**=**៣** (ព្យញ្ជនៈ៣៣តួ)។ ចំណែកឯចំនួន**១២**និង**២១**នេះ គឺតំណាងឲ្យធាតុទឹក **១២** និងធាតុដី

**២១** គឺជាធាតុសុទ្ធ ពុំមែនពណ៌នារៀបរាប់ពីគុណទៀយ ម៉ែមានធាតុទឹក**១២**ឪពុកមានធាតុដី**២១** ព្រោះម៉ែបានបង្ហូរនៅធាតុទឹកច្រើនជាងឪពុក ទើបម៉ែមានមនោសញ្ចេតនាទន់ជាងឪពុក។ បើរែកញែកឲ្យកាន់តែវែងឆ្ងាយទៅទៀត(គំនិតនេះបរទេសគេបំភាន់ ត្រឡប់ដើម្បីបំបែកកូននាគ) គំនិតនេះជាប្រស្នារបស់ព្រះម៉ែនាគដែលគាត់ទុកឲ្យយើងស្រាយ ពុំមែនសម្រាប់ចែកចំនួនគុណម៉ែឪ ឡើយ ព្រោះ **១២=១+២=៣ → ២១=២+១=៣** (ប្រស្នាព្យញ្ជនៈ **៣៣**តួ)។ ពេលណាកូននាគប្រុសស្រីព័ន្ធគ្នា នគរនឹងរុងរឿងឡើងវិញដូចសម័យគោកធ្លក ដូច្នេះហើយទើបដូនតាយើង គាត់បានកសាងប្រាសាទនាគព័ន្ធផុសនៅកណ្តាលទឹកនោះ (សូមមើលប្លង់រូប) ប្រៀបដូចនគរគោកធ្លកដែលអណ្តែតក្នុងមហា សាគរដ៏ធំធេងដោយអំណាចកម្លាំងសាមគ្គីព័ន្ធគ្នារបស់ កូននាគប្រុសស្រីជ្រោងប្រាសាទនោះឲ្យផុស ឡើងផុតពីទឹក ដូចរូបប្រាសាទនាគព័ន្ធនេះ។

ទឹក = អំណាចទឹកចិត្តបរទេសដែលគ្របពីលើខ្មែរ(មនោគមវិជ្ជា ពន្យល់រួចហើយក្នុងភាគមួយ)

នាគពីរ=កូននាគប្រុសស្រី(ខ្ញុំពន្យល់នៅមង្គលបីនិងសិរីបីរួចហើយ)

ប្រាសាទ=ភាពស្តុកស្តម្ភរុងរឿងពីអតីតកាល

នាគព័ន្ធ = កូននាគប្រុសស្រីសាមគ្គីវេញចូលគ្នាជាធ្លុងមួយ (រួមចិត្តតែមួយ)។

ដោយការរែកញែកនេះ ទើបយើងដឹងថាគេបានបំបែកម្តាយឪពុក បុរសស្ត្រីអោយបែកគ្នាដោយភាពមិនយុត្តិធម៌នេះ ដែលវាខុសពីទិដ្ឋិក្នុងព្រះពុទ្ធសាសនារបស់ព្រះសម្មាសម្ពុទទ្រង់ត្រាស់សម្តែងថា គុណមាតាបិតាគឺ **អនន្តគុណ** គុណដែលមិនអាចយកទំហំឬចំនួនណាមួយមកប្រៀបផ្ទឹមបានឡើយ។ ប៉ុន្តែចំពោះដូនតាខ្មែរ បានយកភ្នំព្រះសុមេរុមកប្រៀបផ្ទឹមនោះ ព្រោះតែគុណរបស់មាតាបិតាធំជាងភ្នំនោះទៅទៀត។ រីឯគុណរបស់មាតាបិតា ព្រះអង្គទ្រង់ត្រាស់សម្តែងថា ប្រសិនបើមាតាអត់សីល បិតាអត់សីល គុណគឺសេចក្តីល្អមាតាមានច្រើនជាងបិតាព្រោះហេតុអ្វី? ព្រះអង្គត្រាស់សម្តែងថា ទីមួយ ការមកនូវឈាមរដូវ បិតាធ្វើបានដោយកម្រ ទីពីរការពរផ្ទៃ


ប្រាសាទនាគព័ន្ធ រដូវមានទឹក

បុត្រ បិតាធ្វើបានដោយកម្ម ទីបីការប្រសូត្រនូវបុត្រ បិតាធ្វើបានដោយកម្ម ទីបួនការបំបៅដោះ លាងមូត្រលាមក ធ្វើបង្គន់ឲ្យកូនប្រុសស្រីនោះ គឺបិតាធ្វើបានដោយកម្ម តែបើបិតាមានសីលឬក៏មាននូវគុណធម៌ផ្សេងៗទៀត បិតាមានគុណធំជាង ឬធ្ងន់ជាងទៅតាមគុណធម៌របស់ឪពុកនោះ។ រួមសេចក្ដីមក គុណ មាតាក្ដី បិតាក្ដី គឺអនន្តគុណ គឺគុណដែលមិនអាចរាប់ចំនួនបាន ឬយកទំហំអ្វីទៅវាស់វែងសេចក្ដីល្អរបស់ពួកគាត់បានឡើយ នេះចំពោះតែមាតាបិតាដែលធ្វើព្រះព្រហ្មពិតប្រាកដឲ្យកូន តែប្រសិនបើពួកគាត់ពុំបានបំពេញកាតព្វកិច្ចឲ្យគ្រប់ក្នុង ព្រហ្មវិហារធម៌ទាំងបួននោះទេ គុណនោះក៏ចុះខ្សោយទៅតាមលំដាប់។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ម៉ែឪគ្រប់រូបសុទ្ធតែជាព្រះអរហន្តរបស់កូនប្រុសស្រីជា **ទក្ខិណេយ្យបុគ្គល** (បុគ្គលគួរគោរពថ្វាយបង្គំ) គឺជាបុគ្គលដែលត្រូវទទួលនូវការតបស្នង ពីកូនទាគប្រុសស្រី។ ដូច្នេះចង់ឲ្យនគរមានមហិទ្ធិឫទ្ធិរុងរឿងឡើងវិញ កូនខ្មែរប្រុសស្រីត្រូវតែ បូកភ្នំគឺពូនផ្ដុំកម្លាំងសាមគ្គីឲ្យក្លាយទៅជាភ្នំ ទើបអាចរុញច្រាននូវបាបអកុសលកម្មពីអតីតកាល ឲ្យរបើកឃ្លាតចេញពីអាទិទេពខ្មែរ(ព្រះម៉ែមហានាគ) រួមនិងកូននាគទាំងអស់គ្នាផង។

មិត្តអ្នកអានជាទីគោរពរាប់អានពេលនេះទើបយើងយល់ថា គេយកទ្រឹស្ដីបំភាន់មកបំបែកកូននាគប្រុសស្រី ឲ្យបែកគ្នាងាយស្រួលពួកគេគ្រប់គ្រង **បែកសាមគ្គីស្លាប់មានសាមគ្គីរស់** តើពេលណាហ្ន៎ទើបកូននាគប្រុសស្រីអាចព័ន្ធគ្នាឡើងវិញបាន?

### ២.ប្រាសាទភ្នំហាន់ជ័យ ឬ ភ្នំហាន់ជ័យ (ខេត្តកំពង់ចាម)

អត្ថន័យនៃពាក្យភ្នំ ឬប្រាសាទនេះ ខ្ញុំបានបកស្រាយពន្យល់ត្រួសៗរួចហើយ នៅក្នុងស្នាដៃភាគមួយ ប៉ុន្តែពេលនេះខ្ញុំគ្រាន់តែចង់បញ្ជាក់បន្ថែមថា ហេតុអ្វីបានជាពួកគាត់ ត្រូវហាន់រឿងរ៉ាវភ្នំឲ្យទៅជាចំណិតៗ? រហូតដល់ទៅបាត់ដាន បាត់ទី សូម្បីតែខ្ញុំអ្នកស្រាវជ្រាវក៏លំបាកផ្គុំ ដើររកទីដើម ឬប្រភពដើមរបស់ពួកគាត់មកផ្គុំ ឲ្យចេញជាសាច់រឿងហូរហែ ដើម្បីយកមកពន្យល់កូនខ្មែរ ដែលចង់ដឹងសាវតាពិតរបស់ខ្លួននោះ។ ព្រោះខ្ញុំបានពន្យល់ហើយនៅក្នុងភាគមួយ រឿងបិសាចពស់នៅក្នុងឯកសារជីវតាក្វាន់ និងរឿងគាត់ជាប់ឃុំឃាំងក្នុងគុក សមុទ្រទឹកដោះ តើអ្នកទោសមានសិទ្ធិអំណាចអ្វី ឬមួយមានសេរីភាពដូចជាអ្នកជានោះ គឺមិនដូចគ្នាទេ ដូច្នេះហើយទើបនគរខ្មែរចេះតែផ្លាស់ប្ដូរទីក្រុង ពី

តំបន់មួយទៅតំបន់មួយពុំចេះឈប់ឈរ។ កាលព្រះម៉ែនៅអាចបែងភាគលួចចេញពីគុកបានដោយឫទ្ធិ ព្រះម៉ែចេះតែមកពន្យល់ប្រាប់ពីគំនិត របស់គាត់ឲ្យកូននាគធំជាងគេគឺ**ស្តេច** ដែលជាអ្នកដឹកនាំប្រទេសទៅតាមគំនិតនិងឱវាទរបស់គាត់ (ពន្យល់រួចហើយក្នុងភាគមួយ) ហេតុអ្វីបានជាខ្ញុំថា ស្តេចអ្នកដឹកនាំប្រទេសជាកូននាគធំជាងគេ? ព្រោះស្តេចមួយភិក្ខុសង្ឃមួយ សុទ្ធតែជាអ្នកអាចជ្រកក្រោមដំបូលក្បឿងស្រកានាគ (ព្រះវាំង និងវត្តគេប្រក់ក្បឿងស្រកានាគ) បានទាំងយប់ទាំងថ្ងៃ ក្រៅពីភេទទាំងពីរនេះចេញ គឺពុំសូវមានឱកាសចូលជ្រកក្រោមម្លប់ស្រកាព្រះម៉ែបានទាំងយប់ថ្ងៃឡើយ លុះត្រាតែពេលមានបុណ្យទាន ទើបអាចចូលទៅជ្រកក្រោមម្លប់ដំបូលស្រកានាគ(ព្រះម៉ែ) បានម្តងម្កាល។ ម្យ៉ាងទៀតថ្នាក់ដឹកនាំប្រទេស(ស្តេច) គឺជាអ្នកថែរក្សា និងស្នងមរតកផ្ទាល់ពីព្រះម៉ែ (ដើរតួជាមេនាគ) ដើម្បីរក្សានៅមាតុភូមិនេះ។ សព្វថ្ងៃទីវត្តអារាម ដែលជាទីកន្លែងផ្ទុក និងថែរក្សានូវបណ្តាំមរតកសិល្បៈវប្បធម៌ព្រះម៉ែមួយចំនួនបាន ប្រែប្រួលអស់ទៅហើយ ព្រោះឈប់រក្សាមកុដម៉ែ ហើយនាំគ្នាផ្លាស់មកុដបរទេស យកមកជំនួសវិញ។ ***តើមកុដជាអ្វី?*** មកុដគឺជាក្បឿង ដែលគេប្រក់បិទបាំងនៅលើដំបូល(ក្បាល) ព្រោះពាក្យក្បឿងនេះ មានបង្កប់នូវអត្ថន័យប្រស្នាពេលយើងប្រក់ក្បឿង គឺយើងយកក្បឿងទៅពាក់ក្រាលលើដែរណែង។ ដូចនេះពាក្យ**ក្បឿងពាក់ក្រាល ត្រលប់ពាក្យមកវិញ គឺក្បាលពាក់គ្រឿង** តើត្រូវពាក់គ្រឿងអ្វី? គឺពាក់គ្រឿងរបស់ព្រះម៉ែ មកុដព្រះម៉ែ គឺក្បឿង**ស្រកានាគ** ឬក្បឿងក្បាច់ ប៉ុន្តែសព្វថ្ងៃវត្តនិងទីលំនៅភាគច្រើនៗប្រក់ក្បឿង ដែលនាំចូលពី**បរទេស**។ កូននាគប្រុសស្រីត្រូវពិចារណាមើលសព្វថ្ងៃនេះ **ព្រំប្រទល់ប្រទេសដើរនៅលើដី តទៅអនាគត ព្រំប្រទល់ត្រូវដើរនៅលើក្បាល។** ព្រោះហេតុអ្វី? ព្រោះក្បឿងដែលជាគ្រឿងប្រក់លំនៅឋានសព្វថ្ងៃ សុទ្ធតែមានផ្លាកសំគាល់ឈ្មោះបរទេសជិត ខាងចំណែកឯក្បឿងខ្មែរ ឈប់មានប្រក់បិទបាំងទៀតហើយៗក្បឿងខ្មែរចាស់ៗ ដែលមានត្រាខ្មែរសល់ពីសម័យដើម គេរុះរើយកមកវាយកំទេចចាក់សាបអស់ហើយ។ ដូច្នេះក្បាលខ្មែរ(ដំបូល) លែងមានពាក់មកុដខ្មែរទៀតហើយ នេះគ្រាន់តែជាចំណុចតូចមួយ នៅក្នុងបណ្តាំគំនិតដ៏ធំដូចជាភ្នំរបស់ព្រះម៉ែដែលខ្ញុំបានមើលឃើញ គួរយកមកត្រិះរិះគិតពិចារណា ព្រោះរំលងតែពីរបីជំនាន់ទៀតក្បឿងទាំងនោះនឹងអាចក្លាយទៅជាភស្តុតាងព្រំមួយរបស់បរទេស ដែលយើងលំបាកនឹងប្រកែក។ ខ្មែរឈប់ប្រក់ក្បឿងដែលមានផ្លាកសញ្ញាសំគាល់ ***អត្តសញ្ញាណជាតិ*** ទៀតហើយ បើកូននាគសម័យនេះមិនចាប់

*អារម្មណ៍ទេ គ្រោះថ្នាក់នឹងកើតមានចំពោះមនុស្សជំនាន់ក្រោយ (**ទូកនៅកំពង់នៅ**) ដែលយើងសព្វថ្ងៃបានយកអត្តសញ្ញាណបរទេសមកពាក់ខាងលើក្បាល ហើយគ្រឿងប្រក់ពីលើទាំងនេះ មិនងាយពុកផុយឡើយ វាមានអាយុកាលវែងជាងមនុស្ស។*

## *៣.ប្រាសាទភ្នំជីសូរ ឬភ្នំជីសូរ (ខេត្តតាកែវ)*

*អត្ថន័យដែលខ្ញុំបានលើកមកពន្យល់ គឺខ្ញុំពុំបានយកពីរឿងព្រេងដែលទាក់ទងនឹងភ្នំ មកបកស្រាយឡើយ គឺខ្ញុំយកតែឈ្មោះពិតរបស់ភ្នំនិងប្រាសាទមកធ្វើអត្ថាធិប្បាយតែម្ដង ដើម្បីឲ្យមិត្តអ្នកអានជួយពិចារណា នូវហេតុនិងផល ដែលកើតមានរឿងរ៉ាវជាគំនិតអច្ឆរិយៈ ដែលសព្វថ្ងៃនេះ គេបានប្រសិទ្ធិនាមថា (កម្ពុជារាជាណាចក្រអច្ឆរិយៈ)។ តើនគរនេះ មានអច្ឆរិយៈនៅត្រង់ណា? មិត្តអ្នកអានច្បាស់ជាជ្រាប រួចចាប់ផ្ដើមយល់នូវគំនិតអច្ឆរិយៈរបស់មាតុភូមិ តាមរយៈស្នាដៃបណ្ដាំព្រះម៉ែមហានគរ (ភាគ១) ដែលអ្នកបង្កើតភាពអច្ឆរិយៈទាំងអស់នេះ គឺសុទ្ធតែជាបណ្ដាំគំនិតបណ្ឌិតរបស់ព្រះម៉ែមហានគរ ដែលពីមុនយើងជាកូននាគប្រុសស្រី ពុំបានដឹងនិងយល់ឡើយ រួមទាំងខ្ញុំអ្នកស្រាវជ្រាវផង។ តែពេលនេះទើបយើងរកឃើញ អ្នកបង្កើតភាពអច្ឆរិយៈនេះគឺជាម៉ែដែលកូនខ្មែរភាគច្រើននាំគ្នាជេរគាត់រាល់ៗថ្ងៃ។ ហេតុអ្វីបានជាគេ ធ្វើប្រាសាទភ្នំជីសូរនៅលើកំពូលភ្នំដ៏ខ្ពស់ ហើយបែរជាអ្នកកសាង **ជីកភ្នំ** ក្លាយជារណ្ដៅដូចជាគុក ទើបគាត់ចាប់កសាងប្រាសាទ?*

## *ពន្យល់ពាក្យ (ភ្នំជីសូរ)* *(តាមវចនានុក្រម សម្ដេចព្រះសង្ឃរាជ ជួន ណាត)*

*ភ្នំ =ខ្ញុំបានពន្យល់ហើយ*

*ជី = អ្នកដែលបានបួសជាសាមណេរ ហើយសឹកមកវិញគេហៅថា **ជី** បុរសស្ត្រីដែលទៅសមាទានសីលក៏ហៅថា**ជី** (តាជី ដូនជីឬយាយជី)*

*សូរ = សូរ សព្ទ សំឡេង*

*សូរ = (បា.សំ) សូរៈ អង់អាច ក្លាហាន អាចហ៊ាន ដែលមានចិត្តមោះមុត ក្លៀវក្លា....*

*ភ្នំជីសូរ = គឺជីដែលមានសព្ទសំឡេង អង់អាចក្លាហានមោះមុត លើជីទាំងឡាយព្រោះជីសូរ គឺជាទីខ្ពស់លើសទីទាបទាំងពួង គឺកំពូលលើជីទាំងអស់។ ដូចស្ពានបុរាណមួយ ដែលស្ថិតនៅខេត្តសៀមរាប*

មានឈ្មោះថាស្ពានកំពុងក្តី ហើយស្ពាននោះគាត់សាងពីលើដងស្ទឹងមួយ គឺស្ទឹង **ជីក្រែង**។ តើជីក្រែង មានន័យដូចម្តេច? ហើយស្ពានកំពុងក្តីមានន័យដូចម្តេច?

ជីក្រែង = ជីគាត់ខ្លាចញញើត ធ្វើមិនបានឬជួយព្រះម៉ែមិនបាន ព្រោះនាគក្បាល១៤ នៅខាងលើស្ពានកំពុងកើតក្តីក្តាំគ្នា (កំពុងក្តី) ចំណែកឯជីឡើងមកស្រាយ និងទប់ក្តីគាត់ៗខ្លាចក្រែង ដោះក្តីព្រះម៉ែនៅខាងលើមិនរួច ទើបដូនតាយើងសាងស្ពានកំពុងក្តីនេះនៅលើស្ទឹងជីក្រែង ទុកឲ្យជីជាអ្នកស្រាយក្តីនោះពិចារណា។ ខ្លួនឯងជាពូជទាប នៅក្នុងទឹកខាងក្រោមស្ពាន រឿងអ្វីហ៊ានមកតតាំងក្តីនៅខាងលើ ដោយមិនខ្លាចក្រែងនោះ? នាគនៅស្ពានកំពុងក្តី និងនាគនៅលានព្រះគំលង់ គឺដូចគ្នាប៉ុន្តែខុសគ្នាត្រង់ នាគនៅកំពុងក្តី ក្បាលប្រាំបួននៅពីលើប្រាំ ហើយមានស្ត្រីម្នាក់ឈរទ្រពីខាងក្រោមនាគ សព្វថ្ងៃត្រូវគេដាប់រូបស្ត្រីខាងក្រោមនាគបាត់ហើយ យើងមើលស្ទើរតែពុំយល់ ព្រោះពួកគេចង់លុបបំបាត់ដាន ហើយស្ត្រីនោះគឺតំណាងឲ្យព្រះម៉ែនាគ។ ចំណែកឯនាគនៅលានព្រះគំលង់វិញ គឺក្បាល៥នៅពីលើក្បាល៩និង៧ បញ្ច្រាស់គ្នាជាមួយនឹងនាគនៅកំពុងក្តី (អាថ៌កំបាំងប្រស្នាបញ្ច្រាស់គ្នានេះ ខ្ញុំនឹងពន្យល់នៅភាគ៣)។ យើងត្រឡប់មកតាមដានអាថ៌កំបាំងភ្នំជីសូរវិញ បានជាដូនតាយើងគាត់ជីកភ្នំរួចកសាងប្រាសាទ ព្រោះគាត់ចង់ប្រាប់ថាជីសូរ ដែលកំពូលលើ **ជី** ទាំងឡាយ ត្រូវទៅជួយព្រះម៉ែកំពុងជាប់គុកនោះ ខ្លួនគាត់ក៏ជាប់គុកដូចព្រះម៉ែដែរគ្រាន់តែតិចជាង គឺ**យកថ្លុកទៅលុបត្រពាំង** ពេលណាទើបលុបជិតហ្នឹ។ ចំណែកឯរឿងដែលគេឆ្លាក់នៅលើថ្ពែរ និងប្រាសាទដែលគេធ្វើបិទឃុំយោនីព្រះម៉ែ ខ្ញុំពុំបានពន្យល់ឡើយទុកឲ្យមិត្តអ្នកអានទៅទស្សនាប្រាសាទ និងពិចារណាតាមសាច់រឿងរបស់ព្រះម៉ែដែលខ្ញុំបានពន្យល់ជាហូរហែនោះចុះ នឹងបានដឹងដោយពិស្តារខ្លួនឯង។



**នាគក្បាល៩ លើក្បាល៥**
**(ស្ពានកំពង់ក្តី)**

## ៤.ប្រាសាទភ្នំបាយ៉ង់កោរ (ខេត្តតាកែវ)

ពាក្យ (បយ័ង្គ ឬបល្ល័ង្ក) ខ្ញុំបានពន្យល់ក្នុងភាគ១រួចខ្លះហើយ ដែលខ្ញុំលើកយកមកសរសេរនេះ ដើម្បីបញ្ចូលទៅក្នុងរឿងភ្នំ ដែលទាក់ទងនឹងកេរតំណែលព្រះម៉ែ ចង់ដឹងរឿងព្រះម៉ែ រួចជួយគាត់បាន ទាល់តែបូកភ្នំឬផ្គុំភ្នំ។ រឿងរ៉ាវទាក់ទងនឹងភ្នំនេះ ស្ដេចជ័យវរ្ម័នទី**៧**គាត់បានឆ្លាក់ រូបរឿងទុកនៅក្នុងប្រាសាទ **តាព្រហ្ម** ដែលប្រាសាទនោះគាត់ ធ្វើឧទ្ទិសឲ្យព្រះម៉ែ។ គាត់បានឆ្លាក់សាច់រឿង**របស់ស្ត្រីម្នាក់ ឈរលើផ្កាឈូក កំពុងតែដុះឡើងទៅ ស្ត្រី**នោះ យកទៅដាក់លើបល្ល័ង្កទទេខាងលើ វិញ ដែលបល្ល័ង្កនេះ គាត់ធ្លាប់អង្គុយពីអតីត ដោយកម្មអកុសលធ្វើឲ្យគាត់ធ្លាក់ចុះទៅក្រោម។ ហើយនៅក្នុងរូបនេះដដែល គាត់ឆ្លាក់សកម្មភាពសត្រូវ មកពីគ្រប់ទិសទី ដែលក្នុងដៃមានកាន់ដាវ លំពែង បុកចាក់ទៅលើគាត់ ព្រោះពួកគេមិនចង់ឲ្យស្ត្រីនេះ មកអង្គុយលើបល្ល័ង្ករបស់ខ្លួនវិញឡើយ។ ធម្មតាពៀររមែងរម្ងាប់ដោយការមិនចងពៀរ



រូបព្រះម៉ែ នៅប្រាសាទតាព្រហ្ម
(អាថ៌កំបាំងបាយ៉ង់កោរ)

ហើយពៀរនេះបើអ្នកមិនស្រាយទេ ទោះបីជារលាយអស់ទៅនៃផែនដីក៏ពៀរវេរារបស់ពួកអ្នកមិនរម្ងាប់ដែរ (នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ សម្ដែងប្រោសយក្ខិនី និងនាងកុលធីតា) អត្ថន័យរូបចម្លាក់រឿងខាងលើនេះ ទាក់ទងនឹងរឿងភ្នំបាយ៉ង់កោរ។ ហើយនៅលើភ្នំនេះមានប្រាសាទ បាយ៉ង់កោរ ដុបវិញ្ញាណ ព្រះបាទដៃខ្លី (ជាកូន) ព្រះនាងសក់ក្រអូប ព្រះគោ ព្រះកែវ ហើយមានឈ្មោះភ្នំបាយ៉ង់កោរ សក់ក្រអូប ដុកស្វាគយ ព្រះបក សំពៅលូន វិហារចិន ភ្នំតូចនិងមានទំនប់បុរាណមួយហៅថា**ទំនប់អរូបន្ទាយ**ហើយឈ្មោះទាំងនេះខ្ញុំបានដកស្រង់ចេញពីទស្សនាវដ្ដីមួយ ។

## ៥.ប្រាសាទភ្នំតាម៉ៅ(ខេត្តតាកែវ)

ប្រាសាទភ្នំនេះមានភាពបាក់បែកទ្រុឌទ្រោមយ៉ាងខ្លាំង ហើយប្រាសាទនេះមានទ្វារចូលតែមួយទេ នៅខាងលើទ្វារមានចម្លាក់ផ្ដែរមួយផ្ទាំង សព្វថ្ងៃបានជ្រុះធ្លាក់មកលើដីនៅមុខប្រាសាទ។ រូបក្នុង

ចម្លាក់ផ្ដែរនោះ ត្រូវពួកទុច្ចរិតដាប់បំផ្លាញអស់ហើយ តែបើមើលតាមដានស្នាមរូប គឺរឿងកូរសមុទ្រទឹកដោះ។ នៅក្នុងប្រាសាទនោះមានថ្មធម្មជាតិមួយដុំធំ ថ្មនេះបើមើលពីខាងមុខទ្វារ មិនអាចស្គាល់រូបរាងបានឡើយ ទាល់តែដើរទៅឈរមើលពីខាងក្រោយប្រាសាទ ដែលបាក់បែកមួយចំហៀងខាងក្រោយ ទើបអាចមើលយល់ពីថ្មធម្មជាតិនោះ។ ដូនតាខ្មែរគាត់បានយកបណ្ដាំគំនិត ទៅបង្កប់ទុកក្នុងថ្ម ព្រោះថ្មនោះជារាងក្បាលនាគបើកពារពារកប់ត្រឹមក ហើយត្រូវគេធ្វើប្រាសាទគ្រប ឬក្រុងពីលើ (បក្សីចាំក្រុង)។ បើនិមិត្តរូបក្បាលគាត់ធំម្លឹងៗ តើឲ្យគាត់ចេញមកម្ដេចរួច? ព្រោះមាត់ទ្វារប្រាសាទតូចជាងក្បាលនាគ ដែលជាថ្មធម្មជាតិនោះ នេះជាប្រស្នាអាថ៌កំបាំងទាក់ទងនឹងព្រះម៉ែនាគ ដែលបានប្រតិស្ឋានទុកក្នុងប្រាសាទភ្នំតាម៉ៅនេះ មាននៅសល់ដានស្នាមទុកដល់សព្វថ្ងៃ ដែលយើងជាកូនខ្មែរ ត្រូវពិចារណាបំបែកបណ្ដាំគំនិតរបស់ពួកគាត់ ហើយគាត់អាចចេញមកក្រៅរួច ទាល់តែមានអភូតហេតុធម្មជាតិ រយះដី ឬរញ្ជួយដី..... ទើបអាចចេញពីទីឃុំរួច។

៦. **ភ្នំរទង់** (សព្វថ្ងៃហៅថាភ្នំទទង់) (ន័យពិតពីដើម គឺដើររកទង់) (ខេត្តកំពត)

ហេតុអ្វីបានជាគាត់ដាក់ឈ្មោះភ្នំថា**រកទង់** ព្រោះនៅតំបន់នោះ មានឈ្មោះថា**ដងទង់** (សព្វថ្ងៃឈ្មោះថាស្រុកដងទង់) បើយើងពិចារណាស្វែងរកពាក្យពិតនៅទីនោះ គឺទង់ព្រះម៉ែបានបាត់ទៅហើយ នៅសល់តែដងទង់ប៉ុណ្ណោះ។ ព្រោះភាពរុងរឿងរបស់ព្រះម៉ែពីអតីត បានធ្លាក់ចុះនិងលិចកប់បាត់ទៅក្នុងសមុទ្រទឹកដោះទៅហើយ សព្វថ្ងៃនេះមិនទាន់រកឃើញទង់ព្រះម៉ែនៅឡើយ ដើម្បីយកមកចងបង្ហូតឡើងវិញ ព្រោះហេតុតែយើងមិនដឹង ទើបនាំគ្នាបង្ហូតទង់ក្រពើ (នៅក្នុងភាគ១) តើកេរតំណែលទង់ក្រពើ និងទំនួញប្រេតខែភ្ជុំបិណ្ឌ កើតឡើងពីសម័យណាមក? តាមការស្រាវជ្រាវប្រវត្តិទង់ក្រពើ និងទំនួញប្រេតខែភ្ជុំបិណ្ឌ ដែលទាក់ទងនឹងរឿងប្រេតជាញាតិ យើងអាចយល់បានថា គឺកើតឡើងក្នុងរជ្ជកាលសម្ដេចព្រះបាទអង្គឌួង។ ព្រោះស្ដេចអង្គនេះ គាត់បានសិក្សាវិជ្ជាផ្នែកសមាធិ និងវិបស្សនាកម្មដ្ឋានបានជ្រៅជ្រះ ទៅតាមក្បួនច្បាប់ព្រះពុទ្ធសាសនា។ ធម្មតាអ្នកសិក្សាសមាធិកម្មដ្ឋាន រមែងបាននូវឈានសមាបត្តិ ឬអភិញ្ញាដែលជាគុណធម៌របស់សមាធិ អាចធ្វើឲ្យបុគ្គលនោះដឹងរឿងរ៉ាវពីអតីត បច្ចុប្បន្ន និងតអនាគតរបស់ព្រះម៉ែនាគបាន(រឭកជាតិ)។ គាត់បានមកកសាងទីក្រុងនៅជិតភ្នំ ដែល

*សន្ធប់ព្រះម៉ែ (ភ្នំអង្គារស) ហើយគាត់បានជួបព្រះម៉ែតាមរយៈឈានសមាបត្តិ ហេតុនេះហើយ បានជាគាត់ទុកនៅបណ្តាំប្រស្នាព្រះម៉ែជាច្រើនដូចជា ទង់ក្រពើ ពិធីបុណ្យអុំទូក អកអំបុក សំពះព្រះខែ បណ្តែតប្រទីប បុណ្យភ្ជុំបិណ្ឌ...។ល។ ទុកឲ្យកូននាគសម័យក្រោយឆ្ងល់ និងធ្វើការស្រាវជ្រាវពីអាថិកំបាំងក្នុងបេះដូងព្រះម៉ែ ពេលដែលបាបកម្មព្រះម៉ែអស់ តើកូននាគមានឆ្ងល់ឬទេ? ហេតុអ្វីបានជាយើងជាអ្នកគោរពព្រះពុទ្ធសាសនា ហើយបែរជាឧទ្ទិសបុណ្យឲ្យប្រេតជាញាតិបានតែ ១៥ថ្ងៃ ពីថ្ងៃ១រោជខែភទ្របទ ដល់ថ្ងៃ១៥រោជខែភទ្របទ? កាលពីសម័យពុទ្ធកាល ពុទ្ធបរិស័ទ គេឧទ្ទិសបុណ្យឲ្យញាតិជាប្រេត១២ខែ គឺស្មើនឹង៣៦៥ថ្ងៃឯណោះ ហើយដែលរឿងប្រេតនេះ ទាក់ទង និងញាតិរបស់ព្រះបាទពិម្ពាសារាជ មាននៅក្នុងគម្ពីរព្រះពុទ្ធសាសនា(តិរោកុឌ្ឍសូត្រ)។ នេះហើយដែលជាប្រស្នាដែលស្តេចអង្គឌួង លោកទុកឲ្យកូនខ្មែរសម័យក្រោយ ស្រាយបំបែកចំណាងប្រស្នាកំបាំងនេះ។ ខ្ញុំបានពន្យល់នៅក្នុងទំព័រមុន ពីអាថិកំបាំងមាតាទាំង១២រួចហើយកែវភ្នែកម្តាយទាំង១២ ត្រូវគេខ្វេះយកអស់ដប់មួយគូកន្លះ នៅសល់តែភ្នែកមួយចំហៀងប៉ុណ្ណោះ។ នៅក្នុងសាច់រឿង បានបញ្ជាក់ប្រាប់ថា មិនត្រឹមតែត្រូវគេឆ្កៀលយកកែវភ្នែកទេ(បញ្ញា) គឺពួកគាត់ថែមទាំងបាននាំគ្នាហែកកូន ដែលកើតចេញពីផ្ទៃ ចែកគ្នាបរិភោគដោយគ្មានក្តីមេត្តាករុណាថែមទៀតផងនៅក្នុងគុក។ មានតែមាតាពៅម្នាក់តែប៉ុណ្ណោះ ដែលនៅសល់កែវភ្នែកមួយចំហៀង ហើយភ្នែកម្ខាងនេះបានមើលឃើញនៅបុត្រ ដែលកើតចេញពីផ្ទៃរបស់ខ្លួន ទើបគាត់ពុំបានសម្លាប់កូនបរិភោគ។ តើកែវភ្នែកមួយចំហៀងនេះ តំណាងឲ្យអ្វី? គឺតំណាងឲ្យភ្នែកកូនខ្មែរដែលភ្លឺបានតែ១៥ថ្ងៃ នៅរដូវភ្ជុំបិណ្ឌនោះឯង ហើយ១៥ថ្ងៃនេះទៀតសោត គឺពុំបានភ្លឺគ្រប់ទាំងអស់ឡើយ វាត្រូវមានកើតរោគក្នុងកែវភ្នែក ដែលធ្វើឲ្យការភ្លឺកាន់តែថយចុះ។ ម្យ៉ាងទៀតការធ្វើបុណ្យនេះកូនខ្មែរមួយចំនួនធ្វើពុំត្រឹមត្រូវតាមខ្នាតក្នុងព្រះវិន័យព្រះពុទ្ធសាសនាឡើយ ដោយកូននាគភាគច្រើននាំគ្នាយកបាយបិណ្ឌ ទៅគប់ទៅបោះឲ្យប្រឡាក់ស្មោកគ្រោកពេញទីសេនាសនសង្ឃរួចហើយភិក្ខុសង្ឃជាអ្នកបោសច្រាស។ តើពួកគេនាំគ្នាទៅបោះបាយបិណ្ឌឲ្យប្រេត ឬក៏សន្សំពូជប្រេតខ្លួនឯង? ម្យ៉ាងទៀតសព្វថ្ងៃយើងពុំសូវមាន ព្រះអរិយបុគ្គលដែលមានគុណធម៌ថ្នាក់ខ្ពស់ៗ ឬអ្នកមាននូវសីលបរិសុទ្ធដែលជាពូជនាគទៀតផង ដូច្នេះការឧទ្ទិសបុណ្យជូនទៅពួកប្រេតជាញាតិ គឺលំបាកនឹងទៅដល់ណាស់។ តើក្រពើដែលគេចាប់យកមកធ្វើទង់សល់កេរមកដល់សព្វថ្ងៃនេះគេចាប់នៅទីណា?*

*ក្រពើនេះ បានលេបព្រះនាងក្រពុំឈូក ឬឈូកក្រពុំ គេទៅចាប់បាននៅខេត្តក្រចេះរួចទើបគេភ្លះយកស្បែក មកធ្វើទង់របហូតទល់នឹងសព្វថ្ងៃនេះ(ក្នុងរឿងព្រេង) គេហៅក្លាយថាទង់ព្រលឹង ទង់រលក ឬទង់ឆ្លាមករ។ ព្រះចេតិយរបស់ព្រះម៉ែក្រពុំឈូក ឬឈូកក្រពុំដែលក្រពើលេបនោះ សព្វថ្ងៃនៅក្នុងទីតាំងព្រះវិហារសសរមួយរយ ក្នុងភូមិ**សំបុក** ស្រុក**សំបូរ** ខេត្ត**ក្រចេះ** ហើយពេលណា ទើបផ្កាឈូករអាចរីក រួចបើគាត់នៅក្នុងទី**សំបុកសំបូរ មិនខាយចេះ**យ៉ាងនេះ (**ក្រ + ចេះ**) តើពេលណាកូននាគ អាចធ្វើដឹងឡើងវិញ? តើពេលណាទើបអាចរកទង់ព្រះម៉ែឃើញ? បើទន្លេ**មេ**បាត់ទីបាត់ដានអស់ទៅហើយៗត្រូវគេបិទទន្លេមេថែមទៀត(ទន្លេបិទ)។*

**៧.ភ្នំក្រពើ** (ខេត្តបាត់ដំបង)

*ភ្នំក្រពើនេះនៅក្នុងខេត្តបាត់ដំបង មិត្តអ្នកអានដឹងទេដែលយើងនាំគ្នាធ្វើពើមិនដឹងពីម្នាក់ទៅម្នាក់ ពីមួយជំនាន់ទៅមួយជំនាន់ការមិនដឹងគុណនេះបានពូនទៅជាភ្នំ ដែលមានសល់កេរតំណែលមកដល់សព្វថ្ងៃ ស្ទើរតែគ្រប់ទីកន្លែងនៅពាក្យក្រពើនេះ ពុំមែនមានតែក្នុងខេត្តបាត់ដំបងមួយឡើយ។ មិនត្រឹមតែប៉ុណ្ណឹងទេ ដូនតាគាត់បានប្រាប់ទៀតថា ត្បូងកែវឬដួងកែវរបស់វានៅទល់មេឃងណោះ (ផ្កាយក្រពើ) សព្វថ្ងៃនៅក្នុងខេត្តកំពង់ធំ មានភូមិមួយឈ្មោះថា (ភូមិកាល់មេឃ ឃុំត្បូងក្រពើ ស្រុកសន្ទុក)។ ហើយផ្កាយក្រពើនេះរះនៅតែទិសខាងជើង ព្រោះទិសនេះប្រែមកថាខាងក្រោម (ជើងផ្ទុយពីក្បាល ក្បាល = ត្បូង) នេះជាប្រស្នាគំនិតបង្កប់នៅក្នុងទិស នៅក្នុងពាក្យដែលគាត់ប្រើសម្គាល់ដើម្បីទុកឲ្យយើងវែកញែក រកឲ្យឃើញនូវចម្លើយពិតរបស់ឈ្មោះភ្នំ ក្រពើ ផ្កាយក្រពើ និងទង់ក្រពើ.... ប្រសិនបើយើងពុំឆ្ងល់ ហើយពិចារណាត្រិះរិះទេយើងនៅតែមិនដឹងរឿងពិតក្នុងបណ្ដាំរបស់ព្រះម៉ែដដែល។ សូមឲ្យការមិនដឹងគុណដែលបានក្លាយជាទង់ ផ្កាយ ភ្នំនេះ រលាយបន្តិចម្ដងៗចេញពីក្នុងសន្ដានចិត្តកូននាគ ដោយបុណ្យរបស់កូនខ្មែរបានយល់ដឹងពីបណ្ដាំពិតរបស់ព្រះម៉ែមហានគរ។*

**៨.ប្រាសាទភ្នំបាណន់**(ភ្នំបាទៅបន់)(ខេត្តបាត់ដំបង)

*ឈ្មោះប្រាសាទបាណន់ ឬបាទៅបន់ តើគេទៅបន់ស្រន់ឲ្យអ្នកណា? បាណន់ ➜ បន់ណា គឺកូនប្រុសដែលជាជីសូរនោះ គាត់ទៅបន់ស្រន់បួងសួង ឧទ្ទិសដ្ឋាននូវបុណ្យជូន**ព្រះម៉ែនាគ** ដែលគំនរនៃ*

*ពាក្យ បន់ បួងសួង ទាំងអស់នេះបានគរពូនទៅជាភ្នំ ហេតុតែចង់ឲ្យព្រះម៉ែបានត្រេកអរអនុមោទនានូវបុណ្យ ឆាប់បានរួចចាកពីទីទុក្ខ។ ដូច្នេះអត្ថន័យពិតនៃឈ្មោះប្រាសាទភ្នំនេះ គឺដូចការដែលខ្ញុំបាទបានរៀបរាប់ពន្យល់ត្រួសៗនៅខាងលើ  ហើយប្រាសាទនេះខ្ញុំពុំទាន់បានទៅទស្សនានិងសិក្សាស្វែងយល់ពីរូបចម្លាក់នៅលើប្រាសាទនោះឡើយ។*

***៩.ភ្នំសំពៅ*** *(ខេត្តបាត់ដំបង)*

*សំពៅ គឺជាជលយាន្ត ដែល**ព្រះម៉ែនាគ**បានយកមកធ្វើជាមធ្យោបាយ ដើម្បីពង្រីកទឹកដីកាលសម័យគាត់នៅជាព្រះនាងនាគ (មេ ឬក្មេរ) ហើយឈ្មោះជលយាន្ត(សំពៅ) ទាំងអស់នេះបានគរបន្តៗគ្នាមកសម័យខាងក្រោយ រហូតគរបានក្លាយទៅជាភ្នំ។ ម្យ៉ាងទៀតក្នុងរឿងព្រះនាងសក់ក្រអូប ពេលដែលសត្រូវចាប់គាត់បាន ក៏ទាក់ទងនឹងសំពៅនេះដែរដែលសព្វថ្ងៃមាននៅសល់បទភ្លេងប្រពៃណីក្នុងពិធីមង្គលការ គឺបទ(ស្រាវយុថ្កា សំពៅថយ បើកក្តោង...)។ល។ រឿងព្រេងព្រះនាងរំសាយសក់ ក៏មានទាក់ទងនឹងភ្នំសំពៅដែរ ដែលរូបគាត់សព្វថ្ងៃគេឆ្លាក់ឈរនៅលើក្រពើ ហើយច្បូតសក់មានឈ្មោះថា (នាងគង្ហីងព្រះធរណី) គឺតំណាងឲ្យព្រះមេឬព្រះម៉ែនោះឯង (ពន្យល់រួចហើយនៅក្នុងអាថ៌កំបាំងបាយ)។ ហេតុនេះហើយ ទើបរឿងព្រះម៉ែ ដែលពូនគរជាភ្នំទាក់ទងគ្នាពីមួយទៅមួយពីឈ្មោះរបស់ភ្នំទៅរឿងព្រេងប្រចាំភ្នំ និងរឿងប្រាសាទដែលកសាងនៅលើភ្នំ..... ដែលតភ្ជាប់គ្នារហូតទៅដល់លើមេឃឯណោះ (ផ្កាយ ក្រពើ សេះ កូនមាន់ យាម...) នេះជាការបកស្រាយដោយសង្ខេប។*

***១០.ភ្នំស្រង់*** *(ខេត្តកំពង់ស្ពឺ)*

***ពន្យល់ពាក្យ*** *(ភ្នំស្រង់ និងកំពង់ស្ពឺ)*

*ស្ពឺ = ផ្លែស្ពឺ*

*ស្ពឺ = ស្ពឺចក្រ កាំរបស់ចក្រ មីញ៉ុង ឬលីប*

*កំពង់ស្ពឺ = កំពង់មានដើមស្ពឺ*

កំពុងស្ពឺ = កំពុងវិល

ភ្នំ = (ពន្យល់រួចហើយ)

ស្រង់ = លើកឡើង ជ្រោងឡើង សណ្ដូនឡើង

ភ្នំស្រង់ ➜ ស្រង់ភ្នំ តើន័យពិតរបស់ពាក្យពិតកំពង់ស្ពឺនិងកំពុងស្ពឺ ន័យពិតនៅក្នុងពាក្យមួយណា? សូមមិត្តអ្នកអានស្វែងយល់ដោយខ្លួនឯងទៅតាមបញ្ញាត្រិះរិះ ឈ្វេងយល់នូវការពិត។

បើភ្នំធំម្លឹងៗតើត្រូវយកអ្វីទៅស្រង់? គុណធម៌របស់មាតានិងបិតា បានសន្សំពូនគរហូតមានទំហំធំជាងស្ដេចភ្នំព្រះសុមេរុទៅទៀត បើគុណរបស់គាត់ធំហើយធ្ងន់ម្លឹងៗ តើកូនតាគប្រុសស្រីទៅរែកទៅស្រង់ម្ដេចរួច? ហើយរែកភ្នំនេះ តើត្រូវយកដងរែកអ្វីទៅរែក? គឺមានតែដងរែកភ្នំទើបរែកឬស្រង់ភ្នំរួច (ភ្នំដងរែក)។ នៅក្នុងខេត្តកំពង់ស្ពឺនេះដដែលមានស្រុកមួយមានឈ្មោះថា ស្រុកគងពិសី (គងពិសី =


ចម្លាក់ស្នែផ្ដុំនៅក្បាលស្ពាន សៀមរាប

គងលើស្ត្រី) ពេលយើងពិចារណា អត្ថន័យក្នុងពាក្យនេះយើងនឹងនឹកឃើញដល់រូប ព្រះវិស្ណុដេក ឬផ្ទុំលើសត្វនាគលើសត្វគុជសី (ប្រាសាទខ្លះ) គងលើស្ត្រីដែលជាព្រះម៉ែ(គងពិសី) កំពុងដឹក(កំពុងវិល) គាត់ចេញពីក្នុង សមុទ្រទឹកដោះ។ ក៏ប៉ុន្តែ អ្នកដឹកម៉ែចេញដេក វារលូនយ៉ាងនេះ ពេលណាទើបអាចនាំព្រះម៉ែឡើងមកខាងលើរួច? កំពុងវិល(ស្ពឺ)ទៅមុខដឹករឿងសាវតាព្រះម៉ែចេញ។

**១១.ភ្នំស្រួច** (ខេត្តកំពង់ស្ពឺ)

ភ្នំស្រួច គឺភ្នំដែលខ្ពស់ហើយស្រួច អត្ថន័យពាក្យភ្នំនេះសំដៅទៅលើកូននាគណាដែលមានបញ្ញាស្រួចស្រាវដូចជាភ្នំ គឺមោះមុត អង់អាច ហានក្លា ដែលជាកំពូលលើដីទាំងឡាយ ហ៊ានរែកហ៊ានស្រង់ភ្នំម៉ែភ្នំឪ យកទៅដាក់លើកំពូលព្រះវិហាររបស់គាត់វិញ គឺកំពូលភ្នំស្រួច(កំពូលនៃអរិយធម៌អង្គរ) ន័យម្យ៉ាងទៀត ព្រះម៉ែមហានគរពីអតីតលោកគង់នៅទីស្រួច គឺលើគេ ដូចនេះមិនងាយស្រង់គាត់ទៅ

ដាក់លើបល្ល័ង្កដ៏ខ្ពស់នោះបានដោយងាយស្រួលឡើយ ត្រូវតែប្រើពេលវេលាព្យាយាមដ៏យូរ ទើបអាចសំរេចកិច្ចការដ៏ធំនេះបាន។

**១២.ភ្នំដងរែក** (ខេត្តព្រះវិហារ)

ហេតុអ្វីបានជាដូនតាយើងដាក់ឈ្មោះភ្នំនេះ ថា**ភ្នំដងរែក**? ខ្ញុំបានពន្យល់បកស្រាយរៀបរាប់អាថ៌កំបាំងភ្នំតាំងពីទំព័រដើមរហូតមកទល់នឹងពេលនេះ គឺមានចំនួនច្រើនហើយ។ គុណរបស់ព្រះមាតាបិតាទោះបីស្ដេចភ្នំព្រះសុមេរុដែលទ្រឋានតាវតឹង្ស ក៏ពុំស្មើនឹងគុណរបស់ពួកគាត់ដែរ ប៉ុន្តែហេតុអ្វីបានជាគុណដ៏ធំនេះ បែរជាលិចចុះទៅវិញ? ហេតុតែសេចក្ដីលោភលន់និងប្រកាន់មាំក្នុងឧបាទានក្ខន្ធថា ជាសត្វជាបុគ្គល ជាស្ដេច ជានាម៉ឺនមន្ត្រី ជាឧបាសកឧបាសិកា ជាគ្រហស្ថ ជាបព្វជិត.... ការលោភលន់និងប្រកាន់មាំនេះហើយ តែងធ្វើឲ្យសត្វទាំងនោះជាប់ឃុំក្នុងវដ្តសង្សារ រកទីបំផុតនៃការបញ្ចប់ទុក្ខពុំឃើញគឺនៅវិលវល់ ម្ដងកើត ម្ដងស្លាប់ ម្ដងខ្ពស់ ម្ដងទាប ម្ដងសុគតិ ម្ដងអបាយភូមិ...។ល។ ព្រះធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែង ស្ដាប់ទៅគួរឲ្យសង្វេគណាស់ តើងាយអ្វីនឹងធ្វើឲ្យសត្វដែលក្រាស់ទៅដោយអវិជ្ជានិងតណ្ហាអាចឆ្លងនូវសមុទ្រទុក្ខនេះបាន? យ៉ាងណាមិញ ព្រះមាតាបិតាមហានគរ ពីអតីតកាលក៏ដូច្នោះដែរ ដោយមានការលោភលន់និងប្រកាន់មាំ ព្រោះចង់ឲ្យកូនខ្មែរសម័យខាងក្រោយ សោយសុខក្នុងកេរមរតករបស់ខ្លួន ទើបធ្វើឲ្យពួកគាត់ជាប់ឃុំក្នុងទីទុក្ខ។ គុណរបស់គាត់ធំដូចជាភ្នំ ទុក្ខវេទនារបស់ពួកគាត់ក៏ធំដូចជាភ្នំដែរ ដូច្នេះចង់រែកចង់ស្រង់ភ្នំព្រះមាតាបិតានេះត្រូវយកដងរែកភ្នំទៅរែកទើបរែករួច។ តើអ្នករែកជានរណា? អ្នករែកក៏មានគុណធម៌ស្មើនឹងភ្នំដែរ ទើបអាចលើកដងរែកភ្នំទៅរែកពួកគាត់រួច គឺកូននាគនោះគាត់ឲ្យនាមជាភ្នំជីសូរ ភ្នំបាណន់ បាភ្នំ ភ្នំបាយ៉ង់ កោរ ភ្នំបាខែង បាពួន បាគង...។ល។ កូននាគនេះបានបំពេញនូវគុណធម៌ គឺកតញ្ញូកតវេទី ដូចជាពោធិសត្វ សុវណ្ណសាមដែរ ហើយគាត់ត្រូវស្រង់រែកព្រះមាតាបិតាដើម្បីយកពួកគាត់ទៅដាក់ក្នុងកំពូលព្រះវិហារវិញ (ប្រាសាទព្រះវិហារ) នេះជាអត្ថន័យនៃពាក្យភ្នំដងរែក។ ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើងព្រះអង្គសន្សំនូវបារមីអស់កាល បួនអសង្ខេយ្យមួយសែនផែនដី ទើបអាចរែកព្រះមាតាបិតាទៅកាន់ទីរំលត់ទុក្ខបាន(ព្រះនិព្វាន្ត) ចុះកូននាគប្រុសស្រី ដែលជាអ្នកទទួលបណ្ដាំនិងមរតកព្រះមាតាបិតាវិញ អ្នកមានសន្សំបុណ្យកុសល ដើម្បីឧទ្ទិសមហាកុសលនេះជូនចំពោះពួកគាត់ដែលជាម្ចាស់នគរដែរឬទេ?

**១៣.ប្រាសាទព្រះវិហារ** (ខេត្តព្រះវិហារ)

ដូនតាយើងគាត់បានកសាងប្រាសាទព្រះវិហារក្នុងជួរភ្នំដងរែកព្រោះកូននាគត្រូវរែកព្រះម៉ែ និងព្រះឪយកទៅដាក់លើកំពូលភ្នំព្រះវិហារ ដែលជាវិហារធម៌របស់ពួកគាត់ពីអតីតកាលវិញ។ សព្វថ្ងៃបរទេសឈ្លានពានកំពុងចង់បានប្រាសាទនេះ ព្រមទាំងទឹកដីជាប់ព្រំប្រទល់តំបន់នោះផង ព្រោះគេដឹងថាទីនោះជាដែនដីអាទិទេពខ្មែរ។ ពេលណាគេដណ្តើមបានទីនោះដូចជាគេបាន អាទិទេពរបស់អ្នកនគរនេះ ដូច្នេះហើយទើបគេខិតខំពន្យល់ប្រជាជនគេគ្រប់ស្រទាប់វណ្ណៈថា ប្រាសាទនេះជារបស់ពួកគេ ទោះបីជាដឹងថា ពុំមែនជារបស់ខ្លួនក៏ដោយ។ ដូចជាវាលឥន្ទ្រីពួកគេចេះតែដណ្តើមចង់បាន ព្រោះឥន្ទ្រីតំណាងឲ្យសត្វគ្រុឌ ហើយគ្រុឌនេះកំពុងចាប់នាគ តែឥឡូវវាលឥន្ទ្រី(និមិត្តរូប)នេះគឺជារបស់ខ្មែរ គេមិនអាចមានកម្លាំងឫទ្ធិខាងក្នុងចាប់ព្រះម៉ែបានទៀតឡើយ ព្រោះវាលឥន្ទ្រីជារបស់ខ្មែរ។

ប្រាសាទព្រះវិហារតំណាងឲ្យអ្វី? ប្រាសាទព្រះវិហារតំណាងឲ្យព្រហ្មវិហារធម៌ទាំងបួន ដែលគាត់បានធ្វើដំបូលឲ្យកូននាគប្រុសស្រីជ្រក (**ក្បឿងស្រកានាគ**) ជាម្លប់រាប់ពាន់ឆ្នាំមកហើយ។ ម្លប់នៃព្រហ្មវិហារធម៌នេះបានគរពូនក្លាយទៅជាភ្នំ ហើយកូនខ្មែរប្រុសស្រីដែលជ្រកក្រោមម្លប់នេះ ពុំបានស្គាល់ម្ចាស់ដំបូលឬជម្រករបស់ខ្លួនឡើយ មិនត្រឹមតែប៉ុណ្ណោះយើងនាំគ្នាជេរប្រមាថ មាក់ងាយដល់ម្ចាស់ជម្រកនោះទៀតផង(ជេរអាទិទេពខ្លួនឯង)។

សព្វថ្ងៃនេះរាជរដ្ឋាភិបាលដែលមានសម្តេចនាយកជាប្រមុខ លោកបានខិតខំប្រឹងប្រែងដាក់បញ្ចូលប្រាសាទព្រះវិហារជាសម្បត្តិបេតិកភណ្ឌពិភពលោក គឺលោកជួយរែកស្រង់វិហារធម៌ព្រះមាតាបិតាទៅដាក់លើកំពូលឡើងវិញហើយ។ ដូច្នេះអនាគតដ៏ខ្លីខាងមុខព្រះមាតាបិតាមហានគរនឹងរួចពីទុក្ខហើយនឹងធ្វើឲ្យនគរនេះរុងរឿងដូចសម័យដើម ពេលនោះកូននាគប្រុសស្រីនឹងស្គាល់អាទិទេពខ្លួនឯងជាមិនខាន។

**១៤.ប្រាសាទភ្នំបាខែង** (ខេត្តសៀមរាប)

ប្រាសាទភ្នំបាខែងនេះ ជាភ្នំធម្មជាតិដែលដូនតាខ្មែរបានកសាងប្រាសាទមួយទុកនៅលើកំពូលភ្នំនេះដាក់ឈ្មោះថា ប្រាសាទបាខែងឬភ្នំបាខែង។

**ពន្យល់ពាក្យ** (បាខែង)

បា = កូនប្រុស

ខែង = ដែលក្លៀវក្លា អង់អាច ហ៊ីហា ឫកពាខែងរឹង

បាខែង = បាដែលក្លៀវក្លា អង់អាច ហ៊ីហា បាដែលមានឫកពាខែងរឹង

មុននឹងខ្ញុំពន្យល់ពីអត្ថន័យ,ប្រាសាទបាខែង ខ្ញុំសូមទាញយកឈ្មោះប្រាសាទបាពួន និងប្រាសាទបាគងមកបកស្រាយសិន ព្រោះប្រាសាទទាំងពីរនេះពុំមែនជាប្រាសាទភ្នំឬភ្នំប្រាសាទឡើយ ប៉ុន្តែទាក់ទងនឹងឈ្មោះ**បា**។ នេះគឺជាគុណធម៌ដំបូង ដែលកូនប្រុសរបស់គាត់បានដឹងរឿងគាត់រួចបានោះ ពួនលាក់ខ្លួនដើម្បីជួយស្រោចស្រង់ព្រះម៉ែ នៅក្នុងព្រៃមនុស្សដោយស្ងៀមស្ងាត់ នេះជាអត្ថន័យ**ពាក្យ** ប្រាសាទ**បាពួន** ➔ (**បាលាក់ខ្លួន**ជួយស្រង់ព្រះម៉ែ) ចំណែកប្រាសាទបាគង់សព្វថ្ងៃគេហៅថា បាគង ឈ្មោះរបស់ប្រាសាទនេះ មានពីរ។

**ពន្យល់ពាក្យ** (បាគង់ និង បាគង)

បាគង់ ➔ កូនប្រុសគង់ចាំ ឬអង្គុយចាំព្រះម៉ែឡើងមកពីទីទាប (សមុទ្រទឹកដោះ)

បាគង ➔ បាគងព្រះមេឬព្រះម៉ែឲ្យគាត់ឱបជើង (រូបចម្លាក់ព្រះវិស្ណុដេក នៅក្បាលស្ពាន ប្រាសាទព្រះខ័ន្ធ បន្ទាយសំរ៉ែ ភ្នំដារ បាតស្ទឹងភ្នំ គូលែន) ....។ល។ គឺព្រះវិស្ណុផ្ទុំលើគុជសី ផ្ទុំលើនាគ រួចគងព្រះម៉ែ (ដែលសព្វ ថ្ងៃមានស្រុកមួយនៅក្នុងខេត្តកំពង់ស្ពឺ **គងពិសី** ខ្ញុំបានពន្យល់ខាងលើ រួចហើយ) គាត់វារផង លូនផង ដឹកអូសព្រះម៉ែចេញពីទីឃុំឃាំង។ នៅក្នុងរឿងព្រេងបក្សីចាំក្រុង មានឈ្មោះភូមិស្រុក ដែលទាក់ទងនឹងរឿងនេះ បានសល់កេរដំណែលមកដល់សព្វថ្ងៃ គឺវិហារសួគ៌(សួរ) **ល្វាទេ** និង **រកាកោង** ដែលជាប្រស្នាទាក់ទងក្នុងទំនាយ រឿងព្រេង.....។ល។


**វិស្ណុផ្ទុំនៅប្រាសាទព្រះខ័ន សៀមរាប**


រូបតំណាងពាក្យរកាកោង

*ពន្យល់ពាក្យ* (ក្នុងរឿងបក្សីចាំក្រុង)

*បក្សី = ត្រុឌ*

*ក្រុង = យកអង្រុត ឬសំណាញ់ទៅគ្របក្រុងពីលើ*

*ក្រុង = រាជធានី (ទីក្រុង)*

**ល្វាទេ** = *ល + វា + ទេ ➔លវារចុះ (សាកវារចុះ)*

**រកាកោង** = *(រកា= មាន់) កោង= ពាក់កណ្ដាល*

*មានន័យថា ឆ្នាំរកាទៅនៅសល់ពាក់កណ្ដាលទៀត ព្រោះបុរសដែលបក្សីចាំក្រុង គាត់ត្រូវវារពាក់កណ្ដាលនៃឆ្នាំដែលនៅសល់ដើម្បីនាំព្រះម៉ែចេញ (មើលរូបខាងលើ)។ បើប្រៀបធៀបនឹងមង្គលបីឬសិរីបីបានន័យថា ពីក្បាលដល់ផ្ចិតគឺពាក់កណ្ដាលៗទៀតគឺពីផ្ចិតដល់ចុងជើងព្រោះក្នុងសិរីបីប្រការក្ដីមង្គលបីក្ដី គឺព្រឹកនៅមុខ ថ្ងៃត្រង់នៅទ្រូង ល្ងាចនៅចុងជើង ប្រស្នាពីរខាងដើម គឺស្មើនឹងខាងចុងមួយ។ តាមពិតរឿងព្រះម៉ែរួចពីទុក្ខនោះ ត្រូវចប់ក្នុងឆ្នាំរកាឯណោះ ព្រោះចាស់ៗតែងដំណាលតៗគ្នាទុកក្នុងទំនាយថា* **រកាសាដាន** *ពាក្យថាសាដាននេះ គឺ សាដានព្រះម៉ែ ដែលត្រូវគេលុបមិនឲ្យកូនខ្មែរដឹងនោះឲ្យដឹងឡើងវិញ ក៏ប៉ុន្តែពុំអាចសារួចឡើយ ព្រោះដល់ឆ្នាំរកាត្រូវសាដានព្រះម៉ែបែរជារកាកោងទៅវិញ គឺត្រូវស្មើនឹងពាក់កណ្ដាលពីរដងខាងលើឯណោះ។ នេះខ្ញុំបាទអ្នកស្រាវជ្រាវចង់ពន្យល់រូបចម្លាក់រឿងឲ្យទាក់ទងនឹងឈ្មោះភូមិ ស្រុក ប្រាសាទ ភ្នំ រឿងព្រេងប្រចាំនគរ ឬទំនាយប្រចាំនគរជាដើម* **(ប្រមូលផ្ដុំជ័យ)**។ *ប្រស្នាព្រះម៉ែនេះមិនដែលមានអ្នកណា ចាប់អារម្មណ៍បំបែកបណ្ដាំគំនិតរបស់គាត់ឡើយ បើយើងអត់បំបែកបណ្ដាំប្រស្នានេះទេ គឺពុំអាចរកគន្លឹះបើកទ្វារអាថ៌កំបាំងបណ្ដាំព្រះម៉ែនេះរួចឡើយ* **ទាល់តែយើងផ្គុំផ្គុំរឿងដែលគេហាន់ជាចំណិតៗ** នោះទើបអាចមើលឃើញនូវសាច់រឿងពិតរបស់គាត់បាន។

*ឥឡូវយើងត្រឡប់មកសាច់រឿង***ភ្នំបាខែង***វិញ* ***តើមានអត្ថន័យយ៉ាងណាដែរ?*** *ខ្ញុំបានពន្យល់ក្នុងទំព័រខាងដើមខ្លះៗហើយ ដោយគុណធម៌របស់បា(កូនប្រុស) គាត់សន្សំតាំងពីតូចរហូតដល់ធំប៉ុនភ្នំ ទី*

បំផុតគុណធម៌ដែលសន្សំបាននេះធ្វើឲ្យគាត់អាចលើកដងរែកភ្នំរួច(និមិត្តរូប) ហើយស្រង់រែកភ្នំម៉ែឪដែលលិចកប់ចុះរាប់ពាន់ឆ្នាំឲ្យងើបអណ្ដែតឡើងវិញ រួចរែកពួកគាត់ទៅដាក់លើកំពូលភ្នំព្រះវិហារវិញ។ កាលបើអាទិទេពខ្មែររួចពីទុក្ខទោសហើយនោះ តើកូនខ្មែរអាចរួចពីទោសបានទេ? គឺ **ពិតជាបាន** ពេលដែលដូនតាយើងលែងជាប់ទុក្ខទោសនោះហើយដែលហៅថា **ខែងរ៉ែង**(ប្រាខែង)។ សព្វថ្ងៃកូនខ្មែរបានត្រឹមតែឡើងលើភ្នំប្រាខែង មើលថ្ងៃលិចជាមួយបរទេសតែប៉ុណ្ណោះ គឺពុំបានដឹងពីអត្ថន័យបណ្ដាំពាក្យពិតរបស់ព្រះម៉ែឲ្យមើលឈ្មោះប្រាសាទភ្នំនេះឡើយ។ សូមឲ្យក្លិនក្រអូបនៃបញ្ញារបស់ព្រះម៉ែសក់ក្រអូប ជ្រាបចូលក្នុងបេះដូងកូនខ្មែរប្រុសស្រីឡើងវិញ សូមឲ្យកោះកេរ**ព្រះ**ម៉ែ (ប្រាសាទកោះកែរ**កោះកេរ**ឬកោះគោកឆ្លក) អណ្ដែតឡើងដោយកម្លាំងសាមគ្គីរបស់កូននាគប្រុសស្រី។

**១៥. ភ្នំត្បែងមានជ័យ** (ខេត្តព្រះវិហារ)

ត្បែង = ត្របែង ចងដោយប្រើកូនកំព្រាស៊ករឹត មួលឲ្យតឹង (ចងរួចត្បែងឬត្របែង)

ត្បែង = ឈ្មោះឈើសន្ដានខ្លុង ត្រាច

មានជ័យ = ជម្នះការឈ្នះ ជោគជ័យ

ភ្នំត្បែងមានជ័យ = ចងរឹតត្បែងភ្នំដោយបានជោគជ័យ

តើឈ្មោះភ្នំត្បែងមានជ័យនេះ មានទាក់ទងអ្វីនឹងរឿងព្រះម៉ែមហានគរដែរ? ឯកសាររូបរឿងរបស់ភ្នំត្បែងមានជ័យនេះ ស្ដេចជ័យវរ្ម័នទី៧ ព្រះអង្គបានកសាងទុករូបរឿងនៅប្រាសាទបាយ័ន និងប្រាសាទបន្ទាយឆ្មារ ព្រោះសព្វថ្ងៃមាននៅសល់រូបភាពដែលអាចនៅមើលយល់បាន។

មិត្តអ្នកអានជាទីមេត្រី បើអ្នកទៅទស្សនាប្រាសាទបាយ័ន ពេលអ្នកដើរចូលទៅក្នុងបរិវេណខាងមុខ អ្នកនឹងបានឃើញខ្លោងទ្វារដែលមានមុខព្រហ្មដំបូងគេ ដែលយើងត្រូវដើរឆ្លងកាត់ពីក្រោម។ ពេលនោះអ្នកសម្លឹងមើលទៅខាងលើមុខព្រហ្ម អ្នកនឹងកើតក្ដីសង្ស័យជាមិនខាន ព្រោះនៅខាងលើក្បាលព្រហ្មមានសុទ្ធតែរូបសត្វគ្រុឌឈរស្រាក់ដៃគ្នាជ្រែងត្បែង មិនឲ្យព្រហ្មរើក្បាលរួចឡើយ។ តើមិត្តអ្នកអានមានឆ្ងល់ទេ? បើព្រហ្មមានឋានៈខ្ពស់ទៅហើយ **ហេតុដូចម្ដេចបានជាមានសត្វគ្រុឌជាសត្វតិរិ**

**ធ្លាននៅពីលើ?** កូននាគទាំងឡាយ ចូរអ្នកជួយពិចារណាព្រហ្មម៉ែព្រហ្មឪឡើងវិញដោយពឹងផ្អែកនឹង **ឈរលើគំនិតនិង មនសិការជាតិសុទ្ធៗ** រីឯប្រាសាទបន្ទាយឆ្មារក៏ដូច្នោះដែរ មានសុទ្ធតែមនុស្សអង្គុយស្រាក់គ្នាជុំវិញពីខាងលើក្បាលព្រហ្ម។ តាមឯកសារពន្យល់ពីប្រាសាទយើងដឹងហើយថា ប្រាសាទបន្ទាយឆ្មារ គឺធ្វើឡើងដើម្បីឧទ្ទិសឲ្យកូន រីឯប្រាសាទបាយ័នវិញ គឺធ្វើដើម្បីឧទ្ទិសឲ្យមាតាបិតា។ បើព្រហ្មម៉ែនិងព្រហ្មឪ ត្រូវគេចងត្បៀងជាប់ទៅហើយ ថែមទាំងព្រហ្មកូនក៏គេត្បៀងជាប់ដូចគ្នា ពេលណាទើបយើងអាចស្រាយចំណងត្បៀងទាំងនេះរួច គឺបានន័យថា (យកថ្លុកទៅលុបត្រពាំង)។ សព្វថ្ងៃក្រុមតាបស ឥសី គ្រូមន្តអាគម...តែងតែនាំគ្នាទៅរកអ្នកមានបុណ្យ នៅភ្នំត្បែងនោះដោយពួកគាត់ឮតៗគ្នាក្នុងពុទ្ធទំនាយថា មានអ្នកមានបុណ្យ កំពុងតាំងសិល្ប៍សមាធិនៅក្នុងភ្នំត្បែង។ ប៉ុន្តែតាមន័យពិត ពួកគាត់ត្រូវគេចងត្បៀងជាប់ មកទល់នឹងពេលនេះ ពួកគាត់មិនទាន់រួចពីចំណងបាបកម្មចាស់ផង នេះជាអាថ៌កំបាំងបណ្តាំរបស់ព្រះម៉ែក្នុង **ពាក្យភ្នំត្បែងមានជ័យ**។ ចង់ស្រាយចំណងត្បៀងនេះរួច លុះត្រាតែកូននាគប្រុសស្រីរួមសាមគ្គី ព័ន្ធគ្នាជាធ្លុងមួយហើយឧទ្ទិសនូវមហាកុសល ដែលកើតចេញពីការដឹងឧបការគុណ(កតញ្ញូកតវេទី)ទើបអាចស្រាយនូវចំណងត្បៀងដែលជាបាបកម្មដ៏ធំនេះរួច។



**រូបព្រហ្មបាយ័នមានត្រកុឌស្រាក់ត្បែងពីលើ**

**១៦.ប្រាសាទភ្នំត្រប់** ( ភ្នំទេព្យខេត្តព្រះវិហារ)

ប្រាសាទនេះ ខ្ញុំបាទអ្នកស្រាវជ្រាវទើបតែស្គាល់ឈ្មោះ នៅពេលដែលវិវាទជំលោះប្រាសាទព្រះវិហារកើតឡើង តើវាទាក់ទងអ្វីដែរនៅក្នុងរឿងបណ្តាំព្រះម៉ែមហានគរ? កូននាគប្រុសស្រីទាំងឡាយអ្នកពិតជាធ្លាប់អាន ធ្លាប់ស្តាប់នូវរឿងមរណៈមាតា(ម៉ែស្លាប់) ឬដើមកំណើតត្រីដំរីហើយ រឿងនេះជារឿងរបស់ព្រះម៉ែមហានគរ ដែលសាច់រឿងស្រដៀងនឹងរឿងមាតាទាំង១២ដែរ គ្រាន់តែក្នុងរឿងនេះគឺមានម្តាយតែមួយប៉ុណ្ណោះ។ ម្តាយក្នុងរឿងនេះត្រូវស្ត្រីរួមប្តីជាមួយញុះញង់ប្តីឲ្យយកគាត់ទៅសម្លាប់

នៅពេលដែលគាត់ទៅបង់សំណាញ់ជាមួយប្ដី ហើយប្រពន្ធដើមនោះ គាត់មានកូនស្រីម្នាក់ជាកូនកតញ្ញូកតវេទី(ដឹងគុណ)។ កូនស្រីនៅពេលដែលបាត់ម្ដាយ នាងបានទៅយំរៀបរាប់នៅឯមាត់កំពង់ទឹកដែលម្ដាយស្លាប់ ដោយសារឪពុកនាងសម្លាប់នោះ ហើយគាត់បានកើតជាត្រីដំរី ពេលឮកូនស្រីខ្លួនយំរៀបរាប់ គាត់ក៏បានហែលមកជិតរួចប្រាប់រឿងរ៉ាវដល់កូន។ កូនស្រីតែងតែយកចំណីទៅឲ្យម្ដាយជាត្រីដំរីបរិភោគរាល់ៗថ្ងៃ ធ្វើឲ្យដំណឹងនេះឮទៅដល់ម្ដាយចុង ដែលជាមនុស្សមានចិត្តអាក្រក់ រួចម៉ែចុងនោះបានប្រើកូនស្រីទាំងពីររបស់ខ្លួន ឲ្យទៅល្បួងចាប់ត្រីដំរីនោះមកសម្លាប់ធ្វើម្ហូប។ ពេលដែលសម្លាប់ធ្វើម្ហូបនោះ ឆ្អឹងរបស់ត្រីជ្រុះទៅក្រោម សត្វឆ្មាបានពាំយកឆ្អឹងនោះ ទៅឲ្យកុមារិកាជាកូនៗបានយកឆ្អឹងទៅកប់(បញ្ចុះធាតុ)ក្នុងទីមួយ នៅទីដែលកប់ឆ្អឹងនោះក្រោយមកបានដុះចេញជាដើមត្រប់មួយដើម។ នាងកុមារិកាជាកូន តែងតែទៅស្រោចទឹកដើមត្រប់នោះរាល់ៗថ្ងៃ ធ្វើឲ្យរឿងនេះបានលេចឮទៅដល់ម្ដាយចុងដែលជាមនុស្សព្យាបាទឈ្នានីស ស្ដ្រីនេះបានប្រើកូនឲ្យទៅបោចដើមត្រប់នោះចោលទៀត។ ក្រោយពេលដែលកុមារិកាបានដឹង នាងក៏បានទៅមើលក្នុងទីនោះ ឃើញមាននៅសល់ឫសត្រប់ខ្លះក្នុងដី នាងក៏ប្រមូលនូវឫសទាំងនោះទៅបញ្ចុះក្នុងទីមួយថ្មីផ្សេងទៀត ដែលក្រោយមកទីបញ្ចុះនោះបានដុះចេញឡើងជាដើម **រលួសមាស** (រលស់)។ និយាយពីស្ដេចនគរនោះ ថ្ងៃមួយមានសេចក្ដីអផ្សុកបានចេញទៅប្រពាតព្រៃ រួចបានឃើញនូវដើមរលួសមាសនោះ ស្ដេចបានឲ្យគេរកម្ចាស់ដើមរលួសមាសនេះ ដើម្បីសុំយកទៅដាំក្នុងរាជវាំង ព្រោះឃើញពណ៌សម្បុររបស់វាល្អ។ ពេលដែលស៊ើបដឹងពីម្ចាស់ដើមរលួស ស្ដេចបានពេញចិត្តនឹងកុមារិកានោះ ហើយបានតែងតាំងនាងជាមហេសី នាងកុមារិកាក៏បានឧទ្ទិសដ្ឋាននូវដើមរលួសមាសជាម្ដាយ ឲ្យគាត់ទៅប្រតិស្ឋានក្នុងជើងមាសឯព្រះបរមរាជវាំង ដែលនាងអាចក្លាយជាមហេសីស្ដេចបាន ក៏ដោយសារអំណាចបុណ្យដែលនាងបានបំពេញនូវកតញ្ញូកតវេទី (ការដឹងឧបការគុណ និងតបនូវឧបការគុណនេះ) ។ កូននាគទាំងឡាយ តើអ្នកដឹងទេថា រឿងនេះមានបង្កប់នូវប្រស្នាអ្វីខ្លះ?

**១**. ទាក់ទងនឹងត្រីដំរី (ទីក្រុងយសោធបុរៈឬទីក្រុងដំរី)

**២**. ទាក់ទងនឹងដើមត្រប់ (ដែលសព្វថ្ងៃតំណាងឲ្យប្រាសាទភ្នំត្រប់ ឬភ្នំទ្រព្យ)

៣. ទាក់ទងនឹងដើមរលួសមាស (ដែលប្រស្នាតំណាងឲ្យប្រាសាទរលស់)

យើងដឹងហើយថាទីក្រុងសម័យអង្គរគេហៅថា រាជធានីយសោធបុរៈ ដែលប្រែមកថា ក្រុងអ្នកទាក់ដំរីឬក្រុងដំរី ហើយនគរនេះរុងរឿងបានដោយសារមហិទ្ធិឫទ្ធិបិសាចពស់ (ឯកសារចិន**ជីវតាក្វាន់**បានពន្យល់រួចហើយក្នុងភាគ១)។ ម្តាយក្លាយទៅជាត្រីដំរីមកពីពាក្យ **ស្ត្រី = សត្វ + ត្រី + ដំរី ស្ត្រីដំរីនេះ**បានធ្លាក់លិចកប់ចុះទៅក្នុងសមុទ្រទឹកដោះ (ព្រះម៉ែនាគ) រឺង**ដើមត្រប់** ឬទ្រព្យវិញតំណាងឲ្យធនធានទ្រព្យធនរបស់ខ្មែរ ដែលសព្វថ្ងៃបានពូនគរទៅជាភ្នំ ចំណែក**ដើមរលួស(រលស់)** តំណាងឲ្យបាបកម្មរបស់ព្រះម៉ែរលស់អស់បន្តិចម្តងៗ ព្រោះពាក្យថា **រលស់ ឬរម្លស់** គឺបាត់ចំនួនដើមអស់បន្តិចម្តងៗ (ឧ. ពាក្យថាសងរម្លស់)។ មិត្តអ្នកអានតើមានឆ្ងល់ដែរឬទេ? ក្នុងសាច់រឿងបានប្រាប់ថា ម្តាយស្លាប់ពីមនុស្សទៅកើតជាត្រីដំរី ស្លាប់ពីត្រីដំរីទៅកើតជាដើមត្រប់ ស្លាប់ពីដើមត្រប់ទៅកើតជាដើមរលួសមាស (រលស់)។ បើតាមកាសិក្សាពីព្រះធម៌ក្នុងព្រះពុទ្ធសាសនា ព្រះអង្គទ្រង់ត្រាស់សំដែងថា អកុសលកម្មដែលសត្វបានធ្វើ កម្មនោះតែងនាំសត្វឲ្យធ្លាក់ទៅកាន់អបាយភូមិ៤ (នរក ប្រេត តិរិច្ឆាន អសុរកាយ) ចុះហេតុអ្វីបានជាក្នុងសាច់រឿងដូនតាយើងសរសេរថា **ត្រីដំរីជាសត្វតិរិច្ឆាន** បែរទៅកើតជារុក្ខជាតិទៅវិញ? ព្រោះរុក្ខជាតិពុំមានចិត្ត វិញ្ញាណឡើយ។ គាត់ចង់ឲ្យកូននាគប្រុសស្រីជាអ្នកស្តាប់រឿង អានរឿងនឹងជាអ្នកកាន់ព្រះពុទ្ធសាសនានោះ កើតមានការងឿងឆ្ងល់ រួចធ្វើការស្រាវជ្រាវត្រិះរិះពិចារណា នូវបណ្តាំគំនិតព្រះម៉ែទាំងនេះ។ ការបកស្រាយពន្យល់ជាហូរហែដែលទាក់ទងប្រាសាទភ្នំត្រប់ និងរឿងកំណើតត្រីដំរី ទោះបីជារឿងព្រេងនិទាន ប៉ុន្តែវាបានភ្ជាប់សាច់រឿងទៅនឹងប្រាសាទ ភ្នំ ធម្មជាតិ... ដែលធ្វើឲ្យយើងអាចស្រាយនូវបណ្តាំប្រស្នាព្រះម៉ែបាន ព្រោះឈ្មោះកើតចេញពីមនុស្សអ្នកសន្មត់រួចដាក់សម្គាល់ ហើយបង្កប់អត្ថន័យទៅតាមបញ្ញារបស់បុគ្គលម្នាក់ៗ ដូចជាសព្វថ្ងៃ ម្តាយឪពុកដែលចេះដឹងតែងដាក់ឈ្មោះបុត្រទៅតាមកម្លាំងថ្ងៃដែលកើត ហើយការដាក់ឈ្មោះនោះតែងមានបង្កប់អត្ថន័យដែលខ្លួនជាមាតាបិតាចង់បាន។

**១៧.ភ្នំសន្ទុក** (ខេត្តកំពង់ធំ)

តាមឯកសារទាំងឡាយដែលមានសេសសល់ពីបុរាណនៅលើភ្នំនោះ ពីដើមភ្នំនេះមានឈ្មោះថាភ្នំសន្សំទុក (ភាសានិយាយច្រើនក្លាយ) ព្រោះនៅលើភ្នំបានបន្សល់ទុកនូវឯកសារសាវតាចម្លាក់រូបជាច្រើន ដែលមាននៅសល់ទុកជាកេរមកដល់សព្វថ្ងៃ។ នៅក្នុងព្រះវិហារមានបល្ល័ង្កព្រះពីបុរាណមួយដែលនៅខាងលើបល្ល័ង្កនោះ ពុំមានពុទ្ធបដិមាគង់នៅពីខាងលើឡើយ គឺមានតែផ្កាឈូកក្រពុំមួយទងនៅខាងលើបល្ល័ង្កតែប៉ុណ្ណោះ ចំណែកឯរូបពុទ្ធបដិមាបែរជាចុះមកគង់នៅខាងក្រោមបល្ល័ង្កទៅវិញ

(គំនិតអ្នកឆ្លាក់)។ នៅខាងក្រោយព្រះវិហារនោះ មានរូបដោះស្ត្រីឆ្លាក់ថ្មពីបុរាណពីរ ទីមួយដោះតូចតំណាងឲ្យស្ត្រីនៅក្រមុំ (ខ្មែរ = មេ) ទីពីរដោះធំតំណាងឲ្យស្ត្រីដែលមានប្ដី ហើយមានកូន (ខ្មែរ=ម៉ែ) ហើយនៅក្នុងចន្លោះនៃដោះទាំងគូនេះ មានអណ្ដូងថ្មជីកយ៉ាងជ្រៅ ដែលនៅក្នុងអណ្ដូងនោះ មានសសរថ្មបួនជ្រុងចំនួនបីដើម។ នៅចំហៀងភ្នំឯណោះវិញ មានរូបពុទ្ធបដិមាគ្រប់ឥរិយាបទដែលដូនតាយើងឆ្លាក់ទុកមានទំហំធំៗ ហើយរូបចម្លាក់ទាំងអស់ ជាបណ្ដាំប្រស្នាដែលទាក់ទងនឹងឈ្មោះភ្នំនេះ។ តើរូបចម្លាក់ថ្មទាំងអស់នោះមានអត្ថន័យយ៉ាងណាហ្ន៎? បើយើងមិនបានសិក្សាពិចារណាស្រាវជ្រាវទេ យើងច្បាស់ជាយល់ថា ដូនតាយើងមានពេលទំនេរមកឆ្លាក់រូបលេងទុកនៅទីនោះហើយ (រៀនឆ្លាក់)។

ក .ពេលដែលយើងមើលឃើញផ្កាឈូកក្រពុំដែលស្ថិតនៅលើបល្ល័ង្កនេះ យើងនឹកឃើញដល់ព្រះចេតិយព្រះនាងក្រពុំឈូក នៅឯព្រះវិហារសសរមួយរយក្នុងភូមិសំបុក ស្រុកសំបូរ ខេត្តក្រចេះឯណោះ។ ព្រោះផ្កាឈូកនៅលើបល្ល័ង្កព្រះវិហារភ្នំសន្ទុកនេះ អត្ថន័យរបស់វាគឺជាប់ជាមួយនឹងរឿងព្រះចេតិយព្រះនាងក្រពុំឈូកនៅឯខេត្តក្រចេះនោះ(ពន្យល់នៅក្នុងភ្នំរទង់រួចហើយ)។ ហេតុអ្វីបានជាពុទ្ធបដិមាចុះមកគង់ខាងក្រោមទៅវិញ?

ផ្កាឈូកតំណាងឲ្យបរិស័ទទាំង ៤ ពួក និងតំណាងបញ្ញាបារមីរបស់ព្រះពុទ្ធ និង ព្រះបច្ចេកពុទ្ធដែលត្រូវត្រាស់ដឹងដោយខ្លួនឯង។ យ៉ាងណាមិញ ផ្កាឈូកដែលនៅលើបល្ល័ង្កក៏តំណាងឲ្យបញ្ញាព្រះមាតានាគបិតានាគរួមទាំងកូននាគទាំងទ្វេដែលបញ្ញាទាំងនេះ មិនទាន់អាចរីករួច(ឈូកក្រពុំ)។ ព្រោះយើងទាំងអស់គ្នា កំពុងនៅក្នុងភូមិសំបុក ស្រុកសំបូរ ខេត្តក្រចេះ ម្យ៉ាងទៀតបញ្ញារបស់ពួកគាត់ ត្រូវគេត្បៀងជាប់អស់ហើយ (អាថិកំបាំងភ្នំត្បៀង)។ ចំណែកឯពុទ្ធបដិមា ដែលចុះមកគង់ខាងក្រោមវិញ គឺតំណាងឲ្យពោធិសត្វដែលកំពុងបំពេញបារមីនៅឡើយ (ពោធិសត្វលោកេស្វរៈ) ។

ខ.រូបដែលទាក់ទងនឹងដោះវិញ តើមានអត្ថន័យខ្លឹមសារយ៉ាងណាដែរ? ខ្ញុំបានពន្យល់រួចហើយក្នុងភាគទីមួយពីពាក្យ មេ និងម៉ែ ដូច្នេះរូបចម្លាក់ដោះទាំងពីរនេះ ដោះដែលតូច(ដោះក្រមុំ) គឺកាលគាត់នៅជាព្រះមេ គឺព្រះនាងនាគ ចំណែកឯដោះដែលធំគឺពេលដែលគាត់ក្លាយទៅជាព្រះម៉ែ ឬមាតានាគ (មាតុភូមិ)។ចំណែកឯអណ្ដូងវិញមានអត្ថន័យយ៉ាងណា?

គ. អណ្ដូងគឺជាទីជ្រៅដែលលាក់ទុកនូវបេះដូង គឺក្នុងទ្រូង (ខ្ញុំពន្យល់រួចហើយ) នឹងលាក់ទុកនូវប្រភពទឹកដោះ ដែលបានហូរផ្សព្វផ្សាយចេញមកពេញទូទាំងមាតុភូមិនេះ កូនណាចង់ដឹងពីប្រភពដើមរបស់ទឹកដោះ ទាល់តែចុះទៅក្នុងអណ្ដូងនោះទើបដឹង។ ចុះសសរថ្មបីដើមនោះតំណាងឲ្យអ្វី? ខ្ញុំបានពន្យល់ក្នុងមង្គលបីនិងសិរីបីប្រការរួចហើយ គឺព្រះម៉ែគាត់ជាប់នៅក្នុងគុកទាំងបីជាន់ បើកូនខ្មែរ

*ណាចង់ជួយស្រង់គាត់ទាល់តែរកប្រស្នានៅក្នុងមង្គលទាំងបី និងសិរីបីឬក៏ចុះទៅក្នុងអណ្ដូង ទើបអាចលើកសសរថ្មដែលសោចាក់បិទក្នុងអណ្ដូងនោះចេញរួច ព្រោះវាជានិមិត្តរូបសោបីជាន់ (មេសោបើកបានដោយសារកូន)។ ប៉ុន្តែគួរឲ្យសោកស្ដាយណាស់ ដែលសព្វថ្ងៃនេះអ្នកទេសចរណ៍ដែលទៅលេងលើភ្នំនោះ គេតែងនាំគ្នាបោះលុយចូលទៅក្នុងអណ្ដូង ដើម្បីផ្សងមើលនូវមុខរបរ ការងាររកស៊ីចិញ្ចឹមជីវិតទៅវិញ ដោយពុំបានយល់ពីប្រស្នាគំនិតបណ្ដាំរបស់ព្រះម៉ែនេះឡើយ ព្រោះរវល់តែចង់បានលាភសក្ការៈពីមុខរបរខ្លួន ម្យ៉ាងទៀតហេតុតែមិនដឹងនិងមិនបានពិចារណាឈ្វេងយល់ ធ្វើឲ្យយើងបាត់នូវបញ្ញាដើម្បីគិតត្រិះរិះដោះប្រស្នាមរតកបណ្ដាំព្រះម៉ែនេះ។*

**១៨.ភ្នំជីលា** (ខេត្តកំពង់ចាម)

*ខ្ញុំបានពន្យល់ពីភ្នំជីសូរ និងស្ទឹងជីក្រែងនៅទំព័រខាងដើមរួយហើយ ឥឡូវនេះ ចូលមកដល់ឈ្មោះភ្នំជីលា*

*តើភ្នំជីលាមានន័យដូចម្ដេច? មុនពេលដែលជីចេញទៅប្រមូលរឿង ដែលគេហាន់ជាចំណិតៗ (ហាន់ជ័យ) គាត់បានទៅលាផ្ដែផ្ដាំញាតិមិត្តម៉ែឪថា គាត់នឹងចេញទៅស្វែងរកនូវអាថ៌កំបាំងព្រះម៉ែនេះ ទើបនៅក្នុងតំបន់នោះ មានឈ្មោះទីកន្លែងមួយទៀត ហៅថាចរចា(ជីលាចរចា)។ ដូចស្ទឹងជីនិតពាក្យនេះមានន័យដូចស្ទឹងជីក្រែងដែរ គឺជីនោះគាត់ស្ថិតនៅក្នុងវណ្ណៈទាប ឬត្រកូលទាប (ពូជសំរែ) ដូច្នេះហើយទើបគាត់ក្រែងជួយព្រះម៉ែពុំបាន (ជីក្រែង) ព្រោះខ្លាចដោះក្ដីក្នុងទីខ្ពស់ដូចជាភ្នំពុំរួច ព្រោះរឿងក្ដីក្ដាំរបស់ព្រះម៉ែ ជារឿងដែលស្ថិតក្នុងទីខ្ពស់ (យក្សចាប់ នាងសេតា)។*

**១៩.ភ្នំបាធាយ** (ខេត្តកំពង់ចាម)

*ពាក្យនេះពីមុនឈ្មោះថាភ្នំបាស្ដាយ ព្រោះពាក្យនិយាយច្រើនក្លាយ* **ឧ.** *ស្រីសន្ធរពីមុនស្រីសឈរ កំពង់ចាមពីមុន***កំពុងចាម់** *ទូលគកពីមុន***ទួលគោក** *ទន្លេបាទីពីមុន***ទន្លេបាត់ទី***....។ល។ តើបានោះគាត់ស្ដាយអ្វី? គឺគាត់ស្ដាយនូវបណ្ដាំរឿងរ៉ាវទាំងឡាយ ដែលដូនតាបានហាន់ជាចំណិតៗ ដើម្បីយកមកផ្គុំនៅបណ្ដាំរឿងពីអតីត ឲ្យមានជារូបរាងពិតរបស់ដូនតាឡើងវិញ មានន័យថាបាគាត់ស្ដាយបណ្ដាំរឿង*

ទាំងអស់ ដែលទាក់ទងនឹងរឿងព្រះម៉ែមកផ្គុំ ឲ្យកើតជាដានស្នាមចេញជារូបរាង ព្រោះយើងបាត់ដឹងរឿងយូរមកហើយ (ពាក្យបាត់ដឹងនេះ ខ្ញុំនឹងពន្យល់ពីឈ្មោះភ្នំរាពណ៍នៅទំព័រខាងក្រោយ) ដូច្នេះ**ឲ្យ**ត្រូវដើរប្រមូលស្ដាយនូវរឿងឯណោះបន្តិច ឯណោះបន្តិច មកផ្គុំឲ្យកើតមានជារូបរាងឡើងវិញ។

## ២០.ភ្នំប្រសិទ្ធិ / សិទ្ធី

***ពន្យល់ពាក្យ*** (ប្រសិទ្ធិ /សិទ្ធី)

ប្រសិទ្ធី = ការតាក់តែង ការប្រដាប់ ដំណើរធ្វើឲ្យសម្រេច **ឧ.** ប្រសិទ្ធីឲ្យមានស្រីសួស្ដី ភ្នំប្រសិទ្ធី គឺប្រសិទ្ធីភ្នំឲ្យគ្រប់លក្ខណៈ ប៉ុន្តែបើតាមសាច់រឿងពុទ្ធសែនកង្រីក្ដី បក្សីចាំក្រុងក្ដី ទីភ្នំនេះសុទ្ធតែបានជួយប្រសិទ្ធីអ្នកទាំងពីរក្នុងសាច់រឿង ឲ្យបានរួចពីសេចក្ដីស្លាប់របស់សត្រូវ។ ដូចក្នុងរឿងពុទ្ធសែន ឬរថសែន អាចរួចពីសេចក្ដីស្លាប់របស់ម្ដាយចុងជាយក្សនោះបាន ដោយអំណាចឫទ្ធិលោកតាឥសីជួយបំប្លែងសារ ទីបំផុតពុទ្ធសែនបានរៀបការជាមួយកង្រី ហើយថែមទាំងបានយកគ្រាប់កែវភ្នែក (បញ្ញា) ម្ដាយទាំង១២មកបញ្ចូលឲ្យពួកគាត់វិញ ព្រោះដល់ពេលវេលាបាបកម្មរបស់មាតាទាំង១២ ត្រូវរលស់អស់ (ប្រសិទ្ធីទីមួយ)។ ឯក្នុងរឿងបក្សីចាំក្រុងក៏ដូច្នេះដែរ តួអង្គបក្សីចាំក្រុង និងតាគហៅហ៍ បានរត់រួចពីការដេញតាមសម្លាប់ របស់ពួកកងទ័ពព្រហ្មកិល ក៏នៅក្នុងភ្នំប្រសិទ្ធិនេះដែរ (ប្រសិទ្ធីទីពីរ)។ ព្រោះរឿងការចងពៀរវេរានឹងគ្នា រវាងតួអង្គទាំងពីរនោះ គឺនៅក្នុងភ្នំប្រសិទ្ធីនេះ (ពុទ្ធសែន និងបក្សីចាំក្រុង) ហើយអ្នកទាំងពីរនេះ ទីបំផុតបានក្លាយជាស្ដេច បានឡើងសោយរាជ្យដូចគ្នា ដោយអំណាចប្រសិទ្ធីភ្នំ ឬភ្នំប្រសិទ្ធីនេះ។ ហេតុនេះហើយភ្នំនោះ មិនថាតួអង្គបក្សីចាំក្រុង ឬពុទ្ធសែនឡើយ គឺគ្រាន់តែជាមនុស្សម្នាក់ ប៉ុន្តែដូនតាខ្មែរគាត់ឲ្យមនុស្សទាំងពីរនេះ មានឈ្មោះផ្សេងគ្នាទទួលបាបកម្មក៏ផ្សេងគ្នាទៀត បើចង់ដឹងរឿងព្រះម៉ែ ទាល់តែផ្គុំភ្នំ នេះជាអត្ថន័យពិតរបស់ឈ្មោះភ្នំប្រសិទ្ធិ ដែលយើងជាកូនខ្មែរត្រូវតែពិចារណារាវរកហេតុផលពិតរបស់ឈ្មោះភ្នំនេះ។

**២១.ភ្នំរាពណ៍** (ទីតាំងជិតភ្នំប្រសិទ្ធិ)

***ពន្យល់ពាក្យ*** *(រាពណ៍)*

*រាពណ៍ = នាមរបស់ព្រះបាទទសក័ណ្ឋ ឬទសមុខ (ក្នុងរឿងរាមាយណៈ ឬរាមកេរ្តិ៍)*

*រាប = ដែលមិនរដិបរដុប ដែលឥតប៉ោង ឥតផត ឥតខ្ពស់ទាប ឧ. ដីរាប ផ្លូវរាប*



**យក្សជាន់** **ព្រះមាតា**

*ហេតុអ្វីបានជាភ្នំរាពណ៍មកប្រតិស្ឋាននៅក្នុងទីនេះទៅវិញ? ព្រោះភ្នំនេះ ទាក់ទងនឹងឈ្មោះយក្សនៅក្នុងរឿងរាមកេរ្តិ៍ ដែលសព្វថ្ងៃមានសប្បុរសជនមកកសាងប្រាសាទមួយនៅទីនោះ ឈ្មោះថាប្រាសាទភ្នំរាពណ៍។ នៅក្នុងប្រាសាទ មានតាំងរូបក្រុងរាពណ៍ឈរជាន់ព្រះមាតាមហានគរ (ដែលសព្វថ្ងៃរូបនោះ គេពន្យល់ថា ព្រះសិវៈរាំជាន់កូនក្មេង. មើលរូប) យក្សទសមុខនេះហើយ ដែលបានចាប់ព្រះម៉ែឃុំឃាំងក្នុងសមុទ្រទឹកដោះ (យក្សក្បាលដប់កាន់ក្បាលនាគ ពន្យល់រួចហើយក្នុងភាគទីមួយ)។ ពាក្យថាព្រហ្មមារ គឺយក្សដែលមានមុខបួនជាន់គ្នាពីរដងស្មើនឹងប្រាំបី ហើយជាន់ខាងលើប្រាំបីនោះ មានមុខពីរទៀតត្រូវជាដប់ ទើបយក្សនេះ មានឈ្មោះថា ទសក័ណ្ឋ ឬទសមុខ។ ក្រុងរាពណ៍នេះ និងសេនារបស់គេតាមឡោមព័ទ្ធចាប់ព្រះម៉ែតាំងពីបឹង**យក្សឡោម** រហូតដល់**ភ្នំដំរីរមៀល** ព្រោះទីនោះ មានកន្លែងមួយនៅពីខាងមុខភ្នំហៅថា **ព្រលានយក្ស** ទើបចាប់បានព្រះម៉ែយកទៅឃុំឃាំងទុកក្នុងសមុទ្រទឹកដោះ (ព្រោះព្រលានយក្សសំរាប់យក្សចុះ ពុំមែនយន្តហោះចុះឡើយ)។*

*បើយើងធ្វើដំណើរចាកចេញពីភ្នំរាពណ៍បន្តិចមក មានភូមិមួយឈ្មោះថា **ភូមិតាប្រាប់** តើតាគាត់ប្រាប់យើងពីរឿងអ្វី? គឺគាត់ប្រាប់ពីរឿងក្រុងរាពណ៍ ចាប់ព្រះម៉ែយកទៅឃុំឃាំងក្នុងសមុទ្រទឹកដោះ ក៏ប៉ុន្តែគ្រាន់តែយើងចេញមកដល់ផ្លូវជាតិភ្លាម មានភូមិមួយទៀតឈ្មោះថា**បាត់ដឹង**។ តើពាក្យ*

*បាត់ដឹងមានន័យថាដូចម្តេច? បានន័យថារឿងព្រះម៉ែធំដូចជាភ្នំ ដែលក្រុងរាពណ៍បានចាប់ម៉ែយកទៅឃុំឃាំង តាគាត់ខំរ៉ាយរ៉ាប់ប្រាប់ដំណើររឿងរបស់ជីដូន ទីបំផុតបណ្តាំនេះ កូននាគដែលជាកូនសម័យក្រោយៗ បានធ្វើឲ្យបាត់ដឹងដំណឹងរបស់ព្រះម៉ែអស់រលីង (លុបដាន បាត់ទី បាត់ដឹង ពុំមែនបាត់ផ្លែដឹងនោះឡើយ)។ ខ្ញុំបាទជាអ្នកស្រាវជ្រាវ គ្រាន់តែចង់បន្ថែមរឿងរ៉ាវខ្លះៗ ដែលទាក់ទងនឹងឈ្មោះភូមិស្រុក ធម្មជាតិ រុក្ខជាតិ ទំនៀមទម្លាប់....... មកផ្គុំ ផ្គុំរឿងដែលហាន់ជាចំណិតៗនោះ កកើតបានជារូបរាងអាចឲ្យមិត្តអ្នកអាន មើលឆាប់យល់នូវសាវតាបណ្តាំព្រះម៉ែនេះ។*

***២២.ភ្នំអង្គារស ឬរាជ្យទ្រព្យ*** *(ខេត្តកណ្តាល)*

*អាថ៌កំបាំងភ្នំនេះ ខ្ញុំបានពន្យល់ពីទំព័រខាងដើមរួចខ្លះហើយ ដើម្បីឲ្យកាន់តែច្បាស់ ខ្ញុំគ្រាន់តែលើកយកនូវហេតុភេទ ដែលកើតមានរួចយកមកពន្យល់បន្ថែម នៅក្នុងអាថ៌កំបាំងភ្នំនេះ តាមឯកសារសាវតាស្រុកបរិបូណ៌ ក្នុងសាវតាទាក់ទងនឹងភូមិសាស្ត្រខ្មែរ ដែលរៀបរៀងដោយលោក* **ឌុ គាម** *គាត់បានសរសេរថា ព្រះច័ន្ទរាជាបានឲ្យគេបោះបន្ទាយទ័ព នៅភ្នំព្រះរាជ្យទ្រព្យ(អង្គារស) ពេលដែលព្រះអង្គគង់នៅភ្នំនោះ ទ្រង់បានទតឃើញ**ពន្លឺកែវមនោ** ដ៏អស្ចារ្យដែលជាបុព្វនិមិត្តរបស់ព្រះម៉ែ។ ប៉ុន្តែស្តេចអង្គនោះ ពុំយល់ពីអត្ថន័យពន្លឺកែវមនោ ដែលផ្សាយចេញពីភ្នំនោះ គាត់ក៏សន្និដ្ឋានថា ជាពន្លឺនៃជ័យជម្នះរបស់ខ្លួនទៅវិញ ប៉ុន្តែតាមពិតព្រះម៉ែគាត់ខំសម្តែងឫទ្ធិ ដើម្បីឲ្យកូនជាស្តេចដឹងថា គាត់នៅជាប់ឃុំឃាំងក្នុងភ្នំនេះ។ អភូតហេតុដែលកើតឡើងនេះហើយ បានធ្វើឲ្យកូនខ្មែរនិយាយតៗគ្នាពីមាត់មួយទៅមាត់មួយ ទីបំផុត បានឮដល់ពួកបរទេស ដែលគេខំស្រាវជ្រាវរកបង្កើយនេះ ដើម្បីបិទសន្ធប់ជាយូរយារមកហើយ។ ទើបកាលជាខាងក្រោយ ពួកគេមកសុំសាងពុទ្ធបដិមាមួយអង្គ មានកំពស់១៨ហត្ថព្រះសុគត សន្ធប់បិទរូងភ្នំនោះ ទើបមានឈ្មោះថ្មីថាភ្នំអង្គារស (ហៅតាមកំពស់ពុទ្ធបដិមា)។ ហេតុអ្វីបានជាព្រះម៉ែខំបញ្ចេញពន្លឺឲ្យកូនឃើញ? ហេតុតែចង់ឲ្យកូនជួយគាត់ ព្រោះស្តេចជាអ្នកទទួលមរតកគាត់ បានមកបោះទីតាំងនៅភ្នំនេះ ដោយគាត់សង្ឃឹមថាកូនគាត់នឹងដឹងហើយជួយ ព្រោះគាត់ចេញពុំរួច ប៉ុន្តែមិនដូច្នោះទេ ស្តេចបែរជាយល់ថា ជាពន្លឺនៃជោគជ័យរបស់ខ្លួនទៅវិញ។ រឿងរ៉ាវអភូតហេតុនិមិត្តនេះ បានកើតមានម្តងទៀត នៅពេលដែលស្តេចអង្គនោះ ប្រទានរង្វាន់យសសក្តិដល់ខ្ញុំរាជ*

ការ ដែលបានជួយធ្វើសង្គ្រាមឲ្យព្រះអង្គ។ ពេលនោះ បានបង្កើតឲ្យមានហេតុចម្លែកអស្ចារ្យ គឺថ្ងៃរះចែងចាំងពុំមានភ្លៀង ប៉ុន្តែមានឥន្ទធនូចុះនៅក្នុងទីនោះ មានរស្មីភ្លឺរន្ទាលច្រាលដាលច្រវ៉ាត់ លុះតែងតាំងមន្ត្រីរាជការហើយ ពន្លឺឥន្ទធនូនោះ ក៏រលាយបាត់ទៅវិញ។ រឿងហេតុភេទនេះ កើតមានក្នុងខេត្តអម្រាក់តិរិន្ទបូណ៌ ពេលនោះ ព្រះរាជាក៏បានកែឈ្មោះខេត្តនោះ ដាក់ថាខេត្តបរិបូណ៌វិញ ទៅតាមហេតុភេទនិមិត្តនោះ សព្វថ្ងៃខេត្តនោះហៅថាស្រុកបរិបូណ៌ ក្នុងខេត្តកំពង់ឆ្នាំង។



**ភ្នំអដ្ឋរស មើលពីលើរាងដូចពស់**

ឯរូបរាងភ្នំអដ្ឋារស មើលពីខាងលើ ដូចជាសត្វពស់ ឬនាគបើកពពារ ដែលបែរក្បាលទៅរកពុទ្ធមណ្ឌលវិបស្សនា ឯកន្ទុយនាគនៅម្តុំព្រះវិហារអដ្ឋារស ដែលគេបិទសន្ធប់ពីសម័យមុននោះ។ រូបភាពភ្នំអដ្ឋារសមើលពីខាងលើនេះ មាននៅក្នុងឯកសារ (ខ្ញុំចង់ដឹងពីជនជាតិខ្មែរភាគពីរ និពន្ធដោយលោក Paul Brunon និងស៊ុនហេង ម៉េងឈាង) ហើយរឿងព្រេងដែលទាក់ទងនឹងភ្នំនេះ កូននាគទាំងឡាយសូមអ្នកស្រាវជ្រាវរកមើលក្នុងប្រជុំរឿងព្រេងខ្មែរ រួចត្រិះរិះពិចារណាជាបន្ថែមទៀតចុះ។

## ២៣.ភ្នំនាងកង្រី (ខេត្តកំពង់ឆ្នាំង)

ភ្នំនេះខ្ញុំបាទជាអ្នកស្រាវជ្រាវពុំបានទៅដល់ទីនោះឡើយ គ្រាន់តែឈរសម្លឹងមើលពីចំងាយតែប៉ុណ្ណោះ យើងដឹងហើយថា ភ្នំនេះឈ្មោះកង្រី ហើយនាងកង្រីនេះ គឺជាកូនយក្សឈ្មោះនាងសន្ធមារ។ យក្សសន្ធមារនេះហើយ ដែលបានខ្វេះយកគ្រាប់កែវភ្នែកមាតាទាំង១២ រួចផ្ញើរកែវភ្នែកមាតាទាំង១២នេះ ទៅឲ្យកង្រីជាកូនអ្នកថែរក្សាទុក។ រឿងរ៉ាវទាំងអស់នេះ ដែលកើតឡើងតៗគ្នា ពីមួយជំនាន់ទៅមួយជំនាន់ ធ្វើឲ្យកកើតផ្តុំពូនបានទៅជាភ្នំ(ភ្នំនាងកង្រី) ហើយយើងអាចដឹងរឿងព្រះម៉ែមហានគរ និងរឿងមាតាទាំង១២ លុះត្រាតែបានកែវភ្នែក គឺបញ្ញា ដែលនាងកង្រីបានលាក់ទុកនោះ មកបញ្ចូលឲ្យពួកគាត់វិញទើបភ្លឺ នេះជាបណ្តាំប្រស្នារបស់គាត់។ ហើយអាថ៌កំបាំងរបស់រឿងនេះ មាននៅក្នុងល្បែងក្មេងលេងមួយ គឺល្បែង**បាយខុំ ឬបាយខុន** ព្រោះល្បែងបាយខុំមុននឹងលេង គេត្រូវជីកគ្រលុកដូចជា

គ្រលុកគ្រាប់ភ្នែក ដែលត្រូវគេខ្វេះ រួចយកគ្រាប់មូល តំណាងឲ្យគ្រាប់ភ្នែកមាតាទាំង១២ ទៅដាក់ក្នុងរន្ធនោះ ទើបគេនាំគ្នាខ្វេះយកគ្រាប់នោះ ចេញមកវិញ(នេះជាប្រស្នា ទាក់ទងនឹងរឿងគ្រាប់ភ្នែកមាតាទាំង១២ ដែលយក្សខ្វេះយក)។ ចំណែកឯមរតកជាចំណងដៃវិញ ក្នុងពិធីមង្គលការ ដូនតា និងមាតាបិតាខ្មែរ រួមទាំងសាច់សាលោហិត បានទុកប្រស្នានេះ ក្នុង**បទបាយខុន** ឬខុំក្នុងពិធីចងដៃកូនប្រុសស្រី ដោយពួកគាត់ចង់ប្រាប់ថា យើងជាពូជនាគចងដៃបន្តគ្នា ឬកាន់ដៃតគ្នា ក្នុងភាពងងឹត (ដែលយក្សខ្វេះកែវភ្នែក គឺបញ្ញា) ហើយបញ្ចប់ចុងក្រោយ គឺលុបដាន សាដាន លក់ដាន (បទលុបដាន មូរកន្ទេល លក់កន្ទេល ក្នុងពិធីព្រះថោងតោងស្បៃនាងនាគ)។

## ២៤.**ភ្នំដូនពេញ** (ភ្នំពេញ)

ប្រវត្តិទាក់ទងនឹងទីក្រុងភ្នំពេញ កើតចេញពីរឿងរ៉ាវរបស់ម្ចាស់ភ្នំដំបូង គឺដូនពេញ ចំណែកពាក្យថាពេញ គឺវាផ្ទុយគ្នាពីកន្លះ ពីមុនទីក្រុងភ្នំពេញ មិនមានមនុស្សរស់នៅច្រើនដូចសព្វថ្ងៃនេះទេ។ ប៉ុន្តែក្នុងបច្ចុប្បន្នពាក្យភ្នំពេញនេះ ពិតជាត្រឹមត្រូវតាមឈ្មោះ ហើយមិនត្រឹមតែពេញទេ គឺហៀរហូរហូរហូតមកខាងក្រៅក្រុង ខុសពីជំនាន់អតីតកាល សូម្បីតែបឹងដែលពុំធ្លាប់មានមនុស្សរស់នៅ ឥឡូវក្លាយជាគេហដ្ឋានស្កឹមស្កៃ ហើយច្រើនស្អេកស្កះ។ បើយើងក្រឡេកមើលអតីតប្រវត្តិរបស់ភ្នំនេះ គឺជាស្ត្រីម្នាក់ឈ្មោះពេញជាអ្នកផ្តើមដំបូង ដែលសព្វថ្ងៃគាត់បានក្លាយទៅជាជីដូន ឬដូនពេញ ហើយជីដូននេះ គាត់ជាអ្នកបានទទួលមរតក ពីព្រះម៉ែមហានគរ ពេលណាភ្នំនេះពេញតាមឈ្មោះ ពេលនោះព្រះម៉ែ នឹងរួចផុតពីទុក្ខទោសពីអតីត។

ការរៀបរាប់អំពីឈ្មោះភ្នំ ទោះបីជាខ្ញុំបាទពុំបានលើកយកមកពន្យល់ឲ្យបានគ្រប់ភ្នំ ក៏ឯកសារសោវតានេះ ជាប្រទីបមួយសម្រាប់ឲ្យកូននាគប្រុសស្រី ដែលបានតាមដានអាន ទុកធ្វើជាទុនសំរាប់ត្រិះរិះគិតពិចារណាស្វែងយល់ ទៅលើអ្វីដែលទាក់ទងក្នុងបណ្តាំរឿងអាថ៌កំបាំងរបស់ព្រះម៉ែ។ គាត់ខំបំពេញពលិកម្មគ្រប់បែបយ៉ាង ដើម្បីកូននាគប្រុសស្រី ដែលរស់ក្នុងមាតុភូមិរបស់គាត់នេះ ដូច្នេះសូមឲ្យគុណព្រះមាតាបិតា ដែលធំដូចស្តេចភ្នំ ចូលទៅស្ថិតក្នុងសន្តានចិត្តកូននាគប្រុសស្រីគ្រប់ស្រទាប់វណ្ណៈ ជាពិសេស គឺអាថ៌កំបាំងបណ្តាំរបស់ព្រះម៉ែមហានគរនេះ។ កូននាគទាំងឡាយ ពេលនេះអ្នកដឹង

ពី**សារជាតិ**ខ្មែរជាពូជនាគហើយ ពីមុនយើងពុំបានចាប់អារម្មណ៍ឡើយ ព្រោះយើងគិតថាពូជនាគស្ថិតនៅប្រទេសផ្សេងឯណោះ តាមពិត គឺកូនខ្មែរប្រុសស្រីនេះឯង ដែលជាពូជព្រះនាងនាគពូជអ្នកប្រសើរ ពូជអ្នកកសាងប្រាសាទថ្ម ពូជចក្រភព ហើយចុងក្រោយ គឺជា**ពូជអច្ឆរិយៈ សូមកូននាគរួបរួមគ្នាជួយអាធិទេពអ្នកបង្កើតភាពអច្ឆរិយៈ ឥអច្ឆរាមាតាមហានគរ។**

**IV.** ខ្ញុំនឹងលើកយកឈ្មោះរបស់បឹង ធម្មជាតិ ភូមិស្រុក.... ដែលមានទាក់ទង នឹងរឿងរបស់ព្រះម៉ែ មកបកស្រាយបំភ្លឺ ដើម្បីទុកជាទុនសំរាប់ត្រិះរិះពិចារណា រាវរករឿងពិតរបស់ខ្លួនជាបន្តទៅទៀត។

ក.**បឹងប្រស្នា** (ខេត្តព្រៃវែង)

បឹងប្រស្នានេះ បានប្រតិស្ឋានទុកក្នុងភូមិប្រស្នាធំ (ទីកើតនូវប្រស្នាធំ) ឃុំសេនារាជឧត្តម ស្រុកព្រះស្តេច ខេត្តព្រៃវែងដែលទឹកដីនេះ ពីអតីតកាលជារាជធានីចាស់របស់ចក្រភពខ្មែរបាភ្នំ។ ចុះហេតុអ្វីបានជាដូនតាយើង ដាក់ឈ្មោះថាបឹងប្រស្នា? ខ្ញុំបានពន្យល់ត្រួសៗតាំងពីភាគទី១ រហូតមកទល់នឹងពេលនេះ គឺទាក់ទងនឹងរឿងបណ្តាំប្រស្នារបស់ព្រះម៉ែ ហើយរឿងប្រស្នានេះ យើងពុំបានដឹងទីតាំងរបស់ឈ្មោះនោះត្រង់ណាឡើយ។ ទើបតែថ្ងៃ៨កើត ខែពិសាខ ឆ្នាំរកា ព.ស ២៥៤៩ ត្រូវនឹងថ្ងៃទី១៥ ខែឧសភា គ.ស២០០៥ នៅក្នុង**ភូមិប្រស្នាធំ**នេះប្រជាជននាំគ្នាស្តារបឹងដែលរាក់ឲ្យជ្រៅឡើងវិញ ដើម្បីតម្កល់ទឹកទុកប្រើប្រាស់នៅរដូវប្រាំង ដោយប្រើប្រាស់អង្គរពលកម្ម។ ពេលនោះពួកគាត់ ជីកបានរូបចម្លាក់ថ្មព្រះវិស្ណុផ្ទុំលើនាគ ហើយគងលើស្ត្រីជាព្រះម៉ែ ដែលនៅកណ្តាលផ្ចិតរូប មានផ្កាឈូកមួយទងរីកទ្រព្រះព្រហ្មកំពុងអង្គុយសមាធិ (រឿងព្រះវិស្ណុដេកនេះខ្ញុំបានពន្យល់ក្នុងទំព័រខាងដើមខ្លះហើយ) តើបឹងប្រស្នានៅទីនោះមានប៉ុន្មាន? បឹងប្រស្នានៅទីនោះ មានបី គឺបឹងប្រស្នាតូចពីរ និងបឹងប្រស្នាធំមួយ។



**ចម្លាក់វិស្ណុផ្ទុំនៅបឹងប្រស្នា**

១.បឹងប្រស្នាទីមួយ គឺជាបឹងតូចល្មម ដែលសព្វថ្ងៃមានដុះប្រលិតតូចធំ និងវារីជាតិផ្សេងៗទៀតជាច្រើន បឹងនេះទាក់ទងទៅនឹងរឿងមង្គលបី សិរីបីប្រការក្នុងបឹងទី១ ទាក់ទងមង្គលទី១ ឬសិរីទី១

២.បឹងប្រស្នាទីពីរមានទំហំប្រហាក់ប្រហែលនឹងបឹងប្រស្នាទីមួយដែរ តែបឹងនេះ មានទីតាំងនៅរៀងបន្ទាប់គ្នា អត្ថន័យរបស់បឹង គឺទាក់ទងនឹងមង្គលទី២ ឬសិរីទី២។

៣.បឹងប្រស្នាទីបី គឺជាបឹងធំជាងបឹងតូចទាំងពីរ ដែលប្រជាជនក្នុងភូមិនោះ បានទៅជីកស្ដារ ហើយគាស់បានរូបព្រះវិស្ណុដេកនោះ ដែលរូបនោះកប់នៅចំកណ្ដាលផ្ចិតបឹង នៅទីនោះមានគល់គ្រាក់មួយដើម ដែលបានកប់ជ្រៅទៅក្នុងដីមិនដឹងមានជម្រៅប៉ុន្មានដែលសព្វថ្ងៃនេះ មិនទាន់មានអ្នកណាហ៊ានទៅគាស់គល់គ្រាក់នោះឡើយ (គ្រាក់លុប ➜ គ្រប់លាក់)។ បឹងនេះ ទាក់ទងនឹងមង្គលទី៣ ឬសិរីទី៣ ហើយរឿងទាំងអស់នេះ បានលាក់កំបាំងយ៉ាងស្ងាត់ស្ងៀម សូម្បីតែប្រជាជនដែលរស់នៅក្នុងភូមិនោះ ក៏ពុំដឹងរឿងដែលទាក់ទងនឹងឈ្មោះបឹងប្រស្នានេះឡើយ។ ពាក្យបឹងប្រស្នានេះ ជាពាក្យមានជំរៅ បើគ្រាន់តែឮ គឺពុំអាចចាប់អារម្មណ៍នឹងពាក្យនេះឡើយ ព្រោះយើងពុំនឹកស្មានថា ពួកគាត់បានបង្កប់នៅក្នុងឈ្មោះ ហើយឈ្មោះដដែលនេះ ដែលយើងអាចយល់ និងស្គាល់ក៏ដោយសារគាត់បានរូបព្រះវិស្ណុផ្ទុំនៅទីនោះ បើមិនដូច្នោះ គឺខ្ញុំបាទពុំអាចស្គាល់ភូមិ.បឹងប្រស្នា ដែលជាឬសគល់ដើមនៃអាថ៌កំបាំងខ្មែរនេះបានឡើយ ព្រោះពួកគាត់បន្សល់ទុកឈ្មោះនេះ សម្រាប់ឲ្យយើងជាកូននាគឆ្ងល់ រួចធ្វើការស្រាវជ្រាវរករឿងពិត ដើម្បីដោះប្រស្នារបស់គាត់។

រូបព្រះវិស្ណុនោះ គេឆ្លាក់រាងជាផ្ទាំងសំប៉ែត ហើយគេធ្វើដុំថ្មបីជាន់ ដែលមានជន្លួញត្រណាប់ស៊កបន្តគ្នា ដែលជាន់ទីបីខាងលើ គឺជាផ្ទាំងរូបចម្លាក់បានន័យថា ថ្មពីរផ្ទាំងខាងក្រោមប៉ុនគ្នា ឯផ្ទាំងទីបីដែលមានរូបចម្លាក់ស្ដើងជាង ព្រោះត្រូវយកទៅស៊ក នៅលើជើងទម្រទាំងពីរ។ ក្នុងដុំថ្មទាំងពីរដែលជាទម្រនោះ នៅបាតបន្ទាប់មានដាក់កថាមាសចំនួនច្រើនសន្លឹក(មាសផ្កាកប្បាស) ហើយក្នុងកថានីមួយៗមានឆ្លាក់រូបផ្សេងៗគ្នា កថាទីមួយមានរូបនាគកំពុងហែលឡើងទៅលើ រូបនាគនេះមានឆ្លាក់នៅលើបាំងខ្លែងប្រាសាទបន្ទាយស្រី កថាសន្លឹកទីពីរមានរូបអណ្ដើក ដែលទាក់ទងនៅក្នុងរឿង កូរសមុទ្រទឹកដោះស្វែងរកទឹកអម្រឹត សន្លឹកកថាទីបីមានរូបផ្កាឈូករីក រូបនេះឃើញមាននៅក្នុងដៃស្ត្រីគ្រប់លក្ខ័

ណា និងរូបឆ្នាំនៅលើជញ្ជាំងប្រាសាទបន្ទាយស្រី សន្លឹកកថាទីបួនមានរូបត្រី រូបត្រីនេះ មាននៅក្នុងរឿងកូរសមុទ្រទឹកដោះ និងសង្គ្រាមជាមួយចម្ប៉ានៅបាយ័ន ចំណែកឯសន្លឹកកថាដទៃទៀត ខ្ញុំពុំបានឃើញឡើយ ដោយពួកគាត់បានយកទៅរំលាយ ស្មានថាជាមាសទឹកដប់ ព្រោះ ដូនតាខ្មែរពីសម័យដើមគាត់ពូកែឲ្យទឹកមាសណាស់។ រឿងរូបក្នុងកថាមាស ដែលបង្កប់នៅក្នុងត្រណាប់ថ្មទម្រ គឺជារឿងប្រស្នាអាថ៌កំបាំង ដែលខ្ញុំបានរៀបរាប់ជាហូរហែក្នុងឯកសារសាវតានេះ ដែលទាក់ទងរូបព្រះវិស្ណុដឹកព្រះម៉ែចេញ ហើយរូបនេះ តែងតែមានឆ្លាក់នៅគ្រប់ទីកន្លែងនៃប្រាសាទ និងមានច្រើនបំផុតនៅបាតស្ទឹងភ្នំគូលែន ត្រង់លិង្គ១០០០។

ផ្លូវចូលទៅកាន់បឹងប្រស្នានោះមានផ្លូវពីរ មួយចូលតាមវត្តគោកសំពៅ ឬសំពៅគោក ឯផ្លូវទីពីរចូលតាមផ្លូវប្រមូលព្រហ្ម តើប្រមូលព្រហ្មមានន័យយ៉ាងដូចម្ដេច? អាចដោះប្រស្នាភូមិបឹងទាំងនោះបាន ត្រូវប្រមូលព្រហ្ម ដែលបែកខ្ញែកឲ្យមូលគ្រប់ទាំងបួនវិញ ទើបអាចបំបែកប្រស្នានេះបាន។ តើភូមិតំណាងឲ្យអ្វី? ភូមិតំណាងឲ្យទីកើត ទីប្រសូតនៃពាក្យប្រស្នានេះ តើបឹងតំណាងអ្វី? បឹងតំណាងឲ្យសមុទ្រទឹកដោះ ឬទីឃុំឃាំង ដែលគេបានចាប់ព្រះម៉ែយកទៅឃុំទុករាប់ពាន់ឆ្នាំនោះ គាត់ពុំមែនត្រឹមតែនៅក្នុងទឹកប៉ុណ្ណោះទេ គឺថែមទាំងកប់ក្នុងភក់ថែមទៀត (ថ្មភក់ ឬភក់ថ្ម) ដែលរូបនេះ មានក្នុងក្បាំងក្លែងប្រាសាទបន្ទាយស្រី។ នៅភ្នំគូលែនមានព្រៃមួយឈ្មោះថា ព្រៃទេវតានៅក្នុងព្រៃនោះ ដូនតាគាត់បានឆ្លាក់រូបព្រះវិស្ណុធំដឹកព្រះម៉ែចេញ តើអ្នកដឹងពីអត្ថន័យ ពាក្យព្រៃទេវតា និងរូបព្រះវិស្ណុធំនេះទេ?

ខ.ព្រៃទេវតាមានន័យថា សមាជិកសមាជិកាគណបក្សដែលមាននិមិត្តរូបទេវតា តំណាងឲ្យគណបក្សប្រជាជន ដែលមានចំនួនសមាជិកច្រើននោះគឺព្រៃមនុស្ស ពាក្យនេះគេច្រើនប្រើក្នុងសម័យប៉ុលពតឬសម័យតស៊ូប្រឆាំងនឹងបរទេស ព្រោះលាក់ខ្លួនក្នុងព្រៃធម្មជាតិ ពុំជិតដូចលាក់ក្នុងព្រៃមនុស្សឡើយព្រៃមនុស្ស គឺព្រៃប្រជាជននោះឯង។ ដូចនៅក្នុងក្បួនពុទ្ធទំនាយបានសរសេរថា ដល់ពេលដែលស្ដេចមានឫទ្ធិអាចប្រើភ្លើង ប្រើទឹក ប្រើខ្យល់ ប្រើខ្មោចបាន ពេលនោះនឹងមានចោរឃ្មួញចេញពីព្រៃ។ ក្នុងន័យនេះគាត់ចង់ប្រាប់ថា ចោរលួចចោរប្លន់ គឺចេញពីព្រៃមនុស្សនេះឯងគឺប្រជារាស្ត្រ ពុំមែនចេញពីព្រៃភ្នំធម្មជាតិនោះទេ ព្រោះពាក្យនេះជាពាក្យប្រស្នាបំប្លែងរបស់ដូនតា។ ហេតុអ្វីបានជាមានរូបព្រះវិស្ណុធំ នៅក្នុងព្រៃទេវតា? ន័យបំប្លែងពាក្យរបស់ដូនតាគាត់ចង់ពន្យល់ថា ព្រះវិស្ណុដេកនៅក្នុងព្រៃទេវ

តា គឺនៅក្នុងព្រៃមនុស្សរបស់គណបក្សប្រជាជន ដែលមានរូបទេវតាជានិមិត្ត។ គាត់លាក់ខ្លួនក្នុងព្រៃទេវតាដើម្បីជួយព្រះម៉ែ ដែលជាប់ឃុំឃាំងក្នុងសមុទ្រទឹកដោះ(ពន្យល់រួចហើយ) ហើយរូបចម្លាក់នេះ ខ្ញុំបានមើលប៉ះដោយចៃដន្យ នៅក្នុងទស្សនាវដ្ដីបរទេសមួយ ខ្ញុំបាទពុំនឹកស្មានថា ដូនតាខ្មែរគាត់មាននូវ **បុព្វេនិវាសានុស្សតិ** (រលឹកជាតិបាន) ទៅអនាគតដ៏វែងឆ្ងាយដល់ម្លឹង ទើបគាត់ឆ្លាក់រូបក្នុងព្រៃទេវតា (ឈ្មោះជានិមិត្តរូប) ទុកឲ្យយើងឆ្ងល់រួចគិតត្រិះរិះពិចារណាស្រាយប្រស្នារបស់ពួកគាត់។

### គ.កំចាយមារ

ពាក្យកំចាយមារនេះ ជាឈ្មោះរបស់ស្រុកមួយក្នុងខេត្តព្រៃវែង (**ស្រុកកំចាយមារ**) និងជាឈ្មោះរបស់ភ្នំមួយ នៅក្នុងស្រុកកំពង់សិលា ខេត្តព្រះសីហនុគឺ**ភ្នំកំចាយមារ**។ តើពាក្យកំចាយមារមានអត្ថន័យដូចម្ដេច?

**ពន្យល់ពាក្យ** (កំចាយមារ)

កំចាយ =កម្ចាយ = ធ្វើឲ្យខ្ចាត់ខ្ចាយ

កំចាយមារ ឬកម្ចាយមារ= គឺធ្វើឲ្យមារឬយក្សក្រុងរាពណ៍នោះបែកខ្ចាត់ខ្ចាយអស់

ហើយមារនេះឯងដែលជាម្ចាស់នៃពៀរបានចាប់ព្រះម៉ែមហានគរ យកទៅឃុំឃាំងទុករាប់ពាន់ឆ្នាំក្នុងសមុទ្រទឹកដោះរហូតរឿងរបស់គាត់ពូនបានទៅជាភ្នំហើយអ្នកព្យាយាមកំចាយមារដើម្បីជួយព្រះម៉ែសេចក្ដីព្យាយាមរបស់គាត់ក៏ពូនទៅជាភ្នំដែរ សព្វថ្ងៃភ្នំនេះនៅជាប់ក្នុងជួរភ្នំបូកគោ។ ហេតុអ្វីបានជាស្រុកកំចាយមារ នៅក្នុងខេត្តព្រៃវែង? ព្រោះអំណាចរបស់ក្រុងមារបានពូនទៅជាភ្នំ ចង់កំចាយនូវមារនោះដើម្បីជួយព្រះម៉ែ កូននាគនោះត្រូវសម្ងំលាក់ខ្លួនក្នុងព្រៃមនុស្សដ៏វែងដើម្បីប្រយុទ្ធតតាំងនឹងមារ(ព្រៃវែង)ព្រោះមារបានចាប់ម្ដាយឃុំទុករាប់ពាន់ឆ្នាំហើយនេះខ្ញុំគ្រាន់តែបកស្រាយពាក្យបំភ័ន្តរបស់ដូនតា ដើម្បីរាវរករឿងពិតរបស់ព្រះម៉ែតែប៉ុណ្ណោះ សូមមិត្តអ្នកអានជួយពិចារណានូវឈ្មោះទាំងអស់ ដែលដូនតាបានបន្សល់ទុកឲ្យយើងជាកូននាគកំពុងរស់នៅសព្វថ្ងៃ ឲ្យជួយស្រាយប្រស្នាពួកគាត់។

ឃ. ក្របៅ

ក្របៅនេះ ក៏ជាឈ្មោះសំគាល់ភូមិស្រុកមួយ នៅក្នុងខេត្តព្រៃវែង តើពាក្យក្របៅនេះ មានន័យពិតយ៉ាងដូចម្តេច?

**ពន្យល់ពាក្យ** (ក្របៅ)

ក្របៅ = ឈ្មោះផ្លែឈើមួយប្រភេទដែលអាចបរិភោគបាន

ក្របៅ = ដុំម្សៅដែលសម្រាប់ធ្វើនំបញ្ចុកដែលគេលញ់ផ្តុំជាដុំៗ បម្រុងនឹងស្ងោរ(ក្របៅនំបញ្ចុក)

ក្របៅ = មិនងាយបៅ(កូនកើតមក វាក្របៅដោះម៉ែ)

បើកូននាគប្រុសស្រី ដែលជាអ្នកទទួលមរតកព្រះម៉ែពុំព្រមនាំគ្នាបៅដោះព្រះម៉ែទេ(ហូបបាយដឹងគុណព្រះមេ) តើពេលណាទើបស្គាល់ព្រះម៉ែជាម្ចាស់ដោះ? ដូច្នេះយើងជាកូនខ្មែរប្រុសស្រី បានត្រឹមតែរស់ក្នុងភូមិព្រះម៉ែ បានទទួលកេរពីព្រះម៉ែ តែពុំស្គាល់គាត់ដែលជាម្ចាស់ដោះនោះឡើយ ហើយមិនត្រឹមតែប៉ុណ្ណឹងទេ កូនខ្លះហ៊ានជេរប្រមាថមាក់ងាយដល់ម្ចាស់ដោះនេះថែមទៀតផង។ ឈ្មោះភូមិស្រុក ភ្នំ ធម្មជាតិ ប្រពៃណី ទំនៀមទម្លាប់... តែងរស់នៅជាមួយនឹងយើងរាល់ថ្ងៃ យើងក៏មិននឹកស្មានថា មរតកទាំងនេះបានបង្កប់នូវបណ្តាំប្រស្នាព្រះម៉ែដ៏មានជម្រៅយ៉ាងនេះឡើយ។

## V. ១. បុណ្យអុំទូក លយប្រទីប សំពះព្រះខែ អកអំបុក (អំបុក)

មានពិធីបុណ្យមួយទៀត ដែលទាក់ទងនឹងរឿងក្នុងប្រស្នាព្រះម៉ែនេះដែរ គឺបុណ្យអុំទូក លយប្រទីប សំពះព្រះខែ អកអំបុក តើកូននាគទាំងឡាយអ្នកមានឆ្ងល់ដែរឬទេ? ហេតុអ្វីបានជាគាត់ សន្មត់យកថ្ងៃពេញបូណ៌មីខែកត្តិកធ្វើពិធីបុណ្យនេះ? ហេតុអ្វីបានជាដូនតាយើង ធ្វើខុសពីថ្ងៃសែនលោកខែចិន? នេះហើយជាប្រស្នា ដែលដូនតាយើងបន្សល់ទុកមក ហើយខ្ញុំបាទអ្នកស្រាវជ្រាវចេះតែមានចម្ងល់ដើម្បីជួយរាវរកអាថ៌កំបាំងក្នុងបុណ្យនេះ តើគាត់មានបង្កប់ន័យប្រស្នាអ្វីខ្លះ? ដូនតាយើងគាត់បានខ្ចី

សម្លេកបំពាក់ គឺសំពត់ព្រហ្មញ្ញសាសនា និងអាវព្រះពុទ្ធសាសនា (ទាំងពីរនិកាយ) មកលាក់បិទបាំងរូបរឿងពិតរបស់ខ្លួន (ព្រះម៉ែមហានគរ)។

***ពន្យល់ពាក្យ*** *(កត្តិក)*

*កត្តិក= ឈ្មោះខែទី១២ តាមចន្ទគតិ*

*ឫក្សកត្តិកា = មាន៣០ (ថ្ងៃផ្កាយកូនមាន់)*

*តើខែកត្តិកមានបង្កប់ន័យអ្វីទុកនៅក្នុងពិធីបុណ្យទាំងនេះ?*

***ក.អកអំបុក***

*ក្នុងរាត្រីនៃថ្ងៃពេញបូណ៌មី ខែកត្តិក សម័យពីដើមទាំងស្រីទាំងប្រុស ទាំងចាស់ទាំងក្មេង បាននាំយកនំនែក ស្ករ អំពៅ ដូង.... រួមទាំងអំបែង ត្បាល់ អង្រែ និងឧបករណ៍ផ្សេងៗទៀត ទៅជួបជុំគ្នានៅក្នុងទីវត្តអារាម។ ពេលជួបជុំគ្នាហើយពួកគេចាប់ផ្ដើមលីងស្រូវ រួចបុករែងទៅតាមជំនាញរបស់ពួកគេ ចាស់ៗរៀបចំគ្រឿងសក្ការៈផ្សេងៗ ដើម្បីបូជាគុណព្រះរតនៈត្រៃ និងសម្រាប់ថ្វាយដល់ព្រះពោធិសត្វសសបណ្ឌិត(ទន្សាយ) កាលព្រះបរមគ្រូនៃយើងព្រះអង្គនៅបំពេញបារមីនៅឡើយ។ ដល់វេលាខែពេញពន្លឺ គេចាប់ផ្ដើមនាំគ្នានមស្ការព្រះរតនត្រៃ និងសមាទានសីលទៅតាមឧបនិស្ស័យរួចនាំគ្នាដុតទៀនធូប ដើម្បីផ្សងមើលទឹកភ្លៀងនិងបួងសួងដល់ម្ចាស់ទឹកម្ចាស់ដី និងវត្ថុសក្តិសិទ្ធិ សុំសេចក្តីសុខរៀងៗខ្លួន។ ពិធីអកអំបុកក៏មកដល់ ពួកកំលោះក្រមុំ ដែលមានសេចក្ដីក្លាហាន ឡើងទៅឈរងើយដើម្បីឲ្យគេអក អ្នកណាដែលឈ្នះនឹងបានទទួលនូវរង្វាន់ដែលមានចេក ដូង ស្ករ អំពៅ.... សម្រាប់អ្នកឈ្នះក្នុងការអកនោះ។ ប៉ុន្តែខ្ញុំបាទសុំសួរថា ពេលដែលអ្នកអកងើយមុខទៅលើដើម្បីឲ្យគេយកអំបុកទៅអកនោះ តើពួកគេមានឆ្ងល់ថា ហេតុអ្វីបានជាគេអកអំបុកក្នុងថ្ងៃពេញបូណ៌មី ខែកត្តិកនេះ? ហើយគេមិនធ្វើក្នុងខែដ៏ទៃ? អ្នកអកច្បាស់ជាពុំបានគិតពិចារណានូវអាថ៌កំបាំងនៃបណ្ដាំប្រស្នាព្រះម៉ែនេះឡើយ ព្រោះចិត្តអ្នកអកកំពុងចង់បានរង្វាន់ នៅពេលដែលឈ្នះនេះជា**លោភមូលចិត្ត** របស់បុថុជ្ជន។ ដូនតាយើងគាត់ចង់ប្រាប់ថា បានជាពួកគាត់ទុកនៅទំនៀមទម្លាប់បុណ្យនេះក្នុងខែកត្តិក ព្រោះគាត់*

*ចង់ឲ្យកូននាគទាំងឡាយដែលកំពុងងើយមើលទៅលើក្នុងពេលអកអំបុកនោះ កូននាគមានឆ្ងល់ទេ ផ្កាយកូនមាន់ដែលតំណាងឲ្យខែកត្តិក តើមេរបស់ពួកវា(មេមាន់) បាត់ទៅណាបានជាទុកកូនឲ្យនៅ វញ្ចង់ដូច្នេះ តើគេចាប់មេមាន់យកទៅក្រុងឃុំនៅឯណា? មេនេះគេចាប់ឃុំនៅឯប្រាសាទគុករកា (**គុក ដាក់មាន់**) នៅក្នុងខេត្តកំពង់ធំឯណោះ ចំណែកឯខែពេញបូណ៌មីវិញ គាត់ចង់ប្រាប់យើងថា ពន្លឺខែលើ មេឃភ្លឺចែងចាំងដូចថ្ងៃ រួមទាំងពន្លឺប្រទីប ដែលដុតនៅលើដីថែមទៀត ក៏មិនអាចឲ្យកូននាគមើល ឃើញនូវរឿងពិតរបស់ព្រះម៉ែឡើយ ដោយយើងកើតចេញពីម៉ែទាំង**១២** ដែលយក្សបានខ្វេះកែវភ្នែក គឺបញ្ញាចេញអស់ហើយ តើមានប្រយោជន៍អ្វីចំពោះពន្លឺព្រះច័ន្ទ ក្នុងដួងខែពេញបូណ៌មី និងពន្លឺប្រទីប ដែលដុតនៅលើដី និងបណ្ដែតនៅលើទឹកនោះ។*

## ខ.អុំទូក ឬទូកអុំ

*ហេតុអ្វីពិធីបុណ្យអុំទូកនេះ គេធ្វើតែនៅក្នុងខែកត្តិកនេះដែរ? ខ្ញុំបានពន្យល់ពីទឹកចិត្តម៉ែឪ ដែលបានគ្របដណ្ដប់ទៅលើកូនប្រុសស្រីរួចហើយ តែពេលនេះខ្ញុំចង់ឲ្យកូននាគបានស្គាល់ពីប្រស្នា ក្នុងបុណ្យអុំទូកដែលគេធ្វើក្នុងខែកត្តិកនោះ គឺមានទាក់ទងនឹងទឹកចិត្តម៉ែឪ។ សុភាសិតដែលជាពាក្យប ណ្ដាំរបស់ដូនតាយើង គាត់បានពោលទុកថា ម៉ែឪគិតកូនដូចច្រវាប្រដេញ កូនគិតម៉ែឪវិញ ដូចព្រះបៃរ ក្រោយ ពេលដែលអ្នកទៅមើលបុណ្យអុំទូករាល់ឆ្នាំ តើអ្នកមានបានគិតពិចារណាទេ? ពេលយើងមើ លពីច្រាំងទន្លេទៅ យើងឃើញអ្នកអុំទូក លើកច្រវាឡើងស្រុះគ្នាណាស់ ទើបអាចរុញទូកឲ្យទៅដល់ទី ដៅបាន។ យ៉ាងណាមិញ ទឹកចិត្តរបស់ម៉ែឪក៏ដូចជាច្រវាទូកទាំងនោះដែរ គឺពួកគាត់ស្រុះគ្នាណាស់ អប ស្ងបកូនរុញច្រានកូន គិតគូរកូនសព្វបែបយ៉ាង ទាំងខាងផ្លូវកាយវាចាចិត្ត រុញកូនឲ្យបានទៅដល់ទីដៅ គឺអនាគតរុងរឿងនិងមានសុភមង្គល។ ពួកគាត់ជាច្រវាសុខចិត្តចុះទៅក្នុងទឹក (អបាយភូមិ) ដើម្បីរុញ ច្រានទូកកូន ព្រោះភ័យខ្លាចទូកកូន លិចចុះក្នុងអបាយភូមិ ដូច្នេះហើយពួកគាត់សុខចិត្តធ្វើពលិកម្ម គ្រប់បែបយ៉ាងក្នុងមួយជីវិតរបស់ពួកគាត់ដើម្បីតែកូនប្រុសស្រី។ នេះគឺជា**ព្រហ្មវិហារធម៌** ដែលបាន បង្កប់ជ្រៅទៅក្នុងពិធីបុណ្យអុំទូកនេះ ព្រោះពួកគាត់ពុំធ្វើអ្វីដោយគ្មានបង្កប់ន័យ **បីរួមមួយ** ឡើយ នេះ ជាចម្លើយស្រាយប្រស្នាក្នុងពិធីបុណ្យនេះ។ កូននាគប្រុសស្រីគិតម៉ែឪវិញ ដូចព្រះបៃរក្រោយ តើមាន*

*ន័យដូចម្ដេច? ពាក្យនេះ សូមកូននាគទាំងឡាយ មើលនៅក្នុង**មហាបរិនិព្វានសូត្រ** អ្នកនឹងយល់ពី ប្រស្នាជូនតាជាពុំខាន ហើយខ្ញុំសូមលើកយកវគ្គនេះមកពន្យល់។ គ្រានោះ ព្រះដ៏មានព្រះភាគ ស្ដេច យាងទៅកាន់ក្រុងវេសាលី ក្នុងបុព្វណ្ហសម័យដើម្បីបិណ្ឌបាត លុះស្ដេចយាងត្រឡប់មកវិញ **ទ្រង់ងាក ព្រះភ័ក្ត្រមើលក្រុងវេសាលី ប្រៀបបីដូចដំរីហត្ថីនាគ ងាកមើលក្រោយ** ហើយទ្រង់ត្រាស់ និងព្រះអានន្ទ ថា (**ឥទំបច្ឆិមកំទស្សនំអានន្ទ**) ម្នាលអានន្ទ! តថាគតឃើញក្រុងវេសាលីម្ដងនេះ ជាបច្ឆិមទស្សន៍គឺ ឃើញជាចុងក្រោយនិងជាទីបំផុត តើកូននាគណាដែលងាយនឹងបែរងាកទៅក្រោយ មើលឃើញរឿង ទុក្ខវេទនារបស់ព្រះមាតាបិតាម្ចាស់នគរឃ្មុំ ហេតុអ្វីក៏ពួកគាត់ឲ្យកូនសម័យអង្គរកសាងប្រាសាទថ្មរាប់ ពាន់ ឆ្លាក់រឿងរ៉ាវបណ្ដាំរបស់ពួកគាត់? ព្រោះពួកគាត់មានសង្ឃឹមថា អនាគតនឹងមានកូននាគណា មួយ ងាកបែរទៅក្រោយមើលឃើញរឿងពិតរបស់គាត់ជាពុំខាន រួចគេនឹងព្យាយាមជួយគាត់ឲ្យបាន រួចផុត ពីទុក្ខទោសនិងបាបអកុសលទាំងនោះ។*

*អត្ថន័យដែលខ្ញុំបានលើកយកមកពន្យល់នេះ គឺជាសាវតារឿងពិតរបស់ពួកគាត់ដែលបាន លាក់ទុកក្នុងពិធីបុណ្យនេះ សូមកូននាគទាំងប្រុសស្រីអានហើយគិតពិចារណា តើហេតុផលនៃពិធី បុណ្យខាងលើ ដែលខ្ញុំលើកយកមកពន្យល់នេះ សមតាមហេតុផលដែលឬទេ? ហើយបើត្រឹមត្រូវតាម ការពន្យល់បកស្រាយ សូមជួយស្រាវជ្រាវបន្តបន្ថែមរកឲ្យឃើញនូវសេចក្ដីពិតដើម្បីជួយស្រង់ព្រះម៉ែ ព្រះឪមហានគររបស់យើងដែលពួកគាត់រងចាំឲ្យកូននាគសម័យនេះជួយគាត់(គាត់មានសង្ឃឹមតិចតួច ណាស់ចំពោះយើង ព្រោះសម័យនេះជាសម័យបច្ចេកវិជ្ជាទំនើប និងសម្ភារះទំនើប ហើយក៏ជាសម័យ ដែលកូននាគលែងសូវមានជំនឿលើកម្ម និងផល) ។*

*មិត្តអ្នកអានបានដឹងហើយ ពីអត្ថន័យបុណ្យអុំទូក បណ្ដែតប្រទីប អកអំបុក សំពះព្រះខែ ដែល ជូនតាគាត់ធ្វើក្នុងខែកត្តិកនេះ (**ផ្កាយកូនមាន់**) រួចខ្ញុំក៏បានប្រាប់ហើយថាមេមាន់ គេបានចាប់យកទៅ ក្រុងឃុំនៅគុករកា (គុកដាក់មាន់) ហេតុអ្វីបានជាគាត់យកសត្វមាន់មកប្រៀបធៀបនឹងរឿងព្រះម៉ែ មហានគរ? យើងដឹងហើយថា សភាវៈរបស់សត្វមាន់ សត្វជាបាពុំដែលបណ្ដើរកូន ក្រុងកូន ឬការពារ និងរកចំណីឲ្យកូនឡើយ តែបើមេវិញ ទោះបីជាគេក្រុងក្នុងអង្រុត ក៏នៅតែកកាយក្រុកៗហៅកូនមកជុំ ដើម្បីចញ្ចឹមនិងថែរក្សា។ យ៉ាងណាមិញប្រស្នានេះ ផ្កាយកូនមាននៅខាងលើ ចំណែកឯមេមាន់នៅ*

ជាប់គុកខាងក្រោម ក៏នៅតែគិតកូននៅខាងលើ ដូចជាព្រះម៉ែមហានគរសព្វថ្ងៃ ជាប់ឃុំនៅក្នុងសមុទ្ទ ទឹកដោះទៅហើយ ប៉ុន្តែនិមិត្តរូបរបស់គាត់នៅតែមកការពារព័ទ្ធសីមាការពារក្រុងកូនដដែល (ពិធីបង្វិលពពិល) ហើយឈ្មោះផ្កាយកូនមាន់នោះទៀតសោត គឺមានតែស្រុកខ្មែរទេដែលហៅ។ នៅក្នុងខេត្តកំពង់ធំ (កំពង់ទូលាយ) មានលាក់នូវរឿងជាច្រើនរបស់ដូនតាមហានគរយើង ហើយមិនត្រឹមតែប៉ុណ្ណោះទេ ពួកគាត់បានកសាងប្រាសាទគុកច្រើនណាស់ គឺ**គុករកា គុករមាស គុកនគរ សំបូរព្រៃគុក** នេះខ្ញុំអ្នកស្រាវជ្រាវបានដឹង មិនដឹងថាមានប្រាសាទគុកប៉ុន្មានទៀត ដែលខ្ញុំពុំដឹង? ចំណែកនៅក្នុងខេត្តកំពង់ចាម មានប្រាសាទគុកមួយឈ្មោះថា គុកព្រះធាតុ ហេតុអ្វីបានជាគាត់ធ្វើប្រាសាទ ហើយដាក់ឈ្មោះថាគុកច្រើនម្ល៉េះ? តើប្រាសាទគុកទាំងអស់ហ្នឹង សម្រាប់ដាក់អ្នកណា?

ក្នុងឯកសារសាវតាភាគទីមួយក្តី ភាគទីពីរនេះក្តី ខ្ញុំបាទខិតខំប្រមូលនូវបណ្តាំរឿងរ៉ាវទាក់ទងផ្សេងៗ ដែលខ្ញុំបានឆ្លល់រួចសិក្សាស្រាវជ្រាវអស់ពេលដ៏យូរ ដើម្បីរកចម្លើយពិតមួយយកមកវែកញែកបកស្រាយប្រស្នាពន្យល់ដល់កូននាគទាំងឡាយឲ្យឆាប់ងាយយល់។ តែទោះបីជាយ៉ាងនេះក៏ដោយក៏ខ្ញុំជឿជាក់ថា លំបាកនឹងឲ្យកូនខ្មែរទទួលយកបានណាស់ ព្រោះសព្វថ្ងៃជាសម័យ ដែលកូននាគចូលក្នុងរបត់មនោគមវិជ្ជាបែបថ្មី គឺមនោគមបច្ចេកវិជ្ជាទំនើប និងសំភារៈទំនើប។ មនោគមវិជ្ជាថ្មីនេះហើយ ដែលពុំអាចឲ្យបណ្តាំរឿងអច្ឆរិយៈរបស់ព្រះម៉ែមហានគរ ជ្រៀបចូលទៅក្នុងសន្តានចិត្ត កូននាគប្រុសស្រីបានឡើយ កុំថាតែកូននាគប្រយោល សូម្បីកូននាគផ្ទាល់ គឺកូននាគដែលបានបួសរៀននោះក៏លំបាកនឹងទទួលយកដែរ ព្រោះការមិនដឹងនេះ បរទេសបានបកប្រែបំភ័ន្តជាយូរយារណាស់មកហើយ(អត្ថន័យបទសារិកាកែវអើយក្នុងភាគ១)។ ម្យ៉ាងទៀតគ្រឿងស្រវឹង និងគ្រឿងញៀនគ្រប់ប្រភេទ កំពុងតែសណ្តំកូននាគប្រុសស្រី ឲ្យលង់លក់លែងស្គាល់គុណធម៌ ដែលជាធម៌ខ្ពង់ខ្ពស់របស់ពូជនាគ ជាពិសេសគឺព្រហ្មវិហារធម៌ព្រះម៉ែឪដែលជាដំបូល ហើយកូននាគប្រុសស្រីបានជ្រកក្រោមដំបូលនោះគ្រប់ៗជំនាន់ ទីបំផុតយើងពុំបានមើលឃើញ និងដឹងនូវរឿងអច្ឆរិយៈពីអតីតកាលរបស់ម្ចាស់ដំបូលជម្រកនេះ ដែលកើតឡើងដោយសារតែហេតុអ្វីពីដំបូង?

**២.គុករកា** (ខេត្តកំពង់ធំ)

គុកនេះគេធ្វើសម្រាប់ដាក់មាន់ ដែលខ្ញុំបានពន្យល់ត្រួសៗពីរឿងបក្សីចាំក្រុង ឬពិធីបុណ្យអុំទូក អកអំបុក លយប្រទីប និងសំពះព្រះខែ រួចមកហើយ តែពេលនេះ ខ្ញុំចង់លើកយកពាក្យថាព្រះខែ ឬព្រាំចន្ទមកពន្យល់បន្ថែម។ ហេតុអ្វីក៏គាត់មិននិយាយថា សំពះព្រះចន្ទ បែរជានិយាយថាសំពះព្រះខែទៅវិញ?

ពាក្យខែនេះវាទាក់ទងទៅនឹងជម្ងឺមួយបែបរបស់ផ្លែដូង គឺ **ដូងខែស៊ី** ផ្លែដូងពេលណាវាខូច គ្មានទឹកគ្មានសាច់យើងហៅតៗគ្នាថាដូងខែស៊ី តើខែបានមាត់ឯណាមកស៊ីដូង? នេះជាបណ្ដាំប្រស្នាដែលគាត់ទុកឲ្យកូននាគទាំងឡាយឆ្លល់ជាពិសេស គឺកូននាគដែលពុំព្រមចុះទៅក្នុងទ្រូងព្រះម៉ែ ដើម្បីឲ្យយល់ពីទុក្ខវេទនាក្នុងបេះដូងព្រះម៉ែ។ បើកូននាគទាំងនោះ ពុំយល់ពីទឹកចិត្តព្រះម៉ែបានន័យថា បេះដូងកូននាគនេះត្រូវខែស៊ីអស់ហើយព្រោះហេតុអ្វី? គឺក្នុងបេះដូងរបស់កូននាគនោះ គ្មាននូវទឹកចិត្តកតញ្ញូកតវេទីឡើយគឺមានតែរាងផ្លែដូង ហើយគ្មានសាច់និងទឹកគ្រប់គ្រាន់(អាថ៌កំបាំងផ្លែដូងនេះខ្ញុំបានពន្យល់រួចហើយ នៅក្នុងល្បែងចាក់ទឹកដូងភាគ១)។ ពេលនេះខ្ញុំយកតែពាក្យ **ខែ** មកពន្យល់តែប៉ុណ្ណោះដែលគាត់ប្រាប់ថាដូងខែស៊ី គឺមានអត្ថន័យថា ទឹកចិត្តក្នុងបេះដូងកូននាគប្រុសស្រីត្រូវ ខែថ្ងៃ ពេលវេលាស៊ីអស់ហើយ ព្រោះកូនខ្មែរប្រុសស្រីរវល់គិតត្រឹមតែខ្លួន និងក្រុមគ្រួសារខ្លួនក្នុងពេលបច្ចុប្បន្នតែប៉ុណ្ណោះ ពុំបានគិតគុណព្រះម៉ែពីអតីតនិងតទៅអនាគតខាងមុខឡើយ បានន័យថាពុំបានតបស្នងដល់អ្នក **បង្កបង្កើតមាតុប្រទេស** (ព្រះមាតាបិតាមហានគរ)។ ក្នុងពាក្យទំនៀមដដែល មានពាក្យមួយឃ្លាទៀតពោលទុកថា **កូនរាហ៍កន្លង ឬគ្រាសកន្លង** តើពាក្យរាហ៍កន្លងមានអត្ថន័យដូចម្ដេច? យើងដឹងហើយថាពាក្យថ្ងៃរាហ៍ និងខែរាហ៍(សូរ្យគ្រាសនិងចន្ទគ្រាស) គឺ ***រាហូអសុរិន្ទ*** បានបិទបាំងពន្លឺព្រះអាទិត្យ និងព្រះចន្ទមិនអាចឲ្យបញ្ចេញពន្លឺរស្មីបានឡើយ ចំណែកឯកូនដែលត្រូវរាហ៍កន្លងវិញត្រូវបាត់បង់សតិបញ្ញាស្មារតីដែលតំណាងឲ្យពន្លឺរស្មីនោះ។ ព្រោះដូនតាបានទុកសម្រាប់ឲ្យយើងពិចារណាដែលមាននៅក្នុងប្រាសាទ រឿងព្រេង ទំនៀមទំលាប់ ប្រពៃណី ឈ្មោះភូមិស្រុក ភ្នំ ធម្មជាតិ និងទំនាយផ្សេងៗដ៏ច្រើនស្មុគស្មាញ ដើម្បីឲ្យកូនខ្មែរទាំងអស់យល់ពីប្រស្នាអាថ៌កំបាំង ថាតើនរណាជាអ្នកចាប់ព្រះម៉ែយក

ទៅឃុំ នេះជាការបកស្រាយពន្យល់ពីពាក្យពិត របស់កូនរាហ៍កន្លង។ សរុបសេចក្ដីមកការពន្យល់ពីគុករកាក្ដី ពីដូងខែសុីក្ដី និងរាហ៍កន្លងក្ដី គ្រាន់តែជាពន្លឺប្រទីបដ៏តូចមួយ សំរាប់ជ្រោងបំភ្លឺក្នុងទីងងឹត ឲ្យមានពន្លឺអាចមើលឃើញនូវបណ្ដាំប្រស្នាគំនិតរបស់ព្រះម៉ែ ដែលបានបង្កប់ទុកក្នុងពាក្យនិយាយ ក្នុងជីវភាពរស់នៅរាល់ថ្ងៃរបស់កូននាគពីសម័យមុន ចំណែកសព្វថ្ងៃនេះវិញ យើងពុំបានយកពាក្យទាំងនេះមកប្រៀបធៀបដូចពីសម័យមុនទេ ឧ. ដូចពាក្យគាត់ជេរស្ដីកូនពីមុនថា មិនដឹងខ្យល់ ដំបូកខ្នងទូលក្នុងចុងស្រុក ដំណើបលាយខ្សាយ ក្រពើរមិលគុណ រាហ៍ ឬគ្រាសកន្លង.... វាខុសពីសម័យសព្វថ្ងៃ ដែលសីលធម៌សង្គមបានធ្លាក់ចុះ យើងបានយកពាក្យអសុរោះ គឺយកភេទម្ដាយ(យោនី)មកជេរ ហាក់បីដូចជាពួកគាត់គ្មានស្នៀកពាក់សំពត់បិទបាំង ហើយម្ដាយខ្លះទៀតពួកគាត់បានស្លាប់ពុកឆ្អឹងអស់ទៅហើយ ក៏កូនៗនៅតែនាំគ្នាគាស់គាត់យកមកជេរប្រមាថដដែល។



រូបរាហូលេបព្រះគោព្រះកែវ និងក្បូនគម្ពីរ
(ប្រាសាទបន្ទាយឆ្មារ)

## ៣.គុករមាស (ខេត្តកំពង់ធំ)

ក.ប្រាសាទគុករមាសនេះ ក៏នៅក្នុងខេត្តកំពង់ធំដែរ តើមិត្តអ្នកអានមានឆ្ងល់ទេ ហេតុអ្វីបានជារមាសជាប់គុក? ក្នុងរឿងទីមួយ សត្វរមាសនេះជាយានជំនិះដែលមាននិយាយនៅក្នុងរឿងព្រេងបឹងទុំលែង ក្នុងសាច់រឿងបានប្រាប់ថាស្ដេចអង្គនោះ ទៅស្នេហានាងមុខរាហ៍ (រាហូ) ពេលនោះនាងមុខរាហ៍សួរព្រះអង្គថា ស្ដេចយាងមកដោយយានអ្វី? ព្រះរាជាទ្រង់តបថា បងមកដោយសត្វរមាសឥឡូវចងនៅក្រោមដើមក្រសាំង។ ឯរមាសស្ដាប់មិនច្បាស់ឮតែថាក្រសាំង ក៏នឹកតូចចិត្តថាម្ចាស់ខ្លួនហៅថា សត្វក្រសាំងទៅវិញ រួចហើយរមាសខឹងក៏បោលផ្ដាច់ខ្សែចំណងនោះទៅ ពេលដែលដាច់ចំណងនោះ ត្រូវបានហ្មឈ្មោះទុំ ទាញទប់រមាសរួចដើងគាត់ជ្រែងដី ទើបស្ដេចឲ្យទុំជាហ្មលែងខ្សែរមាសនោះទៅ។ ទីកន្លែងដែលទុំបានឈរជ្រែងដីនោះ កើតបានជាបឹងមួយឈ្មោះ **បឹងទុំលែង** ចំណែកឯសត្វរមាសវិញ ស្ដេចបានដាក់បណ្ដាសាដល់សត្វរមាសនោះថា ពូជអាឯងចាប់ពីថ្ងៃនេះទៅ ត្រូវស៊ីតែបន្លា និងផឹកនូវ

ទឹកល្អក់ជាដរាប។ ហេតុនេះហើយ បានជានៅលើខ្នងសត្វរមាសទាំងឡាយ សព្វថ្ងៃនេះមានស្រទាប់លើខ្នង សណ្ឋានដូចជាគេចងអាន (កែប) ស្បែកក៏ក្រហេងក្រហូងជាច្រើនស្រទាប់ ជាទីជ្រកនៅនៃពួកសត្វក្អែបនិងខ្ទួយ ហើយស៊ីតែឈើ ឬវល្លិ៍ណាដែលមានបន្លាជាអាហារ ផឹកតែទឹកល្អក់ ទោះបីទឹកថ្លាក៏វាយកជើងកូរឲ្យល្អក់សិនទើបវាផឹក ព្រោះវាបានត្រូវទោសបណ្ដាសាព្រះមហាក្សត្រតាំងពីពេលនោះឯង (រមាសជាប់ទោសទីមួយ)។

## -រឿងឥសីមាត់ទិព្វ

ចំណែកឯរឿងទីពីរដែលទាក់ទងនឹងសត្វរមាសគឺរឿង **ឥសីមាត់ទិព្វឬព្រះថៅទិព្វវង្ស** រឿងនេះមាននៅក្នុង**ជាតក**នានា ពុំមែននៅក្នុងជាតកដែលមានក្នុងព្រះត្រៃបិដកឡើយ ព្រោះខ្ញុំបានពន្យល់ហើយ ដូនតាខ្មែរបានរំលាយបីឲ្យរួមតែមួយ។ បើចង់ដឹងរឿងរ៉ាវរបស់លោក ទាល់តែរែកពីរចេញដែលជាសំបក (ពុទ្ធសាសនា ព្រហ្មញ្ញសាសនា) ទើបឃើញខ្លឹមខាងក្នុងដែលជារឿងរបស់គាត់ (ផ្លែដាវលាក់ក្នុងស្រោមដាវ) នេះជាបណ្ដាំប្រស្នាដែលពួកគាត់ខ្ចីសំបករបស់គេមកបិទបាំងសាច់រឿងរបស់ខ្លួន។

ក្នុងសាច់រឿងនេះគាត់បានប្រាប់ថា អ្នកនគរនោះបានក្លាយទៅជាថ្ម ដោយត្រូវបណ្ដាសាឥសីមាត់ទិព្វ ព្រោះស្ដេចនគរនេះ បានប្រើឲ្យគេយកដុំថ្មទៅគរពីខាងលើឥសីមាត់ទិព្វ នៅពេលដែលលោកកំពុងចូលក្នុងឈានសមាបត្តិ ក្នុងដែនទីឧទ្យានរបស់ស្ដេចនោះ ស្ដេចអង្គនេះ ប្រើគេឲ្យយកថ្មទៅគរសង្កត់ ក៏ព្រោះតែហៅតាឥសីពុំឆ្លើយ (អ្នកចូលឈានពុំអាចឮសម្លេងអ្នកហៅឡើយ) ទើបកើតជាកំហឹងនេះឡើង។ ពេលលោកតាឥសី មាត់ទិព្វចេញពីឈានសមាបត្តិវិញ ទុក្ខវេទនាក៏កើតមានឡើងជាទម្ងន់ដោយអំណាចថ្មសង្កត់គាត់ លោកក៏បានអធិដ្ឋានថា សូមឲ្យថ្មនេះ(កម្មនេះ) កើតមានចំពោះអ្នកដែលប្រព្រឹត្តចុះ ទីបំផុតអ្នកក្នុងនគរនេះ ដែលចូលរួមប្រព្រឹត្តនូវបាបកម្មនោះ ក៏បានរឹងក្លាយទៅជាថ្មដោយអំណាចឫទ្ធិរបស់ឥសីមាត់ទិព្វ។ លោកតាឥសី លោកមានកូនសិស្សម្នាក់ឈ្មោះ **ព្រះថៅទិព្វវង្ស** សិស្សនេះហើយដែលលោកបានហៅមកផ្ដែផ្ដាំថា **២០០០** ឆ្នាំក្រោយអ្នកនគរនេះ នឹងបានរួចពីបាបកម្ម ហើយអ្នកដែលអាចជួយពួកគេបានគឺមានតែថៅម្នាក់ប៉ុណ្ណោះ។ ថៅអាចមានជីវិតរស់ទៅ

ដល់សម័យនោះបាន លុះតែចៅបានបរិភោគផ្លែឈើទិព្វនៅឯព្រៃហេមពាន្ត ទើបអាចរស់បានទៅដល់ **២០០០**ឆ្នាំក្រោយ ហើយម្ចាស់ក្សត្រីរបស់ស្ដេចអង្គនេះ នឹងបានជាមហេសីរបស់ចៅក្នុងអនាគត នៅពេលរួចពីកម្មពៀរ។ លោកតាផ្ដែផ្ដាំរួច ក៏ឲ្យថ្នាំទិព្វមួយកញ្ចប់ទៅចៅទិព្វវង្សហើយប្រាប់ថា ថ្នាំទិព្វនេះ ពេលដល់គម្រប់ឆ្នាំដែលរួចកម្ម ចៅយកវាទៅលាយនឹងទឹក រួចយកទៅប្រោះរូបចម្លាក់ថ្មទាំងអស់នោះ ថ្មនឹងក្លាយជាព្រះនគរមនុស្សប្រុសស្រីហើយរស់រានមានជីវិតឡើងវិញ។ លោកតាឥសីក៏ចាប់ផ្ដើមបង្រៀនមន្តវិជ្ជាសព្វបែបយ៉ាងដល់សិស្សដើម្បីទុកការពារខ្លួន ព្រោះនៅតាមផ្លូវទៅកាន់ព្រៃហេមពាន្ត មានអមនុស្សកាចៗនៅរាំងតំណើរ ជាពិសេសគឺនៅនឹងដើមឈើទិព្វនោះ ដែលមានយក្សពីរនាក់នៅថែរក្សា គាត់បង្រៀននិងផ្ដែផ្ដាំកូនសិស្សរួចហើយ ឥសីមាត់ទិព្វជាគ្រូក៏បានសុគតទៅ ដោយអំណាចទុក្ខវេទនា ដែលកើតចេញពីភាពគ្រាំគ្រានៃថ្មសង្កត់។ ព្រះចៅទិព្វវង្ស ដែលជាសិស្សបាន រៀបចំបូជាព្រះសពលោកគ្រូ ហើយក៏បានយកធាតុទៅបញ្ចុះក្នុងទីដ៏សមគួរ ទើបដើរចូលទៅក្នុងព្រះនគរ មើលរូបព្រះនាងច័ន្ទរស្មីអនាគតមហេសីដែលបានក្លាយជាថ្ម រួចនិយាយ ម្នាក់ឯងថា **២០០០**ឆ្នាំក្រោយចាំយើងជួបគ្នា។

ព្រះចៅទិព្វវង្សក៏បានចាកចេញពីនគរនោះ ធ្វើដំណើរទៅកាន់ព្រៃភ្នំហេមពាន្ត ដើម្បីស្វែងរកនូវដើមឈើទិព្វតាមបណ្ដាំរបស់លោកគ្រូ នៅតាមផ្លូវព្រះចៅទិព្វវង្សបានជួបតាបសឥសីជាច្រើន ហើយពួកគាត់ទាំងនោះ បានជួយចង្អុលផ្លូវទៅរកដើមឈើទិព្វនោះ។ ពេលដែលបានឃើញដើមឈើទិព្វហើយ ពួកយក្សដែលថែរក្សាដើមឈើនោះ មិនព្រមឲ្យព្រះចៅទិព្វវង្សចូលទៅជិតបេះឡើយ តែដោយអំណាចមន្តរបស់ឥសីមាត់ទិព្វជាគ្រូបាន ធ្វើឲ្យយក្សទាំងពីរដែលនៅរក្សាដើមឈើទិព្វនោះ បាក់បបខ្លបខ្លាចចេស្ដាព្រះ អង្គទីបំផុតព្រះអង្គបានបេះផ្លែឈើទិព្វនោះ មកបរិភោគតាមបណ្ដាំលោកគ្រូ គឺ ១០០ឆ្នាំហូបមួយផ្លែ រហូតដល់គម្រប់២០០០ឆ្នាំ។ ២០០០ឆ្នាំក្រោយ ព្រះចៅទិព្វវង្សបានដឹងថា ដល់ពេលអ្នកនគរទាំងនោះត្រូវអស់បាបកម្មហើយ គាត់ក៏ធ្វើដំណើរទៅនគរនោះដើម្បីប្រោះថ្ម ពេលដែលទៅដល់ពាក់កណ្ដាលផ្លូវ គាត់ស្ទាបរាវរកថ្នាំទិព្វតែមិនឃើញ ទើបដឹងថាថ្នាំទិព្វបាត់ គាត់ក៏ធ្វើដំណើរត្រឡប់មកក្រោយវិញ ដើម្បីរកពួកយក្សសួរនាំ។ ពេលដែលជួបពួកយក្សហើយ ព្រះចៅទិព្វវង្សក៏សាកសួរពីដំណឹងថ្នាំទិព្វរបស់ខ្លួន ពួកគេប្រាប់ថាដោយខឹង នឹងព្រះចៅដណ្ដើមផ្លែឈើទិព្វគេ ទើបពួក

គេនាំគ្នាលួចយកថ្នាំទិព្វនោះទៅបោះចោល នៅក្នុងមហាសមុទ្របាត់ទៅហើយ ពេលចៅដេកលក់។ ហេតុតែសេចក្តីក្រោធខឹង ពេលនោះចម្បាំងក៏កើតឡើងជាថ្មីទៀត ពួកយក្សបានចាញ់ឫទ្ធិព្រះចៅទិព្វវង្ស ក៏ចេះតែនាំគ្នារត់ រហូតមកដល់មុខអាស្រមឥសីអគ្គីនេត្រ ដោយព្រួសរួសន្ធឹកជើងយក្សរត់កក្រើកដី ពេលនោះឥសីអគ្គីនេត្របានបើកភ្នែកទីបី ធ្វើឲ្យពួកយក្សឆេះរលាយអស់ នៅសល់តែព្រះចៅទិព្វវង្សម្នាក់។ ឥសីឆ្ងល់ក៏សួរថា អ្នកឯងជាសិស្សរបស់គ្រូណា ទើបមិនឆេះដោយអំណាចភ្នែកទីបីរបស់យើង ព្រះចៅបានឆ្លើយប្រាប់ថា ខ្ញុំជាកូនសិស្សលោកតាឥសីមាត់ទិព្វ ហើយចៅទិព្វវង្សក៏បានរ៉ាយរ៉ាប់នូវដំណើររឿងជាហូរហែពីដើមរហូតដល់ចប់ ឲ្យលោកតាឥសីអគ្គីនេត្រស្តាប់។ ពេលបានស្តាប់រឿងរបស់ចៅរួច លោកតាបានប្រាប់ទៅចៅទិព្វវង្សថា ថ្នាំទិព្វរបស់ចៅយក្សបានលួច ហើយយកទៅបោះចោលក្នុងមហាសមុទ្រ ពេលនោះមានស្តេចក្រពើមួយមកស៊ីថ្នាំទិព្វនេះ ដោយអំណាចនៃឫទ្ធិរបស់ថ្នាំទិព្វ ធ្វើឲ្យស្តេចក្រពើនោះក្តៅក្រហល់ក្រហាយនៅក្នុងទឹកពុំបានទើបឡើងមកដេកក្រាំងនៅលើគោករហូតក្រោយមកប្រែក្លាយជាសត្វរមាស ឥឡូវតាបានឃាំងសត្វរមាសនោះទុកហើយ។ ដូច្នេះចូរចៅយកសត្វរមាសនេះ ធ្វើជាយានជំនិះជិះទៅប្រោះអ្នកនគរនោះចុះ! ពេលទៅដល់នគរហើយ ចៅត្រូវយកទឹកមាត់របស់រមាសទៅលាយនឹងទឹក ហើយយកទៅប្រោះលើថ្មទាំងនោះ ព្រោះជាតិថ្នាំទិព្វបានរលាយពេញសព្វសាច់ក្នុងខ្លួនរមាសអស់ហើយ។

ពេលដែលព្រះចៅទិព្វវង្សទៅដល់ព្រះនគរនោះ គាត់រកទីតាំងព្រះនគរពុំឃើញឡើយ ដោយរយៈកាលកន្លងអស់២០០០ឆ្នាំ ធ្វើឲ្យព្រះនគរមានព្រៃដុះក្រាស់ឃ្មឹករកមើលទីតាំងពុំយល់ឡើយ ទើបចៅទិព្វវង្សលើកដៃអធិដ្ឋាននឹកដល់គុណបុណ្យបារមីរបស់លោកតាឥសីមាត់ទិព្វជាគ្រូឲ្យជួយ ទីបំផុតព្រៃនោះ ក៏ក្លាយទៅជាព្រះនគរដូចពីដើមវិញ។ រួចហើយ ចៅទិព្វវង្សក៏ផ្តិតយកទឹកមាត់រមាសមកលាយជាមួយទឹកដើរប្រោះរូបចម្លាក់ថ្ម ហើយរូបទាំងអស់នោះក៏បានប្រែក្លាយជាមនុស្សប្រុសស្រី ស្តេចនាម៉ឺន មន្ត្រី រាស្ត្រ ទៅតាមឋានានុក្រមឡើងវិញ។ ក្រោយពីបានរួចផុតពីបាបកម្មហើយ ស្តេចជាមាតាបិតានគរនេះ បានរៀបចំអភិសេកព្រះនាងច័ន្ទរស្មី ឲ្យទៅព្រះចៅទិព្វវង្សធ្វើជាមហេសី និងបានប្រគល់រាជសម្បត្តិឲ្យព្រះចៅទិព្វវង្សឡើងគ្រងរាជ្យ ចំណែកខ្លួនឯង និងព្រះមហេសីក៏លាចេញទៅបួសជាតាបស។

នៅក្នុងរឿងនេះ បើយើងពុំបានយកមកវែកញែក យើងច្បាស់ជាពុំបានដឹងរឿងពិតរបស់ព្រះម៉ែឡើយ យើងដឹងហើយថា បណ្ដាំព្រះម៉ែព្រះឪ ខ្មែរបានរឹងក្លាយទៅជារឿក្នុងថ្មនៅគ្រប់ប្រាសាទទូទាំងប្រទេស ម្យ៉ាងទៀតស្ដេចក្រពើក្នុងសាច់រឿងបានក្លាយទៅជារមាស (ដោយអំណាចកម្ម) ស្ដេចក្រពើនេះ គឺតំណាងឲ្យភ្នំក្រពើ ទង់ក្រពើ ផ្កាយក្រពើ និងពាក្យក្រពើដែលមាននៅគ្រប់កន្លែង ក្នុងស្រុកនេះ ហើយដែលប្រែក្លាយជារមាសនោះ តើមានន័យយ៉ាងដូចម្ដេចដែរ?

ពាក្យរមាស ➜ រាស្ត្រម ឬរាស្ត្រមក តើរាស្ត្រមកធ្វើអ្វី គឺមកស្ដាប់រឿងរបស់ថ្ម ដែលដូនតាខ្មែរបានផ្ដែផ្ដាំរៀបរាប់ពីបាបកម្មចាស់រាប់ពាន់ឆ្នាំមុនរបស់ពួកគាត់ សព្វថ្ងៃភក់ដែលកប់គាត់នោះ បានរឹងក្លាយទៅជាថ្មហើយ (ថ្មភក់ ឬភក់ថ្ម) ដែលដូនតាខ្មែរបានយកទៅកសាងប្រាសាទថ្មរាប់ពាន់នោះ។ សរុបសេចក្ដីមក រឿងទាំងពីរនេះទាក់ទងនឹងប្រាសាទដែលដាក់ឈ្មោះថាគុករមាស ហើយរឿងប្រាសាទគុករមាស ដែលខ្ញុំបាទបានដកស្រង់យកមកពន្យល់នេះ ដើម្បីទុកជាប្រទីបមួយសម្រាប់ពិចារណាកុំឲ្យយល់ច្រឡំ ថាដូនតាយើងគាត់ធ្វើអ្វីមួយទុកទោះតូចក្ដី ឬធំក្ដី ពុំដែលឥតបង្កប់នូវន័យខ្លឹមសារនោះទេ គឺសុទ្ធតែមានបង្កប់ប្រស្នា **គំនិតបីរួមមួយ** សម្រាប់ឲ្យកូនខ្មែរសម័យក្រោយ បំបែកនូវភាសារូបក្នុងបណ្ដាំគំនិតរបស់ពួកគាត់។

## ៤.គុកនគរ (គុហ៍នគរ)

ប្រាសាទគុកនគរនេះ ព្រះម៉ែគាត់ចង់ពន្យល់ប្រាប់យើង ថាគាត់ជាបឋមក្សត្រ ដែលបានបង្កើតនគរនេះ ដោយហេតុនៃសេចក្ដីលោភលន់ ធ្វើឲ្យពួកគាត់ត្រូវជាប់ទោស ព្រោះក្នុងចម្លាក់រឿងគ្រប់ប្រាសាទទាំងអស់ អត្ថន័យរឿងភាគច្រើន សុទ្ធតែនិយាយពីរឿងព្រះម៉ែត្រូវយក្សចាប់ ហើយរឿងរបស់គាត់ពេលខ្លះមាននិមិត្តរូបជាសត្វនាគ ត្រូវយក្សចាប់ផង គ្រុឌចាប់ផង ហើយថែមទាំងមានថ្មសង្កត់ពីខាងលើថែមទៀត ដូច្នេះហើយពេលដែលសោទ្វារទីមួយចាប់បើកក្នុងថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០០ មកក្នុងនគរនេះចេះតែមានអភូតហេតុរឿងរបស់នាគដើរផុសគ្រប់ទីកន្លែង ព្រោះគាត់ចង់ឲ្យកូននាគប្រុសស្រីជួយគាត់។ រួចពេលខ្លះទៀត រូបរបស់គាត់គេឆ្លាក់ជាស្ត្រីត្រូវយក្សក្បាលដប់ (ទសក័ណ្ឌ) ជាន់ពីលើគាត់ត្រង់ដើមទ្រូង (មើលរូបដែលនិយាយ ពីឈ្មោះភ្នំរាពណ៍) **ឬក៏គេឆ្លាក់រូបគាត់ឃុំក្នុងរង្វង់សីមា**

រូបខ្លះទៀតគេឆ្លាក់ជារូបស្ត្រីទ្រទ្រូង (ទ្រទ្រូង)....។ល។ ប៉ុន្តែគ្រប់រូបចម្លាក់រឿងរបស់គាត់ ក៏បានបើកបង្ហាញពីការជាប់ឃុំ ហើយនឹងពីការរួចពីទីឃុំឃាំងបន្តិចម្ដងៗ (ប្រាសាទរលស់) នេះជាអត្ថន័យ ពិតរបស់ឈ្មោះប្រាសាទគុកនគរ បើអ្នកដឹកនាំដំបូងជាអ្នកជាប់ទោសទៅហើយ នគរជាកេរមរតករបស់គាត់ក៏ត្រូវជាប់គុកដែរ។ នៅក្នុងខេត្តកំពង់ធំ ខ្ញុំបានឃើញប្រាសាទមួយ ដូនតាគាត់សាងសង់កប់ទៅក្នុងដី មើលទៅហាក់បីដូចជា ប្រាសាទនោះ ស្រុតចុះទៅក្រោម ប៉ុន្តែតាមការពិត គាត់ចង់ប្រាប់កូននាគសម័យខាងក្រោយ ឲ្យបានដឹងថា ព្រះម៉ែបានកប់ទៅក្នុងភក់ទៅហើយៗដែលភក់នោះបានរឹងខះទៅជាថ្ម (ថ្មភក់ ឬភក់ថ្ម)។ ដូច្នេះហើយស្ទើរតែគ្រប់ប្រាសាទថ្មទាំងអស់ គាត់តែងតែឲ្យកូនគាត់សម័យកសាងប្រាសាទថ្មនោះ យកថ្មភក់នេះ មកសាងប្រាសាទហើយឆ្លាក់រឿងរបស់ពួកគាត់ ទុកដើម្បីឲ្យកូននាគសម័យក្រោយ ពិចារណាពីប្រស្នាក្នុងថ្មភក់ទាំងនេះ។ ក្នុងសម័យទំទាវអ្នកស្រុកត្បូងឃ្មុំបានក្លាយជាអ្នកទោសយូរអង្វែងគឺ **អ្នកងារ** ឯអ្នកស្រុករលៀវផ្អៀរក៏ជាប់ឈ្មោះថា ជាអ្នកងារដែរ (ភូមិតិវិទ្ធានសម័យអាណានិគមបារាំង) យ៉ាងណាមិញព្រះមាតាបិតាមហានគរក៏ជាអ្នកងារដែរ តែអ្នកងារពួកគាត់ គឺជាប់ទោសរបស់យក្សរាប់ពាន់ឆ្នាំហើយ។ ដូច្នេះទើបកើតមានប្រាសាទគុកនគរនេះឡើង ដើម្បីទុកឲ្យកូនខ្មែរសម័យក្រោយ យកឈ្មោះនេះមកគិតពិចារណាថា ហេតុអ្វីបានជានគរជាប់គុក (គុកនគរ) ខ្ញុំគ្មានសង្ឃឹមថាកូននាគទាំងឡាយជឿទៅលើ ការបកស្រាយនេះឡើយ ព្រោះហាក់បីដូចជារឿងនិទាន ប៉ុន្តែពុទ្ធសាសនិកទាំងអស់ត្រូវតែយល់ថា (**នត្ថិកម្មំសមំពលំ = កម្លាំងអ្វី ស្មើដោយកម្លាំងកម្ម គឺមិនមានឡើយ**) ហើយកម្លាំងកម្មនេះ ទោះបីកុសលកម្មក្ដី អកុសលកម្មក្ដី តែងតែតាមឲ្យផលគ្រប់ៗជាតិ លុះត្រាតែអស់ជាតិជរាព្យាធិ និងមរណៈ (អនុបាទិសេសនិព្វាន) ទើបកម្មនេះក្លាយទៅជាអហោសិកម្ម។

**រូបព្រះមាតាបិតាជាប់ក្នុងសីមា** (បន្ទាយសំរ៉ែ)



## ៥.ប្រាសាទសំបូរព្រៃគុក

អត្ថន័យរបស់ឈ្មោះប្រាសាទនេះក៏មិនខុសពីប្រាសាទគុកដទៃៗទៀតដែរគ្រាន់តែដូនតាយើង គាត់ចង់ពន្យល់បញ្ជាក់ឲ្យបានច្រើនដើម្បីឲ្យយើងកាន់តែឆ្ងល់ថា ទីព្រៃដ៏ស្ងាត់ស្ងៀមដែលលាក់ទុកក្នុង អតីតកាលនេះ ពោរពេញទៅដោយប្រាសាទគុក ហើយប្រាសាទគុកទាំងអស់នេះពុំមែនសម្រាប់ដាក់ មនុស្សនៅខាងក្រៅនគរឡើយ គឺជាគុកសម្រាប់ដាក់មនុស្សនៅក្នុងនគរ ក៏ប៉ុន្តែយើងជាកូននាគ សម័យក្រោយ ពុំបានចាប់ភ្លឹកឆ្ងល់ពីឈ្មោះប្រាសាទទាំងនោះឡើយ ដោយយកពាក្យទាំងនេះ មក សិក្សាស្រាវជ្រាវ និងរែកញែកពិចារណារាវរកហេតុផល ដើម្បីស្វែងរកចម្លើយពិត។ បើយើងត្រិះរិះ ពិចារណាតាមទ្រិស្ដីព្រះសម្មាសម្ពុទ្ធសត្វលោកដែលនៅជាបុថុជ្ជន ក្រាស់ទៅដោយកិលេស រមែងជាប់ គុក គឺសមុទ្ទវដ្តសង្សារ រកទីត្រើយពុំឃើញឡើយ ប៉ុន្តែបើមានបញ្ញាបារមីគ្រប់គ្រាន់ ហើយបានស្ដាប់ ធម៌របស់សប្បុរសទៀតនោះ អរិយមគ្គនិងអរិយផលក៏នឹងកើតឡើង អាចបើកទ្វារព្រះនិព្វានបាន ពេលនោះទ្វារគុក គឺវដ្តសង្សារត្រូវបានបើក។ ដូច្នេះពាក្យពេចន៍ទាំងឡាយ ដែលដូនតាយើងបានយក ទៅដាក់សម្គាល់ជាឈ្មោះ នៅលើវត្ថុអ្វីមួយ សុទ្ធតែមានបង្កប់នូវន័យ ពុំមែនគ្រាន់តែដាក់ឲ្យតែបាន នោះទេ ហើយពាក្យគុកនេះទៀតសោត ពុំមែនជាគុករម្នាស់ស្ករ (ចង្រ្កាន) ឬព្រៃគប់នោះឡើយ។

## ៦.ប្រាសាទគុកព្រះធាតុ

ពាក្យថាព្រះធាតុ គឺជាឆ្អឹងរបស់អ្នកមានគុណណាមួយ ដែលទុកដូចជាព្រះហើយយើងមិនដឹង ថាតើម្ចាស់នៃព្រះធាតុនោះជាអ្នកណាឡើយ នៅពេលដែលយើងមិនបានឆ្ងល់នូវពាក្យនេះ ហើយ ស្រាវជ្រាវ យើងពិតជាមិនអាចរកឃើញនូវអាថ៌កំបាំងនៃពាក្យនេះឡើយ។ ដូចសព្វថ្ងៃនៅខេត្តបាត់ ដំបង មានស្រុកមួយឈ្មោះ **ព្រះនេត្រព្រះ** តើព្រះនេត្រព្រះនេះ ជាភ្នែករបស់ព្រះណា? យើងដឹងហើយ ថាមាតាទាំង១២ ត្រូវបានយក្សឈ្មោះនាងសន្ធមារ ខ្វេះយកគ្រាប់ព្រះនេត្រ (កែវភ្នែក) ដូច្នេះ ឈ្មោះ របស់ស្រុកនេះ វាមានទាក់ទងនឹងឈ្មោះព្រះនេត្ររបស់ម្ដាយទាំង១២ ព្រោះពាក្យព្រះនេត្រព្រះពុំទាន់ បញ្ជាក់ប្រាប់ន័យរបស់ព្រះអង្គណាមួយឡើយ។ ចំណែកឯព្រះធាតុវិញ ក៏មិនខុសពីពាក្យព្រះនេត្រព្រះ ខាងលើឡើយ ប៉ុន្តែយើងឆ្ងល់ថា ហេតុអ្វីបានជាព្រះធាតុនេះ ត្រូវជាប់គុក (គុកព្រះធាតុ)? ខ្ញុំបាន

ពន្យល់រ៉ាយរ៉ាប់ពីឈ្មោះរបស់ប្រាសាទ ដែលទាក់ទងនឹងគុកនៅទំព័រខាងលើ បានសន្និកសន្ធាប់ហើយៗឈ្មោះប្រាសាទគុកព្រះធាតុនេះ បើយើងពុំបានពិចារណាទេ យើងច្បាស់ជាពុំមានក្ដីសង្វេគតក់ស្លុតឡើយ។ កូននាគទាំងឡាយ មនុស្សរស់សត្វរស់ ពេលដែលមានទោសត្រូវជាប់គុក ចុះហេតុអ្វីដូនតាខ្មែរនៅសល់តែព្រះធាតុ(ឆ្អឹង)ទៅហើយ ពួកគាត់នៅតែជាប់គុកទៀត? ព្រោះបាបកម្មរបស់ពួកគាត់មកទល់នឹងសព្វថ្ងៃនេះ មិនទាន់មានកូនខ្មែរប្រុសស្រីណាដឹង រួចជួយឧទ្ទិសនៅមហាកុសលជូនទៅពួកគាត់នៅឡើយ ដើម្បីឲ្យបានរួចពីគុកនៃបាបអកុសលនោះ។ ដូច្នេះហើយ ទើបដូនតាយើងគាត់កសាងប្រាសាទបន្ទាយក្ដី ស្ពានកំពុងក្ដី និងឈ្មោះភូមិស្រុកមួយចំនួនក្នុងមាតុភូមិ ដែលទាក់ទងនឹងឈ្មោះពាក្យថាក្ដី ព្រោះក្ដីរបស់ព្រះម៉ែនេះមិនទាន់មានកូននាគណាឡើយមកស្រាយឡើយ។ សូមកូនខ្មែរទាំងប្រុសទាំងស្រីទូទាំងនគរ រួមសាមគ្គីគ្នាឧទ្ទិសនូវមហាកុសល ដែលកើតចេញពីកតញ្ញូ និងកតវេទី ជូនទៅព្រះមាតាបិតា ដែលលោកមាននូវឧបការគុណ ឲ្យលោកបានរួចផុតពីទុក្ខទោសកម្មពៀរនិងអកុសលទាំងឡាយដែលនៅមាន។

## ៧.ប្រាសាទបន្ទាយក្ដី

តើប្រាសាទនេះមានអត្ថន័យលាក់បាំងយ៉ាងដូចម្ដេច?

**ពន្យល់ពាក្យ** (បន្ទាយក្ដី)

បន្ទាយ = ទីតាំងជម្រក ដីលើកខ្ពស់មានកំពែងមាំមួនព័ទ្ធជុំវិញ

ក្ដី = រឿងរ៉ាវ ក្ដីក្ដាំ ទំនាស់ដែលពុំទាន់បានស្រាយ (ទាញទៅទាញមក)

បន្ទាយក្ដី = ទីតាំងទុកដាក់នៅរឿងក្ដីក្ដាំ តើប្រាសាទនេះទុកដាក់រឿងក្ដីរបស់អ្នកណា?

ខ្ញុំបានសរសេររៀបរាប់តាំងពីភាគទី១ រហូតមកដល់ពេលនេះ រឿងរ៉ាវភាគច្រើនសុទ្ធតែទាក់ទងនឹងក្ដីពីអតីតកាល របស់ព្រះមាតាបិតាមហានគរ ហើយជាពិសេសគឺព្រះម៉ែ ព្រោះគាត់បានតាំងខ្លួនជាម៉ែ (មេ) ដោយព្រមទទួលនូវអវិម្រែកក្ដីដ៏ធ្ងន់ ដែលជាហេតុនាំឲ្យកើតនូវមហាស្ពាបត្យកម្មដ៏ច្រើនព្រោងព្រាតចេញពីកម្លាំងសាមគ្គីរបស់កូនខ្មែរប្រុសស្រី ដែលមានកតញ្ញូពីសម័យមុន បានកសាងបន្តគ្នា

ហើយធ្លាក់ទុកនូវរូបរឿងរបស់ម៉ែឪក្នុងថ្ម ដែលសព្វថ្ងៃហៅថាសិលាចារឹក (ដាប់ធ្លាក់លើថ្ម)។ ហើយប្រាសាទបន្ទាយក្ដីនេះ នៅពីខាងមុខក្លោងទ្វារប្រាសាទ គាត់បានឲ្យកូនជីកស្រះមួយ ដែលមានឈ្មោះថាស្រះស្រង់ ហើយនៅកណ្ដាលស្រះ មានប្រាសាទមួយផ្សេងទៀត ប៉ុន្តែសព្វថ្ងៃរលំបាក់បែកអស់ហើយ ដោយការរុករកកាលពីសម័យអាណានិគម ខឿនប្រាសាទនេះ យើងអាចមើលឃើញបាននៅរដូវប្រាំងដែលទឹកត្រូវស្រក។ ពាក្យថាស្រះស្រង់នេះ គឺពុំមែនស្រង់ទឹក (ដូតទឹក) តែម្យ៉ាងនោះឡើយ គឺមានន័យបង្កប់ផ្សេងមួយទៀត ព្រះម៉ែគាត់ចង់ប្រាប់កូនថា បើកូនចង់ដឹងរឿងក្ដីម៉ែ កូនត្រូវស្រង់បណ្ដាំរឿង (ស្រង់ឲ្យងើបឡើង) យកចេញពីក្នុងស្រះ ដែលនៅមាត់កំពង់ស្រះ គាត់បានឆ្លាក់រូបតោនៅពីខាងលើនិងរូបនាគ(និមិត្តរូបព្រះម៉ែ) ដែលមានសត្វម្ករលេប និងរូបសត្វគ្រុឌចាប់ក្បាលនាគមុខក្រោយ នៅខាងក្រោមជាប់មាត់ទឹក។ ហើយស្រះស្រង់ដដែលនេះ ក៏ជានិមិត្តរូបតំណាងឲ្យសមុទ្រទឹកដោះ ដែលជាទីឃុំឃាំងព្រះម៉ែមហានគរ ចំណែកឯប្រាសាទដែលនៅក្នុងស្រះ ខ្ញុំពុំដឹងឈ្មោះអ្វីឡើយ ប៉ុន្តែគ្រាន់តែដឹងថា ដូនតាយើងគាត់កសាងប្រាសាទក្នុងស្រះនេះ សម្រាប់លាក់ទុកនូវសាវតាបណ្ដាំរឿងក្ដីរបស់គាត់ ហេតុនេះហើយទើបបរទេសដឹងរឿងពួកគេបានគាស់កកាយបាក់បែករលំអស់។

សរុបសេចក្ដីមក ការបកស្រាយដោយសង្ខេបពីអត្ថន័យប្រាសាទបន្ទាយក្ដី គឺជាបន្ទាយលាក់នៅរឿងក្ដី របស់ព្រះមាតាបិតាមហានគរ រីឯស្រះស្រង់ ដែលស្ថិតនៅក្នុងប្លង់ទល់មុខ គឺសម្រាប់ស្រង់រឿងក្ដីដែលលាក់ទុកក្នុងស្រះនោះ ចំណែកឯរូបចម្លាក់ក្នុងប្រាសាទវិញខ្ញុំពុំបានបកស្រាយឡើយ ព្រោះភាគច្រើនត្រូវដាប់បំផ្លាញបាក់បែកអស់។

## ៨.ប្រាសាទប្រែរូប

### ពន្យល់ពាក្យ (ប្រែរូប)

ប្រែ = គឺត្រឡប់ពីម្ខាងទៅម្ខាង ពីមិនដឹងទៅដឹង ប្រែពីចាស់ទៅថ្មី....ពីខ្ពង់ទៅបាត

រូប = អ្វីដែលភ្នែកមើលឃើញ ឧ. រូបរាងកាយមនុស្ស សត្វ ធម្មជាតិផ្សេងៗ (រូបបរមត្ថ២៨)

ប្រែរូប = ប្រែរូបពីមិនដឹងទៅដឹង ប្រែរូបពីមើលមិនឃើញឲ្យមើលឃើញ....(ប្រែត្រឡប់រូប)

សព្វថ្ងៃតាមការពន្យល់របស់បរទេស ថាប្រាសាទនេះពីសម័យដើមសម្រាប់បូជាសពរបស់ស្ដេចក៏ប៉ុន្តែពេលដែលខ្ញុំឡើងទៅមើល បណ្ដាំរឿងតាមជញ្ជាំង និងផ្ដែរប្រាសាទពុំបាននិយាយយ៉ាងនេះឡើយ គឺសាច់រឿងគាត់បានប្រាប់ឲ្យយើងជាកូននាគទាំងអស់ជួយប្រែរូបគាត់ ដែលដេកស្លាប់យូរណាស់មកហើយនោះឲ្យរស់ឡើងវិញ ក្នុងសន្តានចិត្តកូនខ្មែរប្រុសស្រី។ ដូច្នេះពាក្យថាប្រែរូប ឬរូបប្រែតាមអត្ថន័យដែលខ្ញុំបាទស្រាវជ្រាវ គឺប្រែពីស្លាប់មករស់ ប្រែពីក្រដឹង ទៅឆាប់ដឹង (ក្រ + ពើ).... នេះជាអត្ថន័យបណ្ដាំប្រស្នាកំបាំងរបស់ព្រះម៉ែចំពោះឈ្មោះប្រាសាទនេះ ដែលខ្ញុំបានពន្យល់បកស្រាយដោយសង្ខេប។

## *៩.ប្រាសាទក្រវ៉ាន់*

ឈ្មោះរបស់ប្រាសាទនេះ បើតាមខ្ញុំបាទអ្នកស្រាវជ្រាវយល់ពីមុន ឈ្មោះថា **ប្រាសាទក្រវាត់** ព្រោះរូបដែលគេឆ្លាក់ក្នុងប្រាសាទនេះគឺរូបព្រះម៉ែមានក្បាំងគ្រប់ក្រវាត់ពីលើដែលចុងក្បាំងមានក្បាលនាគសងខាងត្រូវយក្សលេបខ្លួនទៅដល់ក ហើយក្បាំងនេះគ្របក្រវាត់វាត់បន្តគ្នា។ ម្យ៉ាងទៀតប្រាសាទនេះប្រាសាទធំកណ្ដាលត្រូវប្រាសាទតូចពីរក្រវាត់អមសងខាងជាប់ ប្រៀបបីដូចម្រាមចង្អុលដៃកណ្ដាលត្រូវម្រាមពីរក្រវាត់អមសងខាងយ៉ាងដូច្នោះ។អត្ថន័យរបស់រូបនេះ គឺព្រះម៉ែនាគដែលបានតាំងខ្លួនជាមេជាម៉ែ ទីបំផុតសេចក្ដីលោភលន់ ក្នុងភាពរុងរឿងថ្កុំថ្កើងបានចងក្រុងក្រវាត់គាត់ ដោយអំណាចនៃនាគ (នាគ = ប្រសើររុងរឿង....)។ ហើយក្នុងប្រាសាទនោះដដែល គាត់បានឆ្លាក់រូបព្រះវិស្ណុជិះគ្រុឌ សព្វថ្ងៃតាមការពន្យល់របស់បរទេស គេនិយាយថា



គ្រុឌជាយានជំនិះរបស់ព្រះវិស្ណុ តែខ្ញុំពុំយល់ឃើញស្របដូចពួកគេថាឡើយ ព្រោះសត្វគ្រុឌនោះហើយដែលចាប់ព្រះម៉ែនាគ ប៉ុន្តែត្រូវព្រះវិស្ណុជាន់ពីលើឲ្យលើកដៃឡើងដើម្បីឲ្យគ្រុឌព្រមលែងព្រះម៉ែនាគ។ ភាគច្រើននៃរូបចម្លាក់ គឺព្រះវិស្ណុជិះលើគ្រុឌៗតែងតែលើកដៃទៅលើបង្ហាញពីការចុះចាញ់ឫទ្ធិរបស់ព្រះវិស្ណុ ពេលនោះហើយដែលព្រះវិស្ណុអាចជួយព្រះម៉ែបាន (នេះជានិមិត្តរូប)។ ឈ្មោះរបស់ប្រាសាទក្រវ៉ាន់ ឬក្រវាត់នេះ មានន័យស្រដៀង នឹងឈ្មោះត្បែងមានជ័យដែរ គឺចងក្រវាត់ត្បែងបានដោយជោគជ័

យ។ ដូចពាក្យចាស់ចំណាំនិយាយតគ្នាថា សត្វត្រកួតគេចងកវានឹងកន្ទុយខ្លួនឯង ចំណែកព្រះមាតាបិតាភាគច្រើន ចងកព្រោះកូនចៅប្រុសស្រី(ចំណងប្រាំប្រការ) ដោយហេតុពួកគាត់មានសេចក្ដីលោភលន់ សុខចិត្តដាច់សីលរួចធ្វើបាបកម្មគ្រប់បែបយ៉ាង ព្រោះចង់ទុកកេរមរតកឲ្យកូនចៅជំនាន់ក្រោយរស់ក្នុងភាពថ្កុំថ្កើង។ ចំណែកខ្លួនឯងសុខចិត្តធ្លាក់ក្នុងអបាយភូមិ ទើបស្ដាយក្រោយហើយស្រែកហៅឲ្យកូនជួយជាខាងក្រោយ (ទំនួញប្រេត) តើមានសារៈប្រយោជន៍អ្វីដែលពួកគេមិនជឿព្រោះមើលមិនឃើញ ដូចមានរឿងព្រះម៉ែមហានគរជាភស្តុតាងស្រាប់ ដែលពួកគាត់នៅជាប់ទោសរហូតមកដល់សព្វថ្ងៃ។

**១០.ប្រាសាទបន្ទាយសំរែ** (ខេត្តសៀមរាប)

**ពន្យល់ពាក្យ** (ស្រែ)

ស្រែ = អ្នកស្រែដែលរស់នៅជិតផ្លូវជាតិ មានវប្បធម៌ស្រដៀងនឹងអ្នករស់នៅទីក្រុងដែរ

សំរែ = អ្នកស្រែរស់នៅជ្រៅដែលពុំមានវប្បធម៌ជឿនលឿន

កាលសម័យពីដើមពួកនេះ បើឃើញរថយន្តបើកចូលទៅ គេនាំគ្នាយកអំពៅ ឬស្មៅទៅឲ្យរថយន្តស៊ី ព្រោះពួកគាត់សម្គាល់ថាជាគោ ដំរី សេះ... ឬបើធៀបមកក្នុងន័យបច្ចុប្បន្ន គឺមនុស្សដែលពុំចេះប្រើប្រាស់ បច្ចេកវិជ្ជាទាន់សម័យ នោះហើយគឺអ្នកសំរែ ដែលខ្លួនដើរមិនទាន់សម័យសម្ភារៈ និងបច្ចេកវិជ្ជាទំនើបនិយមនឹងគេ។




អាថ៌កំបាំងនៃពាក្យប្រាសាទបន្ទាយសំរែនេះ ព្រះម៉ែគាត់ចង់ប្រាប់ពីបុគ្គលិកលក្ខណៈពូជពង្ស កូននាគដែលត្រូវមកនាំគាត់ចេញពីក្នុងគុកទាំងបីជាន់នោះ ព្រោះប្រាសាទនេះគេធ្វើបីជាន់ មានរូបព្រះវិស្ណុដេកដឹកម្ដាយចេញជាពូជអ្នកសំរែបានន័យថា ពូជពង្សនេះមានឋានៈទាបជាងអ្នកស្រែធម្មតាទៅទៀត។ តើងាយអ្វីនិងគេស្គាល់

គាត់? (ខ្ញុំបានពន្យល់ក្នុងភាគ១រួចហើយ) ហើយនៅក្នុងប្រាង្គកណ្ដាល មានកូនមឈូសថ្មតូចមួយនៅពីខាងមុខដែលសព្វថ្ងៃគេពន្យល់ប្រាប់ថាដាក់សាកសពស្ដេច ហើយនៅកណ្ដាលប្រាង្គ មានអណ្ដូងមួយសព្វថ្ងៃត្រូវថ្មលុបជិតអស់ហើយ តែយើងឆ្ងល់ថាកូនមឈូសដ៏តូចនេះ ធ្វើដូចម្ដេចអាចដាក់សាកសពមនុស្សចាស់ (ស្ដេច) បាន? ហើយបើសិនជាបូជាហើយយកធាតុទៅដាក់ ក៏ពុំត្រឹមត្រូវទៀត ព្រោះខ្មែរយើងមានទំនៀមយកធាតុទៅដាក់ក្នុងកោដិ នេះជាប្រស្នាមួយដែលដូនតាយើង ទុកឲ្យកូនខាងសម័យក្រោយស្វែងរកការពិតនេះដោយខ្លួនឯង។ រីឯអណ្ដូងក្នុងប្រាង្គកណ្ដាលនៃប្រាសាទវិញ គឺមានអត្ថន័យដូចអណ្ដូងនៅចន្លោះដោះទាំងគូនៅឯលើភ្នំសន្ទុក និងអណ្ដូងក្នុងប្រាសាទបាយ័ន ព្រោះបើចង់ដឹងបណ្ដាំរឿងព្រះម៉ែពីព្រេងនាយ ត្រូវកូនចុះក្នុងអណ្ដូងព្រះម៉ែ ឬទ្រូងម៉ែ ទើបដឹងរឿងក្នុងបេះដូងគាត់។

## ១១.ប្រាសាទបន្ទាយស្រី

ប្រាសាទបន្ទាយស្រីនេះ មានន័យថា ជាទីតាំងលាក់នូវបណ្ដាំរឿងរ៉ាវរបស់ស្ត្រី ហើយស្ត្រីនោះមិនជាអ្នកដទៃណាឡើយ គឺស្ត្រីដែលជាព្រះម៉ែម្ចាស់មាតុភូមិនេះ ព្រោះរូបរឿងដែលឆ្លាក់ភាគច្រើននិយាយប្រាប់ពីរឿងកូនទៅជួយព្រះម៉ែដែលជាប់ឃុំ។

នៅក្នុងចំណោមរូបរឿងថ្មទាំងអស់ មានរឿងក្នុងក្បាំងក្លែងមួយបាននិយាយរៀបរាប់ពីព្រះវិស្ណុអង្គុយលើបល្ល័ង្ក មានមហេសីអង្គុយលើភ្លៅ ដៃកាន់ឈើ ស្ទូន់រលាស់ទឹកឲ្យព្រះមាតាបិតានៅជាន់ខាងក្រោម រួមទាំងញាតិវង្សានុវង្ស ឲ្យបានរួចពីអំណាចរបស់ យក្សទសមុខ(យក្សមានមុខដប់)។ យក្សទសមុខនេះ បានដាក់ទោសព្រះម៉ែព្រះឪដែលជាប្រមុខអ្នកដឹកនាំពី អតីតដែលយើងបានឃើញនៅក្នុងរឿងកូរសមុទ្រទឹកដោះ តែរូបយក្សទសមុខនោះ ត្រូវរលំដួលបន្តិច ម្ដងៗដោយអំណាចទឹកមន្ត គឺ កតញ្ញូកតវេទីរបស់ ព្រះវិស្ណុរលាស់ពីខាងលើ។


ផ្ទាំងក្លែងប្រាសាទបន្ទាយស្រី

*នេះគ្រាន់តែជាការបកស្រាយអាចខុសត្រូវខុសត្រូវ ក្នុងរូបចម្លាក់រឿងមួយក្នុងចំណោមរូបរាប់ពាន់ម៉ឺនសែន ឲ្យមកជារឿងរបស់ព្រះម៉ែព្រះឪខ្មែរសុទ្ធសាធ ព្រោះខ្ញុំពុំយល់ថារឿងចម្លាក់នៅក្នុងថ្មទាំងអស់នោះ វាពុំមែនជារឿងក្នុងសាសនានោះឡើយ ព្រោះប្រាសាទទាំងអស់នេះ ជាបណ្ដាំកេរមរតកគំនិតព្រះម៉ែ នេះជាការបកស្រាយដោយសង្ខេបពីឈ្មោះ* ***ប្រាសាទបន្ទាយស្រី*** *និងរូប។*

## *១២.ប្រាសាទតាសោម*

***ពន្យល់ពាក្យ*** *(សោម)*

*សោម = ព្រះចន្ទ ព្រះបាទកុវេរ: ព្រះសិវ: អាកាស ខ្យល់ ឈ្មោះទឹកអម្រឹតរបស់ពួកទេវតា ឈ្មោះវល្លិមួយប្រភេទ សំរាប់ស្ងោរយកទឹកមកធ្វើថ្នាំ (មើមសោម ទឹកសោម) ចុះពាក្យថាប្រាសាទតាសោមតើមាននៅក្នុងន័យមួយណា? ចម្លើយ សូមកូននាគប្រុសស្រីគិតឈ្វេងយល់ដោយខ្លួនឯងចុះ តាមការពន្យល់ពាក្យខាងលើ។*

*នៅក្នុងខេត្តតាកែវ មានទីប្រជុំជនមួយស្ថិតនៅក្នុងស្រុកត្រាំកក់ ឈ្មោះថាអង្គតាសោម។ អង្គនេះ កើតមានមុនប្រាសាទតាសោម ព្រោះឈ្មោះទីអង្គនេះ កើតមានក្នុងសម័យ* ***ព្រះម៉ែសក់ក្រអូប*** *(ប្រាយ៉ង់កោរ ពន្យល់រួចហើយ) ដូច្នេះពាក្យដែលដូនតា បានយកមកសម្គាល់ជាឈ្មោះ តែងតែវិវឌ្ឍន៍ទៅតាមកាលវេលានៃការផ្លាស់ប្ដូរទីកន្លែង ហើយថែមទាំងមានបង្កប់នៅអត្ថន័យ ក្នុងឈ្មោះនោះទៀតផង សម្រាប់ទុកជាត្រីវិស័យចង្អុលផ្លូវ ទៅរកសាវតាពិតពីអតីតកាល។*

## ***១៣.ប្រាសាទនាគព័ន្ធ*** *(មើលរូបភាពប្រាសាទក្នុងទំព័រ* **២៣** *)*

***ពន្យល់ពាក្យ*** *(នាគព័ន្ធ)*

*នាគ = (ពន្យល់រួចហើយក្នុងភាគ១)*

*នាគព័ន្ធ = នាគវេញចូលគ្នា នាគព័ន្ធគ្នា នាគសាមគ្គីគ្នា (កូនខ្មែរប្រុសស្រីសាមគ្គីបែបនាគព័ន្ធ)*

*នាគពាន់ = ពូជនាគកើតមានរាប់ពាន់ជំនាន់មកហើយ (រាប់ពាន់ឆ្នាំ)*

អត្ថន័យរបស់ឈ្មោះប្រាសាទនេះ ខ្ញុំបានពន្យល់ខ្លះៗហើយនៅទំព័រមុន ពេលនេះខ្ញុំគ្រាន់តែលើកយកមកបញ្ជាក់ នៅចំណុចណាដែលខ្ញុំមិនទាន់បានពន្យល់។ ប្លង់របស់ប្រាសាទនេះ បើមើលពី




ខាងលើ គឺដូចសញ្ញា**កាកបាទ** (សញ្ញាលេខបូក) ព្រោះដូនតាយើងគាត់បានបញ្ជាក់ពីន័យសាមគ្គីជាកម្លាំងធ្វើឲ្យរឹងមាំ គឺត្រូវតែបូកពុំមែនដក ឬក៏ចែកឡើយ។ ដូច្នេះកូននាគទាំងពីរភេទ ចង់ឲ្យនគរមានឫទ្ធានុភាពឡើងវិញ ទាល់តែកូននាគបូកគ្នា ព័ន្ធគ្នា ហើយដឹងរឿងរបស់ព្រះមេនាគ កាលពីរាប់ពាន់ឆ្នាំមុន ទើបអាចក្លាយជាកម្លាំងមហាសាមគ្គី ដែលអាចនាំនគរឈានទៅរកអានុភាពរុងរឿងឡើងវិញ ប្រសិនបើកូននាគនៅក្រោមមនោគមវិជ្ជា បំបែកនាគរបស់បរទេសនោះ គឺមិនអាចរឹងមាំ និងមានមហិទ្ធិឫទ្ធិរុងរឿងថ្កុំថ្កើងបានឡើយ។ បើយើងក្រឡេកមើលទៅខាងក្នុងទឹក ឃើញមានរូបចម្លាក់សេះមួយកំពុងជញ្ជូនមនុស្ស យកទៅដាក់នៅលើប្រាសាទមួយ ដែលអណ្តែតចេញពីផ្ទៃទឹក ហើយនៅជាន់ខាងក្រោមប្រាសាទ មាននាគមួយគូកំពុងព័ន្ធកន្ទុយគ្នា វេនព័ទ្ធជ្រោងប្រាសាទនោះឡើង (នេះជាអាថ៌កំបាំងប្រស្នារបស់នាគព័ន្ធ)។ ចំណែកឯទឹកនៅខាងក្រោម និងជុំវិញប្រាសាទ គឺតំណាងឲ្យទឹកចិត្តរបស់ព្រះម៉ែនាគ និងតំណាងឲ្យមនោគមវិជ្ជាបរទេស ដែលធ្លាប់គ្របសង្កត់ និងធ្វើអាណានិគម ប៉ុន្តែពេលដែលនាគចាប់ផ្តើមព័ន្ធគ្នា កម្លាំងសាមគ្គីអាចធ្វើឲ្យប្រាសាទអណ្តែត ផុតពីអំណាចបរទេស ហើយមានមហិទ្ធិឫទ្ធិរុងរឿងដូចជាសម័យមហានគរវិញ។ នៅខាងចុងទាំងបួននៃសញ្ញាលេខបូក មានប្រាង្គគ្របទៅលើមុខគ្រប់ទិសទាំងបួន (និមិត្តរូបលាក់បាំងរឿងព្រះម៉ែ)។ មុខទាំងបួននេះ តាមឯកសារបរទេសគេពន្យល់ថា ទឹកដែលហូរចេញពីមាត់នៃរូបទាំងបួន គឺជាថ្នាំសំរាប់ព្យាបាលរោគក្នុងធាតុទាំងបួន ព្រោះគ្រប់មនុស្សសត្វតែងមានធាតុបួន (ទឹក ដី ភ្លើង ខ្យល់) ចំណែកការយល់ពីរូបមុខទាំងបួនរបស់ខ្ញុំវិញ គឺផ្ទុយពីទស្សនៈរបស់បរទេស ខ្ញុំសូមធ្វើការបកស្រាយតាមការស្រាវជ្រាវរបស់ខ្ញុំ ក្នុងបណ្តាំប្រស្នាគំនិតព្រះម៉ែ។

១.***រូបក្បាលព្រះម៉ែ*** ពាក់មុងរាជកប់ត្រឹម**ក**មាត់ហាស្រែកហៅកូនឲ្យជួយ នៅលើក្បាលដែលមានពាក់មកុដ ត្រូវទូលយោនីខ្លួនឯង (ឋិតនៅទិសខាងកើត)។


មុខព្រះម៉ែ នៅប្រាសាទនាគព័ន្ធ

តើអត្ថន័យរបស់រូបនេះ ដូនតាចង់និយាយពីអ្វី? ព្រះម៉ែគាត់ផ្ដែផ្ដាំបញ្ជាក់ប្រាប់កូនថា កាលដែលក្បាលម៉ែមានពាក់មកុដ និងទូលយោនីខ្លួនឯង មកុដតំណាងពេលដែលម៉ែកំពុងគ្រប់គ្រងនគរ(សោយរាជ) យោនីតំណាងទ្វារសម្រាប់បង្កើតនូវកូនប្រុសស្រី ព្រោះហេតុតែតាំងខ្លួនជាម៉ែគេទីបំផុតបាបទាំងឡាយ ដែលខ្លួនបានប្រព្រឹត្ត ព្រោះហេតុនៃការតាំងខ្លួននោះ ត្រូវតែទូលភេទខ្លួនឯង។ រីឯមាត់ហាធំមានហូរទឹកចេញ គឺតំណាងឲ្យទឹកចិត្តក្នុងបេះដូងរបស់ព្រះម៉ែ ស្រែកហៅកូនប្រុសស្រីឲ្យជួយ ដែលទឹកចិត្តនេះ ហូរតាំងពីដាប់ទោសដំបូងរហូតមកដល់សព្វថ្ងៃ ទឹកនេះហូរស្ទើរតែជុំវិញផែនដីទៅហើយ។ ក្បាលកប់ត្រឹម **ក** ខ្ញុំមិនពន្យល់ឡើយ ទុកឲ្យកូននាគប្រុសស្រី ស្វែងយល់ដោយខ្លួនឯងចុះ។ ចំណែកឯមុខម៉ែនេះ គេកសាងទុកនៅទិសខាងកើត មានន័យថា មុនគេគឺគាត់នេះហើយ ដែលបាន **កកើត** ទឹកដីមាតុនេះមុនគេ ខ្ញុំបានពន្យល់ក្នុងអាថ៌កំបាំង (ក្មេរ → ខ្មែរ) ក្នុងភាគមួយ។

២.***រូបក្បាលសេះ*** នៅទិសខាងលិច គឺទល់នឹងមុខព្រះម៉ែដែលនៅទិសខាងកើត តើអត្ថន័យរបស់រូបនេះ ដូនតាចង់និយាយប្រាប់យើងពីអ្វី? រូបក្បាលសេះនេះ សព្វថ្ងៃបាក់បែកស្ទើរតែមើលពុំយល់ ហើយរូបដដែលនេះ ក៏មានទឹកហូរចេញតាមមាត់ដែរ ពាក្យសេះតំណាងឲ្យឆ្នាំមមី ខែអស្សុជ ដែលមានផ្កាយរូបសេះ រះជិតផ្កាយកូនមាន់តំណាងឲ្យខែកត្តិក ដែលខ្ញុំបានពន្យល់ហើយក្នុងពិធីបុណ្យអុំទូក។ ឆ្នាំមមី ឬសេះ តំណាងឲ្យឆ្នាំ ដែលគាត់រួចចេញពីទីឃុំឃាំងលើកទីពីរ នៅថ្ងៃពុធ ១២រោច ខែបុស្ស ឆ្នាំមមី ព.ស២៥៤៦ និងតំណាងឲ្យមនុស្ស ដែលកើតឆ្នាំមមី (រូបមនុស្ស ក្បាលសេះ) ដែលចូលរួមជួយព្រះម៉ែ និងរូបនៅក្នុងគុកលានដល់ដំរី ក៏គេឆ្លាក់រូបសេះមានក្បាលប្រាំដែរ។ ពាក្យថាមមីនេះ មាន


មុខក្បាលសេះ នាគព័ន្ធ

ន័យមួយផ្សេងទៀត គឺមិនទាន់ស្វាងល្អនៅងោកងក់ធ្វើភ្នែកមមី បានន័យថាមកទល់នឹងសព្វថ្ងៃនេះ ព្រះម៉ែរួចពីទោសជាងពាក់កណ្តាលហើយ តែកូននាគនៅងោកងក់ធ្វើភ្នែកមមី មិនដឹងរឿង**ម៉ែ**ដដែល។

៣.***រូបក្បាលដំរី*** (ទិសខាងត្បូង) *រូបក្បាលដំរីតំណាងឲ្យអ្វី?*




រូបក្បាលដំរីនេះ ក៏មានទឹកហូរចេញពីមាត់ដែរ ហើយដូនតាគាត់ចង់ពន្យល់ប្រាប់ថា កាលដែលគាត់ធ្វើរូបនេះនៅទិសខាងត្បូង គឺទិសខាងក្បាល (ត្បូង = ក្បាល) ហើយក្បាលដំរីធំ តំណាងឲ្យក្បាលពោរពេញដោយបញ្ញា នឹងមានមហិទ្ធិឫទ្ធិអាចកសាង បង្កើតនូវចក្រភពអង្គរបាន។ ក្បាលដ៏ធំនេះពីមុនមានក្បាលតែមួយទេ ក្រោយមកក្បាលនេះត្រូវគេហែកជាបី(លានជល់ដំរី) ព្រោះរូបរឿងក្នុងលានជល់ដំរី ហ្មដែលនៅលើក្បាលដំរីទាំងបីនោះឈ្លោះគ្នា រួចហ្មបញ្ជាដំរីឲ្យបោចផ្កាឈូកចោល ដើម្បីឲ្យដោយផ្កាឈូក ដែលធំជាងគេនៅលើខ្នង។ ចំណែកឯក្បាលដំរីក្នុងប្រាសាទនាគព័ន្ធ មាត់ហូរទឹកចេញ គឺព្រះម៉ែគាត់ចង់ប្រាប់ថា ដំរីកំពុងដង្ហោយហៅហ្ម មកជួយស្រង់ដំរីឡើងវិញ គឺបង្រួមក្បាលដំរីដែលហែកជាបីឲ្យរួមមកមួយវិញ **ដូចមានប្រស្នាពោលទុកក្នុងទំនាយពារសុក្រពារសៅរ៍ថា ដំរីរោទរត់រកទ្រមាក ឃើញម្លប់ត្រជាក់សំណាក់ប្រាណា ទំរាំចាំពេលវេលាឲ្យបាន ទើបចរចេញផុតម្លប់នោះឯង**។ ដូច្នេះហើយទើបនៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវមានភ្នំមួយឈ្មោះ ភ្នំដំរីរមៀល ដែលដំរីនេះ បានពួនរឿងខ្លួនទៅជាភ្នំ កំពុងរមៀលចុះក្រោមតាមរកហ្មរបស់ខ្លួនដែលជាពូជទាប (បន្ទាយសំរែ)។



៤.***រូបក្បាលរាជសី ឬតោ***

មុខនេះស្ថិតនៅក្នុងគម្របដំបូលទិសខាងជើង គឺទល់នឹងទិសមុខដំរី (ត្បូង) ហើយមុខចុងក្រោយនេះ ក៏មានទឹកហូរចេញពីមាត់ដូចមុខបី ដែលបានរៀបរាប់ហើយពីខាងលើដែរ។ តាមការស្រាវជ្រាវ និងយល់ឃើញ

របស់ខ្ញុំ ដូនតាគាត់ចង់ប្រាប់ថា កាលដែលគាត់កសាងរូបនេះនៅទិសខាងជើង ខាងជើងមានន័យថា ផ្ទុយពីត្បូង(ក្បាល) នៅទិសទាប ទិសក្រោម ឬក៏ក្រោយ ព្រោះទិសខាងក្បាលដំរី គឺកើតមុន (ទីក្រុងយសោធបុរៈ ឬទីក្រុងដំរី) ចំណែកឯខាងជើងកើតក្រោយ គឺទីក្រុងក្បាលរាជសី ឬទីក្រុងសីហនុ សព្វថ្ងៃក្លាយទៅជា (ខេត្តព្រះសីហនុ)។ នៅប្រាសាទបន្ទាយស្រី គេមានឆ្លាក់រូបមនុស្សក្បាលគ្រុឌ ក្បាលស្វា ក្បាលហង្ស ឬមាន់ ក្បាលរាជសី ឬគោ និងមនុស្សតឿ(តំណាងឲ្យមនុស្ស ដែលមានឋានៈតូចទាប)។ យើងសាកល្បងប្រៀបធៀបសិល្បៈខ្មែរ និងអេស៊ីប ស្ដេចហ្វារ៉ាអុងអេស៊ីប គេឆ្លាក់ខ្លួនគាត់ជាគោក្បាលជាមនុស្ស នៅសិង្ហបុរី គេឆ្លាក់ខ្លួនត្រីក្បាលគោ ចំណែកឯដូនតាខ្មែរវិញ គាត់ឆ្លាក់ខ្លួនជាមនុស្សឯក្បាលជាគោ តើកូននាគប្រុសស្រីអ្នកយល់យ៉ាងណា ចំពោះប្រស្នានេះ? សូមរកចម្លើយ ដោយខ្លួនឯង។ នៅឯប្រទេសឥណ្ឌាវិញ សរសរស្ដម្ភដែលជាស្នាព្រះហស្ដព្រះបាទធម្មាសោក (អសោករាជ) គាត់ក៏បានឆ្លាក់រូបរាជសីឬគោ នៅឈរលើសរសរស្ដម្ភនោះដែរ តើរូបចម្លាក់គោនោះ អាចមានទាក់ទងអ្វីនឹងរូបគោរបស់ដូនតាខ្មែរ? នេះគ្រាន់តែជា គំនិតដែលយកមកឆ្លុះបញ្ចាំងប្រៀបធៀបសិល្បៈវប្បធម៌បរទេសក្នុងពិភពលោក ជាមួយនឹងសិល្បៈវប្បធម៌ដូនតាខ្មែរ ពីអតីតកាលតែប៉ុណ្ណោះ ចំណែកចម្លើយកូននាគស្រាវជ្រាវពិចារណាចុះថាតើអនាគត រាជសីពិតប្រាកដ តើកើតនៅប្រទេសណា? អាថ៌កំបាំងសត្វដំរី និងសត្វរាជសីនេះ ដូនតាបានឆ្លាក់បកស្រាយនៅលើផ្ដែររឿងមួយផ្ទាំងនៅប្រាសាទបន្ទាយស្រី ព្រោះចម្លាក់រឿងនេះ បានរៀបរាប់ពីសត្វទាំងពីរ កំពុងរាំហើយវិលចូលគ្នា រួចរលាយកើតជាសត្វមួយទៀត គឺសត្វគុជសី។ យើងដឹងហើយថាស្ដេចរបស់ពពួកសត្វចតុប្បាទ គឺ**រាជសី** ស្ដេចពពួកសត្វស្លាប




(បក្សាបក្សី) គឺរាជហង្ស ស្ដេចរបស់សត្វល្មូន គឺនាគរាជ ស្ដេចរបស់ពពួកមច្ឆា គឺសុវណ្ណមច្ឆា ឬទេពមច្ឆា... មាននៅក្នុងរឿងព្រេងខ្មែរ។ **ចុះសត្វគុជសី មានន័យដូចម្ដេច?** សត្វ**គុជសី** គឺជាសត្វពីររួមចូលគ្នា ពាក់កណ្ដាលដំរី ពាក់កណ្ដាលរាជសី នេះជាប្រស្នាបណ្ដាំរបស់ដូនតាដែលគាត់ចង់និយាយប្រាប់ថា ទីក្រុងពីររលាយចូលគ្នា ទើបស្វែងរកបណ្ដាំពិត របស់ព្រះម៉ែមហានគរឃើញ ប្រសិនបើមានតែជើងអត់ក្បាលក៏ស្រាយពុំរួច មានក្បាលអត់ជើង ក៏ទៅមុខពុំរួចដូចគ្នា។ ដូច្នេះហើយទើបគាត់សាងរូប

ប្រស្នាទុកក្នុងប្រាសាទនាគព័ន្ធ ទីមួយគឺសត្វរាជសីជិះលើដំរី (រូបជុំវិញប្រាង្គខាងលើសព្វថ្ងៃបាក់បែកអស់) ទីពីរគឺរូបក្បាលដំរីនៅទិសខាងត្បូង និងក្បាលរាជសី នៅទិសខាងជើង។ ហើយដូនតាគាត់ចង់ប្រាប់យើងទៀតថា ចង់ដឹងបណ្តាំរឿងពិតរបស់ព្រះម៉ែទាល់តែបង្វែរទឹក ដែលហូរចេញពីមាត់ក្នុងទិសទាំងបួន (ទឹកចិត្ត) ឲ្យមករួមបញ្ចូលគ្នាតែមួយវិញ (បូក)ទើបដឹងរឿងបណ្តាំព្រះម៉ែហើយអាចជួយគាត់បាន។ ហើយក្នុងឈ្មោះសត្វរាជសីនេះ ដូនតាគាត់បានសរសេរនៅក្នុងទំនាយថ្ងៃសុក្រ ថ្ងៃសៅរ៍ (សាស្ត្រា ពារសុក្រ សាស្ត្រាពារសៅរ៍) បានសម្តែងថា ៖

**អស់**ឱអាសូររាជសីសត្វ សព្វថ្ងៃជ្រកបាត់ក្នុងហេមពាន្ត
មិនឃើញអ្នកមកចេញទូន្មាន ឬអាក់អន់អៀនដំណើរអ្វី។
ឬមួយឃើញបឹងរីងហែងហួត ពិរុណរាំងស្ងួតវិនាសត្រី
ឬឃើញស្មាពីរលើឃ្មាងបី ទើបបានអ្នកថ្លៃមិនចេញមក។
បាត់សូន្យយ៉ាងហ្នឹងដឹងយ៉ាងណា ឬចាំអាចារ្យទៅតាមរក
ឬមួយគ្មានម្លប់នឹងឈប់ជ្រក ទើបកែវពន្លកមិនមកអាយ។
ម្តេចអ្នកមិនអាសូរសព្វសត្វ រង់ចាំពេកក្តាត់លំបាកកាយ សព្វថ្ងៃគ្មានសោះហៅសប្បាយ ព្រួយណាស់ហើយណាយឥតឧបមា។
ហៃជនទាំងឡាយចូរស្តែងស្តាប់ អស់អាថ៌សារស័ព្ទគ្រប់ប្រការ
ពីលោកអ្នកប្រាជ្ញចែងចរចា ចោទចងប្រស្នាដោយប្រាជ្ញប្រាណ។

បើតាមទំនាយខ្ញុំបាទបានដកស្រង់ក្នុងវគ្គ ដែលទាក់ទងនឹងរាជសីនេះ គឺដូនតាយើងគាត់បាន បំបែកប្រស្នារបស់សត្វនេះ ចេញពីក្នុងថ្មរួចបញ្ចូលក្នុងទំនាយ ប៉ុន្តែបើតាមទំនាយបុគ្គល ដែលជាតួអង្គរាជសីនេះ លំបាកណាស់ វេទនាណាស់ ព្រោះគេអាណិតអាសូរ ហើយគាត់សម្ងំលាក់ខ្លួនក្នុងព្រៃមនុស្សមួយនគរ តើងាយអ្វីនឹងរកគាត់ឃើញ (ព្រៃហេមពាន្ត = ព្រៃមនុស្សមួយនគរ។


ចម្លាក់បន្ទាយស្រី

សព្វថ្ងៃយើងស្គាល់គាត់បាន ទៅតាមប្រស្នារូបចម្លាក់តែប៉ុណ្ណោះ ដូច្នេះហើយ ទើបពួកបរទេសចូលចិត្តឲ្យគេដាប់ក្បាលរូបចម្លាក់ចោល(ក្បាលអ្នកតា) រួចហើយគេឧបកិច្ចឲ្យបុគ្គលនោះដាច់ក្បាល ដូចជាស្ដេចជ័យវរ្ម័នទីពីរ ធ្លាប់ឧបកិច្ចកាត់ករូបចម្លាក់ស្ដេចថ្វាយ៉ាងដូច្នោះ។ តើគេឧបកិច្ចឲ្យគាត់ស្លាប់ ឬវិនាសប្រយោជន៍អ្វី? បើតាមរូបរឿងចម្លាក់ក្នុងប្រាសាទ គឺមានតែគាត់ម្នាក់គត់ ដែលអាចប្រែរូបព្រះម៉ែដែលដេកស្លាប់ រាប់រយពាន់ឆ្នាំនោះ ឲ្យរស់ឡើងវិញបាន រូបរឿងនេះ ខ្ញុំបានឃើញក្នុងប្រាសាទប្រែរូប ដែលគេឆ្លាក់មនុស្សមានមុខតោ ឬរាជសីបីស្ត្រីជាព្រះម៉ែដាក់នៅលើភ្លៅ (ពន្យល់រួចហើយអាថ៌កំបាំងប្រាសាទប្រែរូប) និងរូបមួយទៀតនៅប្រាសាទបន្ទាយស្រី គេឆ្លាក់គាត់ឈរជើងតែមួយចំហៀង ផ្ដេកស្ត្រីជាព្រះមាតានៅលើភ្លៅ រួចដៃទាំងពីរកំពុងច្របាច់ស្នាមហែកជាបីឲ្យរួមមកជាមួយវិញ (ដំរីក្បាលបីឬស្ត្រីហែកជាបី) តែគួរឲ្យអនិច្ចាណាស់ក្បាលរបស់បុរសនោះ ត្រូវបានគេដាប់ចោលរួចឧបកិច្ច ឲ្យដាច់ក្បាលបាត់ទៅហើយ (មើលរូបខាងលើ)។

ហើយនៅក្នុងប្រាសាទនាគព័ន្ធនេះដដែល កាលសម័យដែលសៀមចូលមកលុកលុយក្រុងអង្គរ ពួកគេបាននាំយក រូបបដិមាអាទិទេពខ្មែរ ដែលជាបេះដូងប្រាសាទនាគព័ន្ធ ទៅកាន់**ក្រុងស្រីអយុធ្យា**។ ហើយពួកវាថែមទាំងបំផ្លិចបំផ្លាញប្រាសាទនេះ ក្នុងឆ្នាំ១៤៣១ នៃគ.ស (តាមពង្សាវតាសៀម) ព្រោះពួកគេយល់ថា ការបំផ្លាញប្រាសាទនាគព័ន្ធបាន គឺជាការបំផ្លាញដួងកែវអំណាចចក្រពត្តិរបស់ស្ដេចជ័យវរ្ម័នទី៧ (ដួងកែវខ្មែរ) និងស្ដេចដែលត្រូវសោយរាជ្យ បន្ត ពីព្រះអង្គក្រោយៗ។ នៅស.វទី១៦ ភូមាបានចូលលុកលុយ ឈ្លានពានដល់ក្រុងស្រីអយុធ្យា រូបបដិមាការពារប្រាសាទនាគព័ន្ធ (ដួងកែវនាគព័ន្ធ) ដែលសៀមបានយកទៅនោះ ត្រូវបានភូមាយកទៅទុកក្នុងប្រទេសរបស់ខ្លួន ហើយឥឡូវបដិមានេះ ប្រហែលជា នៅក្នុងទីក្រុង **ម៉ានដាឡេ** ឯកសារនេះ ខ្ញុំដកស្រង់ចេញពីសៀវភៅប្រវត្តិសាស្ត្រខ្មែរ សរសេរដោយលោក ដេវិឌឆាណ្ឌលែរ (DavidChandler)។ សរុបសេចក្ដីមកការបកស្រាយ និងពន្យល់ដោយសង្ខេបពីអាថ៌កំបាំងរបស់ឈ្មោះប្រាសាទនេះ គឺជាហេតុផលដ៏ធំមួយ និងពិតប្រាកដដែលគាត់

ចង់ឲ្យកូននាគទាំងស្រីប្រុស រួមសាមគ្គីព័ន្ធគ្នាឡើង ដែលមានន័យគ្រប់គ្រាន់នៅក្នុងប្លង់ **លេខបូក** និងរឿងរ៉ាវក្នុងប្រាសាទនោះ ព្រោះជាតិយើងបាន រងទុក្ខវេទនាគ្រាំគ្រាខ្លោចផ្សា និងទុំឧទ្ទោមជាច្រើនស.វ ហើយ ជាពិសេសនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដែលជាសម័យរំលាយបេះដូងជាតិខ្មែរ (ព្រះម៉ែ) ឲ្យធ្លាក់ចុះក្នុងអន្លង់ដ៏សែនអន្ធការ។

## ១៤. ប្រាសាទតាព្រហ្ម

ប្រាសាទនេះស្តេចជ័យវរ្ម័នទី៧ លោកធ្វើឧទ្ទិសឲ្យព្រះម៉ែ ចុះបើប្រាសាទនេះធ្វើឧទ្ទិសឲ្យម្តាយ ហេតុអ្វីបានជាឈ្មោះប្រាសាទ មាននាមថាតាព្រហ្មទៅវិញ? ប្រាសាទតាព្រហ្មនេះ មានពីរ មួយនៅខេត្តសៀមរាប មួយទៀតនៅខេត្តតាកែវ (ទន្លេ បាត់ទី) កសាងក្នុងរជ្ជកាលស្តេចជ័យវរ្ម័នទី៧។

ពន្យល់ពាក្យ (តាព្រហ្ម)

តា = មនុស្សប្រុសដែលមានវ័យចំណាស់ ជាឪពុករបស់ឪពុកយើង (ហៅថាតា)

ព្រហ្ម = សេចក្តីរីកចិត្ត សេចក្តីប្រសើរចំណែកចិត្ត វេទសីល (មេត្តា ករុណា មុទិតា ឧបេក្ខា ព្រហ្មវិហារធម៌)

តាព្រហ្ម = តាដែលជាឪពុករបស់ឪពុកមាននៅព្រហ្មវិហារធម៌៤ ឬមានចិត្តដ៏ប្រសើរ

ប្រាសាទតាព្រហ្មនេះ ដូនតាគាត់ចង់បញ្ជាក់ប្រាប់យើងថា គាត់មានព្រហ្មដល់ទៅពីរជាន់ ជាន់ទីមួយគាត់មានចំពោះកូនប្រុសស្រីបង្កើត ឯព្រហ្មជាន់ទីពីរ គាត់មានព្រហ្មវិហារធម៌ចំពោះកូននាគទូទៅ ហើយជាពិសេសទៅទៀតនោះ គាត់មានព្រហ្មចំពោះព្រះមាតាព្រះបិតាមហានគរ ដែល កូននាគសម័យនេះ នាំគ្នាភ្លេចគាត់អស់ទៅហើយ។ តាព្រហ្មនេះហើយ ជាតួអង្គរាជសីក្នុងទំនាយ និងជាតួអង្គក្នុងរូបចម្លាក់ ដែលសព្វថ្ងៃគាត់កំពុងសម្ងំលាក់ខ្លួន ក្នុងព្រៃមនុស្សព្យាយាមជួយស្រង់ អ្នកមានគុណចេញពីទីឃុំក្នុងសមុទ្រទឹកដោះ នេះជាហេតុដែលដូនតាដាក់ ឈ្មោះប្រាសាទដែលធ្វើឧទ្ទិសឲ្យព្រះម៉ែនេះឈ្មោះថា**តាព្រហ្ម**។

***១៥.ប្រាសាទព្រះខាន់ ឬខ័ន*** *(ប្រាសាទជ័យស្រី)*

***ពន្យល់ពាក្យ*** *(ព្រះខ័ន និងជ័យស្រី)*

*ព្រះ = ប្រសើរ ខ្ពង់ខ្ពស់ លើសលន់ ជាចម្បង ដែលគួរប្រាថ្នា គួរចង់បាន*

*ខ័ន ឬខាន់ = មកពីពាក្យថា ខ័ឌ្គ (ខាត់) គ្រឿងសស្ត្រាវុធមួយប្រភេទ ដែលផ្លែរបស់វាមានមុខមុត ទាំងពីរខាង មានសណ្ឋានដូចផ្លែលំពែង ប៉ុន្តែធំហើយវែងជាងផ្លែលំពែង ដងខ្លីជាងដងលំពែង ហើយ មានស្រោមស័ករអាចសៀតចង្កេះបាន ដោយមានខ្សែចងស្រាក់ស្រោមនោះ។*

*ជ័យ = ឈ្នះ ជំនះ ការឈ្នះដែលផ្ទុយនឹងចាញ់*

*ស្រី = សិ + រី*

*ព្រះខ័ន = សស្ត្រាវុធដ៏ប្រសើរលើសលន់*

*ជ័យស្រី = ឈ្នះដោយមានសិរី ឈ្នះដោយអំណាចរបស់បុណ្យតាមឲ្យផល*

*ហេតុអ្វីបានជាដូនតាយើង ដាក់ឈ្មោះប្រាសាទនេះថា **ព្រះខ័ន ឬជ័យស្រី**ទៅវិញ? បើប្រាសាទ នេះព្រះបាទជ័យវរ្ម័ន៧ លោកកសាងឧទ្ទិសឲ្យព្រះបិតានោះ នេះជាហេតុដែលខ្ញុំបាទត្រូវយកឈ្មោះនេះ មកវែកញែកពិចារណា រាវរកគំនិតពិតរបស់ដូនតាយើង។ តាមការផ្ទៀងផ្ទាត់នូវអត្ថន័យក្នុងពន្យល់ ពាក្យសម្គាល់ប្រាសាទនោះ ន័យទីមួយគឺអាវុធដ៏ប្រសើរលើសលុប ចំណែកឯន័យទីពីរឈ្នះដោយស្រី (សិរី) ជ័យស្រី គឺស្រីមានជ័យ។ បើយើងបូកបញ្ចូលគ្នាក្នុងឈ្មោះទាំងពីរ មានន័យថា **ស្រីមានជ័យ** ដោយអំណាចអាវុធដ៏ប្រសើខ្ពង់ខ្ពស់(បញ្ញា) ព្រោះពាក្យដូនតាយើងបានពោលទុកថា **ចំណេះជា អាហារ បញ្ញាជាអាវុធ** រីឯសុភាសិតរបស់ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើងព្រះអង្គទ្រង់ត្រាស់សម្ដែងក្នុង ត្រៃសិក្ខាគឺ **សីល សមាធិ បញ្ញា** ព្រោះបញ្ញាក្នុងវិបស្សនាជាអាវុធសម្រាប់កាប់ឆ្ការនូវអវិជ្ជា (បញ្ញា លោកុត្តរ)។ ព្រោះកិច្ចសិក្សាក្នុងព្រះសាសនាមានបី គឺសីលសិក្ខា ចិត្តសិក្ខា (សមាធិ) និងបញ្ញាសិក្ខា*

ហើយសិក្ខាខាងដើមពីរជាកម្លាំងឧបត្ថម្ភសិក្ខាខាងចុងឲ្យកាន់តែខ្លាំងក្លាឡើង ដែលអាចមានកម្លាំងកាប់ឆ្ការនូវអវិជ្ជាដែលជាឫសគល់នៃវដ្តសង្សារបាន។

នៅលើប៉ាំងក្លែងប្រាសាទខាងក្រោយ ដូនតាគាត់បានឆ្លាក់រូបព្រះវិស្ណុដេកលើសត្វគុជសី គងលើព្រះម៉ែរួចនាំគាត់ចេញពីទីឃុំឃាំង ដែលនៅក្នុងដៃដែលច្រត់មានកាន់រាជសារ ដៃមួយទៀតទល់ក្បាល


រូបក្នុងប៉ាំងក្លែងវិស្ណុធំ (ព្រះខ័ន)

ចំណែកឯដៃស្តាំវិញ ដៃមួយកាន់ផ្កាឈូកហុចទៅឲ្យព្រះម៉ែ ដៃបែកមួយទៀតកាន់ដុំបណ្តាំរឿង (ហ្វីល) របស់ព្រះម៉ែ នៅខាងក្រោមសងខាង មានរូបឥសីម្នាងបួនៗ កំពុងអង្គុយបញ្ឈរជង្គង់លើកដៃសំពះ នៅខាងក្រោមពោះគុជសីមានរូបអណ្តើក និងត្រីជាច្រើន។ បើតាមអត្ថន័យក្នុងរូបចម្លាក់ប្រាសាទព្រះខ័ននេះ គាត់ចង់ប្រាប់ថា ព្រះវិស្ណុកំពុងនាំព្រះម៉ែចេញពីទីឃុំឃាំងក្នុងសមុទ្រទឹកដោះ ដែលមានក្រុមឥសីកំពុងឲ្យពរសព្វសាធុការ។ នៅខាងក្រៅប្រាសាទព្រះខ័ន គាត់មានឆ្លាក់រូបគ្រុឌកំពុងចាប់ជាន់នាគ (បក្សីចាំក្រុង) ដែលអត្ថន័យរបស់រូបនេះ គាត់ចង់ប្រាប់យើងថា ព្រះមាតាព្រះបិតារួមទាំងកូននាគទាំងឡាយ សុទ្ធតែនៅក្រោមអំណាចឃុំក្រុងរបស់គ្រុឌជាឆ្នាំ។ ដូច្នេះនៅក្នុងប្រាសាទមួយៗ សុទ្ធតែមានបង្កប់នូវរឿងរបស់ដូនតាយើង និងរឿងកូនចៅគាត់ជំនាន់ក្រោយ ដែលគាត់បានលាក់កប់ទុកក្នុង


គ្រុឌចាប់នាគ (ព្រះខ័ន)

ស្រោមរបស់សាសនាទាំងពីរ បើយើងពុំរែកញែកដោយឈរលើបណ្តាំប្រស្នាព្រះម៉ែទេ យើងច្បាស់ជាគ្មានអ្វីជាមរតករបស់ខ្លួនឡើយ ហើយច្បាស់ជាយល់ថាជារឿងនៅក្នុងសាសនាដូចបរទេសថាដូច្នោះ។ ហើយរូបចម្លាក់មាននៅក្នុងប្រាសាទនេះគឺមានច្រើនណាស់ ខ្ញុំគ្រាន់តែលើកយករូបខ្លះមកពន្យល់ជាបែបភាសាបណ្តាំព្រះម៉ែ ដើម្បីធ្វើការពិចារណាឈ្វេងយល់តែប៉ុណ្ណោះ។

១៦.ប្រាសាទលាក់នាង

***ពន្យល់ពាក្យ*** *(លាក់នាង)*

*លាក់នាង = លាក់ស្ត្រីកុំឲ្យគេរកឃើញ*

*ប្រាសាទលាក់នាងនេះ បើយើងមើលតាមប្លង់ប្រាសាទ ដូនតាយើងគាត់សង់ក្នុងជួរជាមួយប្រាសាទប្រែរូប* ***ប្រាសាទតាព្រហ្ម*** *ហើយនៅជិតស្រះស្រង់ និង****ប្រាសាទបន្ទាយក្ដី****។ តើប្រាសាទលាក់នាងនេះ លាក់នាងមួយណា? ខ្ញុំបានពន្យល់ហើយក្នុងសិរីបី មង្គលបី គឺ* ***អាថ៌កំបាំងលុបដាន*** *តើលុបដានស្នាមអ្នកណា? គឺលុបដានព្រះនាងនាគ ព្រោះពេលដែលគេកំពុងលុបដាន និងលាក់នាងក្នុងបន្ទប់នោះ រូបគាត់(ព្រះនាងនាគ)ពុំទាន់ក្លាយជាព្រះម៉ែនាគឡើយ ព្រោះទើបតែធ្វើមង្គលទីបីចប់។ តើគេលាក់នាងបានជិតដែរឬទេ? គឺលាក់បានជិតល្អណាស់ រហូតមកដល់សព្វថ្ងៃ មិនមានកូននាគណាមួយដឹងពីសាវតាពិតរបស់គាត់ឡើយ មានតែបរទេសដែលនៅជុំវិញគាត់ ធ្លាប់ធ្វើអាណានិគមលើប្រទេសគាត់ ទើបគេដឹងរឿង ព្រោះពួកគេបានទិញស្នាមដាន នៃភាពរុងរឿងរបស់មាតានាគ ដែលជាប់នៅលើកន្ទេល(អាថ៌កំបាំងក្នុង* ***ប្រស្នាលុបដាន សាកន្ទេល និងលក់កន្ទេល****)។ ដូចជារូបចម្លាក់មួយក្នុងប្រាសាទបន្ទាយស្រី សព្វថ្ងៃគេហៅថាស្រីគ្រប់លក្ខណ៍ ឬលក្ស្មី ប៉ុន្តែបើយើងត្រឡប់ពាក្យនេះ (ស្រី****គ្រប់លក្ខណ៍*** *→ ស្រីត្រូវ****គ្រាក់លុប****) គឺលុបលាក់នាងនេះឯង ហើយម្យ៉ាងទៀត បើមើលតាមរូបរឿងចម្លាក់ស្រីនេះ គឺគាត់កំពុងលាក់ក្រុងក្នុងអង្រឹតមួយ ហើយអង្រឹតនេះ អាចរបើកដឹងរឿងបាន លុះត្រាតែកើតមានទេវតាពីខាងលើ។ ចំណែកក្បាច់ចង្វាយអមចំហៀងខាងក្រោមក្បាច់ មានជើងសត្វតោ ឬរាជសី ប៉ុន្តែអត់មានក្បាលឡើយ ហើយក្បាលរាជសី (តោ) អាចមានរូបរាងពេញលេញ នៅបាំងក្លែងខាងលើកំពុងចេញពីមាត់យក្ស ឬម្ករ អត្ថន័យនៃរូបនេះ ខ្ញុំបានពន្យល់នៅក្នុងរឿងប្រាសាទនាគព័ន្ធហើយ។ ពាក្យសរសេរ មានសូរសម្លេងដូចស្រីគ្រប់លក្ខណ៍ ម្យ៉ាងទៀតគឺ* ***ស្រីគ្រប់លាក់*** *មានន័យថា រឿងរបស់ស្ត្រីនេះត្រូវបានលាក់បំបាំង មិនឲ្យគេដឹងរឿងរបស់ខ្លួន(លាក់នាង) ហើយរូបចម្លាក់ភាគច្រើន ដែលដូនតាយើងឆ្លាក់នៅក្នុង* ***បាំងក្លែង*** *ព្រោះពាក្យនេះ មានន័យថា* ***ក្លែងបំបាំងភ្នែក ឬបំភ័ន្តភ្នែក*** *(បំប្លែង)។*

១៧.ប្រាសាទតាព្រហ្មកិល

***ពន្យល់ពាក្យ*** *(ព្រហ្មកិល)*

*ព្រហ្ម = (ពន្យល់រួចហើយ)*

*កិល = បង្អិត រំកិលបន្តិចម្ដងៗ*

*តាព្រហ្មកិល = តារំកិលព្រហ្មវិហារធម៌របស់គាត់បន្តិចម្ដងៗ តើតារំកិលព្រហ្មទៅណា? ដើម្បីអ្នកណា? ប្រាសាទនេះ មានរឿងព្រេងប្រចាំប្រាសាទ ប៉ុន្តែខ្ញុំពុំលើកយករឿងមកពន្យល់ឡើយ គឺយកតែឈ្មោះរបស់ប្រាសាទ មកបកស្រាយតែប៉ុណ្ណោះ ហើយពាក្យតាព្រហ្មនេះ ខ្ញុំបានពន្យល់នៅក្នុងប្រាសាទតាព្រហ្មរួចហើយ ក៏ប៉ុន្តែឥឡូវពាក្យតាព្រហ្មនេះ ត្រូវថែមពាក្យកិល ឬរំកិលពីខាងចុង។ ដែលគាត់រំកិលព្រហ្មនេះ គឺរំកិលព្រហ្មម៉ែ និងព្រហ្មឪ (រូបព្រះវិស្ណុធំ / បន្ទាយសំរែ) បន្តិចម្ដងៗ យកទៅដាក់លើកំពូលភ្នំព្រះវិហារ* ***ដើម្បីឲ្យពួកគាត់ក្លាយជាអាទិទេពក្នុងបេះដូងកូនចៅ*** *ឡើងវិញ ក្រោយពីបានលាក់កប់ទុកក្នុងសមុទ្រទឹកដោះអស់រាប់ពាន់ឆ្នាំមកនោះ។ ចុះហេតុអ្វីបានជាតាពុំដើរ បែរជាដេករំកិលទៅវិញ? ព្រោះខ្ញុំបានពន្យល់រួចហើយពីអាថ៌កំបាំងព្រះវិស្ណុដេក ពាក្យថាដេក គឺនៅលើគ្រែក្នុងបន្ទប់ក្នុងផ្ទះ បើតាមមើលសកម្មភាពនៃរូបគីវារ(ល្វា) លូន រំកិលបន្តិចម្ដងៗ ដោយសេចក្ដីព្យាយាមដើម្បីជ្រោងព្រះមាតាបិតាចេញពីទីទុក្ខ។ ដូច្នេះពាក្យថាប្រាសាទព្រហ្មកិល ឬតាព្រហ្មរំកិល គឺគាត់រំកិលខ្លួនឯងផង រំកិលព្រះមាតាបិតាផង រួមទាំងញាតិសាច់សាលោហិតទាំងពួង ឲ្យបានរួចចាកចេញពីអកុសលកម្មទាំងឡាយដែលបានបន្សល់ទុកពីអតីតកាលមក។*

***១៨.ប្រាសាទតាកែវ***

***ពន្យល់ពាក្យ*** *(តាកែវ)*

*តា = (ពន្យល់ហើយ)*

*កែវ = រតនៈវត្ថុមានសាច់រឹង ហើយស្រួយ ធ្វើពីខ្សាច់ និងសំណ*

*កែវ = ពាក្យប្រៀបធៀប (គឺអ្វីៗដែលរាប់អានថាជាវត្ថុមានតម្លៃ)*

តើតាកែវដែលដូនតាយើងដាក់ឈ្មោះសម្គាល់ប្រាសាទនេះ តើជានរណា? ហើយឈ្មោះកែវនេះគាត់ចង់ប្រៀបធៀបនឹងអ្វី? យើងបានដឹងហើយថា ប្រវត្តិរឿងដ៏ជូរចត់មួយ ដែលកូនខ្មែរគ្រប់ស្រទាប់វណ្ណៈបានស្គាល់និងដឹងគឺរឿង**ព្រះគោព្រះកែវ** ដែលសាច់រឿងនេះ បានត្រូវបើកបង្ហាញពីភាពបែកបាក់ទ្រុឌទ្រោមចុះទន់ខ្សោយ និងឈឺចាប់ខ្លោចផ្សា ធ្វើឲ្យកូននាគប្រុសស្រីចងចាំមិនភ្លេច នូវសាវតាដ៏ជូរចត់ចុងក្រោយនេះ។ តើព្រះកែវក្នុងសាច់រឿង និងតាកែវឈ្មោះប្រាសាទមានអ្វីទាក់ទងគ្នា? រឿងរ៉ាវនៅក្នុងលោកយើងនេះ ពិតជាមានការទាក់ទងគ្នាពីមួយជំនាន់ទៅមួយជំនាន់ ពីមួយជាតិទៅមួយជាតិ រហូតវិលមិនចេះចប់ក្លាយទៅជាកងដ៏ធំមួយ គឺវដ្តសង្សារ ដែលរកទីបំផុតខាងដើម និងខាងចុងពុំឃើញឡើយ។ អាចបញ្ចប់នូវវដ្តសង្សារនេះបាន លុះត្រាតែបានត្រាស់ដឹងនូវសច្ចធម៌ ទើបអាចរំលត់នូវជាតិ ដែលជាហេតុនាំឲ្យមានវដ្តសង្សារនេះ (ពុទ្ធភាសិតដែលព្រះអង្គទ្រង់ត្រាស់សម្ដែងក្នុងបដិច្ចសមុប្បាទធម៌)។ ហើយពាក្យកែវនេះ ប្រសិនបើជាន័យប្រៀបធៀបវិញ ព្រះកែវក្ដី ប្រាសាទតាកែវក្ដី ខេត្តតាកែវក្ដី ដូនកែវក្ដី វត្តកែវសិក្ខាគិរីស្វារៈនៅលើភ្នំព្រះវិហារក្ដី......គឺសុទ្ធតែតំណាងឲ្យបញ្ញាបារមីដ៏កំពូលរបស់ **ពូជពង្សនាគ**។ ពីអតីត បញ្ញារបស់ដូនតាយើងបានក្លាយទៅជាឃ្លាំង ជាប្រាសាទ ជាខេត្ត ជាភ្នំ ហើយបញ្ញានេះត្រូវរលស់បាត់បង់អស់បន្តិចម្ដងៗ រហូតដល់ចុងក្រោយដែលនៅត្រឹមតែព្រះកែវ ក៏ត្រូវពួកបរទេស ឈ្លានពានដណ្ដើមយកទៅអស់ដែរ។ ដូច្នេះហើយដួងកែវ ដែលធ្លាប់តែបំភ្លឺនគរ ឲ្យមានមហិទ្ធិឫទ្ធិពីអតីតកាលនោះ ក្រោយមកត្រូវចុះទន់ខ្សោយបាត់ពន្លឺម្ដងបន្តិចៗ ចេញពីក្នុងសន្ដានចិត្តកូននាគប្រុសស្រី ធ្វើឲ្យនគរយើងចាប់ផ្ដើមងងឹត ដោយខ្វះដួងប្រទីប ដែលជាភ្លើងហ្វា ឬដួងថ្កាយសម្រាប់ទោលបំភ្លឺមើល ឲ្យដឹងនូវគន្លឹះសម្រាប់បើកមើល នូវសាវតាអច្ឆរិយពិតរបស់ខ្លួន។ ដូចសុភាសិតរបស់អ្នកប្រាជ្ញភ្នំជីសូរបានពោលទុកថា **ស្ដេចខ្លៅនាម៉ឺនខ្លៅ ដូចពស់ធាងត្រាវពេនមាត់ជណ្ដើរ ស្ដេចប្រាជ្ញនាម៉ឺនមហិទ្ធិយក្ស ដូចពស់ពញ្ញាក់ពេនមាត់ជណ្ដើរ ស្ដេចប្រាជ្ញនាម៉ឺនប្រាជ្ញ ដូចពស់នាគរាជពាំកែវមនោរា** (ពន្យល់ហើយក្នុងភាគមួយ) ពាក្យ **កែវមនោរា** នេះហើយ ដែលជាប្រទីបសម្រាប់បំភ្លឺនគរឲ្យមានឫទ្ធានុភាពបាន។ ចុះចំណែកវត្ត **កែវសិក្ខាគិរីស្វារៈ**វិញ មានន័យដូចម្ដេចដែរ? មុននឹងខ្ញុំបកស្រាយពន្យល់វត្តនេះ ខ្ញុំពន្យល់អំពីខេត្តស្រះកែវសិន សព្វថ្ងៃនៅក្នុងប្រទេសសៀម ពាក្យថា**ស្រះកែវ** គឺជាស្រះទឹកដែលលាក់ទុកនូវមរតកមានតម្លៃពីអតីតកាល ហើយឈ្មោះខេត្តស្រះកែវនេះ

*វាមានអត្ថន័យស្រដៀងស្រះស្រង់ និងប្រាសាទលាក់នាងក្នុងខេត្តសៀមរាបដែលបានពន្យល់ហើយ។ ប្រាសាទលាក់នាងនេះជាអាថ៌កំបាំងនៃពន្លឺកែវមនោ ដែលខ្ញុំបានពន្យល់ក្នុងឯកសារតាភ្នំរាជទ្រព្យនោះ កែវមនោនេះទៀតសោតត្រូវបានលាក់ទុកនៅក្រោម* ***អំណាចមនោគមវិជ្ជា*** *ដែលខ្ញុំបានពន្យល់អស់ហើយ នៅក្នុងអាថ៌កំបាំងសមុទ្រទឹកដោះ។ រីឯតាកែវ គឺជាកូននាគ ដែលមានបញ្ញាដូចកែវ ជាអ្នកចុះទៅក្នុងស្រះកែវដើម្បីស្រង់នូវដូនកែវ (កែវមនោ) ដែលជាព្រះម៉ែមហានគរនោះ ឲ្យលោកមកគង់លើបល្ល័ង្ករបស់លោកវិញ គឺប្រាសាទព្រះវិហារ (មាតុភូមិ) ។*

***ពន្យល់ពាក្យ*** *(កែវសិក្ខាគិរីស្វរៈ)*

*កែវ = (ពន្យល់រួចហើយ)*

*សិក្ខា = រៀន សិក្សា ស្វាធ្យាយ*

*គិរី = ភ្នំ បព្វតា*

*ស្វរៈ = លោកកេស្វរៈ ពោធិសត្វទៀងតែនឹងបានត្រាស់ជាព្រះពុទ្ធ ទៅអនាគតជាតិ (មហាយាន)*

*ដូច្នេះឈ្មោះថាកែវសិក្ខាគិរីស្វរៈ គឺភ្នំដែលតាកែវនោះកំពុងសិក្សា រៀនសូត្រ សន្សំនូវបារមីឲ្យចាស់ក្លាដូចជាភ្នំ ដើម្បីមានកម្លាំងលើកប្រទីបទ្រោលបំភ្លឺនូវភាពងងឹត ពីអតីតកាលឲ្យភ្លឺឡើងវិញដូចជាភ្នំកែវមនោ ទើបអាចដឹងរឿងហើយទៅស្រង់ភ្នំបាន (ភ្នំស្រង់ ឬស្រង់ភ្នំ) ហេតុអ្វីក៏ខេត្តស្រះកែវនៅក្នុងទឹកដីបរទេស ហើយភ្នំកែវសិក្ខាគិរីស្វរៈ នៅក្នុងទឹកដីខ្មែរទៅវិញ? យើងដឹងហើយថា បរទេសសៀមឈ្លានពាន គេបានយកនិមិត្តរូបសត្វគ្រុឌដែលជាសត្វតំណាងឲ្យជាតិគេ ហើយដែលសត្វគ្រុឌនេះ ដៃកំពុងចាប់កន្ទុយនាគ និងជើងជាន់ក្បាលនាគ រូបចម្លាក់នៅប្រាសាទតាព្រហ្ម ព្រះខ័ន បន្ទាយក្ដី.... (បក្សីចាំក្រុង) ដែលសត្វនាគនោះ ជានិមិត្តរូបរបស់ជនជាតិខ្មែរ ហើយជនជាតិនេះ គឺជាពូជអំបូរព្រះម៉ែនាគ(ព្រះនាងនាគ) ដែលជាម្ចាស់កេរមរតកគំនិតក្នុងការដឹកនាំនគរពីអតីត (ពន្លឺកែវមនោ ឬដូនកែវ)។ ហេតុនេះហើយព្រះមាតានាគ (និមិត្តរូបសត្វនាគ) ដែលលោកត្រូវបានជាប់ឃុំក្នុងសមុទ្រទឹកដោះពីអតីតកាល ដោយអំណាចអកុសលកម្ម ដែលលោកបានប្រព្រឹត្តិពីអតីតកាលតាមឲ្យផលរហូត*

មកទល់សព្វថ្ងៃ ហើយកម្មនេះវាមិនទាន់ឲ្យផលអស់ ដូច្នេះហើយទើបខេត្តស្រះកែវនៅក្នុងទឹកដីបរទេស។ ចំណែកឯកូននាគ ដែលជាអ្នកជួយគាត់ កំពុងតែនៅសិក្សារៀនសូត្រពូតផ្គុំ សន្សំបារមីឲ្យបានគ្រប់ ដើម្បីជាន់គ្រុឌឲ្យព្រមដោះលែងព្រះម៉ែនាគ (រូបចម្លាក់ ព្រះវិស្ណុជិះលើគ្រុឌ) ទើបវត្តកែវសិក្ខាគិរីស្វរៈនិងវាលឥន្ទ្រី (តំណាងឲ្យគ្រុឌ) សព្វថ្ងៃស្ថិតនៅក្នុងទឹកដីខ្មែរ ។

## ១៩.ប្រាសាទក្រោលគោ

ពាក្យថា ក្រោលគោ គឺមានន័យថាប្រមូលគោទាំងអស់ ដែលដើរបែកខ្ញែកពេញវាលឲ្យចូលទៅក្នុងប្រាសាទ ឬក្រោលវិញ។ ហើយរឿងគោនេះក៏វាទាក់ទងទៅក្នុងរឿងព្រះគោ ព្រះកែវផងដែរ ដែលបរទេសសៀមឈ្លានពាន បានចាប់យកព្រះកែវផងព្រះគោផង (ព្រះកែវខ្ញុំបានពន្យល់ហើយ)។ ជាបន្តខ្ញុំនឹងបកស្រាយពន្យល់ពីអាថ៌កំបាំង ពាក្យព្រះគោនៅក្នុងន័យពិតរបស់ឈ្មោះនេះដែលដូនតាខ្មែរបានឆ្លាក់រូបព្រះគោតូចធំ ដាក់ក្នុងប្រាសាទស្ទើរគ្រប់ប្រាសាទ ហើយតែងតែមានព្រះឥសូរជិះ និងព្រះនាងឧមាវតីគង់លើខ្នង មិនតែប៉ុណ្ណោះគាត់ថែមទាំងបានធ្វើប្រាសាទដាក់ឈ្មោះថា ប្រាសាទក្រោលគោ ហើយដោយខ្លាចកូនខ្មែរពុំដឹង គាត់បានហៅឈ្មោះភ្នំជាប់ភ្នំកំចាយមារ ថាភ្នំបូកគោ។

តើន័យពិតរបស់ឈ្មោះភ្នំបូកគោនេះ មានន័យដូចម្ដេចទៅហ្ន៎? ហេតុអ្វីបានជាគោនេះអាចបូករឿងរ៉ាវរបស់ខ្លួនឲ្យក្លាយជាភ្នំមួយយ៉ាងធំដូចនេះ? ខ្ញុំបានរៀបរាប់ពន្យល់រួចហើយថា ដោយគាត់ចង់លាក់រឿងពិតរបស់គាត់ គាត់បានខ្ចីស្រោមបរទេសមកលាក់ផ្លែដាវរបស់ខ្លួន ដើម្បីកុំឲ្យបរទេសគេមើលដឹង ទីបំផុតគាត់ពុំបានលាក់បរទេស បែរជាលាក់កូននាគខ្លួនឯង ដែលជាអ្នកទទួលមរតករបស់គាត់ទៅវិញ(កេរម៉ែ)។ នៅក្នុងសូត្រមួយ នៃគម្ពីរព្រះត្រៃបិដកគឺ(កសិសូត្រ) ពេលនោះព្រះពុទ្ធបរមគ្រូនៃយើង បានប្រមើលមើលនិស្ស័យសត្វនៅពេលទៀបភ្លឺ បានឃើញព្រាហ្មណ៍ពីរនាក់ប្ដីប្រពន្ធ ចូលក្នុងសំណាញ់ញាណរបស់ព្រះអង្គ ទើបព្រឹកឡើងព្រះអង្គនិមន្តទៅបិណ្ឌបាត នៅទីដែលព្រាហ្មណ៍នោះ កំពុងភ្ជួរស្រែ ដែលមានគោរាប់សិបកំពុងភ្ជួររាស់ ហើយព្រះអង្គបានទ្រង់ឈរបិណ្ឌបាតចំពោះមុខព្រាហ្មណ៍នោះ ព្រាហ្មណ៍បានពោលពាក្យដោយចិត្តមិនជ្រះថ្លាថា ព្រះអង្គមិនគិតធ្វើស្រែទេឬ? គិតតែពីដើរសុំគេយ៉ាងនេះ? ព្រះអង្គមានពុទ្ធដិកាទៅកាន់ព្រាហ្មណ៍នោះថា តថាគតធ្វើស្រែអស់បួន

អសង្ខេយ្យកម្រៃមួយសែនមហាកប្ប ពេលនេះកិច្ចធ្វើស្រែរបស់តថាគតគឺចប់ហើយ ព្រាហ្មណ៍នោះឆ្ងល់ក៏សួរទៅកាន់ព្រះសម្មាសម្ពុទ្ធវិញថា តើព្រះអង្គធ្វើស្រែដូចម្ដេច? ហើយឧបករណ៍សម្រាប់ធ្វើស្រែនោះនៅឯណា? ព្រះអង្គទ្រង់ត្រាស់សម្ដែង សុភាសិតប្រៀបធៀបដោះការសង្ស័យរបស់ព្រាហ្មណ៍នោះថា៖

**១**/ សទ្ធារបស់តថាគត គឺជាពូជ

**២**/ តបៈ និងការសង្រួមឥន្ទ្រីយរបស់តថាគត គឺជាទឹកភ្លៀង

**៣**/ បញ្ញារបស់តថាគត គឺជានឹម និងផ្លៀងនង្គ័ល

**៤**/ ហិរិ និងឱត្តប្បៈរបស់តថាគត គឺជាដងនង្គ័លនិងចន្ទោល

**៥**/ ចិត្តរបស់តថាគត គឺជាខ្សែសម្រាប់ទាញគោ

**៦**/ សតិរបស់តថាគត គឺជាផាល និងជន្លួញ

**៧**/ សច្ចៈ គឺការគ្រប់គ្រងកាយវាចាចិត្តសង្រួមអាហារក្នុងផ្ទៃ និងធ្វើការដកជំរះស្មៅ

**៨**/ ការឈប់សម្រាករបស់តថាគត គឺជាព្រះនិព្វាន

**៩**/ សេចក្ដីព្យាយាមរបស់តថាគត គឺជា**គោ** ដែលអូសទៅនូវនង្គ័ល ដើម្បីបំបែកនូវអាចម៍បំណះ គឺបំបែកនូវរូបធម៌ នាមធម៌ដាក់ចុះនូវធុរៈដ៏ធ្ងន់ ហើយដើរទៅកាន់ទីដ៏ក្សេម គឺព្រះនិព្វាន(ទាំងនេះ គឺជាការធ្វើស្រែរបស់តថាគត)

បើតាមន័យភាសិតរបស់ព្រះសូត្រនេះ ដូនតាខ្មែរដែលគាត់បានយកនិមិត្តរូបគោនេះ (ប្រាសាទព្រះគោ ក្រោលគោ បូកគោ...) គឺតំណាងឲ្យសេចក្ដីព្យាយាមដែលសេចក្ដីព្យាយាមនេះនៅរាយប៉ាយគាត់បានប្រមូលផ្ដុំបញ្ចូលក្នុងក្រោលវិញ ហើយទីបំផុតបានពូនទៅជាភ្នំ (បូកគោ = បូកសេចក្ដីព្យាយាម) បើពុំមានកម្លាំងវិរិយទេ តើធ្វើម្ដេចអាចកសាងប្រាសាទថ្មរាប់ពាន់បាន? បើពុំមានវិរិយពលៈនោះទេ ធ្វើម្ដេចអាចស្រង់ភ្នំព្រះម៉ែព្រះឪដ៏ធំ រើកទៅដាក់លើព្រះវិហារឡើងវិញបាន? នេះជាអត្ថ

ន័យពិតរបស់ប្រាសាទក្រោលគោ និងប្រាសាទតាកែវ (ព្រះគោព្រះកែវ) ដែលពីអតីតរហូតមកដល់បច្ចុប្បន្ន ត្រូវរាហូអសុរិន្ទលេបបាំងបាត់ពន្លឺរស្មីអស់ទៅហើយ (រូបភាពចម្លាក់រាហូលេបនឹងក្អែព្រះគោ




ព្រះកែវចម្លាក់ននៅប្រាសាទបន្ទាយឆ្មារ ដែលប្រាសាទនេះ ដូនតាធ្វើឧទ្ទិសឲ្យកូនខ្មែរគ្រប់ៗជំនាន់)។ ម្យ៉ាងទៀតព្រះគោព្រះកែវ ដែលនៅសេសសល់ត្រូវបរទេសឈ្លានពាន ដណ្តើមយករអស់ជាចុងក្រោយ ក្នុងសម័យឧត្តុង្គលង្វែក។ តើធ្វើដូចម្តេចអាចធ្វើឲ្យពូជនាគនេះ មានឫទ្ធានុភាពឡើងវិញបាន? កូននាគទាំងឡាយពេលអ្នកយល់ហើយ ត្រូវរួមសាមគ្គីគ្នាព័ន្ធគ្នាជាធ្លុងមួយ ជ្រោងទង់វិរិយិន្ទ្រីយ ជ្រោងទង់បញ្ញិន្ទ្រីយឡើង ហើយសូមឲ្យដួងកែវ គឺកម្លាំងជាធំរបស់បញ្ញា និងកម្លាំងជាធំនៃសេចក្តីព្យាយាម កើតមានឡើងវិញចំពោះកូននាគប្រុសស្រី ការបកស្រាយដោយសង្ខេបនេះជាចម្លើយប្រស្នា ឈ្មោះ **ប្រាសាទក្រោលគោ**។

## ២០.ប្រាសាទក្រោលរមាស

អត្ថន័យនៃពាក្យ ឬប្រាសាទនេះ ខ្ញុំបានពន្យល់ក្នុងអាថ៌កំបាំងប្រាសាទគុករមាសហើយ ខ្ញុំមានតែបួងសួងសុំឲ្យទឹកថ្នាំទិព្វ ដែលមានក្នុងខ្លួនរមាសនោះ មកជួយប្រោះព្រំអ្នកនគរ ដែលបានក្លាយខ្លួនជាថ្មរាប់ពាន់ឆ្នាំនោះ ឲ្យរស់រានមានជីវិតឡើងវិញ ដូចប្រស្នាក្នុងរឿងឥសីមាត់ទិព្វ ឬព្រះថោទិព្វវង្ស។ សូមឲ្យកូននាគទាំងអស់ឆាប់រួចផុតពីគុក គឺអកុសលកម្មចាស់ពីអតីត ហើយសូមឲ្យរឿងរ៉ាវក្នុងថ្មទាំងឡាយឆាប់មានជីវិតរស់រវើក រួចនិយាយពីបណ្តាំរឿងប្រាប់កូនខ្មែរឲ្យបានដឹងពីសាវតាពិតរបស់ខ្លួន ។

## ២១.<u>ប្រាសាទព្រះបាលិលេយ្យ</u>

តើអត្ថន័យពិតរបស់ឈ្មោះប្រាសាទនេះ មានន័យយ៉ាងណាហ្ន៎? ឈ្មោះបាលិលេយ្យនេះ គឺតំណាងឲ្យដំរីមួយនៅក្នុងគម្ពីរព្រះត្រៃបិដក ពេលនោះភិក្ខុក្នុងដែនអាឡវីបានឈ្លោះទាស់ទែងគ្នាព្រោះតែរឿងអាបត្តិបន្តិចបន្តួច ក៏កើតរឿងបែកបាក់គ្នា ក្រោយមកព្រះសម្មាសម្ពុទ្ធពន្យល់ឃាត់ឃាំងពុំបាន

*ព្រះអង្គក៏ស្តេចយាងទៅគង់ចាំព្រះវស្សា នៅព្រៃ**បាលិលេយ្យ**នោះទៅ ដែលនៅក្នុងព្រៃនោះ មានដំរីពោធិសត្វ និងបរិវារនៅគាល់បម្រើអស់កាលត្រីមាស។ ហើយដំរីនេះព្រះអង្គបានព្យាករណ៍ថា តទៅអនាគតនឹងបានត្រាស់ ជាព្រះសម្មាសម្ពុទ្ធមួយព្រះអង្គ ជាវិរិយាធិកដែលត្រូវសន្សំបារមីរាប់អសង្ខេយ ពេលបានត្រាស់ទ្រង់មានព្រះនាមថា សុមង្គលសម្មាសម្ពុទ្ធ (នៅក្នុងអនាគតទសវង្ស)។ ចុះហេតុអ្វីក៏ដូនតាយកឈ្មោះដំរីព្រះពោធិសត្វ មកដាក់ជាឈ្មោះប្រាសាទ? ខ្ញុំបានពន្យល់ហើយ ពីរអាថ៌កំបាំងក្បាលដំរី ក្បាលរាជសីនៅប្រាសាទនាគព័ន្ធ ព្រោះព្រះបាទជ័យវរ្ម័នទី៧ គាត់បានលើកតម្កើងព្រះពុទ្ធសាសនាបែបមហាយាន ប៉ុន្តែគាត់ពុំបានលើកជាចំហបែបហិនយាន ព្រោះហេតុអ្វី? ព្រោះបើគាត់កាន់បែបហិនយាន(យានតូច) គាត់ពុំអាចធ្លាក់រឿងរ៉ាវរបស់ព្រះម៉ែ និងរឿងរបស់កូននាគដែលត្រូវសរជាតិមកបំពេញបារមីជួយព្រះម៉ែបានឡើយ ព្រោះពុទ្ធសាសនា**ហិនយាន** ព្រះអង្គបានបរិនិព្វានទៅហើយ មានតែពុទ្ធសាសនា**មហាយាន** ទេដែលនៅមានព្រះពោធិសត្វ នូវបំពេញបារមីបន្តទៅទៀត។ ដូច្នេះត្រូវមានកូននាគណាម្នាក់សរជាតិ មកបំពេញនូវបារមី ដើម្បីជួយស្រោចស្រង់ព្រះមាតាបិតាមហានាគ និងអ្នកនគរនេះ ឲ្យបានរួចផុតពីបាបកម្ម ដែលពួកគាត់បានសាងពីអតីតកាល។ នេះជាហេតុដែលនាំឲ្យស្តេចអង្គនេះ កាន់ព្រះពុទ្ធសាសនាបែបមហាយាន(យានធំ) ហើយខ្លួនរបស់ព្រះអង្គក៏បាន តាំងនាមជា **ព្រះពោធិសត្វលោកេស្វរៈ** ហើយកសាងប្រាសាទដាក់ឈ្មោះថា **បាលីលេយ្យ** ព្រោះព្រះម៉ែគាត់ចង់ប្រាប់យើងថា ដំរីនេះនៅបំពេញបារមីនៅឡើយ។*

## ២២.<u>*ប្រាសាទព្រះពិធូរ ឬវិធូរបណ្ឌិត*</u>

*តើអត្ថន័យឈ្មោះរបស់ប្រាសាទនេះទាក់ទងទៅនឹង **អាថ៌កំបាំងព្រះម៉ែមហានគរ** មានន័យយ៉ាងដូចម្តេចដែរ? ពាក្យថា**ពិធូរ ឬវិធូរ**នេះ គឺជាឈ្មោះព្រះពុទ្ធបរមគ្រូនៃយើង កាលព្រះអង្គនៅបំពេញបារមីនៅឡើយ គឺរឿងវិធូរបណ្ឌិត ដែលត្រូវយក្សចាប់បោកព្រះអង្គផ្ទប់ទៅនឹងថ្មឲ្យស្លាប់ ដើម្បីវះយកបេះដូងទៅឲ្យកូនស្រីនាគ ព្រោះកូនស្រីនាគនោះ បានស្រែកច្រៀងថា អ្នកណាយកបេះដូងវិធូរបណ្ឌិតបានខ្ញុំនឹងយកអ្នកនោះធ្វើជាស្វាមី(ប្តី)។ ពេលដែលយក្ស ចាប់គាត់បោកផ្ទប់ទៅនឹងថ្មដើម្បីឲ្យស្លាប់ គាត់បែរជាមិនស្លាប់ ដោយអំណាចបុណ្យបារមីរបស់ពោធិសត្វអង្គនោះ ទើបព្រះពោធិសត្វសួរទៅយ*

ក្សនោះ យក្សក៏បានរៀបរាប់ដំណើររឿងជាហូរហែប្រាប់ទៅព្រះអង្គ។ ព្រះអង្គក៏សំដែងធម៌ពន្យល់យក្ស ហើយប្រាប់យក្សថាប្រពន្ធរបស់ស្តេចនាគរាជ ពុំចង់ស៊ីបេះដូងខ្ញុំឡើយ គឺគ្រាន់តែចង់ស្តាប់ធម៌ទេសនាក្នុងចិត្តរបស់ខ្ញុំតែប៉ុណ្ណោះ(អធិប្បាយរឿងដោយសង្ខេប)។ ពាក្យថាចង់ស៊ីបេះដូង សូមកូននាគទាំងឡាយបកទៅក្រោយមើលរឿងសិរីបីប្រការ មង្គលបី និងល្បែងចាក់ទឹកដូង នោះនឹងដឹងរឿងពិតនៃឈ្មោះប្រាសាទនេះហើយ ដែលព្រះមាតានាគគាត់ចង់ផ្តែផ្តាំប្រស្នាដល់យើងថា តើកូននាគណាមួយដែលព្រមខ្វេះបេះដូងទៅឲ្យគាត់បរិភោគ(យកបេះដូងឧទ្ទិសឲ្យយក្ស) នេះជាអាថ៌កំបាំងរបស់ឈ្មោះ**ប្រាសាទព្រះវិធូរបណ្ឌិត**។

## ២៣. <u>ភិមានអាកាស ឬវិមានអាកាស</u>

តើឈ្មោះរបស់ប្រាសាទនេះ មានបង្កប់នូវអាថ៌កំបាំងអ្វី? យើងបានដឹងរួចហើយ នៅក្នុងឯកសារសាវតារអាថ៌កំបាំងបណ្តាំព្រះម៉ែមហានគរភាគទីមួយ ដែលខ្ញុំបានរ៉ាយរ៉ាប់ពីការកត់ត្រារបស់អ្នកការទូតចិន ជីវតាក្វាន់ ពីរឿងរបស់ខ្មែរយើងក្នុងសម័យនោះ។ គាត់និយាយថា ស្តេចតែងតែទៅជួបបិសាចពស់ (នាគក្បាលប្រាំបួន) នៅក្នុងប្រាសាទវិមានអាកាសនេះដើម្បីរួមរ័ក នេះជាភាសារបស់អ្នកការទូតនោះ ប៉ុន្តែតាមន័យពិត គឺស្តេចបានទៅជួបព្រះមាតាដើម្បីទទួលនូវ**ឱវាទ** ដែលព្រះម៉ែបានមកចង្អុលបង្ហាញកូននៅនាទីចុងក្រោយ ដែលគាត់អាចចេញពីទីឃុំក្នុងសមុទ្រទឹកដោះបាន។ ពាក្យថា **វិមានអាកាស** គឺជាវិមានអណ្តែតនៅលើអាកាស ព្រោះព្រះមាតាគាត់តែងតែនិម្មិតជាស្រ្តីមកជួបកូន (ស្តេច) មានន័យថា រូបរាងពិតរបស់ព្រះមាតា គឺពុំអាចចេញពីទីឃុំឃាំងរួចឡើយ មានតែនិម្មិតចិត្តដោយអំណាចមនោមយិទ្ធិតែប៉ុណ្ណោះ ព្រោះចិត្តដូចជាអាកាសគ្មានរូប គ្មានក្លិន គ្មានពណ៌សម្បុរ...។ល។ ហើយបុគ្គលដែលអាចនិម្មិតចិត្តចេញមកបាន ត្រូវមានឈានសមាបត្តិ និងអភិញ្ញា ដែលជាគុណធម៌របស់សមាធិ ដូច្នេះទើបប្រាសាទនេះមានឈ្មោះថា**វិមានអាកាស ឬភិមានអាកាស** សម័យនោះ គាត់អាចដកចិត្តចេញមកជួបកូនបាន តែសម័យក្រោយគឺអត់ទេបរទេសគេដើរបិទ ដើរសន្ធប់អស់ហើយចំពោះរូងណាដែលគេសង្ស័យនេះជាន័យពិត របស់ឈ្មោះប្រាសាទវិមានអាកាស។

## ២៤.ប្រាសាទមេបុណ្យខាងកើត

*ហេតុអ្វីបានជាគាត់ដាក់ឈ្មោះប្រាសាទនេះថា មេបុណ្យខាងកើត? ពាក្យថា**មេបុណ្យ** វាផ្ទុយគ្នាពីមេបាប ព្រោះសភាវធម៌ទាំងពីរនេះ ពុំអាចរលាយចូលគ្នាបានឡើយ ពាក្យថា បុណ្យ គឺប៉ែកខាង**កុសលាធម្មា** ឯពាក្យថាបាប គឺ **អកុសលាធម្មា**។ ចុះហេតុអ្វីក៏ចាំបាច់មាន មេបុណ្យខាងកើតផង មេបុណ្យខាងលិចផង អត្ថន័យនៃឈ្មោះនេះ ខ្ញុំបាទនឹងខិតខំស្រាវជ្រាវ ប្រមូលផ្តុំឯកសារយកមកពន្យល់ទាំងខាងព្រហ្មញ្ញសាសនាព្រះពុទ្ធសាសនា និងបណ្តាំគំនិត ព្រះម៉ែសម្រាប់យកមកបកស្រាយបំភ្លឺចំងល់ ដែលមាននៅក្នុងចិត្តពីឈ្មោះមេបុណ្យទាំងពីរ នេះ។ ប្រាសាទនេះ ដូនតាគាត់ច្រើនធ្វើក្នុងបារាយណ៍ (ក្នុងទឹក) ដោយគាត់បានពូនដីជាកោះ ហើយមានទឹកព័ទ្ធជុំវិញ រួចគាត់ចាប់ផ្តើមកសាងប្រាសាទ ឆ្លាក់រឿងទុកក្នុងប្រាសាទនោះ ដើម្បីជាប្រយោជន៍ទុកឲ្យកូនទាគសម័យក្រោយសិក្សា និងស្វែងយល់រឿងពិតរបស់ព្រះម៉ែ។ មេបុណ្យខាងកើតមានទឹកដក់តែក្នុងរដូវវស្សា ចំណែករដូវប្រាំងពុំមានទឹកឡើយ ដូច្នេះវាផ្ទុយ នឹងពាក្យដែលថាសមុទ្រទឹកដោះ ព្រោះគ្មានទឹកនេះម្យ៉ាងៗទៀតបើយើងប្រៀបធៀបមក ប្រាសាទអង្គរវត្ត ឬអង្គរតូច ដែលគាត់ធ្វើឧទ្ទិសឲ្យព្រះវិស្ណុនោះគឺប្រាសាទមានផ្លូវពិតប្រាកដតែ ក្នុងទិសខាងលិចទេ ចំណែកឯទិសខាងកើតវិញគឺគ្មានផ្លូវចេញចូលត្រឹមត្រូវឡើយ។ ចុះហេតុ អ្វីបានជាគេធ្វើប្រាសាទអង្គរវត្ត បែរមុខទៅទិសខាងលិច? ព្រោះមេបុណ្យខាងកើតពុំមានទឹក ចិត្តគ្រប់គ្រាន់សម្រាប់ជួយស្រង់ព្រះម៉ែឡើយ មានតែមេបុណ្យទិសខាងលិចតែប៉ុណ្ណោះដែល អាចជួយស្រង់ព្រះម៉ែបាន ដូចនេះហើយទើបគេកសាងប្រាសាទអង្គរវត្តបែរមុខទៅទិសខាង លិចព្រោះប្រាសាទនេះ គេធ្វើឧទ្ទិសឲ្យព្រះវិស្ណុដែលដេកវារលូននាំព្រះម៉ែចេញ រហូតដល់មាន ពាក្យទំនាយដែលចាស់ៗនិយាយតៗគ្នាថានឹងមានអ្នកមានបុណ្យ មកពីទិសខាងលិច(គឺពួក គាត់លិចចុះក្នុងសមុទ្រទឹកដោះ) ជួយលើក**ព្រះសាសនា** ព្រោះអ្នកប្រាជ្ញតាក់តែងទំនាយនោះ គាត់មើលតាមប្លង់ពិតនៃប្រាសាទ និងរឿងរ៉ាវចម្លាក់ក្នុងប្រាសាទ ដូចខ្ញុំបានពន្យល់មកនេះ។*

សរុបសេចក្ដីមក អត្ថន័យរបស់ឈ្មោះប្រាសាទមេបុណ្យខាងកើត គឺគាត់ចង់ពន្យល់ប្រាប់យើងថាមេបុណ្យនោះ មានគុណធម៌ពុំទាន់គ្រប់គ្រាន់អាចជួយស្រង់ជួយរើកព្រះមាតាបិតាមហានគរបានឡើយលុះត្រាតែកើតមានមេបុណ្យពីខាង**លិច** ទើបព្រះមាតាបិតាអាចរួចពីទុក្ខទោសបាន ព្រោះទំនាយដូនតាគាត់ដកចេញរឿងពីក្នុងថ្ម។

## ២៥.ប្រាសាទមេបុណ្យខាងលិច

ប្រាសាទនេះ មានទីតាំងនៅក្នុងបារាយណ៍ទឹកថ្លា គឺនៅកណ្ដាលបារាយណ៍ឬបារាយណ៍ ខាងលិច។

**ពន្យល់ពាក្យ** (បារាយណ៍)

បា = ធឹក គ្រប់គ្រង អ្នកគ្រប់គ្រង រក្សា ទំនុកបម្រុង...

បា = កូនប្រុស ម្នាលបា...ហៅសត្វផ្ទុយពីមេគឺបា

រាយណ៍ = នរាយណ៍ (ខ្មែរនិយមហៅព្រះនរាយណ៍) វិស្ណុ ហរ:



កោះមេបុណ្យខាងលិចមើលពីលើរាងដូចក្បាលក្រពើ

បា + នរាយណ៍ នេះជាការយល់ឃើញ របស់ខ្ញុំបាទជាអ្នកស្រាវជ្រាវព្រោះហេតុអ្វី? ព្រោះនៅប្រាសាទមេបុណ្យខាងលិចនេះ គេគាស់បាន រូបបដិមាព្រះវិស្ណុធំ (នរាយណ៍)ដែលមានទំហំធំ ហើយរូបនេះ បានកសាងដោយលោហធាតុចម្រុះ ដែលមានត្រឹមតែពាក់កណ្ដាលពីក្បាលដល់ទ្រូង ចំណែកឯពាក់កណ្ដាលខាងជើងពុំទាន់រកឃើញឡើយ សព្វថ្ងៃរូបនេះ បានតម្កល់ទុកក្នុងសារមន្ទីរជាតិភ្នំពេញ។ ហើយរូបរាងរបស់កោះប្រាសាទមេបុណ្យនោះ បើមើលពីខាងលើ គឺពួកគាត់ពូនកោះជារូបក្បាល

ក្រពើ(រូបថតខាងលើនេះ នៅក្នុងសៀវភៅ Book guides of Ancient Angkor) ដូច្នេះវាទាក់ទងនឹងល្បែងចាក់ទឹកដូងបែបទីមួយដែលថា **កន្ទុយខ្លែងខ្មែរពាក់ក្បាលក្រពើ** តាមអត្ថន័យពិតរបស់កោះនេះ មានបង្កប់នៅរូបរាងក្បាលក្រពើដ៏ធំ ហើយនៅក្នុងកោះនោះមានមេបុណ្យម្នាក់ គឺ**ព្រះវិស្ណុ ឬព្រះនារាយណ៍** ។ តើព្រោះហេតុអ្វី? ដូនតាគាត់បានបង្កប់ភាសាគំនិតក្នុងរូបចម្លាក់និងឈ្មោះមេបុណ្យ តំណាងឲ្យមនុស្សម្នាក់ជាព្រះវិស្ណុដែលសន្សំនូវគុណធម៌ គឺបារមីញាណធំជាងគេនៅក្នុងកោះ ដែលមានរាងក្បាលក្រពើនោះ ហើយគ្រប់រូបនៃព្រះវិស្ណុតែងតែឃើញដូនតាឆ្លាក់ស្ទើរតែគ្រប់ប្រាសាទ និងគ្រប់ទីកន្លែងដែលគាត់ត្រូវឆ្លាក់ គឺព្រះវិស្ណុដេកទល់ដៃរួចគងគាបព្រះម៉ែនៅចុងជើង។ ហេតុអ្វីបានជាគេធ្វើប្រាសាទមេបុណ្យនេះនៅទិសខាងលិច? ព្រោះពាក្យថាលិចវាផ្ទុយពីកើតគឺរះឡើងបានន័យថា បុគ្គលជាមេបុណ្យនេះមិនងាយនឹងងើបរួចឡើយ ព្រោះហេតុអ្វី? ព្រោះគាត់បានលិចចុះទៅក្នុងសមុទ្រទឹកដោះ(សមុទ្រទុក្ខ) ជាមួយព្រះម៉ែមហានាគទៅហើយ ដើម្បីប្រមូលផ្តុំកម្លាំងចុះជួយស្រង់ម្តាយ ឲ្យឡើងមកខាងលើវិញ តើពេលណាទើបអាចស្រង់គាត់រួច បើរឿងរ៉ាវរបស់គាត់ក្លាយទៅជាភ្នំទៅហើយនោះម្យ៉ាងទៀតរឿងនេះ បានលាក់កប់ទុករាប់ពាន់ឆ្នាំ ធ្វើដូចម្តេចដែលអាចឲ្យមនុស្សសម័យនេះទទួលយកនិងជឿនូវបណ្តាំរឿងរបស់គាត់បាន? លុះត្រាតែកូននាគជឿនូវហេតុផលនៃកម្លាំងកម្ម ទើបអាចជឿរឿងពិតនេះបាន។ ដូច្នេះប្រាសាទមេបុណ្យនេះបើយើងចង់ទៅទស្សនាយើងត្រូវជិះទូកឆ្លងកាត់វាលបឹងដ៏ធំមួយ ប្រៀបដូចជាសមុទ្រយ៉ាងដូច្នោះ ហើយសព្វថ្ងៃប្រាសាទនេះ បាក់បែកអស់ហើយ ដោយសារការគាស់កកាយពីសំណាក់ពួកបរទេសសម័យអាណានិគម ស្វែងរកនូវបេះដូងមេបុណ្យរបស់ប្រាសាទនេះ។ ព្រះសម្មាសម្ពុទ្ធគ្រប់ៗព្រះអង្គ តែងសន្សំមេបុណ្យទាំង**៣០** គឺបារមី**១០** ឧបបារមី**១០** បរមត្ថបារមី**១០** បារមី ឬមេបុណ្យទាំង**៣០** នេះហើយសម្រាប់អភិសេកពោធិសត្វគ្រប់ៗព្រះអង្គ ឲ្យបានគង់លើរតនបល្ល័ង្កត្រាស់ដឹងនូវសច្ចធម៌ជាព្រះសម្មាសម្ពុទ្ធនោះឯង។ យ៉ាងណាមិញ រឿងដែលទាក់ទងនឹងប្រាសាទមេបុណ្យទាំងពីរនេះ តួអង្គដែលគេបានឆ្លាក់ទុកក្នុងប្រាសាទនោះ ខាងព្រហ្មញ្ញសាសនាជាព្រះវិស្ណុ.... ចំណែកខាងពុទ្ធសាសនាគេហៅថា **ព្រះពោធិសត្វលោកេស្វរៈ....** ចំណែកក្នុងបណ្តាំគំនិតព្រះម៉ែមហានគរវិញ គឺកូននាគដែលមាននូវកតញ្ញូនិងកតវេទី។ ហើយភាគច្រើនក្នុងអាចិកំបាំងនគរខ្មែរយើង ដូនតាគាត់តែងដាក់បញ្ចូលបុគ្គលនោះ ទៅក្នុងរឿង**ព្រេង ប្រាសាទ ភ្នំ ទំនៀម**

***ទម្លាប់ ប្រពៃណី ទំនាយ....*** *ហើយតួអង្គនេះ បានបញ្ចេញនូវសកម្មភាពផ្សេងៗទៅតាមកាល និងពេលវេលា ទីកន្លែង ដើម្បីសន្សំនូវបារមីដូចតួយ៉ាងសិលាចារឹករបស់ស្ដេចជ័យវរ្ម័នទី៧ ដែលមានន័យថា* ***គុណធម៌ដែលខ្ញុំបានធ្វើ និងកសាងហើយនេះ ខ្ញុំសូមឧទ្ទិសជូនព្រះមាតាបិតាខ្ញុំ ឲ្យឆាប់រួចផុតពីវដ្ដទុក្ខ ហើយទីបំផុតនឹងអាចត្រាស់ដឹងនូវអមតធម៌ គឺព្រះនិព្វាន*** *សូមឲ្យពួកគាត់ឆាប់រួចពីទុក្ខវេទនា ដោយអំណាចមហាកុសលរបស់កូននាគប្រុសស្រីសម័យបច្ចុប្បន្ននេះ រួមសាមគ្គីគ្នាឧទ្ទិសបញ្ជូននូវបុញ្ញកម្មទៅឲ្យពួកគាត់ ដែលកើតចេញពីកម្លាំងកតញ្ញូកតវេទី (កតញ្ញូ=ដឹងគុណ / កតវេទី=តបគុណ) របស់កូននាគប្រុសស្រី ។*

## ២៦.ប្រាសាទអង្គរវត្ត ឬអង្គរតូច

*ហេតុអ្វីបានជាដូនតាយើងដាក់ឈ្មោះប្រាសាទនេះថា អង្គរវត្ត ឬអង្គរតូច ?*

***ពន្យល់ពាក្យ*** *(អង្គ និងអង្គរ)*

*អង្គ = អវយវៈ រូប តួរូបកាយ រាងកាយ ខ្លួនប្រាណ ភាគ...*

*អង្គ = អង្គជាតិ (ព្រះឥសូរ) ឬសិវលិង្គ (លិង្គព្រះសិវៈ) ប្រដាប់ភេទរបស់បុរស...*

*អង្គ = នាក់ រូប ខ្លួន ទ្រង់ លោក សម្រាប់ប្រើចំពោះតែព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះពុទ្ធរូប ព្រះអរហន្ត ក្សត្រិយ ទេវតាសក្ដិធំ បព្វជិតថ្នាក់ខ្ពស់...*

*អង្គរ = (អង់ + គរ) អង្គ គរតគ្នាជាគំនរ បើតាមការឈ្វេងយល់របស់ខ្ញុំបាទ ពាក្យថា អង្គរនេះន័យទីមួយគឺអង្គជាតិ(លិង្គ) គរគ្នា បូកគ្នា គ្រប់សម័យកាល ទើបបានក្លាយទៅជាស្ដេចលិង្គដ៏ធំនៅលើកំពូលភ្នំបូក ដែលសព្វថ្ងៃស្ដេចលិង្គនេះ ត្រូវបានគេបំផ្លាញអស់ហើយ។ ន័យទីពីរ គឺបូកតួអង្គព្រះវិស្ណុតូចៗ ដែលគេឆ្លាក់ទ្រនៅខាងក្រោមស្ពានឬផ្លូវចូលប្រាសាទ គ្រប់ជើងទ្រប្រាសាទ ហើយអង្គព្រះវិស្ណុដែលតូចៗ ទ្រស្ពានបូកបញ្ចូលគ្នាយូរៗទៅ បានក្លាយទៅជាអង្គព្រះវិស្ណុធំដែលគេឆ្លាក់នៅផ្លូវចេញសព្វថ្ងៃយើងហៅថា*___**តារាជ**___ *និងព្រះវិស្ណុដែលនៅកំពូលកណ្ដាល ឬប្រាសាទកណ្ដាល (បាកាន ឬបាកាន់) តើ*___**បា**___*គាត់កាន់អ្វី? គឺគាត់កាន់ម្កុដ ឬក្បួនគម្ពីររឿងរ៉ាវរបស់ព្រះម៉ែនៅក្នុងសមុទ្រទឹកដោះ ពេលដែលគាត់ចុះទៅស្រង់ព្រះម៉ែ ហើយទប់ពួកទេវតា និងពួកយក្សឈប់ឲ្យចងកម្មពៀរគ្នា ។*

*តើអត្ថន័យអង្គជាតិតូចៗបូកបញ្ចូលគ្នា ឬគរគ្នានឹងអត្ថន័យអង្គព្រះវិស្ណុតូចៗ បូកបញ្ចូល ឬគរគ្នា តើន័យទាំងពីរខាងលើនេះ ន័យមួយណាពិតនឹងត្រឹមត្រូវ? យើងដឹងហើយថាប្រាសាទនេះ ដូនតាគាត់ធ្វើទុកឲ្យឬឧទ្ទិសឲ្យព្រះវិស្ណុ (ព្រះនរាយណ៍) បើប្រាសាទនេះ គាត់ធ្វើឧទ្ទិសឲ្យព្រះវិស្ណុ អត្ថន័យទីពីរដែលខ្ញុំបានពន្យល់ខាងលើ ពិតជាត្រឹមត្រូវជាង គឺ**រូបព្រះវិស្ណុតូចៗ** កាន់ដៃគ្នាទ្រក្រោមស្ពាន ហើយក្នុងមួយវគ្គ ឬមួយសង្កាត់តែងតែមានសត្វគ្រុឌនៅរាំងម្តង ដូច្នេះការផ្គុំ ឬគរនូវអង្គរូបព្រះវិស្ណុតូចៗនេះ ទើបធ្វើឲ្យប្រាសាទមានឈ្មោះថា **អង្គរតូច**។ ចុះចំណែកឈ្មោះមួយទៀត ដែលយើងហៅថាអង្គរវត្តវិញ មានន័យយ៉ាងណា? **អង្គរវត្ត** ន័យទីមួយ ព្រោះនៅជាប់ប្រាសាទមានវត្តដែលតំណាងឲ្យព្រះពុទ្ធសាសនា ទើបគេហៅថាអង្គរវត្ត ឯន័យទីពីរ ពាក្យខ្មែរសព្វថ្ងៃច្រើនតែនិយាយតគ្នាថា យកចង្ហាន់ឬទេយ្យវត្ថុផ្សេងៗ និងបច្ច័យបួនជាដើមទៅវត្ត ពាក្យវត្តក្លាយមកពីពាក្យថា វត្តប្រតិបត្តិ ឬវត្តបដិបត្តិ គឺបដិបត្តិឬប្រតិបត្តិឲ្យបានត្រឹមត្រូវទៅតាមត្រៃសិក្ខា (**សិល សមាធិ បញ្ញា**) នេះគឺជាពាក្យដែលយើងគ្រប់គ្នាតែងប្រើសម្រាប់ហៅទីអាវាស ឬអារាមថា **វត្ត**។ មិនថាភិក្ខុ សាមណេ ឧបាសក ឧបាសិកា តែងតែមានកិច្ចវត្តទៅតាមត្រៃសិក្ខារៀងៗខ្លួន ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ទ្រង់បានត្រាស់សម្តែងសរសើរនូវបុគ្គលណា ដែលបានបូជាព្រះអង្គដោយបដិបត្តិបូជា គឺជាការបូជាដ៏ឧត្តម (បរិនិព្វានសូត្រ) នេះជាកិច្ចវត្តប្រតិបត្តិរបស់ពុទ្ធសាសនិកទាំងឡាយ។ ចុះចំណែកអង្គរវត្តវិញ មានន័យយ៉ាងណា? គឺមានន័យថា ព្រះវិស្ណុដែលដូនតាប្រសិទ្ធិនាមឲ្យឬធ្វើប្រាសាទឧទ្ទិសឲ្យនោះ គាត់ត្រូវមានវត្តប្រតិបត្តិដើម្បីសន្សំបារមី ឲ្យបានក្រាស់ក្រៃលរហូតអាចមានកម្លាំងស្រង់ ឬរែកអ្នកមានគុណ ទៅដាក់លើកំពូលព្រះវិហារវិញបាន ព្រោះប្រាសាទអង្គរវត្ត ដូនតាគាត់កសាងតាមប្លង់* **លោកុត្តរៈ** *ឬប្លង់អាទិទេព។ ព្រោះន័យរបស់ព្រះវិស្ណុ (នរាយណ៍) គឺទ្រទ្រង់លោក ថែរក្សាលោក និងស្រោចស្រង់លោក ដូច្នេះគាត់មានកិច្ចវត្តស្រោចស្រង់ទ្រទ្រង់ និងថែរក្សានូវអាទិទេពរបស់ខ្លួន គឺព្រះមាតាបិតាមហានាគ នេះជាអត្ថន័យរបស់ឈ្មោះអង្គរវត្ត។ ចុះហេតុអ្វីបានជាគាត់ធ្វើប្រាសាទគក់ទ្រូងទុកឲ្យព្រះវិស្ណុ? យើងដឹងហើយថា មនុស្សដែលមានទុក្ខនិយាយមិនចេញ គឺមានតែគក់ទ្រូងខ្លួនឯង ទើបបានធូរស្បើយ ពុំ*



រូបព្រះវិស្ណុតូចៗគគ្នាបានជារូបធំជិះលើគ្រុឌ

មែនអ្នកមានសេចក្តីសប្បាយរីករាយជាអ្នកគក់ទ្រូងឡើយ នេះជាអាថ៌កំបាំងប្រាសាទគក់ទ្រូង ដែលគេធ្វើទុកឲ្យព្រះវិស្ណុគក់ ពេលដែលតឹងចិត្តលំបាកចិត្តនិយាយមិនចេញ ឬក៏ស្រាយប្រស្នាកំបាំងព្រះម៉ែមិនរួច ឬមួយស្រាយរួចហើយយកទៅប្រាប់គេៗមិនជឿហើយគេមិនជួយ។ ហេតុអ្វីក៏ក្នុងប្រាសាទអង្គរវត្តនេះ ដូនតាគាត់ឆ្លាក់រូបអប្សរាច្រើនម្លេះ? ហើយក្នុងអប្សរារាប់រយពាន់នោះ មានតែពីរទេ ដែលមួយលានអណ្តាត មួយទៀតសើចចេញធ្មេញ? បើយើងចម្លងសិល្បៈ វប្បធម៌ពីឥណ្ឌាហេតុអ្វីក៏អប្សរាឬអច្ឆរាខ្មែរមិនមានពាក់អាវ?

**ពន្យល់ពាក្យ** (អប្សរា)

អប្សរា = អច្ឆរាស្ត្រី ដែលមានពណ៌សម្បុរ ស្បែកថ្លាស្រស់ផូរផង់ ឬស្ត្រីដែលមានមុខស្រស់បំព្រង (ស្រីសួគ៌ ស្រីទេពអប្សរ)

ក្នុងឯកសារអាថ៌កំបាំងបណ្តាំព្រះមាតាមហានគរភាគទី១ ខ្ញុំបានពន្យល់រួចហើយពីពាក្យថា មេ ឬខ្មែរ ហើយពាក្យថាមេឬខ្មែរ ដែលជាការទាក់ទាញនូវពួកបុរសៗឲ្យជាប់ជំពាក់ក្នុងវត្ថុកាម **គឺរូប សម្លេង ក្លិន រស ផោដ្ឋព្វ (កាមគុណប្រាំ)** រហូតបង្កើតបានសង្គ្រាមជាបន្តបន្ទាប់ ទីបំផុតប្រមុខនៃមេ សុខចិត្តចុះចាញ់ដោយអំណាចមន្តស្នេហ៍របស់ព្រះថោង (កៅណ្ឌិន ហ៊ុនទៀន ឥសីកម្ពុ...) ហើយជាតំណតមកខាងក្រោយ អច្ឆរាទាំងនេះ ដែលមានពាក្យហៅថាព្រះមេ ឬខ្មែរបានក្លាយជាព្រះម៉ែឬខ្មែរ ហើយអាថ៌កំបាំងរបស់ព្រះមេនិងព្រះម៉ែនេះ បានលិចចុះទៅជាមួយខ្លួននៅក្នុងសមុទ្រទឹកដោះ(សមុទ្រទុក្ខ)។ រឿងរបស់មេ និងម៉ែនេះទៀតសោត គឺតួអង្គព្រះវិស្ណុបានចុះតាមទ្រូង (ទ+រូង) ទៅក្នុងបេះដូងរបស់ព្រះម៉ែ ទើបបានដឹងនូវសាវតារឿងរាប់ពាន់ឆ្នាំមុន ដែលបានលាក់កប់ទុកក្នុងសមុទ្រនៃអតីតកាលដ៏សែនវែងឆ្ងាយ ពោរពេញទៅដោយក្តីទុក្ខក្នុងការព្រាត់ប្រាស (ប្រាសាទស៊ូព្រាត់) បាក់បែកគំនុំគុំកួនព្យាបាទចងពៀរឈ្នានីស ព្រោះហេតុតែគាត់ធ្លាប់បានរំលោភឈ្លានពានលើបណ្តាប្រទេសរាប់រយដោយហេតុតែតាំងខ្លួនជាព្រះមេ ឬព្រះម៉ែ។ ហេតុនេះហើយ ទើបអប្សរារាប់ពាន់គាត់ឆ្លាក់ពុំមានពាក់អាវ ព្រោះគាត់ចង់បញ្ជាក់ប្រាប់កូននាគសម័យខាងក្រោយថា គាត់ពុំបានចម្លងវប្បធម៌គេទាំងស្រុងនោះទេ គឺជាវប្បធម៌ប្រពៃណីរបស់គាត់ជាព្រះមេនិងព្រះម៉ែ ដែលបានបង្ហូរទឹកដោះបំបៅកូនរហូតក្លាយទៅ

ជាសមុទ្រ (ពន្យល់ហើយក្នុងភាគ១)។ រីឯអប្សរាពីរ មួយលានអណ្ដាត មួយសើចចេញធ្មេញ អត្ថន័យរបស់រូបទាំងពីរនេះបើតាមការយល់ឃើញរបស់ខ្ញុំ អប្សរាលានអណ្ដាត ដោយ**អណ្ដាត** គឺជាអវយវៈម្យ៉ាងសម្រាប់បញ្ចេញនូវសូរស័ព្ទសម្លេង ដែលអាចនិយាយចេញដោយការត្រិះរិះគិតក្នុងចិត្ត វាផ្ទុយពីមនុស្សគដែលពុំអាចនិយាយបាន យ៉ាងណាមិញអប្សរាដែលលានអណ្ដាតនោះ ពីមុនពុំអាចនិយាយចេញឡើយ បានត្រឹមតែបិទមាត់តែឥឡូវគាត់អាចបញ្ចេញសម្លេងបានខ្លះហើយ (អច្ឆរាមួយក្នុងរាប់ពាន់) ទោះបីជាសម្លេងរបស់គាត់មិនទាន់បានឮផ្សព្វផ្សាយទូទាំងនគរក៏ដោយ ក៏អាចឲ្យឮដល់កូននាគដែលចុះទៅស្រង់គាត់(ព្រះវិស្ណុ) ហើយអប្សរាលានអណ្ដាតនេះ គាត់ឆ្លាក់នៅជិតនឹងប្រាសាទគក់ទ្រូងដើម្បីឲ្យយើងជាកូននាគចេះឆ្ងល់ និងចេះពិចារណា។ ចំណែកឯអប្សរាញញឹមចេញធ្មេញវិញ គាត់ឆ្លាក់នៅគៀនជញ្ជាំងផ្លូវចេញសម្រាប់មនុស្សមានវណ្ណៈទាប ព្រោះខ្លោងទ្វារសម្រាប់ចេញចូលនៅអង្គរតូច មានចែកវណ្ណៈ ហើយព្រះវិស្ណុនាំរឿងរបស់អប្សរាចេញមកខាងក្រៅ គាត់ជាពូជទាបគឺពូជសំរែ ន័យរបស់អប្សរាចេញធ្មេញ គឺបង្ហាញពីសម្រស់របស់ធ្មេញ មើលក្នុងមង្គលទីបី គឺមង្គលការ(បុកល័ក្ខ ធ្វើធ្មេញ តប់ធ្មេញ បន្សាបពិសនាគ) ដែលមង្គលទីបីនោះបានប្រាប់ថា ចុះទៅដល់ចុងជើងហើយ គឺអប្សរាចាប់ផ្ដើមធ្វើដំណើរចេញពីសមុទ្រទឹកដោះដែលជាទីឃុំឃាំង(និយាយរៀបរាប់ពីបណ្ដាំរឿងរបស់ខ្លួន)។

សរុបសេចក្ដីមក តាមការបកស្រាយពន្យល់ដោយសង្ខេបពីឈ្មោះប្រាសាទ និងរឿងរ៉ាវចម្លាក់ក្នុងប្រាសាទអង្គរវត្ត ឬអង្គរតូចនេះ កូននាគទាំងឡាយច្បាស់ជាមានបញ្ញាអាចឈ្វេងយល់ថា ជាបណ្ដាំសាវតារឿងរបស់ព្រះមេ និងព្រះម៉ែសុទ្ធសាធដែលគាត់បានលាក់បញ្ចូលទៅក្នុងព្រហ្មញ្ញសាសនាដើម្បីជាការក្លែងបំភាន់។

## ២៧.ប្រាសាទសួព៌ត្រ ឬប្រាសាទនាងដប់ពីរ

តើពាក្យថា សួព៌ត្រ និងស៊ូព្រាត់ ពាក្យមួយណាត្រឹមត្រូវ?

**ពន្យល់ពាក្យ** (សួព៌ត្រ ឬស៊ូព្រាត់)

សួព៌ត្រ = ដើរលើខ្សែព៌ត្រ

ស៊ូព្រាត់ = ស៊ូព្រាត់ប្រាសគ្នា ដោយអំណាចបាបកម្មតាមឲ្យផល

បើតាមការសិក្សាស្រាវជ្រាវ ឈ្មោះរបស់ប្រាសាទនេះ មានឈ្មោះមួយទៀតថា ប្រាសាទនាងដប់ពីរ ឬនាងពីរដណ្ដប់ រឿងនេះខ្ញុំបានពន្យល់ខ្លះៗហើយ ដែលទាក់ទងនឹងមាតាទាំងដប់ពីរ ក្នុងរឿងឈ្មោះភ្នំប្រសិទ្ធិ។ ដែលខ្ញុំលើកយកមករើកញែកពន្យល់នេះ ចង់ឲ្យកូននាគទាំងឡាយនាំគ្នាពិចារណាឈ្វេងយល់ឡើងវិញថា តើពាក្យប្រាសាទសួព្រ៍ត្រ និងស៊ូព្រាត់ តើពាក្យណាមួយត្រឹមត្រូវ? ព្រោះពាក្យនិយាយរបស់ខ្មែរយើងច្រើនមានកម្លាយពាក្យ ដូច្នេះវាធ្វើឲ្យបាត់អត្ថន័យដើមនៃឈ្មោះ ដូចជាប្រាសាទស៊ូព្រាត់នេះជាដើមដែលមាតាទាំងដប់ពីរលោកសុខចិត្តស៊ូព្រាត់ប្រាសស្វាមី បុត្រាបុត្រី ដោយហេតុតែការញុះញង់របស់យក្សធ្វើឲ្យស្វាមីខ្វះគ្រាប់កែវភ្នែក (បញ្ញា)ហើយយកទៅដាក់ឃុំឃាំងនៅក្នុងប្រាសាទទាំងដប់ពីរ។ ទីបំផុត ពួកគាត់ដោយអំណាចអកុសលកម្មគាត់ត្រូវព្រាត់ប្រាសកែវភ្នែកស្វាមី បុត្រាបុត្រី ពេលសេចក្ដីស្រេកឃ្លានកើតឡើង គាត់បាននាំគ្នាហែកកូនដែលកើតចេញពីផ្ទៃរបស់ខ្លួន ចែកគ្នាបរិភោគដូចជាប្រេត (កម្មរបស់ប្រេតក្នុងជាតក) ដូច្នេះពាក្យថា **ស៊ូព្រាត់ គឺ**ត្រឹមត្រូវជាងពាក្យ**សួព្រ៍ត្រ** ព្រោះអ្នកទាំងនោះសុខចិត្តព្រាត់ប្រាសនូវរបស់ដែលជាទីស្រឡាញ់។ ប្រាសាទស៊ូព្រាត់នេះ គាត់បានកសាងនៅទល់មុខនឹងលានព្រះគម្លង់ និងលានជល់ដំរី ដែលកន្លែងទាំងពីរនេះ សុទ្ធតែជាគុកឃុំឃាំងព្រះមាតាបិតា និងកូនដែលត្រូវឡើងមកជួយស្រង់រើកពួកគាត់។

ការរៀបរាប់ក្នុងមង្គលបី សិរិបីឈ្មោះភ្នំប្រាសាទ ភូមិស្រុក ទំនៀមទម្លាប់ ប្រពៃណី ទំនាយ.... ដែលខ្ញុំបានលើកយកមកបកស្រាយនេះ ទោះបីជាមិនបានគ្រប់ទីកន្លែង និងក្បោះក្បាយ ក៏អាចទុកដូចជាដួងប្រទីបមួយ សម្រាប់ទ្រោលបំភ្លឺមើលឲ្យឃើញនូវបណ្ដាំប្រស្នាគំនិតពិតរបស់ព្រះម៉ែមហានាគ ដែលលោកខិតខំបំពេញពលិកម្មគ្រប់បែបយ៉ាងដើម្បីបន្សល់ទុកនូវគំនិតអច្ឆរិយ ដែលសព្វថ្ងៃពិភពលោកគេបានស្ញើចសរសើរនូវក្លិនក្រអូប ដែលបានសាយភាយចេញពីបញ្ញារបស់លោក ហើយយើងជាកូននាគ បែរជាពុំបានដឹងពីការផ្ដែផ្ដាំរឿងពិតក្នុងបេះដូងព្រះម៉ែទៅវិញដូច្នេះសូមឲ្យពន្លឺនេះជួយបំភ្លឺឲ្យកូននាគទាំងឡាយបានដឹង ហើយនឹងខិតខំជួយពួកគាត់ឲ្យបានរួចពីអកុសលកម្មចាស់នេះតាមការផ្ដែផ្ដាំទុករបស់ពួកគាត់ ។

## VI. ឥទ្ធិពលពុទ្ធសាសនា និងព្រហ្មញ្ញសាសនាក្នុងនគរខ្មែរ

តើព្រហ្មញ្ញសាសនា និងពុទ្ធសាសនាមានអាថ៌កំបាំងអ្វីជាមួយបណ្ដាំប្រស្នាគំនិតរបស់ព្រះម៉ែ?

### ក.ព្រហ្មញ្ញសាសនា

ព្រហ្មញ្ញសាសនានេះបានចូលមកប្រតិស្ឋានទុកក្នុងនគរ តាំងពីយូរយារណាស់មកហើយ ចុះហេតុអ្វីបានជាពួកគាត់ សុខចិត្តទទួលយកសាសនានេះ មកធ្វើជាកេរមរតកទុកឲ្យកូនគាត់សម័យក្រោយ? យើងបានដឹងហើយថា ប្រវត្តិដើមអ្នកនគរមេនេះ មុននឹងសាសនាទាំងពីរចូលមកប្រតិស្ឋាន អ្នកនគរមានជំនឿសាសនាខ្លួនឯងរួចទៅហើយ តែក្រោយមកពេលដែលព្រះថោងចូលមកលុកលុយ សាសនាទាំងពីរក៏បានចូលមកតាមអ្នកចំណូលថ្មី។ ហើយសាសនាទាំងពីរ បានបូកនឹងសាសនាដើមមួយទៅជាបីរួមមួយ ទើបអាចរុញអរិយធម៌របស់ពួកគាត់ ឲ្យឡើងទៅដល់កំពូលបាន ហើយសាសនាទាំងអស់នេះទៀតសោត បើអ្នកខាងក្នុងមិនទទួលយកមកទុកទេ ក៏មិនអាចឋិតថេរមកដល់សព្វថ្ងៃនេះបានឡើយ។ ដែលគាត់យល់ព្រមឲ្យសាសនានេះមកប្រតិស្ឋាន ព្រោះរឿងរ៉ាវដែលមានក្នុងគម្ពីរវេទមានសាច់រឿងស្រដៀងនឹងសាច់រឿងរបស់គាត់ ដូចជារឿង **កូរសមុទ្រទឹកដោះ រាមកេរ្ដិ៍ ក្រឹស្ណៈ**.... ភាគច្រើនក្នុងសាច់រឿងគឺប្រហាក់ប្រហែលនឹងរឿងគាត់ ទើបគាត់ខ្ចីសំបកគេមកលាក់អាថ៌កំបាំងសាវតាពិតរបស់ខ្លួន ព្រោះកាលពីសម័យមុន មិនដូចសម័យកាលខាងក្រោយឡើយ គាត់ខ្ចីសំបកពីគេ មករំលាយចូលប្រស្នាគំនិតរបស់ខ្លួន បង្កើតបានជាអាទិទេពសំខាន់ៗ ដូចជា**ព្រះឥសូរ** តំណាងអ្នកបង្កើតលោក និងបំផ្លាញលោក **ឧ.** ស្ដេចជ័យវរ្ម័នទី២ តាំងខ្លួនជាព្រះឥសូរលើកំពូលភ្នំគូលែន **ព្រះព្រហ្ម** តំណាងឲ្យអ្នកបង្កើតលោក **ឧ.** មុខព្រហ្មបាយ័ន បន្ទាយក្ដី តាព្រហ្ម បន្ទាយឆ្មារ.... ហើយ**ព្រះវិស្ណុ** តំណាងឲ្យសភាវៈទ្រទ្រង់លោក ថែរក្សាលោក ស្រោចស្រង់លោក **ឧ.** ស្ដេចសូរ្យវរ្ម័នទី២ មានឈ្មោះថា បរមវិស្ណុលោក និងអាទិទេពដ៏ទៃទៀតជាច្រើន ពុំដូចសម័យខាងក្រោយ គឺពុំមានបញ្ចូលរឿងខ្មែរទៅក្នុងសាសនា ដូចសម័យពីមុនឡើយ។ ដោយពួកបរទេសធ្វើអាណានិគម គេបានបង្រៀនយើងឲ្យសរសេរ គូរ ឆ្លាក់ពីរឿងសាសនាសុទ្ធសាធ ដើម្បីបំភាន់កូនខ្មែរសម័យក្រោយ ឲ្យយល់ច្រឡំថា រឿងរ៉ាវក្នុងថ្មពីអតីតកាលក្ដីរឿងរ៉ាវក្នុងព្រះវិហារសម័យកាលជាខាងក្រោយក្ដី គឺនិយាយតែពីរឿងសាសនា ។ ដូច្នេះ គំនិតខ្ចីសំបកយកមកលាក់សាច់ជាគំនិតប្រកបទៅដោយប្រស្នាអាថ៌កំបាំង ទាល់តែយើងជាកូនគាតសម័យខាងក្រោយចេះឆ្ងល់ រួចឈ្វេងយល់ដោយឈរលើប្រស្នាគំនិតព្រះម៉ែ រែកពីរ ទុកមួយ ទើបរកឃើញរឿងពិតរបស់ខ្លួន **ឧ.** យើងឆ្ងល់ថា ដូនតាគ្រាន់តែ

ជាអ្នកទទួលឥទ្ធិពលពីគេ ហេតុអ្វីក៏ពួកគាត់មានមហិទ្ធិឫទ្ធិសម្បើមម្ល៉េះ ដោយពួកគាត់មានបញ្ញាអាចកសាងប្រាសាទថ្មបានរាប់ពាន់ ហើយក្នុងចំណោមប្រាសាទថ្មទាំងនោះ មានប្រាសាទមួយចំនួនគាត់បានឆ្លាក់មុខព្រហ្មធំៗរាប់សិបមុខ ព្រោះគាត់ចង់បញ្ជាក់ប្រាប់កូនខ្មែរសម័យក្រោយឲ្យបានយល់ថាគាត់ជាប្រមុខនៃព្រហ្មក្នុងនគរនេះ គ្មានព្រហ្មខាងក្រៅណាមកគ្របសង្កត់បញ្ញាគាត់បានឡើយ ដែលគាត់ទទួលយកព្រហ្មពីខាងក្រៅ គឺគ្រាន់តែសាច់រឿងវាប្រហាក់ប្រហែល នឹងរឿងរបស់ខ្លួន ម្យ៉ាងទៀតគាត់ចង់លាក់បាំងបំភាន់ភ្នែកបរទេស កុំឲ្យពួកគេមើលយល់ រួចដាប់បំផ្លាញប្រស្នាគំនិតនេះចោល។ បើពួកគេដាប់បំផ្លាញចោល ពេលដែលអកុសលកម្មរបស់គាត់ត្រូវអស់ តើបានកូននាគសម័យក្រោយណាជួយគាត់ បើរូបចម្លាក់នៅលើថ្មត្រូវគេដាប់បំផ្លាញអស់ទៅហើយនោះ តើកូននាគដែលត្រូវជួយគាត់ទៅស្រាវជ្រាវឯកសារសាវតាពិតរបស់ថ្មនៅឯណា? ដូច្នេះហើយ ទើបសម័យខាងក្រោយ ពួកបរទេសគេបានយល់ពីបណ្ដាំគំនិតរបស់ដូនតាខាងលើគេបានប្រើកូនខ្មែរ ដែលគ្មានមនសិការជាតិឲ្យដាប់បំផ្លាញបេះដូងខ្លួនឯងចោលដើម្បីជាថ្នូរនឹងប្រាក់។ ប្រាសាទថ្មទាំងនោះ បើគ្មានរូបរឿងចម្លាក់នៅលើជញ្ជាំងទេ តើមានប្រយោជន៍អ្វី ចំពោះកូនខ្មែរអ្នកស្រាវជ្រាវសាវតារបស់គាត់ ព្រោះរូបរឿងទាំងអស់នោះ គឺជាឯកសារសាវតាពិតដែលនិយាយពីភាសាគំនិតរបស់ព្រះម៉ែ។

សរុបសេចក្ដីមក ឥទ្ធិពលព្រហ្មញ្ញសាសនាដែលដូនតាទទួលយកមកធ្វើជាកេរមរតក គឺអត្ថន័យទីមួយ រឿងនៅក្នុងសាសនាដូចរឿងរបស់គាត់ និងអត្ថន័យទីពីរគាត់ចង់ឲ្យកូនខ្មែរជំនាន់ក្រោយចេះបន់ស្រន់បួងសួង.... ក្នុងពិធីបុណ្យផ្សេងៗប្រចាំនគរដើម្បីឲ្យនឹកឃើញដល់ពួកគាត់ដែលជាបុព្វទេពអ្នកកកើតមាតុភូមិនេះ(ព្រះមេព្រះម៉ែ) និងន័យពិតម្យ៉ាងទៀត គាត់ចង់លាក់បណ្ដាំរឿងបំភ័នភ្នែកពួកជនបរទេសសម័យខាងក្រោយដែលត្រូវចូលមកលុកលុយឈ្លានពានក្នុងនគរនេះ ក្នុងពេលដែលនគរចុះទន់ខ្សោយ ពេលដែលព្រះមាតានាគលោកមិនអាចចេញពីទីឃុំឃាំងមកផ្ដល់ឱវាទបាន។

## ខ.ព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនា ដែលដូនតាគាត់បានយកមកប្រតិស្ឋានទុកជាកេរមរតក មានពីរនិកាយ ទីមួយគឺ និកាយហិនយាន(ថេរវាទ) ទីពីរគឺ និកាយមហាយាន(អាចារ្យវាទ) ហើយនិកាយទាំងពីរនេះដែលរីកចម្រើនខ្លាំង គឺនិកាយមហាយាន ក្នុងសម័យព្រះបាទជ័យវរ័ន្មទី៧។ តើនិកាយមហាយាន និងហិនយានមានអត្ថន័យអ្វីសម្រាប់លាក់បណ្ដាំអាថ៌កំបាំងគំនិតព្រះមាតាមហានគរ?

**១.ពុទ្ធសាសនាមហាយាន** (យានធំ)

ក្នុងគម្ពីរមហាយានបានសម្តែងប្រាប់ថា នឹងមាននូវពោធិសត្វមួយអង្គទៀត ដែលនឹងត្រូវបានត្រាស់ដឹងជាព្រះពុទ្ធនៅចុងនៃភទ្ទកប្បនេះ គឺព្រះសម្មាសម្ពុទ្ធសិរអារ្យមេត្រីយ ដូច្នេះមានន័យថា នៅមានពោធិសត្វត្រូវបំពេញបារមីនៅឡើយ។ ហេតុនេះហើយ ទើបស្តេចជ័យវរន្ម័ទី៧ លោកបានទ្រទ្រង់នូវព្រះពុទ្ធសាសនាបែបមហាយាននេះ ឲ្យបានរុងរឿងឡើងនៅសម័យលោកគ្រប់គ្រងប្រទេស ព្រោះលោកបានប្រកាសខ្លួនឯងថា ជា**ពោធិសត្វលោកេស្វរៈ** ដើម្បីទុកជាប្រស្នាឲ្យកូនខ្មែរជំនាន់ក្រោយ ធ្វើការសិក្សាពិចារណាឈ្វេងយល់ថា គាត់ខ្ចីពុទ្ធសាសនាពីខាងក្រៅមក ប៉ុន្តែពោធិសត្វពិតប្រាកដ គឺជាខ្លួនគាត់ទៅវិញទេ ពុំមែនពោធិសត្វមកពីខាងក្រៅឡើយ ហើយបើគាត់ជាព្រះពោធិសត្វទៅហើយ រឿងរ៉ាវក្នុងថ្មគឺសុទ្ធតែជារឿងរបស់គាត់ទាំងអស់ គាត់ខ្ចីសំបកសាសនាមកលាក់ទុករឿងពិតរបស់ខ្លួន។ ដូច្នេះហើយ សម័យគាត់ពុំបានលើកតម្កើងព្រះពុទ្ធសាសនា បែបហិនយាន(យានតូច) ព្រោះហិនយានពុំមានព្រះពោធិសត្វសរជាតិ ដើម្បីបំពេញនូវបារមីទៀតឡើយ ព្រោះព្រះអង្គបានបរិនិព្វានទៅហើយ។ ទោះបីជាគាត់ពុំបានលើកតម្កើងក៏ព្រះពុទ្ធសាសនាបែបហិនយាន ត្រូវបានគោរព និងបូជាទូទាំងនគរដែរ។ ដូច្នេះហើយ ព្រះពុទ្ធសាសនាមហាយាន គឺជាសំបកមួយយ៉ាងសំខាន់ សម្រាប់លាក់ទុកនូវរឿងព្រះមាតាមហានគរ និងរឿងកូននាគដែលត្រូវសរជាតិបំពេញបារមីជួយព្រះមាតាមហានគរឲ្យបានរួចផុតពីបាបកម្មនៅពេលដែលកម្មគាត់ត្រូវអស់ ដូចមានភាសិតមួយឃ្លា របស់ស្តេចជ័យវរ័ន្មទី៧ ដែលបានចារឹកទុកលើថ្មមានន័យថា **ដោយសារគុណធម៌ ដែលខ្ញុំបានសាងក្នុងស្នាដៃទាំងអស់នេះ ខ្ញុំសូមឧទ្ទិសដល់ព្រះមាតាខ្ញុំ ពេលដែលលោករំដោះខ្លួនរួចផុតពីបាបកម្ម សូមឲ្យបានសម្រេចជាពោធិសត្វ (ពុទ្ធមាតា) ទៅអនាគតជាតិ** ដកស្រង់ចេញពីសៀវភៅ ខ្ញុំចង់ដឹងពីជនជាតិខ្មែរ។

ដោយយោងទៅតាមការបកពន្យល់ខាងលើ ទើបយើងដឹងថាដូនតាខ្មែរពីសម័យដើម លោកពុំដែលចម្លងពីគេមកទាំងស្រុងទេ គឺលោកតែងតែបញ្ចូលគំនិតរបស់ខ្លួនទៅលាក់ទុកក្នុងសាសនា ដើម្បីជាប្រយោជន៍លាក់បំបាំងភ្នែកអ្នកដទៃ ហើយនឹងទុកឲ្យកូនខ្មែរសម័យក្រោយឈ្វេងយល់ រួចបំបែកដកយករឿងគាត់ចេញពីសាសនាដើម្បីជួយគាត់ វាខុសពីសម័យខាងក្រោយដែលពួកអាណានិគមគ្រប់គ្រងខ្មែរ ពួកគេបានដឹងពីរអាថ៌កំបាំងនេះគេក៏បង្រៀនឲ្យកូនខ្មែរសរសេរ គូរឆ្លាក់.... ពីរឿងសាសនាសុទ្ធៗ គឺពុំមានលាយបណ្តាំប្រស្នាគំនិតព្រះម៉ែ ដូចពីសម័យដែលគាត់ចេញពីគុករួចឡើយ **ឧ.** សព្វថ្ងៃព្រះវិហាររបស់ព្រះពុទ្ធសាសនា ស្ទើរទូទាំងប្រទេសតែងតែនាំគ្នាគូរឆ្លាក់រឿងរ៉ាវព្រះជាតកក្នុងសាសនាសុទ្ធៗពុំមានលាយពីបណ្តាំប្រស្នាគំនិតព្រះម៉ែ ដូចពីសម័យមុនឡើយ។ ទាំងនេះជាគំនិត

បរទេស ដែលបានបំភាន់កូនកៃ្មរសម័យខាងក្រោយ ឲ្យយល់ច្រឡំពីរឿងរ៉ាវនៅលើប្រាសាទថ្មពីអតីតកាល និងរឿងក្នុងព្រះវិហារបច្ចុប្បន្ន គឺជារឿងដែលរៀបរាប់នូវអត្ថន័យរបស់សាសនាសុទ្ធសាធ។

**២.ព្រះពុទ្ធសាសនាហិនយាន** (យានតូច)

ព្រះពុទ្ធសាសនាហិនយាន (ថេរវាទ) ក៏បានចូលមកដំណាលគ្នានឹងមហាយានដែរ(អាចារ្យវាទ) តែពុទ្ធសាសនាបែបហិនយាន ពុំសូវមានបន្សល់ទុកនូវសំណង់ប្រាសាទធំៗ បញ្ជាក់ពីឥទ្ធិពលនៃព្រះពុទ្ធសាសនា បែបថេរវាទនេះឡើយ ព្រោះខ្ញុំបានពន្យល់ខាងលើហើយថា ពុទ្ធសាសនាបែបថេរវាទ ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ព្រះអង្គបានបរិនិព្វានទៅហើយ។ ប៉ុន្តែព្រះមាតាមហានគរ លោកត្រូវតែទទួលយកព្រះពុទ្ធសាសនាបែបថេរវាទនេះ មកទុកជាមរតកឲ្យកូនកៃ្មរជំនាន់ក្រោយ ព្រោះនិកាយនេះជាឫសគល់ពិតប្រាកដរបស់ព្រះពុទ្ធសាសនាពុំដូចជានិកាយមហាយានឡើយ។ ឱវាទរបស់ព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គទ្រង់ត្រាស់សម្ដែងអស់ **៤៥**ព្រះវស្សា ៖

ទី**១**ព្រះអង្គហាមមិនឲ្យសត្វធ្វើបាបទាំងពួង

ទី**២**ព្រះអង្គឲ្យសត្វបំពេញនូវបុណ្យកុសល

ទី**៣**ព្រះអង្គឲ្យសត្វសម្អាតចិត្តរបស់ខ្លួនឲ្យស្អាតផូរផង់

ឱវាទទាំងបីនេះ គឺជាពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធគ្រប់ៗព្រះអង្គ ដើម្បីឲ្យសត្វស្គាល់**គុណទោស បាបបុណ្យ នរកសួគ៌** ហើយនឹងផ្លូវទៅកាន់ទីរំលត់ទុក គឺព្រះនិព្វាន។ ដូច្នេះហើយ ទើបមានរឿងព្រះជាតក បានមកប្រតិស្ឋានជាឈ្មោះប្រាសាទ រូបចម្លាក់ ឧ. ប្រាសាទ វិធុរបណ្ឌិត ធម្មានន្ទ បាលិលយ្យ សេះពលាហកៈ សត្វអណ្ដើក (តំណាងឧបាទានក្ខន្ធ៥ ក្នុងរឿងកុមារកស្សបៈ)....។ល។ ព្រះមាតាមហានគរ លោកយល់តាមបុព្វេនិវាសានុស្សតិ ដែលលោកចម្រើនបាន (រលឹកជាតិបានទៅអនាគត) បើព្រះពុទ្ធសាសនា ពុំមាននៅសល់ក្នុងនគរនេះទេ គាត់ពុំអាចរួចពីអកុសលកម្មចាស់បានឡើយ ព្រោះពេលដែលកូនកៃ្មរ ពុំគោរពកាន់ព្រះពុទ្ធសាសនាពួកគេពិតជាគ្មានគុណធម៌នៅក្នុងខ្លួន (សីល សមាធិ បញ្ញា) គ្មានដឹងគុណទោសបាបបុណ្យ ហើយបើកូននាគទាំងអស់ ពុំមានគុណធម៌ទាំងនេះ ធ្វើម្ដេចអាចឧទ្ទិសបុណ្យជូនទៅគាត់បាន (ទំនួញប្រេត) នេះហើយជាអាថ៌កំបាំងបណ្ដាំព្រះម៉ែ ដែលព្រះពុទ្ធសាសនាបានក្លាយទៅជាកេរមរតករបស់គាត់ ដែលយើងសព្វថ្ងៃបានទទួលនូវកេរនេះគ្រប់ៗគ្នា លើកលែងតែកូននាគមួយចំនួនដែលទៅទទួលសាសនាដទៃក្រៅពីមរតកព្រះម៉ែ។ នៅក្នុងរតនបុគ្គលរកបានដោយកម្រនៅក្នុងលោកប្រាំយ៉ាងនោះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងថា ៖

១. ព្រះអរហន្តសម្មាសម្ពុទ្ធបរមគ្រូនៃយើង ជារតនបុគ្គលរកបានដោយកម្រក្នុងលោក

២. បុគ្គលដែលចេះប្រកាសសម្ដែងនូវព្រះធម៌ និងព្រះវិន័យ ដែលព្រះសម្មាសម្ពុទ្ធទ្រង់បានប្រកាសសម្ដែងហើយ

៣. បុគ្គលដែលអាចស្ដាប់យល់នូវអាថ៌របស់ព្រះធម៌ និងព្រះវិន័យ ដែលព្រះសម្មាសម្ពុទ្ធទ្រង់បានប្រកាសសម្ដែងហើយ

៤. បុគ្គលដែលអាចប្រតិបត្តិឲ្យបានត្រឹមត្រូវទៅតាមព្រះធម៌ និងព្រះវិន័យ ដែលព្រះសម្មាសម្ពុទ្ធទ្រង់បានប្រកាសសម្ដែងហើយ

៥/ បុគ្គលដែលមាននូវកតញ្ញូ និងកតវេទិតា

ហេតុនៃរតនបុគ្គលទាំងប្រាំខាងលើនេះ លោកសង្ឃឹមថានឹងមានកូននាគណាមួយ ដែលរស់ក្នុងទឹកដីរបស់គាត់គេនឹងចុះក្នុងទ្រូង(បេះដូង) របស់គាត់រួចដឹងរឿងក្នុងចិត្ត ហើយកូននាគនោះនឹងព្យាយាមជួយស្រង់គាត់ជាពុំខាន ព្រោះគាត់រលឹកជាតិទៅអនាគតដឹងយ៉ាងដូច្នេះ។ ដូចជារឿងនៅក្នុងជាតកមួយ ព្រះអង្គបានត្រាស់សម្ដែងថា កាលព្រះអង្គនៅជាពោធិសត្វបំពេញបារមីនៅឡើយ ពេលនោះព្រះអង្គជាអ្នកជំនួញម្នាក់ បានដើរកណ្ដាលថ្ងៃក្ដៅដើម្បីចេញទៅជួញ ហើយបានទៅជ្រកនៅក្រោមម្លប់ឈើមួយដើម ដែលនៅក្នុងម្លប់នោះមានបុរសម្នាក់បានចូលជ្រកមុនព្រះអង្គ។ ពេលនោះព្រះអង្គបានសួរទៅបុរសនោះថា តើអ្នកមានម្ជូស្លាទេឲ្យខ្ញុំសុំមួយម៉ាត់មកព្រោះខ្ញុំស្រេកទឹក និងជូរមាត់ណាស់ បុរសដែលអង្គុយជ្រកមុននោះ ក៏ហុចម្លូស្លាឲ្យព្រះពោធិសត្វមួយម៉ាត់ ដើម្បីបំបាត់ការស្រេក និងជូរមាត់ លុះបាត់ហាត់ហើយអ្នកទាំងពីរក៏បានធ្វើដំណើរទៅកាន់កំពង់ផែ ដើម្បីឡើងជិះសំពៅចេញទៅជួញ។ សំពៅនោះចេញពីច្រាំងបានចំនួនប្រាំពីរថ្ងៃ ក៏ត្រូវខ្យល់ព្យុះបោកបក់ពន្លិច ព្រះអង្គមានក្ដារមួយបន្ទះតោងហែលធ្វើជាក្បូន ចំណែកឯបុរសដែលបានឲ្យម្លូស្លាដល់ព្រះអង្គ កាលនៅជ្រកក្រោមម្លប់ឈើនោះ កំពុងប្រឹងហែលនឹងដៃ។ ពេលដែលពោធិសត្វក្រឡេកឃើញបុរសនោះ លោកក៏នឹកឃើញដល់ឧបការៈគុណរបស់បុរសនោះ ពេលអាត្មាអញកំពុងស្រេកទឹក និងជូរមាត់បានបុរសនេះ ឲ្យម្លូស្លាមួយម៉ាត់ដើម្បីបំបាត់សេចក្ដីស្រេក ដូច្នេះដើម្បីតបនូវគុណនេះព្រះអង្គបានហុចបន្ទះក្ដារកំពុងតោងទៅឲ្យបុរស ដែលមានឧបការៈគុណនោះ រួចខ្លួនព្រះអង្គឯងខំប្រឹងហែលនឹងដៃទៅតាមយថាកម្មទៅ។ ដោយអំណាចនៃកតញ្ញូ និងកតវេទីនេះបានធ្វើឲ្យញាប់ញ័រទៅដល់ទេពធីតាដែលថែរក្សារមហាសមុទ្រ ព្រះនាងបានគិតត្រិះរិះថា បើអាត្មាអញមិនទៅជួយស្រង់បុរសដែលដឹងគុណគេនេះទេ ក្បាលអាត្មាអញនឹងប្រេះបែកជាប្រាំពីរភាគជាពុំខាន ពេលនោះទេវតាក៏ហោះឆ្ពោះទៅទីកន្លែងដែលពោធិសត្វកំពុងហែល រួចចាប់ឱបបីព្រះអង្គយកទៅដាក់នៅលើគោក ហើយក៏និម្មិតជាសម្លៀកបំពាក់ និងអាហារជាទិព្វថ្វាយដល់ព្រះពោធិសត្វបានស្លៀកពាក់និងបរិភោគ។ រីឯបុរសដែលបានក្ដារតោង

*នោះវិញ រយៈពេលយូរទើបបានអណ្ដែតមកដល់ច្រាំងពេលឃើញព្រះពោធិសត្វនៅលើច្រាំងមុនក៏សួរដោយឆ្ងល់ថា ហេតុអ្វីក៏អ្នកមកដល់គោកលឿនម្លេះ? ពោធិសត្វបានពោលរៀបរាប់តាមដំណើររឿងដែលខ្លួនដឹងគុណ និងតបគុណដល់អ្នកមានឧបការៈ ពេលនោះព្រះអង្គចង់ឲ្យបុរសនេះបានអាហារ និងសំពត់ជាទិព្វដូចខ្លួនដែរ តែគេពុំអាចទទួលយកបានឡើយ ព្រោះគាត់គ្មាននូវគុណធម៌អ្វីដែលត្រូវបានរបស់ជាទិព្វទាំងនោះឡើយ ទើបព្រះពោធិសត្វលោកប្រាប់ឲ្យបុរសនោះ ត្រេកអរ និងអនុមោទនានូវបុណ្យរបស់ខ្លួន ដែលបានបំពេញក្នុងការដឹងគុណ និងតបគុណ បុរសនោះក៏ឆ្លើយ ថា* ***សាធុ សាធុ*** *ទើបទេវតាថែរក្សាមហាសមុទ្រនិម្មិតសំពត់អាវ និងអាហារជាទិព្វឲ្យដល់បុរសនោះ។ ក្រោយមកទេវតាក៏បានបីពរអ្នកទាំងពីរ យកមកដាក់ដល់លំនៅដ្ឋានរៀងៗខ្លួន ហើយក៏បាននិម្មិតជាកែវកងមាសប្រាក់ឲ្យដល់បុរសទាំងពីរទុកចិញ្ចឹមជីវិតឈប់ឲ្យទៅធ្វើជំនួញតទៅទៀត។*

*នេះគ្រាន់តែជាស្លាមួយម៉ាត់សោះ ក៏ព្រះអង្គសុខចិត្តលះបង់ជីវិតដើម្បីតបនូវឧបការៈគុណព្រោះក្ដារដែលព្រះអង្គតោងនៅក្នុងសមុទ្រនោះ ដូចជាក្បូនសំរាប់ជួយជីវិតព្រះអង្គ ឲ្យរួចផុតពីសេចក្ដីស្លាប់ តែព្រះអង្គសុខចិត្តលះបង់នូវក្ដារនោះដើម្បីតបគុណ ទើបព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងនូវរតនបុគ្គល ដែលរកបានដោយកំរ ទី៥គឺបុគ្គលដែលមាននូវកតញ្ញូ និងកតវេទី ដែលព្រះអង្គប្រារព្ធលើបុគ្គល ដែលជាពោធិសត្វបានបំពេញនូវបារមីក្នុងរឿងខាងលើ។ ចំណែកព្រះមាតាមហានគរវិញ ដែលលោកបានទុកកេរមរតករាប់ពុំអស់ឲ្យកូនខ្មែរសម័យក្រោយ ទទួលនូវមរតករបស់លោកនេះ ព្រះម៉ែក៏លោកមានសេចក្ដីសង្ឃឹមយ៉ាងមុតមាំដូច្នោះដែរ។ ព្រោះលោកដឹងថា នឹងមានកូននាគណាមួយងាកបែរមើលទៅខាងក្រោយហើយដឹងរឿងក្នុងចិត្តរបស់ខ្លួន កូននាគទាំងនោះគេនឹងព្យាយាមជួយគាត់ជាមិនខាន។ ទាំងនេះ គឺជាមូលហេតុដែលព្រះមាតាមហានគរលោកបានទទួលយក ព្រះពុទ្ធសាសនាមកទុកជាកេររបស់ខ្លួន សម្រាប់ទុកឲ្យកូនគាត់ជំនាន់ក្រោយៗ ព្រោះព្រះសាសនានេះ មានសារៈប្រយោជន៍នាំសត្វទៅរកសុគតិភព (កាមភព រូបភព និងអរូបភព) ហើយនឹងនាំសត្វឲ្យចេញចាកពីសង្សារទុក្ខ(ព្រះនិព្វាន) រួមទាំងខ្លួនគាត់ផង ដែលរងទុក្ខទទួលទោសមកដល់សព្វថ្ងៃ ព្រោះមិនបានប្រតិបត្តិតាមឱវាទព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សម្ដែងហើយនិងទុកសម្រាប់ឲ្យកូននាគសម័យក្រោយយល់ដឹងពីគុណទោសបុណ្យបាប....អាចជួយចម្លងគាត់ឲ្យរួចផុតពីទីទុក្ខទោសនោះ* ***ដោយការឧទ្ទិសបុណ្យ។ ឧ. បើសិនណារឿងរ៉ាវទាំងអស់ ដែលខ្ញុំបានរៀបរាប់ ក្នុងភាគមួយ និងភាគពីរនេះវាជារឿងរបស់អស់លោកអ្នកអានក្នុងបច្ចុប្បន្នវិញ ហើយអស់លោកអ្នកបានបំពេញពលិកម្មមួយជីវិត ដើម្បីកូនចៅញាតិមិត្ត ប្រុសស្រី តែទីបំផុតពួកគេទាំងនោះពុំបានតបនូវ សេចក្ដីល្អទៅអស់លោកអ្នកវិញ ហើយថែម***

***ទាំងដេរប្រមាថមាក់ងាយដល់លោកអ្នកអានទៀត តើក្នុងចិត្តរបស់លោកអ្នកអានទាំងអស់ មានអារម្មណ៍ឈឺចាប់ដូចម្ដេចដែរ?***

*សរុបសេចក្ដីមក ព្រហ្មញ្ញសាសនាក្ដី ព្រះពុទ្ធសាសនាក្ដី សុទ្ធតែមានសារៈប្រយោជន៍សម្ដែងគាត់ និងកូនគាត់ដែលជាអ្នកទទួលស្នងមរតកសម័យក្រោយៗ ព្រោះក្នុងសាសនាទាំងពីរជាសំបកដែលអាចលាក់បិទបាំងនូវសាវតារឿងពិតរបស់ខ្លួនផង និងជាពាក្យទូន្មានប្រៀនប្រដៅ ដល់កូនចៅនាគសម័យក្រោយផង។ ហើយម្យ៉ាងទៀត គាត់បានទុកបណ្ដាំប្រស្នាដើម្បីឲ្យកូនប្រុសស្រីសម័យខាងក្រោយឈ្វេងយល់ថា ហេតុអ្វីបានជាមានសាសនាបីរួមមួយ(**ព្រហ្មញ្ញ ព្រះពុទ្ធ បណ្ដាំព្រះម៉ែ**) នេះជាគំនិត ដែលខ្ញុំបាទបានស្រាវជ្រាវឃើញនៅក្នុងសាវតាប្រស្នាអាថ៌កំបាំងបណ្ដាំព្រះម៉ែមហានគរ ។*

*ខ្ញុំព្រះករុណាខ្ញុំបាទ ក៏សូមអភ័យទោសពីសំណាក់ព្រះគុណម្ចាស់ អស់លោក និងមិត្តអ្នកអានគ្រប់ភេទ ទាំងគ្រហស្ថ និងបព្វជិត... នូវរាល់កំហុសឆ្គងទាំងឡាយណា ដែលកើតមានឡើងដោយអចេតនា ដែលខ្ញុំបាទបានលើកយកសាច់រឿងមកជាឧទាហរណ៍ ពីក្នុងព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសនា។ ព្រោះស្នាដៃនេះជាការស្រាវជ្រាវចងក្រងលើកទីពីរ ហើយក៏សូមឲ្យព្រះពុទ្ធសាសនារុងរឿងឡើងវិញ ដោយបញ្ញាកូនខ្មែរប្រុសស្រីបានដឹង និងមើលឃើញពីបាបកម្មក្នុងអតីតរបស់ព្រះមាតាបិតាមហានគរយើង ហើយអ្នកជួយវាយអត្ថបទភាគពីរនេះ គឺកូនរបស់ខ្ញុំបាទឈ្មោះគៀត វង្សចន្ទ័ភូមានជាសិស្សរៀននៅអនុវិទ្យាល័យកម្មករក្រុង។*

*ខ្ញុំព្រះករុណាខ្ញុំបាទ ក៏សូមឧទ្ទិសនូវសេចក្ដីព្យាយាម ដែលខិតខំស្រាវជ្រាវ**សាវតាបណ្ដាំព្រះម៉ែមហានគរ**នេះ ក្នុងនាមខ្ញុំព្រះករុណាខ្ញុំបាទជាកូនខ្មែរម្នាក់បានកើត និងចេះដឹងហើយរីកធំធាត់ដោយកេរមរតកព្រះម៉ែ(ព្រះពុទ្ធសាសនា ព្រហ្មញ្ញសាសនា និងសាសនព្រះម៉ែ) សូមឲ្យផលនៃបុណ្យនេះកើតមានចំពោះលោកអ្នកដ៏មានគុណមាន**មាតាបិតា ជីដូនជីតា គ្រូឧបជ្ឈាយាចារ្យ ញាតិធម៌**ដែលសុទ្ធតែជាអ្នកមានឧបការគុណ គ្រប់ៗកាលទាំងបី (អតីត បច្ចុប្បន្ន អនាគត) សូមឲ្យជួបប្រសព្វតែនៅសេចក្ដីសុខក្នុងសម្បត្តិទាំងបី គឺសុខក្នុងសម្បត្តិមនុស្ស សុខក្នុងសម្បត្តិទេវតា និងសុខរួចចាកទុក្ខទាំងពួងគឺព្រះ*

និព្វាន ហើយសូមជួបតែពរទាំងឡាយប្រាំប្រការ គឺ ***អាយុ វណ្ណៈ សុខៈ ពលៈ*** និង***បដិភាណៈ*** កុំបីឃ្លៀងឃ្លាតឡើយ។

ស្នាដៃសង្ខេបសារតាព្រះម៉ែភាគទីពីរនេះបានស្រាវជ្រាវ និងចងក្រងរួចជាស្ថាពរនៅថ្ងៃ អង្គារ៍ **១២**កើត ខែភទ្របទ ឆ្នាំឆ្លូវ ឯកស័ក ព.ស **២៥៥៣**ត្រូវនឹងថ្ងៃទី **០១** ខែកញ្ញា ឆ្នាំ**២០០៩**

ការខិតខំស្រាវជ្រាវនេះ ខ្ញុំសូមរក្សាសិទ្ធិទាំងស្រុង !.....

ពីខ្ញុំព្រះករុណាខ្ញុំបាទអ្នកទទួលមរតកព្រះម៉ែ

**គៀត ចាន់ថុន**

អតីតសិស្សសាលាវិចិត្រសិល្ប